# កាលប្បវត្តិតុលាការខ្មែរក្រហម

## ៣០ មេសា ១៩៩៤

សភាសហរដ្ឋអាមេរិក បានអនុម័តច្បាប់ស្តីពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលចែងថា «គោលការណ៍របស់សហរដ្ឋអាមេរិកគឺគាំទ្រក្នុងការនាំយកសមាជិកខ្មែរក្រហមមកកាត់ទោសចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩» ។

## ១៣ មករា ១៩៩៥

មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបង្កើតឡើងជាផ្លូវការ ដោយអនុលោមតាមច្បាប់ស្តីពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលទទួលបានប្រាក់ជំនួយចំនួន ៤៩៩.២៨៣ ដុល្លារអាមេរិក សម្រាប់រយៈពេលពីរឆ្នាំក្នុងការអនុវត្តនូវកម្មវិធីស្រាវជ្រាវអំពីប្រល័យពូជសាសន៍កម្ពុជា របស់សាកលវិទ្យាល័យយ៉េល ។ (ការិយាល័យ ស៊ើបអង្កេតអំពើប្រល័យពូជសាសន៍នៅកម្ពុជា (EAP/CGP), ការិយាល័យកិច្ចការអាស៊ី-ប៉ាស៊ីហ្វិក, ក្រសួងការបរទេសសហរដ្ឋអាមេរិក, ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។

## ១៤ កញ្ញា ១៩៩៦

រាជរដ្ឋាភិបាលកម្ពុជាបានលើកលែងទោស អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការលើកលែងទោសនេះគ្របដណ្តប់លើសាលក្រមប្រកាសដាក់ទោសដោយតុលាការប្រជាជនបដិវត្តន៍ទៅលើ អៀង សារី កាលពីឆ្នាំ១៩៧៩ ដែលបានសម្រេចថា អៀង សារី ត្រូវបានកាត់ទោសប្រហារជីវិត និងរឹបអូសទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងអស់ ។

## ១១ មេសា ១៩៩៧

គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានអនុម័តសេចក្តីសម្រេចលេខ១៩៩៧/៤៩ ។ សេចក្តីសម្រេចនេះបានស្នើសុំឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ តាមរយៈតំណាងពិសេសរបស់លោក ធ្វើការពិនិត្យរាល់សំណើសម្រាប់ជំនួយក្នុងការឆ្លើយតបទៅនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរកាលពីអតីតកាលលើច្បាប់កម្ពុជាក៏ដូចជាច្បាប់អន្តរជាតិ ។

### ១២ ខែសភា ១៩៩៧

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ បានមានព្រះរាជបន្ទូលថា ព្រះអង្គសព្វព្រះរាជហឫទ័យដើម្បីទទួលការវិថ្ច័យទោសស្របគ្នានឹងមេដឹកនាំខ្មែរក្រហម ដើម្បីឆ្លើយបំភ្លឺទៅកាន់អ្នករិះគន់ព្រះអង្គដែលបានអះអាងថា ព្រះអង្គ មានការទទួលខុសត្រូវមួយផ្នែកសម្រាប់អំពើប្រល័យពូជសាសន៍ ដែលបានកើតឡើងក្នុងរវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ។

### ១១ មិថុនា ១៩៩៧

ខៀវ សំផន អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យបានប្រកាសថា សុន សេន និងប្រពន្ធរបស់គាត់ឈ្មោះ យុន យ៉ាត ត្រូវបានចាប់ខ្លួនពីបទចារកម្មនិងសកម្មភាពក្បត់ប្រឆាំងនឹងចលនាខ្មែរក្រហម ។ ខ្មែរក្រហមបានចោទប្រកាន់អ្នកទាំងពីរថា ជាចារកិច្ចរបស់នាយករដ្ឋមន្ត្រីទី២ ហ៊ុន សែន និងរដ្ឋាភិបាលរបស់វៀតណាម ។ (The Cambodia Daily, ១២ មិថុនា ១៩៩៧)

### ១៥ មិថុនា ១៩៩៧

សុន សេន និងភរិយាឈ្មោះ យុន យ៉ាត រួមទាំងសាច់ញាតិ៨នាក់ទៀតត្រូវបានសម្លាប់ ។ (The Nation, ២៥ មិថុនា ១៩៩៧)

### ២១ មិថុនា ១៩៩៧

សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ និងសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ បានស្នើសុំជំនួយពីអង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ "ក្នុងការនាំយកអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតមកកាត់ទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដែលប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។ ខាងក្រោមនេះគឺជាអត្ថន័យទាំងស្រុងនៃសំណើសុំជំនួយ ៖

ជម្រាបជូនលោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ

តាងនាមឲ្យប្រជាជននិងរាជរដ្ឋាភិបាលកម្ពុជា យើងខ្ញុំបានសរសេរសំណើរជូនលោក ដើម្បីស្នើសុំជំនួយពីអង្គការសហប្រជាជាតិក៏ដូចជាសហគមន៍អន្តរជាតិផងដែរ ក្នុងការនាំយកអ្នកដែលមានការខុសត្រូវមកកាត់ទោសចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលកើតឡើងនៅក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។

សេចក្តីសម្រេចនៅខែមេសា ឆ្នាំ១៩៩៧ របស់គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ នៅប្រទេសកម្ពុជា បានស្នើឲ្យ«លោកអគ្គលេខាធិការ តាមរយៈតំណាងពិសេសរបស់លោកដោយមានកិច្ចប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្ស ធ្វើការពិនិត្យរាល់សំណើរបស់កម្ពុជាចំពោះជំនួយក្នុងការឆ្លើយតបទៅនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរកាលពីអតីតកាលច្បាប់កម្ពុជាក៏ដូចជាច្បាប់អន្តរជាតិក្នុងគោលបំណងនាំមកនូវការផ្សះផ្សាជាតិ ការពង្រឹងលទ្ធិប្រជាធិបតេយ្យនិងការដោះស្រាយពីបញ្ហាការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ» ។

ប្រទេសកម្ពុជា ពុំមានធនធាន និងជំនាញ ក្នុងការរៀបចំដំណើរការនីតិវិធីដ៏សំខាន់នេះនៅឡើយទេ ។ ដូច្នេះយើងខ្ញុំជឿថា នេះគឺជាការចាំបាច់ណាស់ក្នុងការស្នើសុំជំនួយពីអង្គការសហប្រជាជាតិ ។ យើងខ្ញុំបានយល់ពីកិច្ចខិតខំប្រឹងប្រែងប្រហាក់ប្រហែលក្នុងការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងប្រទេសរ៉្វាន់ដា និងអតីតប្រទេសយូហ្គោស្លាវី ហើយសូមស្នើសុំជំនួយប្រហាក់ប្រហែលគ្នានេះមកឲ្យប្រទេសកម្ពុជា ។

យើងខ្ញុំជឿជាក់ថា ឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងនេះគឺជាការព្រួយបារម្ភរបស់មនុស្សគ្រប់រូបនៅទូទាំងសកលលោកពីព្រោះថា ឧក្រិដ្ឋកម្មទាំងអស់នេះបានលុបបំបាត់នូវការគោរពសិទ្ធិមនុស្សជាមូលដ្ឋានមួយ គឺសិទ្ធិសម្រាប់រស់រានមានជីវិត ។ យើងខ្ញុំសង្ឃឹមថា អង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិ អាចជួយសម្រួលដល់ប្រជាជនកម្ពុជា ក្នុងការស្វែងរកការពិតពីសម័យកាលនោះ និងនាំយកអ្នកដែលមានការទទួលខុសត្រូវទាំងនោះទៅកាត់ទោស ។ មានតែមធ្យោបាយនេះទេ ដែលធ្វើឲ្យសោកនាដកម្មមួយនេះអាចឈានទៅដល់សេចក្តីបញ្ចប់មួយដោយពេញលេញ ។

សូមលោកអគ្គលេខាធិការទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ចុះហត្ថលេខាដោយ : សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី១

ចុះហត្ថលេខាដោយ : សម្តេច ហ៊ុន សែន

នាយករដ្ឋមន្ត្រីទី២

(http://www.khmerinstitute.org/docs/UNKRreportx.htm)

## ២៣ មិថុនា ១៩៩៧

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានបញ្ជូនលិខិតរបស់នាយករដ្ឋមន្ត្រីទាំងពីរទៅកាន់ប្រធានមហាសន្និបាតរបស់អង្គការសហប្រជាជាតិ និងប្រធានក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ។ (A/51/930-S/1997/488 of 24 June 1997)

## ១២ ធ្នូ ១៩៩៧

មហាសន្និបាតរបស់អង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចលេខ៥២/១៣៥ ដែលបានស្នើឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ ធ្វើការត្រួតពិនិត្យលើសំណើរបស់អាជ្ញាធរកម្ពុជា ស្តីពីជំនួយក្នុងការឆ្លើយតបទៅនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរកាលពីអតីតកាលទៅលើច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ ។ ខាងក្រោមនេះគឺជាផ្នែកខ្លះនៃសេចក្តីសម្រេច ៖

ក្នុងឆន្ទៈដែលថា ប្រវត្តិសាស្ត្រនៃសោកនាដកម្មរបស់ប្រទេសកម្ពុជាតម្រូវឲ្យមានវិធានការពិសេសមួយ ដើម្បីធានាឲ្យបាននូវការការពារសិទ្ធិមនុស្សចំពោះមនុស្សគ្រប់រូបនៅក្នុងប្រទេសកម្ពុជា ដើម្បីកុំឲ្យគោលនយោបាយនិងការអនុវត្តនៃអតីតកាលវិលត្រឡប់មកវិញម្តងទៀត ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩១ ។

អនុម័តយល់ព្រមទៅលើយោបល់របស់តំណាងពិសេសរបស់អង្គការសហប្រជាជាតិដែលថ្លែងថា ការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបំផុតនៅក្នុងប្រវត្តិសាស្ត្រថ្មីៗរបស់ប្រទេសកម្ពុជា គឺបង្កឡើងដោយក្រុមខ្មែរក្រហម ហើយអំពើឧក្រិដ្ឋរបស់ខ្មែរក្រហម ដែលរួមបញ្ចូលទាំងការចាប់និងសម្លាប់ឈ្លើយសឹក គឺបានបន្តមានរហូតដល់ពេលបច្ចុប្បន្ននេះ ។ គួរកត់សម្គាល់ថា មិនទាន់មានមេដឹកនាំខ្មែរក្រហមណាម្នាក់ត្រូវបាននាំយកមកកាត់ទោសចំពោះបទឧក្រិដ្ឋទាំងនោះឡើយ ។

ស្នើសុំលោកអគ្គលេខាធិការ ធ្វើការពិនិត្យលើសំណើរបស់អាជ្ញាធរកម្ពុជាសម្រាប់ជំនួយក្នុងការឆ្លើយតបទៅនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរកាលពីអតីតកាលលើច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ ដែលរួមទាំងលទ្ធភាពនៃការជ្រើសតាំងក្រុមអ្នកជំនាញមួយក្រុមដោយអគ្គលេខាធិការ ដើម្បីវាយតម្លៃលើភ័ស្តុតាងដែលមានស្រាប់ ហើយស្នើឲ្យមានវិធានការបន្ថែមក្នុងគោលបំណងនាំមកនូវការផ្សះផ្សាជាតិ ការពង្រឹងលទ្ធិប្រជាធិប-តេយ្យ និងការដោះស្រាយបញ្ហាការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ ។

## ១៥ មេសា ១៩៩៨

ប៉ុល ពត ស្លាប់ដោយសារជំងឺគាំងបេះដូងក្នុងអាយុ៧៣ឆ្នាំ ក្នុងស្រុកអន្លង់វែងក្បែរព្រំដែនថៃ ជាកន្លែងដែល ប៉ុល ពត ត្រូវបានឃុំឃាំងបន្ទាប់ពីត្រូវបានកាត់ទោសក្នុងរយៈពេលមួយថ្ងៃ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧ ។ (Bangkok Post, ១៧ មេសា ១៩៩៨)

## ១៣ កក្កដា ១៩៩៨

អនុលោមតាមសេចក្តីសម្រេចលេខ៥២/១៣៥របស់មហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៧ អគ្គលេខាធិការបានតែងតាំងក្រុមអ្នកជំនាញការបីរូបសម្រាប់ប្រទេសកម្ពុជា ដើម្បី

វាយតម្លៃលើភស្តុតាងដែលមានស្រាប់ ក៏ដូចជាវាយតម្លៃពីភាពដែលអាចធ្វើទៅបាន ក្នុងការនាំយកមេដឹកនាំខ្មែរក្រហមទៅកាត់ទោស និងដើម្បីស្វែងរកជម្រើសក្នុងការនាំយកមេដឹកនាំខ្មែរក្រហមទៅកាត់ទោសនៅចំពោះមុខយុត្តាធិការជាតិ ឬអន្តរជាតិ ។ *(A/52/1007 of 7 August 1998)*

### ៣១ កក្កដា ១៩៩៨

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានបង្កើតក្រុមអ្នកជំនាញមួយក្រុមដែលរួមមាន លោក នីនៀន ស្ទីហ្វិន (Ninian Stephen) មកពីប្រទេសអូស្ត្រាលីជាប្រធាន, ចៅក្រម រ៉ាសូមម័រ ឡាឡាស (Judge Rajsoommer Lallah) មកពីកោះម៉ូរីសឺស (Mauritius) និងលោកសាស្ត្រាចារ្យ ស្ទីវិន រ៉ាន័រ (Steven Ratner) មកពីសហរដ្ឋអាមេរិក ដើម្បីវាយតម្លៃពីភាពដែលអាចធ្វើទៅបាន ក្នុងការនាំខ្លួនមេដឹកនាំខ្មែរក្រហមមកកាត់ទោស ។

### ១៤ វិច្ឆិកា ១៩៩៨

ក្រុមអ្នកជំនាញការបានធ្វើដំណើរបំពេញទស្សនកិច្ចក្នុងប្រទេសកម្ពុជា ហើយបានវាយតម្លៃទៅលើភស្តុតាងដែលរក្សាទុកនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ *(រស្មីកម្ពុជា, ១១ វិច្ឆិកា ១៩៩៨)*

### ២៦ ធ្នូ ១៩៩៨

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសពីការចុះចូលជាមួយរដ្ឋាភិបាលរបស់មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ពីររូបគឺ នួន ជា និង ខៀវ សំផន ។ *(The Cambodia Daily, ២៨ ធ្នូ ១៩៩៨)*

### ៤ កុម្ភៈ ១៩៩៩

ប្រជាជនកម្ពុជាចំនួន២៣គ្រួសារបានបំពេញពាក្យបណ្តឹងទៅកាន់តុលាការ ប៊ែលហ្ស៊ិក ដើម្បីប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហម នួន ជា, ខៀវ សំផន និង អៀង សារី ដោយចោទប្រកាន់អ្នកទាំងនេះពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ ដើមបណ្តឹងត្រូវបានលើកទឹកចិត្តឲ្យធ្វើការចោទប្រកាន់ បន្ទាប់ពីជនរងគ្រោះនៅក្រោមអំណាចផ្តាច់ការរបស់ ពីណូជេ (Pinochet) បានទទួលជោគជ័យក្នុងការចេញដីកាចាប់ខ្លួនជាអន្តរជាតិចំពោះអតីតអ្នកកាន់លទ្ធិផ្តាច់ការរូបនេះ ។ *(Phnom Penh Post, ១៩ កុម្ភៈ-៤មិនា ១៩៩៩)*

### ៥ កុម្ភៈ ១៩៩៩

ប្រទេសចិនបានសម្តែងការប្រឆាំងទៅនឹងការបង្កើតតុលាការអន្តរជាតិមួយ សម្រាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ដោយអះអាងថាបញ្ហានេះគឺជាកិច្ចការផ្ទៃក្នុងរបស់កម្ពុជាតែប៉ុណ្ណោះ ។ ថាង ជាស៊ាន (Tang Jia Xuan) រដ្ឋមន្ត្រីក្រសួងការបរទេសចិនបានថ្លែងថាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងតុលាការអន្តរជាតិ ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ គឺជាគំនិតរបស់ប្រទេសលោកខាងលិច ជាពិសេសសហរដ្ឋអាមេរិក ។ *(រាយការណ៍ដោយ Rita Patiyasvi និង Marisa Chimprabha ៦ កុម្ភៈ ១៩៩៩)*

### ៧ កុម្ភៈ ១៩៩៩

អៀង ធីរិទ្ធ ដែលជាប្រពន្ធរបស់ អៀង សារី និងជារដ្ឋមន្ត្រីក្រសួងអប់រំនិងសង្គមកិច្ចក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បានសរសេរលិខិតមួយច្បាប់ឆ្លើយតបទៅនឹងអត្ថបទរបស់កាសែត ឌឹខេមបូឌាដេលី (The Cambodia Daily) ចុះថ្ងៃទី៥ ខែកុម្ភៈ ដែលមានចំណងជើងថា "អៀង សារី ព្រមានចំពោះចលាចលថ្មីពាក់ព័ន្ធនឹងការបង្កើតសាលាក្តីខ្មែរក្រហម" ។ អត្ថបទនេះសរសេរថា អៀង ធីរិទ្ធ គឺជាសមាជិកម្នាក់ក្នុងចំណោមសមាជិក៤នាក់នៃគណៈកម្មាធិការមជ្ឈិមរបស់ខ្មែរក្រហមដែលរស់នៅតំបន់ប៉ៃលិន ។ *(រស្មីកម្ពុជា, ១១ កុម្ភៈ ១៩៩៩ និង The Cambodia Daily, ៥ កុម្ភៈ ១៩៩៩)*

### ១២ កុម្ភៈ ១៩៩៩

រាជរដ្ឋាភិបាលកម្ពុជាបានបញ្ចូលអ្នកដែលនៅសល់ពីរបបខ្មែរក្រហមទៅក្នុងកងយោធពលខេមរភូមិន្ទ ។

### ១៨ កុម្ភៈ ១៩៩៩

របាយការណ៍របស់ក្រុមអ្នកជំនាញការមកកម្ពុជា ដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៥២/១៣៥ ត្រូវបានចេញផ្សាយ ។ របាយការណ៍នេះបានណែនាំឲ្យមានការបង្កើតតុលាការអន្តរជាតិមួយនិងគណៈកម្មការស្វែងរកការពិត ដើម្បីដោះស្រាយឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមនោះ ។

### ៦ មីនា ១៩៩៩

អតីតសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា ឈិត ជឿន ហៅ ម៉ុក ឬតាម៉ុក ត្រូវបានចាប់ខ្លួនដោយកងកម្លាំងយោធាកម្ពុជាក្រោមច្បាប់កម្ពុជាឆ្នាំ១៩៩៤ ស្តីពីការដាក់ក្រុមខ្មែរក្រហមឲ្យនៅក្រៅច្បាប់ ។ *(Bangkok Post, ៧ មិនា ១៩៩៩)*

### ១៥ មីនា ១៩៩៩

របាយការណ៍របស់ក្រុមអ្នកជំនាញការមកកម្ពុជា ដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៥២/១៣៥ ត្រូវបានប្រគល់ជូនក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងមហាសន្និបាតអង្គការសហប្រជាជាតិ ។ នៅក្នុងរបាយការណ៍នោះ ក្រុមអ្នកជំនាញបានណែនាំឲ្យមានការបង្កើតតុលាការអន្តរជាតិមួយ ដើម្បីកាត់ទោសមន្ត្រីខ្មែរក្រហមពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ ដែលប្រព្រឹត្តឡើងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ *(A/53/850-S/1999/23/1)*

## ៥ ឧសភា ១៩៩៩

កាំង ហ្កេកអ៊ាវ ហៅ ឌុច អតីតប្រធានគុកទួលស្លែង ត្រូវបានដកស្រង់សម្តីថា នួន ជា បានបញ្ជាឲ្យគាត់សម្លាប់ជនបរទេសនៅគុកទួលស្លែង ដោយ«ដុតសាកសពជនបរទេសទាំងនោះនឹងកង់ឡានដើម្បីកុំឲ្យនៅសល់ឆ្អឹង» ។ *(Far Eastern Economic Review, ១៣ ឧសភា ១៩៩៩)*

## ២៩ កក្កដា ១៩៩៩

នៅក្នុងកិច្ចពិភាក្សាជាមួយអ្នកតំណាងអចិន្ត្រៃយ៍របស់កម្ពុជា ការិយាល័យកិច្ចការច្បាប់ធ្វើការបង្ហាញពីសំណើរបស់អង្គការសហប្រជាជាតិ ស្តីពីការបង្កើតតុលាការចម្រុះមួយ សម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ (កំណត់សម្គាល់មួយដែលបង្ហាញពីធាតុផ្សំសំខាន់ៗនៃតុលាការចម្រុះនេះត្រូវបានចែកចាយ) ។

## ១២ សីហា ១៩៩៩

រដ្ឋសភាជាតិកម្ពុជាអនុម័តច្បាប់ថ្មីមួយ ដោយធ្វើការពន្យាររយៈពេលនៃការឃុំខ្លួនមុនការកាត់សេចក្តីពីរយៈពេល ៦ខែ ទៅ ៣ឆ្នាំ ចំពោះជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មសង្គ្រាមឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ *(រស្មីកម្ពុជា, ១៤ សីហា ១៩៩៩)*

## ១៣ សីហា ១៩៩៩

មន្ត្រីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានរិះគន់ច្បាប់ដែលរដ្ឋសភាកម្ពុជាបានអនុម័តក្នុងការអនុញ្ញាតឲ្យមានការឃុំខ្លួនរយៈពេល៣ឆ្នាំមុនការកាត់សេចក្តី ចំពោះជនសង្ស័យដែលត្រូវបានចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ លោកស្រី រ៉ូសម៉ារី ម៉ាក់គ្រីរី (Rosemary McCreery) ប្រធានការិយាល័យរបស់ស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានថ្លែងថាការឃុំខ្លួនរយៈពេល៣ឆ្នាំគឺជាការបំពានដល់បទដ្ឋានយុត្តិធម៌អន្តរជាតិ ។ *(The Cambodia Daily, ១៣ សីហា ១៩៩៩)*

រដ្ឋាភិបាលកម្ពុជាថ្លែងថា ខ្លួនចង់រក្សាការគ្រប់គ្រងទូទៅទៅលើតុលាការដែលមានទម្រង់ជាអន្តរជាតិ ហើយដែលគាំទ្រដោយអង្គការសហប្រជាជាតិ។ លោកទេសរដ្ឋមន្ត្រី សុខ អាន បានថ្លែងថា ការកាត់ទោសនឹងត្រូវធ្វើឡើងនៅក្នុងតុលាការកម្ពុជា ប៉ុន្តែកម្ពុជាទទួលយកការចូលរួមពីសំណាក់ចៅក្រមបរទេស និងអ្នកជំនាញច្បាប់បរទេសផ្សេងៗទៀត។ (The Cambodia Daily, ១៦ សីហា ១៩៩៩)

## ២០ សីហា ១៩៩៩

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត "ក្រុមការងាររបស់ខ្លួនសម្រាប់កិច្ចសហប្រតិបត្តិការជាមួយអ្នកជំនាញច្បាប់បរទេស និងការរៀបចំសម្រាប់ដំណើរការនីតិវិធីនៃអង្គជំនុំជម្រះសេចក្តីរបស់មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់" ដែលមានលោកទេសរដ្ឋមន្ត្រី សុខ អាន ជាប្រធាន។

ក្រុមការងារបានចាប់ផ្តើមការងាររបស់ខ្លួនដោយការធ្វើសេចក្តីព្រាងច្បាប់។ សេចក្តីព្រាងច្បាប់ដំបូងនេះត្រូវបានបង្កើតឡើងនៅខែសីហា ឆ្នាំ១៩៩៩ ហើយបានប្រគល់ឲ្យគណៈប្រតិភូនៃអង្គការសហប្រជាជាតិដែលដឹកនាំដោយលោក រ៉ាល្ហ្វ ហ្សាក់គ្លីន (Ralph Zacklin) អនុប្រធាន របស់លោក ហែន កូរ៉ែល (Hans Corell) ដែលជាអគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកខាងកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិ។

សេចក្តីព្រាងច្បាប់កម្ពុជាទទួលបានការចូលរួមឧបត្ថម្ភផ្នែកច្បាប់ និងបច្ចេកទេសផ្សេងៗពីអ្នកជំនាញច្បាប់មកពីប្រទេសបារាំង ឥណ្ឌា រុស្ស៊ី អូស្ត្រាលី និងសហរដ្ឋអាមេរិក បន្ថែមពីលើការរួមឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។

គណៈប្រតិភូដំបូងរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានបញ្ជូនមកបំពេញការងារនៅខែសីហា ឆ្នាំ ១៩៩៩ បានធ្វើការសិក្សាពីសេចក្តីព្រាងច្បាប់ដំបូង និងបានបង្ហាញពីសេចក្តីច្បាប់ព្រាងរបស់ខ្លួន។ នៅពេលនោះគឺពុំទាន់មានការព្រមព្រៀងគ្នានៅឡើយទេ។ ចំណុចខុសគ្នាចម្បងនោះគឺថា លោក ហ្សាគ្លីន (Zacklin) ចង់ឲ្យចៅក្រមបរទេសមានចំនួនច្រើនជាង ខណៈពេលដែលកម្ពុជាទាមទារឲ្យចៅក្រមខ្មែរមានចំនួនច្រើនជាង។ (www.cambodia.gov.kh/krt/english/chrono.htm)

## ២៥-៣១ សីហា ១៩៩៩

ក្រុមបេសកកម្មដំបូងរបស់អង្គការសហប្រជាជាតិមកកម្ពុជា គឺត្រូវបានស្នើសុំឲ្យធ្វើការចរចាស្តីអំពីផ្នែកច្បាប់ និងផ្នែកបច្ចេកទេសក្នុងការបង្កើតតុលាការចម្រុះមួយដែលស្ថិតនៅក្រោមច្បាប់កម្ពុជា និងដែលបំពេញទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ។ ការអត្ថាធិប្បាយស្តីពីសេចក្តីព្រាងច្បាប់កម្ពុជាត្រូវបានដាក់ប្រគល់ជូន។

### ៣១ សីហា ១៩៩៩

ក្រុមមន្ត្រីរបស់អង្គការសហប្រជាជាតិ និងក្រុមមន្ត្រីកម្ពុជា បានបញ្ចប់កិច្ចចរចាដែលមានរយៈពេលមួយសប្តាហ៍ ដោយមិនទទួលបានការព្រមព្រៀងគ្នាពីរបៀបនៃការបង្កើតតុលាការប្រល័យពូជសាសន៍នោះទេ ។ ជំនួយការរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ លោក រ៉ាហ្វ ហ្សាគ្លីន (Ralph Zacklin) បានថ្លែងថា ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា មិនបំពេញទៅតាមលក្ខខណ្ឌដែលអង្គការសហប្រជាជាតិជឿជាក់ថា មានសារសំខាន់ចំពោះតុលាការនោះទេ «អង្គការសហប្រជាជាតិនឹងឈប់ចូលរួមក្នុងដំណើរការនេះ» ។ គណៈប្រតិភូអង្គការសហប្រជាជាតិបានសង្ខេបអត្ថន័យសំខាន់ក្នុងលិខិតថា ៖

...ប្រសិនបើអង្គជំនុំជម្រះសេចក្តីរបស់មេដឹកនាំខ្មែរក្រហម ចង់បំពេញទៅតាមបទដ្ឋានយុត្តិធម៌ឥតលម្អៀង និងស្របច្បាប់អន្តរជាតិ និងជាពិសេសគឺទទួលបានការគាំទ្រ និងការទទួលស្គាល់តាមផ្លូវច្បាប់ពីសហគមន៍អន្តរជាតិនោះ វាមានសារសំខាន់ណាស់ដែលធាតុផ្សំជាអន្តរជាតិនៃតុលាការមួយនេះមានលក្ខណៈគ្រប់គ្រាន់ ហើយដូច្នេះតុលាការនេះនឹងត្រូវបានទទួលស្គាល់ថាមានប្រសិទ្ធិភាពទាំងពីសំណាក់ជាតិ និងអន្តរជាតិ ។ ដំណើរការនេះនឹងមិនអាចសម្រេចបានដោយគ្រាន់តែបន្ថែមចំនួន ចៅក្រមបរទេសចូលទៅក្នុងសមាសធាតុនៃប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់នោះទេ ។ មានតែតុលាការពិសេសមួយ ដែលបំបែកចេញពីប្រព័ន្ធតុលាការកម្ពុជាមានស្រាប់ ក្នុងនោះរួមមានទាំងជនជាតិកម្ពុជា និងជនជាតិបរទេស ដែលនឹងបម្រើការជាចៅក្រមព្រះរាជអាជ្ញា និងបុគ្គលិកតែប៉ុណ្ណោះទេដែលអាចសម្រេចកិច្ចការនេះបាន ។

### ៦ កញ្ញា ១៩៩៩

តាម៉ុក និង ឌុច ត្រូវបានចោទប្រកាន់ពី«បទប្រល័យពូជសាសន៍» នៅក្រោមច្បាប់មាត្រា១ ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៩ ។ *(បញ្ជារបស់រដ្ឋអាជ្ញាតុលាការយោធា លេខ ០៤៨/៩៩)*

### ១៨ កញ្ញា ១៩៩៩

អតីតមេដឹកនាំខ្មែរក្រហម អៀង សារី និង នួន ជា ដែលបច្ចុប្បន្នបានចងសម្ព័ន្ធភាពជាមួយរដ្ឋាភិបាលរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើសេចក្តីថ្លែងការណ៍មួយដោយលើកឡើងពីលទ្ធភាពនៃការវិលត្រឡប់មកវិញនូវសង្គ្រាមស៊ីវិល ប្រសិនបើតុលាការនេះត្រូវបានបង្កើតឡើងមែននោះ ។ សេចក្តីថ្លែងការណ៍នេះ ថែមទាំងធ្វើការរិះគន់ពីការទាមទាររបស់ក្រុមសិទ្ធិមនុស្ស និងអ្នកនយោបាយគណបក្សប្រឆាំងដែលចង់ធ្វើការកាត់ទោស នួន ជា និង អៀង សារី ។

## ២០ កញ្ញា ១៩៩៩

ខណៈពេលចូលរួមក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៥៤ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រគល់ជូនឯកសារមួយច្បាប់ទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណាន់ (Kofi Annan) ដោយបង្ហាញពីជម្រើសបីសម្រាប់ការចូលរួមរបស់អង្គការសហប្រជាជាតិនៅក្នុងតុលាការ ៖ ១) ផ្តល់ក្រុមអ្នកច្បាប់ និងធ្វើការចូលរួមក្នុងតុលាការ ដែលប្រព្រឹត្តឡើងនៅក្នុងប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ។ ២)ផ្តល់ការប្រឹក្សាច្បាប់ដោយមិនចូលរួមដោយផ្ទាល់នៅក្នុងអង្គជំនុំជម្រះ និង ៣)ដកខ្លួនទាំងស្រុងចេញពីតុលាការដែលត្រូវបានស្នើឡើងនេះ ។ *(The Cambodia Daily, ២០ សីហា ១៩៩៩)*

## ២៣ កញ្ញា ១៩៩៩

ពេលត្រឡប់មកពីការជួបពិភាក្សាជាមួយលោក កូហ្វី អាណាន់ (Kofi Annan) អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីរបៀបនៃការកាត់ទោសអតីតបក្ខពួករបស់ ប៉ុល ពត មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលបានសម្រេចថា នឹងបន្តដំណើរការការកាត់ទោសដោយខ្លួនឯង ។ ជាជាងការបង្កើតឡើងនូវតុលាការដែលមានលក្ខណៈជាអន្តរជាតិ ដែលស្នើឡើងដោយអង្គការសហប្រជាជាតិ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សុខ អាន បានថ្លែងថា រដ្ឋាភិបាលកម្ពុជានឹងស្វែងរកការប្រឹក្សាយោបល់ពីអ្នកជំនាញច្បាប់ឯករាជ្យពីសហរដ្ឋអាមេរិក និងបារាំង ដើម្បីការពារការរិះគន់ពីភាពត្រឹមត្រូវតាមផ្លូវច្បាប់ដែលកម្ពុជាខ្វះខាត ។ លោក សុខ អាន បាននិយាយថា «យើងនឹងបន្តធ្វើការលើសេចក្តីព្រាងច្បាប់របស់យើង ហើយខ្ញុំសន្យាថានឹងធ្វើការរាយការណ៍ស្តីពីដំណើរការវិវត្តន៍របស់យើងជូនដល់អង្គការសហប្រជាជាតិ» ។ *(The Cambodia Daily, ២៤ កញ្ញា ១៩៩៩)*

## ៨ តុលា ១៩៩៩

ក្រសួងការបរទេសសហរដ្ឋអាមេរិកលុបឈ្មោះខ្មែរក្រហមចេញពីបញ្ជីភេរវករ ដោយសារតែអង្គការខ្មែរក្រហម មិនមែនជាអង្គការភេរវកម្មដែលនៅឋិតថេរទៀតឡើយ» ។ *(The Cambodia Daily, ៨ តុលា ១៩៩៩)*

## ១៩ តុលា ១៩៩៩

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គាំទ្រសំណើរបស់សហរដ្ឋអាមេរិកសម្រាប់តុលាការមួយដែលរួមមានចៅក្រមកម្ពុជាបីរូប និងចៅក្រមពីររូបដែលជ្រើសតាំងដោយអង្គការសហប្រជាជាតិ ។ សេចក្តីសម្រេច

តម្រូវឲ្យ«មានមតិភាគច្រើនលើសលប់» ដែលយ៉ាងហោចណាស់មានចៅក្រមមួយរូប ដែលជ្រើសតាំងដោយអង្គការសហប្រជាជាតិ យល់ពល់ការធ្វើសេចក្ដីសម្រេចចិត្តទៅលើសាលក្រមរបស់តុលាការ ។ (The Cambodia Daily, ២០ តុលា ១៩៩៩)

## ២០ ធ្នូ ១៩៩៩

រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនសេចក្ដីព្រាងច្បាប់ទៅអង្គការសហប្រជាជាតិ ដែលបង្ហាញពីមធ្យោបាយក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម នៅក្នុងអង្គសវនាការពិសេសមួយនៃតុលាការក្រុងភ្នំពេញជាមួយនឹងវត្តមានភាគច្រើននៃចៅក្រមកម្ពុជា និងក្រុមព្រះរាជអជ្ញាដែលក្នុងនោះមានភាគីបរទេសមួយរូប និងភាគីខ្មែរមួយរូបក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងថា «កម្ពុជានឹងអនុម័តច្បាប់នេះទោះបីជាមាន ឬមិនមានការយល់ស្របពីអង្គការសហប្រជាជាតិក៏ដោយ» ។ (The Cambodia Daily, ២២ ធ្នូ ១៩៩៩)

## ២៣ ធ្នូ ១៩៩៩

លោក សុខ អាន ថ្លែងថា«អគ្គលេខាធិការអង្គការសហប្រជាជាតិលោក កូហ្វី អាណាន់ បានធ្វើអត្ថាធិប្បាយទៅលើសេចក្ដីព្រាងច្បាប់ដោយបានបង្ហាញថា អង្គការសហប្រជាជាតិជ្រើសរើសយកជម្រើសទីពីរនៃអនុសាសន៍របស់យើង» ។ (លោក សុខ អាន សំដៅទៅដល់ជម្រើសបីដែលសម្ដេច ហ៊ុន សែន បានស្នើជូនទៅលោក កូហ្វី អាណាន់ កាលពីថ្ងៃទី២០ ខែកញ្ញា) ។

## ២៤ ធ្នូ ១៩៩៩

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើវិសោធនកម្មលើសេចក្ដីព្រាងច្បាប់របស់តុលាការ ដើម្បីឲ្យការចំណាយរបស់តុលាការ ដែលកាលពីមុនជាការចំណាយរបស់មូលនិធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិនឹងក្លាយជាការចំណាយរួមមួយនៃមូលនិធិដែលបានមកពីជំនួយរបស់អង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាល និងប្រទេសដទៃទៀត ដែលរួមទាំងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ ។ សេចក្ដីកែប្រែនោះបានបញ្ជាក់ថា ប្រសិនបើប្រទេសដទៃចង់បញ្ជូនចៅក្រម ឬព្រះរាជអាជ្ញាមកក្នុងដំណើរការនីតិវិធីនេះ ប្រទេសទាំងនោះត្រូវតែចេញថ្លៃចំណាយដោយខ្លួនឯង ។ (The Cambodia Daily, ២៥-២៦ ធ្នូ ១៩៩៩)

## ២៧ ធ្នូ ១៩៩៩

លោក បែនសុន សាមៃ មេធាវីរបស់ តាម៉ុក និយាយថា លោកមានគម្រោងចេញដីការកោះហៅសាក្សីនៃអតីតមេដឹកនាំប៉ុន្មានរូបនៅក្នុងពិភពលោក ដែលរួមទាំងអតីតប្រធានាធិបតីសហរដ្ឋអាមេរិកចំនួនបីរូប ដើម្បីសាកសួរអ្នកទាំងអស់នោះ អំពីការជួយឧបត្ថម្ភគាំទ្រមកលើរបបកម្ពុជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ។ អ្នកដែលលោកមេធាវីមានបំណងកោះហៅរួមមាន លោកអតីតប្រធានាធិបតីសហរដ្ឋអាមេរិក ជីមី ខាធ័រ (Jimmy Carter), លោកអតីតប្រធានាធិបតីសហរដ្ឋអាមេរិក រ៉ូណាល់ រីហ្គេន (Ronald Reagan), និងលោកអតីតប្រធានាធិបតីសហរដ្ឋអាមេរិក ហ្សក ប៊ូស (George Bush), ក៏ដូចជាលោក ម៉ាហ្គារេត ថាតឆឺ (Margaret Thatcher) និងលោក ហេនរី ឃីស៊ីងជឺ (Henry Kissinger) ។

### ២៨ ធ្នូ ១៩៩៩

សេចក្តីព្រាងច្បាប់ទីពីរសម្រាប់តុលាការ ត្រូវបានបញ្ជូនទៅឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាមួយ នឹងការស្នើសុំមួយទៀត ដោយឲ្យធ្វើការឆ្លើយតបភ្លាមៗ ។

### ៥ មករា ២០០០

ទីប្រឹក្សាច្បាប់អង្គការសហប្រជាជាតិ លោក ហែន កូរេល (Hans Corell) បានជួបពិភាក្សាជាមួយលោកឯកអគ្គរាជទូត អ៊ុច បូរិទ្ធ តំណាងអចិន្ត្រៃយ៍របស់កម្ពុជាប្រចាំអង្គការសហប្រជាជាតិ ដើម្បីបញ្ជូនការឆ្លើយតបរបស់អង្គការសហប្រជាជាតិ ទៅលើសេចក្តីព្រាងច្បាប់ទីពីរពាក់ព័ន្ធនឹងការបង្កើតតុលាការ ។ *(The Associate Press, ៦ មករា ២០០០)*

### ៦ មករា ២០០០

គណរដ្ឋមន្ត្រីកម្ពុជាបានអនុម័តទៅលើសេចក្តីព្រាងច្បាប់ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់រានមានជីវិតពីបទប្រល័យពូជសាសន៍ ទោះបីជាអង្គការសហប្រជាជាតិនៅតែបារម្ភអំពីដែនកំណត់ ដែលត្រូវបានដាក់មកលើចៅក្រមអន្តរជាតិក៏ដោយ ។ *(South China Morning Post, ៧ មករា ២០០០)*

### ១៤ មករា ២០០០

គណរដ្ឋមន្ត្រីកម្ពុជាបានធ្វើការកែប្រែទៅលើសេចក្តីព្រាងច្បាប់ស្តីពីតុលាការ ដើម្បីអនុញ្ញាតឲ្យមានការចូលរួមពីសំណាក់ចៅក្រមបរទេសមួយរូប នៅក្នុងដំណើរការស៊ើបអង្កេត ។

### ១៨ មករា ២០០០

អង្គការសហប្រជាជាតិទទួលបានឯកសារបកប្រែនៃសេចក្ដីព្រាងច្បាប់ ដែលបានកែប្រែស្ដីពីការបង្កើតសាលាក្ដីកាត់ទោសខ្មែរក្រហម ។

## ១៩ មករា ២០០០

ឯកឧត្ដម សុខ អាន បានប្រាប់អ្នកសារព័ត៌មានថា លោកបានដាក់សេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើតតុលាការកាត់ទោសខ្មែរក្រហមថ្វាយព្រះអង្គម្ចាស់ នរោត្ដម រណឫទ្ធិ ដើម្បីយកទៅពិភាក្សាដេញដោលនៅក្នុងរដ្ឋសភាជាតិ ។ *(Kyodo, ១៩ មករា ២០០០)*

## ២៧ មករា ២០០០

វេទិកាពិភាក្សាជាសាធារណៈលើកទីមួយនៅកម្ពុជា ស្ដីពីតុលាការកាត់ទោសខ្មែរក្រហមត្រូវបានប្រារព្ធធ្វើឡើងនៅខេត្តបាត់ដំបង ភាគពាយ័ព្យនៃប្រទេសកម្ពុជា ។ ប្រជាជនប្រហែល១០០នាក់ ដែលរួមទាំងមន្ត្រីខ្មែរក្រហមថ្នាក់កណ្ដាលផង បានចូលរួមក្នុងវេទិកាពិភាក្សានេះ ។ *(Reuters, ២៧ មករា ២០០០)*

## ៤ កុម្ភៈ ២០០០

អតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ខៀវ សំផន និយាយថា លោកស្ម័គ្រចិត្តឡើងមកនិយាយនៅក្នុងវេទិកាសាធារណៈ ។ *(Phnom Penh Post, ៤-១៧ កុម្ភៈ ២០០០)*

## ៨ កុម្ភៈ ២០០០

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្ដល់សញ្ញាជាវិជ្ជមានមួយ ប៉ុន្តែលោកមិនត្រៀមខ្លួនដើម្បីប្រគល់ការគ្រប់គ្រងលើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទៅឲ្យអង្គការសហប្រជាជាតិឡើយ ដែលធ្វើឲ្យសេចក្ដីសង្ឃឹមរបស់តុលាការប្រល័យពូជសាសន៍អន្តរជាតិមួយនេះមានលក្ខណៈកាន់តែតិចតួចទៅ ។ ក្នុងឱកាសនិយាយទៅកាន់អ្នកសារព័ត៌មាន ក្រោយកិច្ចប្រជុំបក្សជាឯកជនមួយ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើការរិះគន់ចំពោះការទាមទាររបស់អង្គការសហប្រជាជាតិ ដែលចង់ឲ្យមានការកាត់ទោសជាអន្តរជាតិទៅលើរបបវាលពិឃាត ដោយលោកបានអះអាងថា នេះជាការលោភលន់មួយ និងបានជំរុញឲ្យពិភពលោកបង្វែរការចាប់អារម្មណ៍មកលើភាពក្រីក្ររបស់កម្ពុជាវិញ ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងថា «ខ្ញុំសូមផ្ញើសារដ៏សំខាន់មួយថា ៖ ពិភពលោកគួរតែធ្វើការចាប់អារម្មណ៍ទៅលើសន្តិភាព ការផ្សះផ្សាជាតិ ការបង្រួបបង្រួមជាតិ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ជាជាងតុលាការកាត់ទោសខ្មែរក្រហម» ។ *(AFP, ៩ កុម្ភៈ ២០០០)*

លោកអគ្គលេខាធិការ កូហ្វី អាណាន់ និយាយថា លោកមិនយល់ស្របនឹងសេចក្តីព្រាងច្បាប់របស់តុលាការ ដែលអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានោះទេ ។ លោកគូលបញ្ជាក់ពីបញ្ហាសំខាន់ៗចំនួន៤ គឺធានាឲ្យបានថាអ្នកដែលត្រូវបានចោទប្រកាន់នឹងត្រូវចាប់ខ្លួន, មិនមានការអភ័យទោស ឬលើកលែងទោស, ការតែងតាំងព្រះរាជអាជ្ញាអន្តរជាតិដោយឯករាជ្យ និងការតែងតាំងចៅក្រម បរទេសក្នុងចំនួនភាគច្រើន ។ (Kyodo News Agency, ១០ កុម្ភៈ ២០០០)

## ១០ កុម្ភៈ ២០០០

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បដិសេធចំពោះការឆ្លើយតបរបស់លោក កូហ្វី អាណាន់ ស្តីពីសេចក្តីព្រាងច្បាប់បង្កើតតុលាការកាត់ទោសខ្មែរក្រហម ដោយមានប្រសាសន៍ថាវាមិនយុត្តិធម៌សម្រាប់ប្រទេសកម្ពុជាទេ ។ នៅក្នុងសារលិខិតមួយផ្ញើជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ លោកនាយករដ្ឋមន្ត្រីអះអាងថា លោកមិនបានស្វាគមន៍ចំពោះគម្លាតនៅក្នុងមុខតំណែងរវាងអង្គការសហប្រជាជាតិ និងកម្ពុជានោះទេ ជាពិសេស ដោយសារតែមុខតំណែងទាំងនេះ ត្រូវបានកាន់កាប់ដោយប្រទេសជាសមាជិកផ្សេងទៀត ។ (Xinhau, ១០ កុម្ភៈ ២០០០)

## ១២ កុម្ភៈ ២០០០

នៅក្នុងការថ្លែងក្រៅសន្និសីទពាណិជ្ជកម្មអង្គការសហប្រជាជាតិនៅទីក្រុងបាងកក លោកអគ្គលេខាធិការ កូហ្វី អាណាន់ បានមានប្រសាសន៍ថា លោកមានសុទិដ្ឋិនិយមថា បេសកកម្មថ្មីរបស់អង្គការសហប្រជាជាតិនៅកម្ពុជា នឹងអាចដោះស្រាយភាពខុសគ្នាជាមួយរដ្ឋាភិបាលកម្ពុជាអំពីការបង្កើតតុលាការ ។ (AFP, ១១ កុម្ភៈ ២០០០)

## ១៤ កុម្ភៈ ២០០០

អតីតរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក លោក ហេនរី ឃីស៊ីងជឺ (Henry Kissinger) ធ្វើទៅលើការស្នើសុំដែលថា លោកគួរតែឡើងធ្វើសក្ខីកម្មឲ្យភាគីការពារក្តីនៅក្នុងតុលាការប្រល័យពូជសាសន៍ខ្មែរក្រហម ដោយលោកនិយាយថា គោលនយោបាយសង្គ្រាមត្រជាក់របស់លោក គឺដើម្បីបញ្ឈប់កងទ័ពព្រៃកម្ពុជា ។ លោក ឃីស៊ីងជឺ និយាយថា “ខ្ញុំធ្វើជាសាក្សីឲ្យព្រះរាជអជ្ញាគឺល្អជាងធ្វើជាសាក្សីឲ្យខាងមេធាវីការពារក្តី ហើយខ្ញុំជឿថា ប្រជាជនទាំងអស់នៅតំបន់នេះដែលដឹងអំពីកម្ពុជានឹងគាំទ្រក្នុងរឿងនេះ” ។ (Associated Press, ១៤ កុម្ភៈ ២០០០)

## ៦ មីនា ២០០០

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើការរិះគន់អង្គការសហប្រជាជាតិដោយមានប្រសាសន៍ថា អតីតអគ្គលេខាអង្គការសហប្រជាជាតិចំនួន៣រូប គួរតែទទួលខុសត្រូវចំពោះការអនុញ្ញាតឲ្យខ្មែរក្រហមកាន់កាប់អាសនរបស់កម្ពុជានៅអង្គការសហប្រជាជាតិ ក្នុងអំឡុងចុងទសវត្សរ៍ឆ្នាំ១៩៧០ និងទសវត្សរ៍ឆ្នាំ១៩៨០ ។ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ មានព្រះបន្ទូលប្រាប់អ្នកសារព័ត៌មានថា ព្រះអង្គយល់អំពី«ការពិត»នៃជំហររបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប៉ុន្តែព្រះអង្គម្ចាស់ និងព្រះបិតារបស់ទ្រង់ (សម្តេចព្រះ នរោត្តម សីហនុ សង្ឃឹមថា នឹងមានការធ្វើសម្បទានមួយអាចសម្រេចបាន ។

## ១៦ មីនា ២០០០

ក្រុមអ្នកចរចារបស់អង្គការសហប្រជាជាតិនិងកម្ពុជា បានបើកកិច្ចប្រជុំចរចារលើកទីមួយក្នុងវគ្គចុងក្រោយបំផុត ដើម្បីពិភាក្សាលើភាពខុសគ្នាដ៏គួរឲ្យកត់សម្គាល់ស្តីពីទម្រង់បែបបទនៃតុលាការខ្មែរក្រហម ។ បញ្ហាសំខាន់ចំនួន៤ត្រូវបានយកមកដាក់នៅលើតុចរចារ តើអ្នកណាជាអ្នកកំណត់ឈ្មោះជនសង្ស័យនៅក្នុងអង្គជំនុំជម្រះ? ថាតើរាជរដ្ឋាភិបាលកម្ពុជានឹងធ្វើការឃាត់ខ្លួនរាល់ជនសង្ស័យទាំងអស់ដែរឬទេ? តើរាជរដ្ឋាភិបាលដែលកំពុងតែដោះស្រាយបញ្ហាខ្មែរក្រហម នឹងធ្វើការការពារអតីតក្រុមខុទ្ទាមមួយចំនួនពីការកាត់ទោសដែរឬទេ? តើចៅក្រមបរទេសនិងចៅក្រមកម្ពុជានឹងត្រូវតែងតាំងដោយរបៀបណា? (The Cambodia Daily, ១៦ មិនា ២០០០)

## ២១ មីនា ២០០០

លោក ហែន កូវ៉ែល អ្នកតំណាងអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ និងលោក សុខ អាន បានឆ្លើយឆ្លងលិខិតគ្នាចំពោះបញ្ហាពាក់ព័ន្ធនឹងការលើកលែងទោស សហព្រះរាជអាជ្ញា និងអំណាចក្នុងការធ្វើការដោយឯករាជ្យ ក្នុងករណីដែលមានភាពចម្រូងចម្រាសកើតឡើង ។ បញ្ហានៃយន្តការក្នុងការដោះស្រាយជម្លោះគឺនៅតែមិនទាន់សម្រេចនៅឡើយទេ ។

## ២២ មីនា ២០០០

បន្ទាប់ពីកិច្ចចរចាដែលប្រព្រឹត្តទៅអស់រយៈពេលមួយសប្តាហ៍រួចមក កម្ពុជានិងអង្គការសហប្រជាជាតិបានប្រកាសថា ខ្លួនមិនអាចឈានទៅដល់ការយល់ស្របគ្នាអំពីរបៀបនៃការបង្កើតតុលាការចម្រុះមួយសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហមបានទេ ។

### ១០ មេសា ២០០០

សម្ដេចព្រះ នរោត្ដម សីហនុ ប្រកាសថា ព្រះអង្គស្ម័គ្រចិត្តក្នុងការឡើងទៅឆ្លើយបំភ្លឺនៅចំពោះមុខតុលាការដែលដំណើរការដោយកម្ពុជា ឬតុលាការប្រល័យពូជសាសន៍ ដែលរៀបចំដោយអន្តរជាតិ ដើម្បីពន្យល់អំពីតួនាទីរបស់ព្រះអង្គនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ *(The Nation, ១១ មេសា ២០០០)*

### ១៩ មេសា ២០០០

លោក កូហ្វី អាណាន់ បានសរសេរលិខិតមួយច្បាប់ ផ្ញើជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីឆ្លើយតបនឹងការគាំទ្ររបស់មេដឹកនាំកម្ពុជាទៅលើគម្រោងការរបស់សហរដ្ឋអាមេរិក ទាក់ទងនឹងរបៀបនៃការដោះស្រាយបញ្ហាចំពោះការចោទប្រកាន់នៅក្នុងតុលាការចម្រុះមួយនេះ ។ អ្នកដឹកនាំការចរចា លោក សុខ អាន ឆ្លើយតបនឹងសំបុត្ររបស់លោក កូហ្វី អាណាន់ ថា «ខ្ញុំមិនទាន់បានត្រួតពិនិត្យនៅឡើយទេ» ។ លោក កូហ្វី អាណាន់ បានប្រាប់អ្នកសារព័ត៌មាននៅឯទីស្នាក់ការអង្គការសហប្រជាជាតិថា «មានតែឆ្លងកាត់ការត្រួតពិនិត្យឲ្យបានហ្មត់ចត់ទេ ទើបអាចធ្វើឲ្យមានការផ្ដល់យោបល់និងបកស្រាយទាក់ទងនឹងដំណើរការនេះបាន» ។ មានសំណើមួយចំនួនត្រូវបានស្នើឡើងដើម្បីដោះស្រាយភាពរាំងស្ទះដែលយើងជួបប្រទះ ។ ភាពរាំងស្ទះទាំងនោះទាក់ទងនឹងរបៀបនៃការដោះស្រាយស្ថានភាព នៅពេលដែលព្រះរាជអាជ្ញាមួយរូបមិនយល់ស្របនឹងព្រះរាជអាជ្ញាមួយរូបទៀត» ជាពិសេស របៀបដែលយន្តការត្រួតពិនិត្យដ៏មានប្រសិទ្ធភាព អាចដំណើរការបាន ។ *(The Cambodia Daily, ២២-២៣ មេសា ២០០០)*

### ២២ មេសា ២០០០

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឆ្លើយតបនឹងសំបុត្ររបស់អគ្គលេខាធិការអង្គការសហប្រជាជាតិកាលពីថ្ងៃទី១៩ ខែមេសា ដែលក្នុងនោះលោកបានអះអាងថា ការឆ្លើយឆ្លងសំបុត្ររវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាមិនអាចធ្វើអ្វីបានទេ មុនពេលដែលច្បាប់មិនទាន់បានអនុម័ត ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើសុំឲ្យមាន«សវនាការពិសេស»មួយ ដើម្បីដោះស្រាយភាពចម្រូងចម្រាសរវាងសហព្រះរាជអាជ្ញា ។

### ២៥ មេសា ២០០០

លោក កូហ្វី អាណាន់ បានផ្ញើលិខិតទីពីរជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីឆ្លើយតបនឹងលិខិតកាលពីថ្ងៃទី២២ ខែមេសា ដោយជំរុញឲ្យលោកនាយករដ្ឋមន្ត្រីទទួលយកសំណើរបស់អង្គការសហប្រជាជាតិ ។

### ២៧ មេសា ២០០០

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឆ្លើយតបទៅនឹងលិខិតរបស់លោក កូហ្វី អាណាន់ កាលពីថ្ងៃទី២៥ ខែមេសា ដោយស្នើសុំឲ្យធ្វើការពង្រីកយុត្តាធិការលើអាជ្ញាយុកាលរបស់អង្គជំនុំជម្រះដោយកាត់ទោសលើឧក្រិដ្ឋកម្មដែលកើតមានតាំងពីឆ្នាំ១៩៧០ ។

### ២៩ មេសា ២០០០

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានយល់ស្របនឹងសំណើរបស់សមាជិកព្រឹទ្ធសភាអាមេរិក លោក ចន ខេរី (John Kerry) ។ នៅក្នុងសំណើនោះ ក្រុមចៅក្រមដែលរួមមានចៅក្រមកម្ពុជា៣រូប និងចៅក្រមបរទេស២រូប នឹងធ្វើការដោះស្រាយទៅលើជម្លោះទាក់ទងនឹងការចោទប្រកាន់ ។ ដើម្បីរារាំងជម្លោះមួយបន្តកើតមានទៀតមានការយល់ស្របពីចៅក្រមចំនួន៤រូប ។

### ១៧ ឧសភា ២០០០

លោក អាណាន់ បានសរសេរលិខិតមួយផ្ញើជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីចង់បានការអះអាងបញ្ជាក់បន្ថែមដែលថាលោកនាយករដ្ឋមន្ត្រីបានយល់ព្រមនឹងសំណើ ដែលធ្វើឡើងនៅក្នុងលិខិតរបស់លោកអគ្គលេខាធិការ ដែលធ្វើឡើងនៅថ្ងៃទី១៩ ខែមេសា តាមរយៈព្រឹទ្ធសមាជិក ចន ខេរី ទាក់ទងនឹងយន្តការក្នុងដោះស្រាយភាពមិនស្របគ្នារវាងសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា និងយុត្តាធិការលើអាជ្ញាយុកាលរបស់តុលាការដែលត្រូវកំណត់ត្រឹមតែអំឡុងឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ។

### ១៩ ឧសភា ២០០០

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្ញើលិខិតមួយទៅលោក កូហ្វី អាណាន់ ដើម្បីបង្ហាញពីការគាំទ្ររបស់លោក ទៅលើរូបមន្តសម្បទានដែលសម្របសម្រួលដោយសមាជិកព្រឹទ្ធសភាអាមេរិក ចន ខេរី នៅខែមេសា ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ (រស្មីកម្ពុជា, ២៦ មេសា ២០០០)

### ៦ កក្កដា ២០០០

អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា បានបញ្ចប់សេចក្តីលម្អិតនៃសេចក្តីព្រាងច្បាប់សម្រាប់ការបង្កើតតុលាការ ។ តុលាការដែលនឹងជិតកើតមាននេះ នឹងក្លាយជាតុលាការកម្ពុជា ដែលមានការចូលរួមពីសំណាក់ព្រះរាជអាជ្ញា និងចៅក្រមអន្តរជាតិ ។

## ៧ កក្កដា ២០០០

លោក ហែន កូរ៉ែល បានបង្ហាញអនុស្សារណៈនៃការយោគយល់គ្នាស្តីពីសេចក្តីព្រាងច្បាប់ ដែលនឹងដឹកនាំកិច្ចសហការរវាងអង្គការសហប្រជាជាតិនិងប្រទេសកម្ពុជា ស្តីអំពីការបង្កើតនិងប្រតិបត្តិការរបស់សាលាក្តី ។ អនុស្សារណៈនឹងត្រូវបានចុះហត្ថលេខាដោយអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីសភាកម្ពុជាអនុម័តច្បាប់ស្តីពីតុលាការនេះ ។ លោក កូរ៉ែល និង លោក ឳម យិនទៀង ទីប្រឹក្សាជាន់ខ្ពស់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើទស្សនកិច្ចទៅកាន់មហោស្រពចតុមុខ ដែលអាចក្លាយជាសាលសវនការមុនពេលដែលក្រុមប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិចាកចេញពីប្រទេសកម្ពុជា ។

## ២៨ កញ្ញា ២០០០

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចង្អុលបង្ហាញថា អតីតរដ្ឋមន្ត្រីក្រសួងការបរទេសរបស់ខ្មែរក្រហម អៀង សារី មិនគួរត្រូវបាននាំយកទៅកាត់ទោសពីបទប្រល័យពូជសាសន៍នោះទេ ។ (នៅឆ្នាំ១៩៧៩ អៀង សារី ជាមួយនឹង ប៉ុល ពត ត្រូវបានកាត់ទោសប្រហារជីវិតដោយកំបាំងមុខ ។ ប៉ុន្តែ អៀង សារី ទទួលបានការលើកលែងទោសពីសម្តេចព្រះ នរោត្តម សីហនុ បន្ទាប់ពីលោកបានចុះចូលជាមួយរាជរដ្ឋាភិបាលនៅឆ្នាំ១៩៩៦) ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបន្ថែមទៀតថា វាអាស្រ័យទៅលើតុលាការ និងសភា ជាតិ ដែលកំពុងពិចារណាទៅលើសេចក្តីព្រាងច្បាប់អំពីតុលាការកាត់ទោសខ្មែរក្រហមតែប៉ុណ្ណោះ ថាតើគួរធ្វើ យ៉ាងណាចំពោះ អៀង សារី ។ *(The Cambodia Daily, ២៥ កញ្ញា ២០០០)*

## ១៧ តុលា ២០០០

ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បានថ្លែងប្រាប់អ្នកសារព័ត៌មានថា សម្តេចព្រះ នរោត្តម សីហនុ បានបង្ហាញពីព្រះទ័យចង់ឲ្យមានការពន្យារចំពោះដំណើរការតុលាការ ព្រោះព្រះអង្គមានការព្រួយបារម្ភអំពីសន្តិភាព និងស្ថេរភាពនៅក្នុងប្រទេស ។ ព្រះអង្គម្ចាស់បានបន្ថែមទៀតថា សេចក្តីព្រាងច្បាប់របស់តុលាការនឹងមិនទាន់អនុម័តនៅក្នុងឆ្នាំនេះទេ ពីព្រោះរដ្ឋាភិបាលកំពុងតែព្រួយបារម្ភពីទឹកជំនន់ដែលកំពុងតែកើតឡើងថ្មីៗនេះជាង ។

## ១៨ តុលា ២០០០

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសតាមវិទ្យុជាតិពីបំណងរបស់សម្តេចក្នុងការជំរុញឲ្យច្បាប់ស្តីពីតុលាការខ្មែរក្រហមមានដំណើរការទៅមុខ ។ សម្តេចមានប្រសាសន៍ថា «យើងត្រូវការឲ្យមានតុលាការនៅពេលឆាប់ៗនេះ បើមិនដូច្នេះខ្មោចរបស់ខ្មែរក្រហមនៅតែតាមលងយើង» ។ *(The Associated Press, ១៨ តុលា ២០០០)*

## ២ វិច្ឆិកា ២០០០

ប្រជាជាតិចំនួន១១ ដែលរួមមានទាំងប្រទេសជប៉ុន អូស្ត្រាលី កាណាដា និង ហូល្លង់ បានដាក់ជូនសេចក្តីសម្រេចមួយដល់គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដោយសំណូមពរឲ្យរដ្ឋាភិបាលកម្ពុជាបង្កើតតុលាការមួយដើម្បីកាត់ទោសខ្មែរក្រហម ។

## ២០ វិច្ឆិកា ២០០០

យោងទៅតាមរបាយការណ៍របស់សារព័ត៌មានបានឲ្យដឹងថា ការធ្វើដំណើរទស្សនកិច្ចរយៈពេលមួយថ្ងៃនៅប្រទេសកម្ពុជារបស់សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិកលោក ចន ខេរី ប្រហែលជាអាចជម្រុញឲ្យកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញសម្រេចទៅបាន ។ លោក ខេរី ត្រឡប់ទៅប្រទេសរបស់លោកវិញជាមួយនឹងការសន្យាយ៉ាងមុតមាំពីសំណាក់ លោក សុខ អាន សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ថា ដំណើរការរបស់អង្គជំនុំជម្រះ នឹងដើរទៅមុខតាមពេលកំណត់ដែលអាចជំរុញឲ្យសភាជាតិធ្វើការអនុម័តច្បាប់នេះនៅខែធ្នូ បាន ។ *(Phnom Penh Post, ២៤ វិច្ឆិកា-៧ ធ្នូ ២០០០)*

## ២៨ វិច្ឆិកា ២០០០

គណៈកម្មការនីតិកម្មនៃរដ្ឋសភានិងក្រុមការងាររបស់រដ្ឋាភិបាល ធ្វើការបញ្ចប់កិច្ចពិភាក្សារបស់ខ្លួនលើសេចក្តីព្រាងច្បាប់ស្តីពីតុលាការ ។ ច្បាប់នេះគឺរួចរាល់ក្នុងការយកមកពិភាក្សាដេញដោលនៅក្នុងរដ្ឋសភាជាតិ ។ *(www.cambodia.gov.kh/krt/english/chrono.htm)*

## ២៨ វិច្ឆិកា ២០០០

នៅក្នុងបទសម្ភាសន៍ជាមួយទូរទស្សន៍ជប៉ុន លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើការបញ្ជាក់ម្តងទៀតថា ការកាត់ទោស អៀង សារី ប្រហែលជាអាចបង្កើតបញ្ហាសម្រាប់ប្រទេសកម្ពុជា ។ ប៉ុន្តែ លោកអះអាងថា "ការកាត់ទោស ខៀវ សំផន និង នួន ជា ប្រហែលជាមិនមានបញ្ហាអ្វីទេ" ។ *(The Associated Press, ៣ ធ្នូ ២០០០)*

## ៤ ធ្នូ ២០០០ UNGA A/RES/55/95

សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ UNGA A/RES/55/95

**កថាខណ្ឌទី១៨** ៖ សូមទទួលស្វាគមន៍ចំពោះសេចក្ដីសម្រេចជាស្ថាពរនៃកិច្ចពិភាក្សារវាងរដ្ឋាភិបាលកម្ពុជា និងអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ ស្ដីពីការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ។ សូមអំពាវនាវយ៉ាងខ្លាំងក្លាទៅកាន់រដ្ឋាភិបាល ដោយរួមទាំងការជួយសម្របសម្រួលក្នុងការសម្រេចនូវដំណើរការតាក់តែងច្បាប់ឲ្យបានរួសរាន់តាមតែអាចធ្វើទៅបាន ដើម្បីធានាឲ្យបានថា មេដឹកនាំខ្មែរក្រហមទាំងនោះ នឹងត្រូវបាននាំយកមកកាត់ទោសដោយស្របទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពស្មើគ្នា ភាពឥតលម្អៀង និងដំណើរការនីតិវិធីស្របច្បាប់ ជាពិសេសសូមជំរុញឲ្យរដ្ឋាភិបាលបន្តសហការជាមួយអង្គការសហប្រជាជាតិស្ដីពីបញ្ហានេះ ព្រមទាំងសូមស្វាគមន៍កិច្ចខំប្រឹងប្រែងរបស់អគ្គលេខាធិការដ្ឋាន និងសហគមន៍អន្តរជាតិ ដែលបានជួយឲ្យរដ្ឋាភិបាលមកដល់ទីបញ្ចប់នេះ ។ (www.cambodia.gov.kh/krt/english/chrono.htm)

## ១៩ ធ្នូ ២០០០

អៀង សារី ប្រាប់សារព័ត៌មានថា លោកបានចូលរួមចំណែកក្នុងការកសាងជាតិ ក៏ដូចជាការផ្សះផ្សាជាតិឡើងវិញ ចាប់តាំងពីការចុះចូលរបស់លោកជាមួយរាជរដ្ឋាភិបាលនៅខែកញ្ញាឆ្នាំ១៩៩៦មក ។ លោកបានបន្ថែមទៀតថា លោកគ្រាន់តែទទួលបន្ទុកកិច្ចការបរទេសតែប៉ុណ្ណោះ នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយលោកមិនមែនជាអ្នកមានការទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍នោះទេ ។

## ២៩ ធ្នូ ២០០០

រដ្ឋសភាជាតិរបស់កម្ពុជា ទទួលបានសេចក្ដីព្រាងច្បាប់ស្ដីពីតុលាការពីសំណាក់ក្រុមការងាររបស់រាជរដ្ឋាភិបាល ។ សមាជិកសភាចំនួន៩៨រូបក្នុងចំណោម១២២រូប បានធ្វើការគាំទ្រចំពោះជំពូកមួយនៃច្បាប់ស្ដីពីតុលាការកាត់ទោសខ្មែរក្រហម ។ ច្បាប់នេះត្រូវបានរំពឹងថានឹងសម្រេចឲ្យបានចប់សព្វគ្រប់នៅដើមខែមករានេះ ។ (The Cambodia Daily, ៣០-៣១ ធ្នូ ២០០០)

## ២ មករា ២០០១

រដ្ឋសភាកម្ពុជាបានអនុម័តជាឯកច្ឆន្ទ នូវសេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ (The Washington Post, ៣ មករា ២០០១)

## ៣ មករា ២០០១

សហរដ្ឋអាមេរិកស្វាគមន៍ចំពោះជំហានរបស់រដ្ឋសភាកម្ពុជា ក្នុងការបង្កើតមធ្យោបាយក្នុងការស៊ើបអង្កេត និងកាត់ទោសមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ចំពោះឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តទៅនៅអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ *(South China Morning Post, ៣ មករា ២០០១)*

## ៩ មករា ២០០១

លោក ហែន កូរ៉ែល ផ្ញើលិខិតមួយច្បាប់ទៅកាន់រាជរដ្ឋាភិបាលកម្ពុជា ដោយបង្ហាញពីការមិនយល់ស្របចំពោះសេចក្តីព្រាងច្បាប់ដែលត្រូវបានអនុម័តហើយនោះ ។ អង្គការសហប្រជាជាតិស្នើសុំឲ្យមានការផ្លាស់ប្តូរទៅលើមាត្រាចំនួន១៨ក្នុងចំណោមមាត្រាទាំងអស់ចំនួន៤៩នៃសេចក្តីព្រាងច្បាប់ ។ លោក ហែន កូរ៉ែល ក៏បានអះអាងដែរថា សេចក្តីព្រាងច្បាប់នេះខ្វះខាតនូវបទបញ្ញត្តិមួយ ក្នុងការធានាឲ្យមានការត្រួតពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយពីសំណាក់អង្គការសហប្រជាជាតិ ដើម្បីធានាឲ្យបានថា ព្រះរាជអាជ្ញាមានអំណាចចោទប្រកាន់ជនសង្ស័យដែលស្ថិតនៅក្រោមការលើកលែងទោស ។

## ៩ មករា ២០០១

ការបកប្រែក្រៅផ្លូវការមួយលើច្បាប់ដែលត្រូវបានអនុម័តដោយរដ្ឋសភាជាតិកាលពីថ្ងៃទី២ ខែមករា ឆ្នាំ២០០១ គឺទទួលបានពីការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅភ្នំពេញ ។ នៅក្នុងសារលិខិតចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០១ លោក ហែន កូរ៉ែល បានលើកឡើងអំពីការព្រួយបារម្ភទាក់ទងនឹងបទបញ្ញត្តិខ្លះៗនៃច្បាប់នេះ ។

## ១៥ មករា ២០០១

ព្រឹទ្ធសភាកម្ពុជាបានអនុម័តជាឯកច្ឆ័ន្ទ នូវសេចក្តីព្រាងច្បាប់ស្តីពីអង្គជំនុំជម្រះនេះ ។ *(The Cambodia Daily, ១៦ មករា ២០០១)*

## ១៩ មករា ២០០១

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា ខៀវ សំផន ដែលជាប្រមុខរដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យកាលពីខែមេសា ឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៩ បានផ្ញើលិខិតមួយច្បាប់ដែលបានសេចក្តីថា លោកស្ម័គ្រចិត្តប្រឈមមុខចំពោះអង្គជំនុំជម្រះប្រសិនបើមានការចាំបាច់ ។ *(រស្មី កម្ពុជា, ២១ មករា ២០០១)*

## ៩ កុម្ភៈ ២០០១

លោក ហែន កូរ៉េល ស្នើសុំឲ្យមានការបកប្រែជាផ្លូវការ នូវច្បាប់ដែលត្រូវបានអនុម័តហើយនោះ ។

## ១២ កុម្ភៈ ២០០១

ក្រុមប្រឹក្សាធម្មនុញ្ញបានអនុម័តទៅលើសេចក្តីព្រាងច្បាប់ ។ លោក យ៉ង់ សែម សមាជិកក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើសេចក្តីសន្និដ្ឋានថា ច្បាប់នេះគឺ "ស្របទៅតាមច្បាប់រដ្ឋធម្មនុញ្ញ" ។ យ៉ាងណាមិញ ក្រុមប្រឹក្សាបានធ្វើការកត់សម្គាល់ពីភាពមិនយល់ស្របគ្នាខាងផ្នែកបច្ចេកទេស ទាក់ទងនឹងវិធានទី៣នៃសេចក្តីព្រាងច្បាប់ដែលស្នើឲ្យមានការកាត់ទោសប្រហារជីវិតធ្វើជាទោសធ្ងន់បំផុត ។ ដោយសារតែទោសប្រហារជីវិតត្រូវបានលុបបំបាត់ចេញពីច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា បច្ចុប្បន្នក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថា នឹងផ្ញើសេចក្តីព្រាងច្បាប់នេះទៅឲ្យរដ្ឋសភាវិញដើម្បីធ្វើវិសោធនកម្ម ។ (www.cambodia.gov.kh/krt/english/chrono.htm)

## ២៣ កុម្ភៈ ២០០១

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថា សេចក្តីព្រាងច្បាប់ត្រូវតែបញ្ជូនទៅដំណាក់កាលព្រាងវិញ ហើយនឹងត្រូវលើកយកមកពិភាក្សាដោយសភាជាតិម្តងទៀត ដោយសារតែមានការមិនយល់ស្របគ្នាខាងផ្នែកបច្ចេកទេសដែលលើកឡើងដោយក្រុមប្រឹក្សាធម្មនុញ្ញ ដោយបញ្ជាក់ពីកំហុសឆ្គងខាងបច្ចេកទេសនៅក្នុងការតាក់តែងច្បាប់ ដែលធ្វើឡើងដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលមានកំណត់ពីការកាត់ទោសប្រហារជីវិត ។ ការពិតដែលថាច្បាប់នេះត្រូវតែឆ្លងកាត់ការពិភាក្សាដេញដោលពីសំណាក់សភាជាតិជាលើកទីពីរនេះ បានធ្វើឲ្យអង្គការសហប្រជាតិមានភាពអស់សង្ឃឹម ។ អ្នកនាំពាក្យរបស់អង្គការសហប្រជាជាតិ លោក ហ្វ្រិដ អេកខាដ (Fred Eckard) បានប្រាប់អ្នកសារព័ត៌មាននៅទីក្រុងញូវយ៉កថា "វាមើលទៅហាក់ដូចជាយើងកំពុងតែត្រូវចាប់ផ្តើមពីកាំជណ្តើរក្រោម ឡើងទៅលើម្តងទៀតអ៊ីចឹង" ។ *(The Cambodia Daily, ២៦ កុម្ភៈ ២០០១)*

## ២៥ មេសា ២០០១

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថា លោកចង់រក្សាទុកអដ្ឋិធាតុរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម ដើម្បីធ្វើជាភ័ស្តុតាងសម្រាប់ការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលបានគ្រោងទុករួចនេះ ដែលក្រោយពីនេះ ជោគវាសនានៃអដ្ឋិធាតុទាំងអស់នេះ នឹងអាចត្រូវបានសម្រេចដោយការធ្វើប្រជាមតិជាសាធារណៈ ។ លោកនាយករដ្ឋមន្ត្រីមានប្រសាសន៍ទៀតថា ច្បាប់នេះនឹងត្រូវយកមកពិភាក្សាដេញដោលជា

លើកទីពីរដោយគណៈរដ្ឋមន្ត្រី នៅមុនខែមិថុនា ហើយបន្ទាប់មកច្បាប់នឹងបញ្ជូននេះទៅកាន់រដ្ឋសភាជាតិ ។ (The Cambodia Daily, ២៦ មេសា ២០០១)

គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានអនុម័តសេចក្តីសម្រេចមួយដែលគាំទ្រថវិការដោយប្រទេសជប៉ុន ដែលបានជំរុញឲ្យរដ្ឋាភិបាលកម្ពុជាបង្កើតតុលាការប្រល័យពូជសាសន៍ឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ។

## ១៨ ឧសភា ២០០១

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បដិសេធចំពោះការចោទប្រកាន់របស់អ្នកសារព័ត៌មានដែលថា ប្រទេសចិន កំពុងតែដាក់សម្ពាធមកលើរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងបញ្ហាសាលាក្តី ។ ផ្ទុយមកវិញ លោកនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា "អ្នកដែលដាក់សម្ពាធមកលើខ្ញុំគឺអគ្គលេខាធិការអង្គការសហប្រជាជាតិលោក កូហ្វី អាណាន់ លោកមន្ត្រីប្រធានផ្នែកច្បាប់របស់អង្គការសហប្រជាជាតិ លោក ហែន កូរ៉ែល និងសមាជិកព្រឹទ្ធសភារបស់អាមេរិកលោក ចន ខេរី ។ (Far Eastern Economics Reivew, ២៤ ឧសភា ២០០១)

## ២១ ឧសភា ២០០១

លោក កូហ្វី អាណាន់ ជម្រុញឲ្យរដ្ឋាភិបាលកម្ពុជាគាក់តែងច្បាប់សម្រាប់សាលាក្តីឲ្យបានលឿន ។ លោក កូហ្វី អាណាន់ បានប្រាប់អ្នកសារព័ត៌មានថា ការិយាល័យរបស់លោកមិនបានទទួលដំណឹងអ្វីសោះពីរដ្ឋាភិបាលកម្ពុជាស្តីពីសាលាក្តីនេះអស់រយៈពេល៦ខែមកហើយ ។

## ១ មិថុនា ២០០១

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន សន្យាថា នឹងឲ្យសច្ចាប័នទៅលើច្បាប់ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិនៃទីក្រុងរ៉ូម ។ ប្រសិនបើទទួលបានការយល់ព្រមពីរដ្ឋសភាប្រទេសកម្ពុជានឹងក្លាយទៅជាប្រទេសដំបូងគេក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ក្នុងការឲ្យសច្ចាប័នទៅលើច្បាប់នេះ ។ លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា "ប្រទេសកម្ពុជានឹងទទួលផលប្រយោជន៍ច្រើនជាងគេ ដោយសារបទពិសោធន៍មិនអាចប្រៀបផ្ទឹមបានស្តីពីអំពើប្រល័យពូជសាសន៍នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ" ។

## ៤ មិថុនា ២០០១

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ ស្នើឲ្យសាកលវិទ្យាល័យធម្មសាត្រប្រគល់កំណត់ហេតុរបស់ នួន ជា ដែលបានសិក្សាផ្នែកច្បាប់នៅសកលវិទ្យាល័យនេះដោយទទួលបានអាហារូបករណ៍នៅទសវត្សរ៍ឆ្នាំ១៩៤០ ហើយបន្ទាប់មក បានធ្វើការឲ្យក្រសួងការបរទេសថៃមួយរយៈ ដោយលោកនិយាយថា

កំណត់ហេតុនេះអាចមានផ្ទុកនូវភ័ស្តុតាងសំខាន់សម្រាប់តុលាការខ្មែរក្រហម ។ (Bangkok Post, ៥ មិថុនា ២០០១)

## ៨ មិថុនា ២០០១

នៅក្នុងលិខិតផ្ញើឲ្យលោក សុខ អាន លោក ហែន កូរ៉ែល ធ្វើការស្នើម្តងទៀតទាក់ទងនឹងភាពចាំបាច់នៃអត្ថបទបកប្រែផ្លូវការ និងភាពត្រូវគ្នានៃអត្ថបទទាំងពីរនេះ (ខ្មែរនិងអង់គ្លេស) ។

## ១២ មិថុនា ២០០១

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជូនដំណឹងដល់ម្ចាស់ជំនួយអន្តរជាតិនៅពេលជួបប្រជុំពិគ្រោះយោបល់រយៈពេលពីរថ្ងៃដែលប្រារព្ធឡើងនៅទីក្រុងតូក្យូថា ប្រទេសកម្ពុជាមានគម្រោងអនុម័តច្បាប់តុលាការនៅពេលឆាប់ៗនេះ ។ លោកនាយករដ្ឋមន្ត្រីបាននិយាយថា លោកមានការគោរពយ៉ាងជ្រាលជ្រៅចំពោះយុត្តិធម៌ដូចនេះតុលាការខ្មែរក្រហមនឹងអាចចាប់ផ្តើមដំណើរការនៅចុងឆ្នាំនេះ ។ (The Cambodia Daily, ១៥ មិថុនា ២០០១)

## ១៧ មិថុនា ២០០១

នួន ជា អតីតប្រធានខាងមនោគមន៍វិជ្ជារបស់ខ្មែរក្រហម និងជាបងធំទីពីរបាននិយាយថា លោកនឹងប្រឈមមុខចំពោះតុលាការ ក៏ដូចជាទទួលយកភាពស្របច្បាប់របស់តុលាការនេះផងដែរ ។ យ៉ាងណាមិញ នួន ជា បានទទូចថា ខ្លួនមិនបានដឹងអ្វីទាំងអស់ទាក់ទងនឹងការសម្លាប់ រហូតទាល់តែក្រោយពេលចុះចូលជាមួយរាជរដ្ឋាភិបាលនៅខែធ្នូ ឆ្នាំ១៩៩៨ ។ (The Cambodia Daily, ១៩ មិថុនា ២០០១)

## ២២ មិថុនា ២០០១

រដ្ឋាភិបាលកម្ពុជាបានធ្វើការកែប្រែសេចក្តីព្រាងច្បាប់របស់តុលាការ ដោយប្តូរការកាត់ទោសប្រហារជីវិតឲ្យទៅជាការជាប់ពន្ធនាគារអស់មួយជីវិតវិញសម្រាប់ទោសធ្ងន់បំផុត ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ថែមទាំងបានបង្ហាញពីសុទិដ្ឋិនិយមរបស់លោកថា តុលាការនឹងអាចដំណើរការបាននៅចុងឆ្នាំនេះ ។ (The Cambodia Daily, ២៣-២៤ មិថុនា ២០០១)

## ២២ មិថុនា ២០០១

តំណាងពិសេសរបស់ស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិ ទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស លោក ភីតឌឺ ឡឺប្រ៊ីត្ស (Peter Leuprecht) ថ្លែងថា អៀង សារី គួរតែត្រូវបានកាត់ទោសចំពោះឧក្រិដ្ឋកម្មដែលបាន

ប្រព្រឹត្តឡើងនៅក្នុងកំឡុងឆ្នាំ១៩៧៥-១៩៧៩ និងថា ការកាត់ទោសតែ តា ម៉ុក និងឌុច នោះមិនគ្រប់គ្រាន់ទេ ។ (The Cambodia Daily, ២៥ មិថុនា ២០០១)

## ២៧ មិថុនា ២០០១

ឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍របស់សារព័ត៌មាននាពេលថ្មីៗ ដែលថាអង្គជំនុំជម្រះអាចចាប់ផ្តើមឡើងនៅឆ្នាំនេះ អង្គការសហប្រជាជាតិបានចេញសេចក្តីប្រកាសព័ត៌មានមួយដែលអះអាងថា អង្គជំនុំជម្រះដែលមិនមានការទទួលជាអន្តរជាតិនឹងមិនអាចចាប់ផ្តើមបានទេ ដរាបណាអនុស្សរណៈនៃការយោគយល់គ្នារវាងអង្គការសហប្រជាជាតិ និងកម្ពុជាមិនទាន់ត្រូវបានចុះហត្ថលេខានិងឲ្យសច្ចាប័ន ។ (Bangkok Post, ៥ សីហា ២០០១)

## ២៨ មិថុនា ២០០១

សម្តេចព្រះ នរោត្តម សីហនុ បានធានាចំពោះលោក ភីតធឺ ឡឺប្រឺត្យ (Peter Leuprecht) ថាព្រះអង្គ នឹងចុះហត្ថលេខាទទួលស្គាល់ច្បាប់ ដើម្បីបង្កើតតុលាការមួយដែលទទួលជំនួយពីអង្គការសហប្រជាជាតិ ដើម្បីនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស ។

## ២៩ មិថុនា ២០០១

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និយាយថា ប្រសិនបើអង្គការសហប្រជាជាតិមិនពេញចិត្តនឹងច្បាប់ថ្មី អង្គការសហប្រជាជាតិអាចដកខ្លួនចេញបាន ។ លោកបន្តទៀតថា “ប្រសិនបើអង្គការសហប្រជាជាតិមិនចូលរួម នោះវាកាន់តែងាយស្រួលដល់ខ្ញុំ ។ ខ្ញុំនឹងអនុវត្តកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ” ។ (The Cambodia Daily, ៣០ មិថុនា-១ កក្កដា ២០០១)

## ៣០ មិថុនា ២០០១

ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បានបញ្ជាក់បន្ថែមទៅលើសម្តីរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលថា ប្រទេសកម្ពុជានឹងមិនខ្វិនលំទោនចំពោះការទាមទាររបស់អង្គការសហប្រជាជាតិទេ ពាក់ព័ន្ធនឹងច្បាប់របស់អង្គជំនុំជម្រះ ។ ព្រះអង្គបានសង្កត់ធ្ងន់ថា “ប្រទេសកម្ពុជានឹងមិនធ្វើការចរចាបន្តទៀតទេ ហើយទោះបីជាអង្គការសហប្រជាជាតិយល់ព្រម ឬមិនយល់ព្រមទទួលស្គាល់ក៏ដោយចំពោះច្បាប់នេះ នោះគឺជាបញ្ហារបស់អង្គការសហប្រជាជាតិ” ។ (Reuters, ៣០ មិថុនា ២០០១)

**៧ កក្កដា ២០០១**

នៅក្នុងលិខិតផ្ញើជូនលោក ហែន កូរ៉ែល លោក សុខ អាន សម្តែងការយល់ដឹងពីទំនាក់ទំនងរវាងច្បាប់និងកិច្ចព្រមព្រៀង ។ ទោះបីជាលោកយល់ស្របនឹងគោលការណ៍ដែលថា ច្បាប់និងកិច្ចព្រមព្រៀងត្រូវ តែមានភាពស្របគ្នាយ៉ាងណាក៏ដោយ ក៏លោកបានជំទាស់ចំពោះ«ការដាក់បន្ទាប់» នេះដដែល ។

**៦ កក្កដា ២០០១**

នៅក្នុងការឆ្លើយតប លោក ហែន កូរ៉ែល បានធ្វើការបញ្ជាក់ម្តងទៀតពីតម្រូវការនៃភាពស្របគ្នារវាងឯកសារទាំងពីរ ។

**១១ កក្កដា ២០០១**

រដ្ឋសភាជាតិបានអនុម័តទៅលើច្បាប់ស្តីពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បន្ទាប់ពីការអនុម័តច្បាប់នេះ លោក សុខ អាន បានប្រាប់អ្នកសារព័ត៌មានថា លោក និងលោក ហែន កូរ៉ែល «នឹងបន្តការចរចារជាមួយគ្នាបន្ថែមទៀតបន្ទាប់ពីច្បាប់នេះចូលជាធរមាន» ។

**១២ កក្កដា ២០០១**

សម្តេចព្រះ នរោត្តម សីហនុ បានប្រកាសថាព្រះអង្គនឹងមិនពាក់ព័ន្ធនៅក្នុងដំណើរការរបស់សាលាក្តីទេ ជាពិសេសទាក់ទងនឹងបញ្ហា«ថាតើគួរតែធ្វើការកាត់ទោស អៀង សារី, នួន ជា, និង ខៀវ សំផន ដែរឬទេ» ។ *(The Cambodia Daily, ១៣ កក្កដា ២០០១)*

**១៣ កក្កដា ២០០១**

ព្រឹទ្ធសភាកម្ពុជាទទួលបានច្បាប់ស្តីពីតុលាការខ្មែរក្រហម ដែលបានកែតម្រូវរួច ។

**១៦ កក្កដា ២០០១**

ការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាមនៅសាកលវិទ្យាល័យអាមេរិក បានចេញផ្សាយសេចក្តីរាយការណ៍មួយដោយលោក ស្ទេហ្វិន ហេដឺ (Stephen Heder) និង ប្រាយអេន ធីតធីម័ន (Brian Tittemore) ដែលធ្វើការបង្ហាញពីការចោទប្រកាន់និងភ័ស្តុតាង ដែលមានជាប់ពាក់ព័ន្ធនឹងលទ្ធភាពក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមចំនួន៧រូបដែលនៅរស់ ។ មេដឹកនាំដែលត្រូវបានយកមកពិចារណានៅក្នុងរបាយការណ៍គឺ នួន ជា, អៀង សារី, ខៀវ សំផន, តា ម៉ុក, កែ ពក, ស៊ូ ម៉េត និង មាស មុត ។

## ១៨ កក្កដា ២០០១

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថា ការចោទប្រកាន់មេដឹកនាំខ្មែរក្រហមគឺជាសេចក្ដីសម្រេចរបស់តុលាការ មិនមែនអ្នកស្រាវជ្រាវជាន់ខ្ពស់នោះទេ ។ លោកនាយករដ្ឋមន្ត្រីបានចាត់ទុកការស្រាវជ្រាវនេះថា ជាការជ្រៀតជ្រែករបស់បរទេសទៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ។ *(The Associated Press, ១៨ កក្កដា ២០០១)*

## ២៣ កក្កដា ២០០១

ព្រឹទ្ធសភាកម្ពុជាបានអនុម័តជាឯកច្ឆន្ទទៅនឹងច្បាប់ថ្មីស្ដីពីតុលាការ ។ បន្ទាប់ពីការបោះឆ្នោតយល់ព្រម លោក សុខ អាន បានប្រាប់អ្នកសារព័ត៌មានថា លោកមានសុទិដ្ឋិនិយមថាប្រទេសកម្ពុជា និងអង្គការសហប្រជាជាតិនឹងអាចឈានទៅដល់ដំណោះស្រាយមួយ ហើយ“កាលបរិច្ឆេទនៃដំណើរការនីតិវិធីរបស់តុលាការគឺអាស្រ័យទៅលើកិច្ចចរចាទាំងនេះ” ។ *(Reuters, ២៤ កក្កដា ២០០១)*

## ៣០ កក្កដា ២០០១

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយនៅក្នុងឱកាសថ្ងៃសុន្ទរកថានៅក្នុងសាលាគរុកោសល្យថា “រដ្ឋាភិបាលមិនទាន់បានចេញបញ្ជាឲ្យចាប់ខ្លួន ខៀវ សំផន, នួន ជា ឬ កែ ពក នៅឡើយទេ” ដោយលោកបានលើកឡើងថា ការចាប់ខ្លួននេះគឺត្រូវតែមានតុល្យភាពជាមួយសន្តិភាព និងការផ្សះផ្សាជាតិ ។ *(AFP, ៣១ កក្កដា ២០០១)*

## ១ សីហា ២០០១

លោក សុខ អាន បានបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជានៅតែសុំឲ្យមានការចូលរួមរបស់អង្គការសហប្រជាជាតិ នៅក្នុងដំណើរការរបស់តុលាការប្រល័យពូជសាសន៍នេះ ។ នៅក្នុងឱកាសថ្ងៃសុន្ទរកថាឯស្រុកកំណើតរបស់លោកនៅខេត្តតាកែវ លោក សុខ អាន មានប្រសាសន៍ថា “យើងត្រូវការភាពជាដៃគូរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ក្នុងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ” ។ *(Deutsche Press-Agentur, ២ សីហា ២០០១)*

## ៧ សីហា ២០០១

ក្រុមប្រឹក្សាធម្មនុញ្ញអនុម័តលើសេចក្ដីព្រាងច្បាប់លើកទីពីរ ស្ដីពីការបង្កើតតុលាការមួយសម្រាប់កាត់ទោសមេដឹកនាំនៃរបបខ្មែរក្រហម ។ (The Cambodia Daily, ៨ សីហា ២០០១)

## ១០ សីហា ២០០១

សម្ដេចព្រះ នរោត្ដម សីហនុ ឡាយព្រហស្ដលេខាលើច្បាប់ "ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់កាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ (The Associated Press, ៨ កក្កដា ២០០១)

## ១៤ សីហា ២០០១

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍នៅក្នុងពិធីសម្ពោធមួយ ដែលមានការចូលរួមពីសំណាក់អតីតមេបញ្ជាការទ័ពខ្មែរក្រហមថា មេដឹកនាំថ្នាក់ខ្ពស់យ៉ាងច្រើន១០នាក់នឹងត្រូវនាំយកមកកាត់ទោសនៅតុលាការដែលបានគ្រោងទុកនេះ ។ ចំណែកកម្មាភិបាលថ្នាក់ទាបនិងកណ្ដាលនឹងមិនស្ថិតនៅក្នុងចំណោមមេដឹកនាំទាំង ១០នាក់ ដែលនឹងត្រូវយកមកកាត់ទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនេះទេ ។ "ដូច្នេះកុំភ័យខ្លាច កុំរត់ចូលព្រៃ ។ តុលាការនេះគឺគ្រាន់តែធ្វើការកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមតែប៉ុណ្ណោះ" ។ (The Voice of Cambodia, ១៤ សីហា ២០០១)

## ១៦ សីហា ២០០១

ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកលោក ខេន វីដឺមេន (Kent Wiedemann) មានប្រសាសន៍ថារដ្ឋាភិបាលកម្ពុជា បានផ្ដល់នូវការសន្យាជាលាយលក្ខណ៍អក្សរយ៉ាងច្បាស់លាស់ថា អៀង សារី អាចត្រូវបាននាំយកមកកាត់ទោសនៅចំពោះមុខតុលាការខ្មែរក្រហម ហើយក៏បាននិយាយទៀតថា ប្រសិនបើ អៀង សារី មិនត្រូវបានយកមកកាត់ទោសទេ សហរដ្ឋអាមេរិកអាចដកជំនួយចេញពីតុលាការនេះបាន ។ (The Cambodia Daily, ១៧ សីហា ២០០១)

## ១៨ សីហា ២០០១

លោក សុខ អាន បានដាក់ជូនអង្គការសហប្រជាជាតិនូវច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលត្រូវបានអនុម័តនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ជាភាសាខ្មែរជាមួយនឹងកំណត់សម្គាល់ថា អត្ថបទបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសនិងភាសាបារាំង កំពុងត្រូវបានពិនិត្យបញ្ចប់ ។

**២០ សីហា ២០០១**

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា ខៀវ សំផន មិនអាចគេចផុតពីការប្រឈមមុខចំពោះការកាត់ក្តីបានទេ ទោះបីជាគាត់បដិសេធថា គាត់មិនជាប់ពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ក៏ដោយ ។ ដកស្រង់ចេញពីច្បាប់ស្តីពីអង្គជំនុំជម្រះរបស់កម្ពុជា ដែលសេចក្តីចម្លងត្រូវបានបញ្ជូនទៅឲ្យអង្គការសហប្រជាជាតិនៅឯទីក្រុងញូវយ៉ក ខៀវ សំផន បានបដិសេធថាគាត់មិនបានបញ្ជាឲ្យមានការសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ *(South China Morning Post, ២១ សីហា ២០០១)*

**៣០ សីហា ២០០១**

អង្គការសហប្រជាជាតិទទួលបានឯកសារបកប្រែជាផ្លូវការ ពីភាសាខ្មែរទៅភាសាអង់គ្លេស និងបារាំង ដោយអមជាមួយនឹងលិខិតរបស់លោក សុខ អាន ផ្ញើជូនលោក ហែន កូរ៉ែល ។

**៣០ សីហា ២០០១**

សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិកពីររូបផ្តល់យោបល់ថា អង្គការសហប្រជាជាតិមិនគួរចូលរួមក្នុងការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមទេ ប្រសិនបើរដ្ឋាភិបាលកម្ពុជាមិនអនុញ្ញាតឲ្យមានការការពារសន្តិសុខដើម្បីធានាឲ្យមានបទដ្ឋានផ្នែកច្បាប់កំរិតខ្ពស់ ។ *(The Cambodia Daily, ៨-៩ កញ្ញា ២០០១)*

**៣១ សីហា ២០០១**

កងទ័ពកម្ពុជានិយាយថា ខ្លួនបានដករថក្រោះនិងកាំភ្លើងធំចេញពីអតីតទីបញ្ជាការខ្មែរក្រហមហើយ ប៉ុន្តែបានបដិសេធថា ការផ្លាស់ទីនេះគឺមិនមែនដើម្បីចៀសវាងអំពើហឹង្សាដែលអាចកើតឡើង មុនពេលតុលាការប្រល័យពូជសាសន៍កើតមានឡើងនោះទេ ។

**១៣ កញ្ញា ២០០១**

កែ ពក ដែលជាអតីតមេបញ្ជាការរងកងទ័ពខ្មែរក្រហម បានបដិសេធថាខ្លួនមិនមានជាប់ពាក់ព័ន្ធនឹងអំពើឃោរឃៅដែលបានសម្លាប់ប្រជាជនកម្ពុជាជាង១លាននាក់នោះទេ ដោយនិយាយថា គាត់គ្រាន់តែជាសមាជិកថ្នាក់តូចម្នាក់ ហើយឈរជើងនៅផ្នែកដ៏តូចមួយនៃប្រទេសតែប៉ុណ្ណោះ ។ គាត់ថែមទាំងបដិសេធនឹងពាក្យចចាមអារ៉ាម ដែលថាគាត់កំពុងតែស្នើសុំទិដ្ឋាការដើម្បីធ្វើដំណើរទៅប្រទេសចិន ។ *(The Cambodia Daily, ១៣ កញ្ញា ២០០១)*

## ៧ តុលា ២០០១

លោក សុខ អាន ផ្ញើលិខិតទៅលោក ហែន កូរ៉ែល អញ្ជើញលោកឲ្យមកប្រទេសកម្ពុជា ដើម្បីសម្រេចបញ្ចប់លើមាត្រាទាំងឡាយស្តីពីកិច្ចសហប្រតិបត្តិការ ។

## ៨ តុលា ២០០១

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានជំរាបជូនលោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ខេន វីដឺមេន ថាសម្តេច«ពិតជាអន្ទះសារចង់ចូលរួមក្នុងអង្គជំនុំជម្រះ» ដោយប្រើប្រាស់ច្បាប់ដែលមានការយល់ព្រមពីរដ្ឋាភិបាលកម្ពុជានិងឡាយព្រហស្តលេខាដោយសម្តេចព្រះ នរោត្តម សីហនុ កាលពីខែសីហា ។ រដ្ឋាភិបាលកម្ពុជាបានផ្ញើលិខិតអញ្ជើញទៅឲ្យអង្គការសហប្រជាជាតិដើម្បីបន្តកិច្ចពិភាក្សាស្តីពីការកាត់ទោស និងបញ្ចប់ដំណើរការបង្កើតអង្គជំនុំជម្រះនេះ ។ *(The Cambodia Daily, ១០ តុលា ២០០១)*

## ១០ តុលា ២០០១

នៅក្នុងលិខិតចុះថ្ងៃទី១០ខែតុលា ផ្ញើជូនលោក សុខ អាន លោក ហែន កូរ៉ែល ថ្លែងថា អង្គការសហប្រជាជាតិនៅតែមានការព្រួយបារម្ភចំពោះបញ្ហាមួយចំនួន ។ បញ្ហាចម្បងបំផុតគឺថា តើឯកសារមួយណា (ច្បាប់ ឬកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ) ដែលនឹងគ្រប់គ្រងការអនុវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងករណីដែលមានការមិនយល់ស្របគ្នារវាងឯកសារទាំងពីរនេះ ។ *(សេចក្តីសង្ខេបថ្លែងដោយលោក ហែន កូរ៉ែល, ៨ កុម្ភៈ ២០០២)*

## ១៥ តុលា ២០០១

ចក្រភពអង់គ្លេសផ្តល់ជំនួយ៥សែនដុល្លារទៅឲ្យអង្គការសហប្រជាជាតិ ដើម្បីជួយជាមូលនិធិដល់អង្គជំនុំជម្រះសេចក្តីរបស់មេដឹកនាំខ្មែរក្រហមនៅប្រទេសកម្ពុជា ។ អង់គ្លេស គឺជាប្រទេសដំបូងគេដែលផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុជាផ្លូវការដល់តុលាការដែលបានស្នើឡើងនេះ ។ ឯកអគ្គរាជទូតអង់គ្លេស លោក ស្ទីហ្វិន ប្រ៊ីត្យ (Stephen Bridges) បានថ្លែងថា «ថ្មីៗនេះ រដ្ឋាភិបាលអង់គ្លេសបានផ្តល់ប្រាក់ជំនួយ ៥សែនដុល្លារ ទៅឲ្យអង្គការសហប្រជាជាតិនៅឯទីក្រុងញូវយ៉ក ដើម្បីជាជំនួយដល់ដំណើរកាត់ទោសខ្មែរក្រហមនៅកម្ពុជា» ។ *(មូលនិធិអង្គការសហប្រជាជាតិ, UN Wire, ១៥ តុលា ២០០១)*

### ២ វិច្ឆិកា ២០០១

ប្រទេសជប៉ុនមានគម្រោងជ្រើសតាំង លោក គូនីជី ស៊ីបាហារ៉ា (Kuniji Shibahara) ដែលជាសាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យហ្គាគឹសីអ៊ីន (Gakushuim University) ធ្វើជាចៅក្រមនៅអង្គជំនុំជម្រះ ។ *(The Japanese Times Online, ៣ វិច្ឆិកា ២០០១)*

### ២៣ វិច្ឆិកា ២០០១

នៅក្នុងសារលិខិតផ្ញើជូនលោក ហែន កូរ៉ែល លោក សុខ អាន ថ្លែងថា «បើទោះបីជាមាត្រានៃកិច្ចសហប្រតិបត្តិការ អាចបញ្ជាក់ឲ្យបានច្បាស់លាស់ទាក់ទងនូវភាពស្រពេចស្រពិលនៅក្នុងច្បាប់ និងធ្វើការបរិយាយពីសេចក្តីលម្អិតក៏ដោយ ក៏មាត្រានេះមិនអាចគ្រប់ដណ្តប់ទៅលើច្បាប់ដែលទើបតែត្រូវបានប្រកាសឲ្យប្រើជាផ្លូវការបានទេ» ។

លោក សុខ អាន ទទួលស្គាល់លិខិតនេះ ហើយធ្វើការពិនិត្យឡើងវិញនូវសេចក្តីព្រាងនៃកិច្ចព្រមព្រៀងដោយថ្លែងថា ការឆ្លើយតបរបស់លោកនៅតែមិនទាន់ពេញលេញនៅឡើយទេ ។ លោកបានជំទាស់ចំពោះភាពដែលកិច្ចព្រមព្រៀងមានវិសាលភាពជាងច្បាប់ ។

### ២៥ វិច្ឆិកា ២០០១

ការចរចាររវាងកម្ពុជានិងអង្គការសហប្រជាជាតិស្តីពីការបង្កើតអង្គជំនុំជម្រះ ត្រូវបានអាក់ខានដោយសារបញ្ហាថា តើភាសាណាមួយដែលនឹងត្រូវប្រើប្រាស់ជាផ្លូវការនៅក្នុងសវនាការអង្គជំនុំជំម្រះ ។ *(Cambodia Today, ភ្នំពេញ, ២៦ វិច្ឆិកា ២០០១)*

### ១៤ ធ្នូ ២០០១

រាជរដ្ឋាភិបាលកម្ពុជាចេញផ្សាយសារាចរ ស្តីពីការរៀបចំអដ្ឋិធាតុរបស់ជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៨) និងការរៀបចំស្រុកអន្លង់វែងឲ្យក្លាយទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ ។

### ១៨ ធ្នូ ២០០១

នៅក្នុងសារលិខិតផ្ញើឲ្យលោក សុខ អាន លោក ហែន កូវ៉ែល បានលើកឡើងថា ការឆ្លើយតបដ៏ពេញលេញមួយនឹងត្រូវបានបញ្ជូនមកឲ្យកម្ពុជា នៅពេលកម្ពុជាបញ្ចប់ការពិនិត្យឡើងវិញនូវអនុសាសន៍ទាំងឡាយរបស់អង្គការសហប្រជាជាតិ ។

## ១៩ ធ្នូ ២០០១

របាយការណ៍សន្និសីទរបស់សហរដ្ឋអាមេរិច ស្តីពី H.R.2506 កិច្ចប្រតិបត្តិការបរទេស ការនាំចេញហិរញ្ញវត្ថុ និងច្បាប់ស្តីពីកម្មវិធីសមស្របដែលពាក់ព័ន្ធឆ្នាំ២០០២ (ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១) “លក្ខខណ្ឌជំនួយចំពោះតុលាការខ្មែរក្រហម ដែលត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលកម្ពុជាស្តីពីការសម្រេចចិត្ត និងការអះអាងចំពោះសមាជថា តុលាការមានលទ្ធភាពក្នុងការផ្តល់យុត្តិធម៌ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងលក្ខណៈឥតលំអៀង និងអាចជឿទុកចិត្តបាន” ។

សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ UNGAA/RES/56/169

**ជំពូក៤ ៖ តុលាការខ្មែរក្រហម**

**កថាខណ្ឌទី២** ៖ សូមស្វាគមន៍ចំពោះការប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានកើតឡើងនៅកំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយកត់សម្គាល់ជាមួយនឹងសេចក្តីកោតសរសើរ បទបញ្ញត្តិទូទៅ សមត្ថកិច្ចនៃច្បាប់ និងបទបញ្ញត្តិស្តីពីតួនាទីមួយ សម្រាប់អង្គការសហប្រជាជាតិធ្វើឲ្យរដ្ឋាភិបាលកម្ពុជាធានាឲ្យបានថា មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនិងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌និងទំនៀមទម្លាប់អន្តរជាតិ ព្រមទាំងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយកម្ពុជា នឹងត្រូវបាននាំយកមកកាត់ទោសឲ្យស្របទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពមិនលម្អៀង និងដំណើរការនីតិវិធីស្របច្បាប់ ។ សូមជំរុញឲ្យរដ្ឋាភិបាលបន្តសហការជាមួយអង្គការសហប្រជាជាតិទៅលើបញ្ហានេះ ។ ស្វាគមន៍ចំពោះកិច្ចខំប្រឹងប្រែងរបស់លេខាធិការដ្ឋាននិងសហគមន៍អន្តរជាតិ ក្នុងការជួយឲ្យរដ្ឋាភិបាលកម្ពុជាអាចឆ្ពោះទៅកាន់ទីបញ្ចប់នេះបាន ដែលជំរុញឲ្យរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិសម្រេចលើកិច្ចព្រមព្រៀងដោយមិនមានការពន្យារពេល ។

សូមបានធ្វើឲ្យអង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្តើម បំពេញតួនាទីរបស់ខ្លួនបានយ៉ាងឆាប់រហ័ស ។ ជាពិសេសសូមអំពាវនាវទៅកាន់សហគមន៍អន្តរជាតិឲ្យផ្តល់ជំនួយទាក់ទងនឹងបញ្ហានេះ រួមមានទាំងជំនួយហិរញ្ញវត្ថុ និងការឧបត្ថម្ភជាបុគ្គលិកទៅអង្គជំនុំជម្រះ ។ (*www.cambodia.gov.kh/krt/english/chrono.htm*)

## ២១ មករា ២០០២

រដ្ឋមន្ត្រីក្រសួងការបរទេសលោក ហោ ណាំហុង បង្ហាញពីគំនិតទុទិដ្ឋិនិយមទៅលើអង្គជំនុំជម្រះដោយលើកហេតុផលថា «យោងទៅតាមការិយាធិបតេយ្យរបស់អង្គការសហប្រជាជាតិ គឺវាគ្មានសង្ឃឹមនោះទេដែលថា ការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងអាចដំណើរការទៅបានក្នុងពេលឆាប់ៗនេះ ពីព្រោះមេដឹកនាំខ្មែរក្រហមប្រហែលជាស្លាប់មុនពេលដែលអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលមានការព្រមព្រៀងគ្នា ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។ *(រស្មីកម្ពុជា, ២៥ មករា ២០០២)*

## ២២ មករា ២០០២

លោក សុខ អាន ផ្ញើសារទូរលេខចំនួនបីទំព័រទៅឲ្យអង្គការសហប្រជាជាតិ «ដើម្បីលុបបំបាត់មន្ទិលសង្ស័យ ហើយធ្វើការបង្ហាញយ៉ាងច្បាស់លាស់» អំពីជំហររបស់រដ្ឋាភិបាលចំពោះការបង្កើតតុលាការនេះ ។ *(The Cambodia Daily, ២៣ មករា ២០០២)*

## ៨ កុម្ភៈ ២០០២

អគ្គលេខាធិការអង្គការសហប្រជាជាតិ ធ្វើការណែនាំដល់ទីប្រឹក្សាច្បាប់របស់គឺលោក ហែន កូរ៉ែល ដើម្បីបញ្ជូនលិខិតមួយច្បាប់ទៅកាន់រាជរដ្ឋាភិបាលកម្ពុជា ដោយថ្លែងឲ្យដឹងថាអង្គការសហប្រជាជាតិនឹងមិនបន្តធ្វើការចរចារជាមួយរាជរដ្ឋាភិបាលស្តីពីការបង្កើតតុលាការពិសេស ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមទេ ។ នៅក្នុងការថ្លែងទៅកាន់សារព័ត៌មានប្រចាំថ្ងៃ លោក ហែន កូរ៉ែល ថ្លែងថា «តាមការណែនាំរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិនឹងមិនបន្តធ្វើការចរចារជាមួយរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីពីបទឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ» ។ *(The Cambodia Daily, ៨ កុម្ភៈ ២០០២)*

## ១០ កុម្ភៈ ២០០២

លោក សុខ អាន មានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាមានការសោកស្តាយចំពោះការសម្រេចចិត្តរបស់អង្គការសហប្រជាជាតិ ដែលបានប្រកាសកាលពីថ្ងៃទី៨ ខែកុម្ភៈ ។ «រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តបើកទ្វារធ្វើការពិភាក្សាបន្តទៅទៀត ។ យើងមិនបានបិទទ្វារដូចលោក ហែន កូរ៉ែល ទេ» ។ *(The Cambodia Daily, ១០ កុម្ភៈ ២០០២)*

## ១១ កុម្ភៈ ២០០២

សេចក្តីប្រកាសព័ត៌មានអង្គការលើកលែងទោសអន្តរជាតិថ្លែងថា «សេចក្តីប្រកាសដែលថាអង្គការសហប្រជាជាតិកំពុងតែដកពីកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយរដ្ឋាភិបាលកម្ពុជា ក្នុងការនាំយកជនដែលដាប់

សន្និយ ដែលរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សនៅក្នុងសម័យខ្មែរក្រហមយកមកកាត់ទោសនោះ គឺមិនមែនជាការភ្ញាក់ផ្អើលអ្វីទេ ។ លទ្ធផលការស្ទង់មតិជាក់ស្ដែងនៅឆ្នាំនេះ គឺថាប្រជាជនកម្ពុជានៅតែមិនទាន់អាចខិតចូលទៅជិតការទទួលបានយុត្តិធម៌នៅឡើយទេ ដែលនេះហើយគឺជាសោកនាដកម្មដ៏ពិតប្រាកដនោះ» ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពាវនាវដល់អង្គការសហប្រជាជាតិឲ្យធ្វើការពិចារណាម្ដងទៀតចំពោះការដកខ្លួនចេញពីកិច្ចពិភាក្សា ស្ដីពីការនាំយកអតីតមេដឹកនាំខ្មែរក្រហមទៅកាត់ទោស ដែលអាចជម្រុញឲ្យពិភពលោកមិន«ដើរដូវខុសម្ដងទៀត»តាមអតីតអ្នកដឹកនាំប្រទេសមុនៗ ។ លោកនាយករដ្ឋមន្ត្រីបានប្រាប់អ្នកសារព័ត៌មានថា ប្រទេសកម្ពុជាអាចរង់ចាំរយៈពេល«ពីរឬបីខែ»ទៀត ដើម្បីឲ្យអង្គការសហប្រជាជាតិផ្លាស់ប្ដូរការសម្រេចចិត្ត ប៉ុន្តែលោកក៏បានបន្តទៀតថា រដ្ឋាភិបាលរបស់លោកនឹងមិនរង់ចាំជារៀងរហូតទេ ។ *(CNN.com/WORD, ១១ កុម្ភៈ ២០០២)*

## ១២ កុម្ភៈ ២០០២

លោក សុខ អាន មានប្រសាសន៍នៅក្នុងសេចក្ដីថ្លែងការណ៍ឆ្លើយតបនឹងការប្រកាសដកខ្លួនរបស់អង្គការសហប្រជាជាតិចេញពីកិច្ចចរចាស្ដីពីអង្គជំនុំជម្រះថា «រាជរដ្ឋាភិបាលកម្ពុជានៅតែប្ដេជ្ញាចិត្តស្វែងរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ជូនមុខឲ្យប្រជាជនកម្ពុជា និងមនុស្សជាតិទាំងអស់ ។ យើង ជឿថា ច្បាប់ដែលត្រូវបានប្រកាសឲ្យប្រើកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ បានផ្ដល់នូវមូលដ្ឋាននៃដំណើរការនីតិវិធីនៅក្នុងតុលាការកម្ពុជា ដោយមានការចូលរួមពីអន្តរជាតិ និងបំពេញទៅតាមបទដ្ឋានទទួលស្គាល់ដោយអន្តរជាតិ ហើយយើងពិតជាសង្ឃឹមយ៉ាងមុតមាំថា អង្គការសហប្រជាជាតិនឹងក្លាយជាអ្នកចូលរួមចំណែកមួយនៃដំណើរការនេះ» ។

សហរដ្ឋអាមេរិកជំរុញឲ្យអង្គការសហប្រជាជាតិ កុំឲ្យបោះបង់ចោលកិច្ចខិតខំប្រឹងប្រែងក្នុងការចូលរួមក្នុងអង្គជំនុំជម្រះនេះ ។ *(Wire-News from AP, ១២ កុម្ភៈ ២០០២)*

លោក សុខ អាន ផ្ញើសារលិខិតមួយជូនលោក ហែន កូរ៉ែល ដោយបង្ហាញពីភាពសោកស្ដាយចំពោះសេចក្ដីប្រកាសដកខ្លួនចេញពីការចរចារបស់អង្គការសហប្រជាជាតិ ហើយសង្ឃឹមយ៉ាងមុតមាំថា អង្គការសហប្រជាជាតិនឹងវាកមកធ្វើការបញ្ចប់កិច្ចព្រមព្រៀងនៃកិច្ចសហប្រតិបត្តិការ និងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ *(Phnom Penh Post, ១៥-២៨ កុម្ភៈ ២០០២)*

## ១៤ កុម្ភៈ ២០០២

មេធាវីស្នើសុំឲ្យដោះលែង តា ម៉ុក បន្ទាប់ពីអង្គការសហប្រជាជាតិដកខ្លួនចេញពីដំណើរការកាត់សេចក្ដីខ្មែរក្រហម ។ តាម៉ុក អាយុ៧៥ឆ្នាំ ត្រូវបានឃុំខ្លួននៅឆ្នាំ១៩៩៩ នៅក្រុងភ្នំពេញ ដើម្បីរង់ចាំការកាត់ទោស

ចំពោះតួនាទីរបស់គាត់នៅក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ ។ តាមច្បាប់កម្ពុជា តា ម៉ុក ត្រូវតែទទួលការចោទប្រកាន់ជាផ្លូវការ ឬក៏ត្រូវបានដោះលែងវិញនៅថ្ងៃទី៦ ខែមីនា ។ (Reuters, ១៥ កុម្ភៈ ២០០២)

## ១៥ កុម្ភៈ ២០០២

មេបញ្ជាការកងពលខ្មែរក្រហម កែ ពក អាយុ៦៨ឆ្នាំ ស្លាប់ដោយសារតែជំងឺ លើសឈាម និងទឹកនោមផ្អែម ។ គាត់បានធ្វើដំណើរទៅប្រទេសថៃនៅខែមករា ដើម្បីធ្វើការព្យាបាល ក្រោយមកគាត់ក៏ដាច់សរសៃឈាម ហើយត្រូវបានបញ្ជូនមកស្រុកអន្លង់វែងភាគខាងជើងប្រទេសកម្ពុជា ជាកន្លែងដែលគាត់ស្លាប់ ។ (Reuters, ១៦ កុម្ភៈ ២០០២)

## ២០ កុម្ភៈ ២០០២

សហគមន៍អឺរ៉ុបជំរុញឲ្យអង្គការសហប្រជាជាតិកុំបោះបង់ការចរចាជាមួយកម្ពុជា ស្តីពីការបង្កើតតុលាការកាត់ទោសខ្មែរក្រហម ។ (Reuters, ១៦ កុម្ភៈ ២០០២)

សមាជិកសភា១៨រូបមកពីគណបក្ស សម រង្ស៊ី ស្នើឲ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់២រូបទៀត បង្ហាញខ្លួននៅរដ្ឋសភាជាតិដើម្បីពន្យល់ពីមូលហេតុនៃការបរាជ័យក្នុងការចរចាជាមួយអង្គការសហប្រជាជាតិស្តីពីតុលាការកាត់ទោសខ្មែរក្រហម ។ (The Cambodia Daily, ២២ កុម្ភៈ ២០០២)

## ២៦ មេសា ២០០២

សេចក្តីប្រកាសរបស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិលេខ E/CN.4/2002/89

**កថាខណ្ឌទី១៨** : អំពាវនាវទៅដល់រដ្ឋាភិបាលកម្ពុជាដើម្បីធានាឲ្យបានថាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌ និងទំនៀមទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិ ដែលទទួលស្គាល់ដោយប្រទេសកម្ពុជា ទៅកាត់ទោសដោយស្របទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងស្របទៅតាមនីតិវិធីច្បាប់ ។ កិច្ចការនេះតម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិសហការគ្នា ហើយអំពាវនាវដល់ភាគីទាំងពីរដើម្បីបន្តកិច្ចពិភាក្សា ស្តីពីការបង្កើតតុលាការកាត់ទោសខ្មែរក្រហម និងអំពាវនាវដល់សហគមន៍អន្តរជាតិឲ្យជួយផ្តល់ជាជំនួយទាក់ទងនឹងបញ្ហានេះ ។

(www.cambodia.gov.kh/krt/english/chrono.htm)

## ១៣ មីនា ២០០២

លោក កូហ្វី អាណាន់ និយាយថា ប្រទេសកម្ពុជាត្រូវតែផ្លាស់ប្តូរជំហររបស់ខ្លួន ប្រសិនបើចង់ឲ្យអង្គការសហប្រជាជាតិជួយបង្កើតតុលាការខ្មែរក្រហមក្រោមស្តង់ដារអន្តរជាតិ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ "ឯកអគ្គរដ្ឋទូតចំនួន ១២រូបបានមកជួបខ្ញុំនិយាយពីរឿងនេះ ហើយអ្នកទាំងនោះយល់ថាយើងគួរតែពិចារណាឡើងវិញ ។ ខ្ញុំបានណែនាំគេថា វាអាចមានប្រសិទ្ធភាពជាងនេះ ប្រសិនបើអ្នកការទូតទាំងនេះធ្វើសំណើរទៅរដ្ឋាភិបាលទីក្រុងភ្នំពេញ ហើយបញ្ចុះបញ្ចូលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឲ្យធ្វើការផ្លាស់ប្តូរជំហរ និងឥរិយាបថរបស់លោក ហើយសូមឲ្យលោកនាយករដ្ឋមន្ត្រីផ្ញើសារជាក់លាក់មួយទៅកាន់អង្គទូតទាំងនោះថាលោកចាប់អារម្មណ៍ទៅលើតុលាការមួយដែលគួរឲ្យទុកចិត្ត និងដែលស្របទៅតាមបទដ្ឋានអន្តរជាតិ ត្រង់នេះហើយដែលលោកអគ្គរដ្ឋទូតទាំងនោះត្រូវចាប់ផ្តើមធ្វើ ។ *(អង្គការសហប្រជាជាតិ, SG/SM/8160, ១៣ មិនា ២០០២, អត្ថបទចម្លងសន្និសិទកាសែត ដោយលោក កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅឯទីស្នាក់ការអង្គការសហប្រជាជាតិ)*

## ១៥ មីនា ២០០២

ក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីបញ្ហាសាលាក្តីខ្មែរក្រហមបានថ្លែងថា សេចក្តីថ្លែងការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ ឆ្លុះបញ្ចាំងពីការយល់ច្រឡំលើជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ។ ច្បាប់ស្តីពីការកាត់ទោសខ្មែរក្រហមដែលជាលទ្ធផលនៃការចរចាទាំងនោះ ផ្តល់នូវការត្រួតពិនិត្យ និងតុល្យភាពរវាងចំនួនសមាជិកនិងអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់ចៅក្រមកម្ពុជា និងបរទេស ចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញា ហើយផ្តល់ការធានាសិទ្ធិស្របច្បាប់ជូនដល់ចុងចោទ ។ កម្ពុជាបានបង្ហាញបំណងរបស់ខ្លួនដើម្បីពន្យល់ពីសិទ្ធិទាំងនេះឲ្យកាន់តែលម្អិតថែមទៀត នៅក្នុងមាត្រានៃកិច្ចសហប្រតិបត្តិការ ។ អង្គការសហប្រជាជាតិមិនបានគូសបង្ហាញពីការរំលោភបំពានដល់បទដ្ឋានដែលទទួលស្គាល់ជាអន្តរជាតិណាមួយនោះទេ នៅក្នុងច្បាប់ស្តីពីការកាត់ទោសខ្មែរក្រហមរបស់កម្ពុជា ហើយក៏មិនបានឆ្លើយតបទៅនឹងលិខិតរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលធ្វើនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០២ ដែលលិខិតនេះបានផ្តល់ការឆ្លើយតបលម្អិតទៅលើការលើកឡើងចំនួន១១ចំណុចរបស់លោក ហែន កូរ៉ែល ។ *(សេចក្តីថ្លែងការរបស់ក្រុមការងារសាលាក្តីខ្មែរក្រហមនៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពីបញ្ហាសាលាក្តីខ្មែរក្រហម, ភ្នំពេញ ១៥ មិនា ២០០២)*

## ២០ មីនា ២០០២

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា អង្គការសហប្រជាជាតិមានពេល៣ខែ ដើម្បីចូលរួមកិច្ចពិភាក្សាឡើងវិញជាមួយកម្ពុជា ក្នុងការបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់ ។ លោកបានបញ្ជាក់ថា ប្រសិនបើកិច្ចពិភាក្សានោះមិនលេចចេញជារូបរាងតាមពេលកំណត់ទេ កម្ពុជានឹងពិចារណានូវជម្រើសដទៃទៀត ដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះចំនួន ១លាន ៧សែននាក់ ដែលបានស្លាប់ក្រោមអំពើដ៏សាហាវឃោរឃៅនៃរបបលទ្ធិម៉ៅជ្រុលហួសហេតុ ហើយជម្រើសនោះអាចជាសាលាក្តីដែលជួយគាំទ្រដោយបរទេស ឬសាលាក្តីខ្មែរទាំងស្រុង ។ "ខ្ញុំចង់ប្រកាសម្តងទៀតថា ទ្វារនៅតែបើកចំហសម្រាប់រយៈពេល៣ខែទៀត ។ ភាពអត់ធ្មត់របស់យើងមានដែនកំណត់ ។ យើងមិនចង់ឲ្យនរណាម្នាក់ដើរចេញនោះទេ យើងចង់ឲ្យគេចូលរួម ។ *(Cambodia Today, ២០ មិនា ២០០២)*

## ៩ មេសា ២០០២

រដ្ឋាភិបាលទីក្រុងញូវដែលី សន្យាគាំទ្រសម្រាប់ការបន្តឲ្យមាននូវសាលាក្តីចម្រុះខ្មែរក្រហម ប្រសិនបើអង្គការសហប្រជាជាតិដកខ្លួនចេញជាអចិន្ត្រៃយ៍ ។ ក្នុងពេលធ្វើដំណើរបំពេញទស្សនកិច្ចនៅកម្ពុជា នាយករដ្ឋមន្ត្រីឥណ្ឌា អាតាល់ ប៊ីហារី វ៉ាជ៉ាយី (Atal Bihari Vajpayee) បានសន្យាថា ប្រទេសឥណ្ឌា នឹងបញ្ជូនចៅក្រមម្នាក់សម្រាប់ការកាត់ទោសនេះ ប្រសិនបើអង្គការសហប្រជាជាតិនៅតែរក្សាការសម្រេចចិត្តដកខ្លួនចេញ ។ *(The Cambodia Daily, ១០ មេសា ២០០២)*

## ២ កក្កដា ២០០២

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បង្ហាញពីឆន្ទៈក្នុងការសម្រុះសម្រួល ដើម្បីចាប់ផ្តើមការចរចាដែលជាប់គាំងនោះឡើងវិញ ។ លោកបានផ្តល់ឲ្យមានការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសាលាក្តី ។ *(The Cambodia Daily, ៤ កក្កដា ២០០២)*

## ៣ កក្កដា ២០០២

បេសកជនផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ភិទើ ឡឺប្រិច (Peter Leuprecht) បង្ហាញពីក្តីសង្ឃឹមថា សាលាក្តីដែលអាក់ខាននោះនឹងមានដំណើរការទៅមុខ ហើយនិយាយថា ប្រទេសជាមិត្តមួយចំនួនបន្តព្យាយាមជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ចូលរួមជាមួយគ្នាដើម្បីពិភាក្សាបន្តពីសាលាក្តីចម្រុះនេះ ។ *(The Cambodia Daily, ៤ មេសា ២០០២)*

អង្គការសហប្រជាជាតិបដិសេធការស្នើសុំរបស់កម្ពុជាក្នុងការពិនិត្យឡើងវិញនូវគម្រោងដែលជាប់គាំងសម្រាប់ការបង្កើតសាលាក្តីនោះ ដោយនិយាយថា អង្គការសហប្រជាជាតិត្រូវការការធានាបន្ថែមថា កម្ពុជា

នឹងរៀបចំឲ្យមានតុលាការកាត់ទោសមេដឹកនាំ«វាលពិឃាត»ប្រកបដោយយុត្តិធម៌ ។ (Reuters, ៤ កក្កដា ២០០៧)

### ១២ កក្កដា ២០០៧

សារលិខិតមួយច្បាប់ពីលោក កូហ្វី អាណាន់ ផ្ញើរជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានខ្លឹមសារថា «ការសម្រេចចិត្តបញ្ចប់ការចរចានៅថ្ងៃទី៨ ខែកុម្ភៈ គឺធ្វើឡើងដោយផ្អែកលើមូលហេតុដែលថា ការិយាល័យដែលខ្ញុំបានផ្ដល់ជូនមិនទាន់ចេញជាលទ្ធផលនៅឡើយ» ដូច្នេះ«ដើម្បីឲ្យខ្ញុំចូលរួមបន្តការចរចារនេះបន្តទៀត ខ្ញុំត្រូវការអាណត្តិមួយឲ្យច្បាស់លាស់ពីមហាសន្និបាត ឬក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ ប្រសិនអាណត្តិនោះត្រូវបានផ្ដល់ឲ្យ ខ្ញុំនឹងរៀបចំខ្លួនចូលរួមបន្តការពិភាក្សាជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីបំពេញកិច្ចការនេះ» ។ (www.cambodia.gov.kh/krt/english/chrono.htm)

### ១៨ តុលា ២០០៧

សារលិខិតមួយច្បាប់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជូនលោក កូហ្វី អាណាន់ ថ្លែងថា «យើងទន្ទឹងរង់ចាំសេចក្ដីសន្និដ្ឋានបញ្ចប់ដ៏បន្ទាន់មួយនៃកិច្ចការជាបឋម ប្រសិនបើលោកគិតថា វាចាំបាច់សម្រាប់អង្គការសហប្រជាជាតិដើម្បីវិលត្រឡប់ទៅចូលរួមតុពិភាក្សា ដើម្បីឲ្យយើងទាំងអស់គ្នា អាចសន្និដ្ឋានបញ្ចប់ការចរចារជាមួយនឹងកិច្ចព្រមព្រៀងដែលភាគីទាំងពីរពេញចិត្ត ហើយបន្តឆ្ពោះទៅរកការបង្កើតអង្គជំនុំជម្រះវិសាមញ្ញមួយដ៏ពិតប្រាកដ» ។ (www.cambodia.gov.kh/krt/english/chrono.htm)

### ២០ សីហា ២០០៧

លោក កូហ្វី អាណាន់ បានប្រាប់កម្ពុជាថា លោកនឹងបន្តកិច្ចពិភាក្សាឡើងវិញស្ដីពីការកាត់ទោសអំពើប្រល័យពូជសាសន៍ ប្រសិនបើរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិចង់ឲ្យលោកធ្វើបែបនោះ ។ លោកបានសរសេរលិខិតមួយច្បាប់ទៅកាន់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយនិយាយថា ដើម្បីឲ្យលោកបន្តចូលរួមក្នុងការចរចារនោះ លោកត្រូវការអាណត្តិមួយយ៉ាងច្បាស់លាស់ពីមហាសន្និបាត ឬក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ (Reuters, ២១ សីហា ២០០៧)

### ២៧ សីហា ២០០៧

«កិច្ចប្រជុំនៅទីក្រុងញូវយ៉ក ដែលរៀបចំដោយប្រទេសជប៉ុន ប្រារព្ធធ្វើនៅទីស្នាក់ការគណៈកម្មាធិការជប៉ុន ដោយមានការចូលរួមពីប្រទេសដែលមានការចាប់អារម្មណ៍ រួមមាន បារាំង ចក្រភពអង់គ្លេស កាណាដា អូស្ត្រាលី សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប កូរ៉េខាងត្បូង ជប៉ុន និងប្រទេសជាសមាជិកអាស៊ាន (ហ្វីលីពីន

សិង្ហបុរី ថៃឡង់ដ៍ ឥណ្ឌូនេស៊ី និងកម្ពុជា) ។ នេះជាការប្រជុំដំបូងដើម្បីធ្វើការផ្លាស់ប្តូរយោបល់អំពីអ្វីដែលសហគមន៍អន្តរជាតិអាចធ្វើទៅបាន ដើម្បីស្តារឲ្យមានការចរចារឡើងវិញ ។
(*www.cambodia.gov.kh/krt/english/chrono.htm*)

## ២១ ធ្នូ ២០០២

មហាសន្និបាតអង្គការសហប្រជាជាតិអនុម័តនូវសេចក្តីសម្រេចមួយ ដែលស្នើឲ្យអគ្គលេខាធិការបន្តធ្វើការចរចារឡើងវិញដោយមិនពន្យារពេល ដើម្បីសម្រេចកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយផ្អែកលើការចរចារពីមុន និងដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញមួយ ដែលស្របទៅតាមបទបញ្ញត្តិនៃសេចក្តីសម្រេចបច្ចុប្បន្ន ដើម្បីឲ្យអង្គជំនុំជម្រះវិសាមញ្ញនឹងអាចចាប់ផ្តើមដំណើរការបានយ៉ាងឆាប់រហ័ស ។ សេចក្តីសម្រេចនេះត្រូវបានអនុម័តដោយមានសំឡេងអនុបវាទពីប្រទេសចំនួន ៣៩ ។

## ៣០ វិច្ឆិកា ២០០២

លោក ខៀវ សំផន និយាយថា លោកនិងមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដទៃទៀតត្រៀមខ្លួននឹងផ្តល់ភ័ស្តុតាងស្តីពីការងារផ្ទៃក្នុងនៃរបបម៉ៅជ្រុលនិយមដ៏អាថ៌កំបាំងនេះដែលដឹកនាំដោយបងធំទី១ ប៉ុល ពត ប្រសិនបើគណៈកម្មាធិការស្វែករកការពិតបែបអាហ្វ្រិកខាងត្បូងត្រូវបានបង្កើតឡើង ។ *(AFP, ២ ធ្នូ ២០០២)*

## ២ ធ្នូ ២០០២

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា រដ្ឋាភិបាលរបស់លោកកំពុងតែរង់ចាំការយល់ព្រមជាផ្លូវការមួយនៃសេចក្តីសម្រេចនោះ «នៅអំឡុងសប្តាហ៍ខាងមុខនេះ ។ អ្វីដែលយើងព្រួយបារម្ភ គឺការរស់រានរបស់ប្រជាជនកម្ពុជាដែលរួចផុតពីកណ្តាប់ដៃរបស់ ប៉ុល ពត» ។ *(AFP, ២ ធ្នូ ២០០២)*

## ១៩ ធ្នូ ២០០២

អង្គការសហប្រជាជាតិអនុម័តនូវអាណត្តិមួយ ដែលតម្រូវឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិលោក កូហ្វី អាណាន់ វិលត្រឡប់ទៅតុចរចារជាមួយរាជរដ្ឋាភិបាលកម្ពុជាវិញ ។ សេចក្តីសម្រេចដែលតម្រូវឲ្យលោក អាណាន់ ចាប់ផ្តើមកិច្ចពិភាក្សាសាជាថ្មី ដោយគ្មានការពន្យារពេលនេះ ត្រូវបានអនុម័តដោយការបោះឆ្នោតដែលមានសំឡេងចំនួន១៥០យល់ព្រមនិង៣០អនុបវាទ ។ *(The Cambodia Daily, ២០ ធ្នូ ២០០២)*

## ២៣ ធ្នូ ២០០២

លោក ប៉ែនសុន សម័យ ដែលជាមេធាវីរបស់ តាម៉ុក ស្នើឲ្យដោះលែងកូនក្តីរបស់លោកជាបណ្តោះអាសន្នដោយសំអាងលើបញ្ហាសុខភាពនិងមនុស្សធម៌ ។

## ២៥ ធ្នូ ២០០២

សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ មានព្រះបន្ទូលថា "រដ្ឋាភិបាលត្រូវតែធ្វើការបន្ធូរបន្ថយដើម្បីសម្របសម្រួលជាមួយអង្គការសហប្រជាជាតិ ប្រសិនបើកិច្ចពិភាក្សាដែលចាប់ផ្តើមឡើងវិញស្តីពីសាលាក្តីខ្មែរក្រហមត្រូវដំណើរការទៅមុខ ។ ទាំងអង្គការសហប្រជាជាតិនិងកម្ពុជា បានដឹងពីជំហររបស់គ្នារួចហើយ ។ បើយើងត្រឡប់មកវិញដោយគ្រាន់តែធ្វើការពិភាក្សាស្តីពីបញ្ហាដដែលៗ ដែលជាជំហរនាំឲ្យយើងជាប់គាំងដូចពីមុននោះ យើងមិនអាចមានការចរចារបានទេ ។

## ៦ មករា ២០០៣

ក្នុងកិច្ចឆ្លើយតបទៅនឹងការអញ្ជើញរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ គណប្រតិភូរបស់កម្ពុជាដែលដឹកនាំដោយលោក សុខ អាន បានទៅដល់ទីក្រុងញូវយ៉ក និងគ្រោងចូលរួមកិច្ចប្រជុំចំនួន៧លើក លើទីមួយ គឺជួបជាមួយលោកអគ្គលេខាធិការ និង៦លើកទៀតគឺជួបជាមួយតំណាងអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលដឹកនាំដោយលោក ហែន កូរ៉ែល ដើម្បីរៀបចំការបន្តការចរចារឡើងវិញ ស្តីពីការជំនុំជម្រះសេចក្តីខ្មែរក្រហម ស្របតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥៧/២២៨ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ ។

## ១៧ មីនា ២០០៣

អង្គការសហប្រជាជាតិនិងកម្ពុជា សម្រេចកិច្ចព្រមព្រៀង ដើម្បីបង្កើតតុលាការប្រល័យពូជសាសន៍ពិសេសមួយសម្រាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ ក្រុមអ្នកច្បាប់របស់អង្គការសហប្រជាជាតិ និងប្រធាននៃអ្នកចរចាររបស់កម្ពុជាបានយល់ព្រម និងគាំទ្រមាត្រានៃកិច្ចព្រមព្រៀង ។ កិច្ចព្រមព្រៀងត្រូវតែទទួលបានការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ និងរដ្ឋសភាជាតិកម្ពុជា មុនពេលការងារស្តីពីការបង្កើតតុលាការអាចបន្តធ្វើទៅបាន ។

## ១៨ ខែមីនា ឆ្នាំ២០០៣

ស្ថានទូតចក្រភពអង់គ្លេសប្រចាំនៅទីក្រុងភ្នំពេញ បានចេញសេចក្តីប្រកាសព័ត៌មានមួយដើម្បីស្វាគមន៍ចំពោះការចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងសម្តែងនូវការប្តេជ្ញាចិត្តក្នុងការបន្តគាំទ្រតុលាការ ដែលឧបត្ថម្ភដោយអង្គការសហប្រជាជាតិ ។ ជាការផ្តល់មតិយោបល់លើកិច្ចព្រមព្រៀង រដ្ឋមន្ត្រីក្រសួងការបរទេស ម៉ៃអូប្រៀន (Mike O'Brien) មានសុទិដ្ឋិនិយមថា នៅទីបំផុតសាលាក្តីនឹងបិទទំព័រនៃរយៈកាលសោកនាដកម្មនៃប្រវត្តិសាស្ត្ររបស់កម្ពុជា ជាពិសេសគឺនាំយកអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឃោរឃៅដែលកើតឡើងក្នុងរបបខ្មែរក្រហមដោយអះអាងថា តុលាការនឹងផ្តល់ឱកាសមួយដល់ប្រជាជនកម្ពុជា ធ្វើការដោះស្រាយជាមួយបញ្ហាពីអតីតកាលរបស់គេ ហើយឈានទៅរកការផ្សះផ្សាជាតិឡើងវិញ ។ *(សេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតអង់គ្លេសប្រចាំនៅទីក្រុងភ្នំពេញ, ១៨ មិនា ២០០៣)*

## ២១ មីនា ២០០៣

អង្គការលើកលែងទោសអន្តរជាតិនិយាយថា ខ្លួនមានការព្រួយបារម្ភយ៉ាងខ្លាំងពីបទបញ្ញត្តិនៅក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀង "ដែលឆ្លុះបញ្ចាំងពីភាពឃ្លាតឆ្ងាយចេញពីច្បាប់និងបទដ្ឋានអន្តរជាតិនាពេលបច្ចុប្បន្ន" ។ អង្គការនេះបញ្ជាក់ថា ភាពខ្វះខាតនៃកិច្ចព្រមព្រៀងគឺមានលក្ខណៈធ្ងន់ធ្ងរ "ដែលធ្វើឲ្យរាំងស្ទះដល់ការចុះហត្ថលេខារបស់អង្គការសហប្រជាជាតិលើកិច្ចព្រមព្រៀងនោះ ប្រសិនបើមិនមានការកែសម្រួលឡើងវិញ" ។ យ៉ាងណាមិញ សេចក្តីព្រាងបទបញ្ញត្តិ ដែលអង្គការលើកលែងទោសអន្តរជាតិទទួលស្គាល់នោះរួមមានការបដិសេធចំពោះការលើកលែងទោស ឬអនុគ្រោះទោសចំពោះជនណាម្នាក់ដែលត្រូវបានធ្វើការស៊ើបអង្កេត ឬចោទប្រកាន់ពីបទឧក្រិដ្ឋដែលមានក្នុងកិច្ចព្រមព្រៀង ដែលឃ្លាមួយនេះ សំដៅទៅដល់ជនទាំងឡាយណា ដែលពីមុនធ្លាប់ត្រូវបានផ្តល់ការលើកលែងទោសដោយអាជ្ញាធរកម្ពុជា (សេចក្តីព្រាងច្បាប់ មាត្រា១១) បទបញ្ញត្តិដែលថារាល់ដំណើរការនីតិវិធីទាំងអស់ត្រូវធ្វើ ឡើងជាសាធារណៈ (សេចក្តីព្រាងច្បាប់ មាត្រា១២.២) និងការដកចេញនូវទោសប្រហារជីវិត (មាត្រា១០) ដែលស្របទៅតាមតុលាការអន្តរជាតិដទៃទៀត ។

## ២៨ មីនា ២០០៣

គណៈរដ្ឋមន្ត្រីកម្ពុជាយល់ស្របចំពោះសេចក្តីព្រាងនៃកិច្ចព្រមព្រៀង ជាមួយអង្គការសហប្រជាជាតិស្តីពីការបង្កើតតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ *(The Hindu International, ២៩ មិនា ២០០៣)*

## ៣១ មីនា ២០០៣

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិចេញរបាយការណ៍មួយលេខ (A/57/769) នៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិ ដោយធ្វើការរិះគន់ទៅលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ ។ លោកបានប៉ាន់ប្រមាណថា អង្គជំនុំជម្រះវិសាមញ្ញអាចនឹងចំណាយលើស១៩លានដុល្លារ ដូច្នេះលោកបានស្នើមូលនិធិរួមរបស់អង្គការសហប្រជាជាតិឲ្យផ្តល់វិភាគទានកំណត់មួយ តែមិនមែនតាមការស្ម័គ្រចិត្តនោះទេ ។ (www.cambodia.gov.kh/krt/english/chrono.htm)

## ១ ឧសភា ២០០៣

គណៈកម្មាការទីបីនៃមហាសន្និបាតអង្គការសហប្រជាជាតិ អនុម័តលើសេចក្តីសម្រេចយល់ព្រមទទួលស្គាល់កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ទាក់ទងនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជា ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្រោមច្បាប់កម្ពុជា ។

## ២ ឧសភា ២០០៣

គណៈកម្មការទីបីអនុម័តលើសេចក្តីសម្រេចមួយដោយយល់ស្របទៅនឹងសេចក្តីព្រាងនៃកិច្ចព្រមព្រៀង ហើយថ្លែងថា អង្គការសហប្រជាជាតិគួរតែផ្តល់មូលនិធិទៅឲ្យអង្គជំនុំជម្រះវិសាមញ្ញ តាមរយៈវិភាគទានស្ម័គ្រចិត្ត ។ (www.cambodia.gov.kh/krt/english/chrono.htm)

## ១៣ ឧសភា ២០០៣

កិច្ចប្រជុំពេញអង្គលើកទី៨៥ នៃមហាសន្និបាតលើកទី៥៧ អនុម័តសេចក្តីសម្រេចលេខ 57/228B ដោយយល់ស្របទៅនឹងសេចក្តីព្រាងនៃកិច្ចព្រមព្រៀង និងវិភាគទានស្ម័គ្រចិត្ត ។ (www.cambodia.gov.kh/krt/english/chrono.htm)

## ៦ មិថុនា ២០០៣

អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅសាលមហោស្រពចតុមុខក្នុងទីក្រុងភ្នំពេញ ។ (រស្មីកម្ពុជា, ៦ មិថុនា ២០០៣)

## ១៦ មិថុនា ២០០៣

រាជរដ្ឋាភិបាលកម្ពុជាដាក់ជូនរដ្ឋសភាពជាតិ នូវកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់ទោសក្រោមច្បាប់កម្ពុជា ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ (The Cambodia Daily, ១៩ មិថុនា ២០០៣)

## ១៩ មិថុនា ២០០៣

ប្រទេសអូស្ត្រាលីសន្យាផ្តល់ប្រាក់១លាន៥សែនដុល្លារអូស្ត្រាលី សម្រាប់អង្គជំនុំជម្រះវិសាមញ្ញ បន្ថែមលើទឹកប្រាក់២៦៦,០០០ដុល្លារអូស្ត្រាលី ដែលបានផ្តល់នៅក្នុងទម្រង់ផ្សេងៗនៃជំនួយផ្នែកបច្ចេកទេស ទាក់ទងនឹងការកាត់ទោសខ្មែរក្រហម ។ (www.cambodia.gov.kh/krt/english/chrono.htm)

## ១ កក្កដា ២០០៣

លោកស្រី ខៀវ ប៉ុណ្ណារី ប្រពន្ធទីមួយរបស់អតីតមេដឹកនាំខ្មែរក្រហម ប៉ុល ពត ស្លាប់ក្នុងអាយុ ៨៣ឆ្នាំ នៅទីក្រុងប៉ៃលិន ។ *(រស្មីកម្ពុជា, ៥ កក្កដា ២០០៣)*

## ១៣ សីហា ២០០៣

ឯកសាររាប់ពាន់សន្លឹកដែលនិយាយពីអំពើឃោរឃៅ ដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ត្រូវបានបញ្ជូនទៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងប្រទេសបារាំង បន្ទាប់ពីមានការគំរាមកំហែងផ្នែកសន្តិសុខជាបន្តបន្ទាប់ ។ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាលោក ឆាំង យុ និយាយថា ភ័ស្តុតាងប្រមាណជា ៧០ ភាគរយត្រូវបានរក្សាទុកយ៉ាងមានសុវត្ថិភាពនៅប្រទេសទាំងនោះ ។ *(AFP, ១៣ សីហា ២០០៣)*

## ១១ វិច្ឆិកា ២០០៣

បន្ទាប់ពីសិក្សាគម្រោងរយៈពេលពន្ធឆ្នាំសម្រាប់សាលាក្តី អង្គការសហប្រជាជាតិយល់ស្របថា ការចំណាយប្រហែលជាមានចំនួន៤០លានដុល្លារសហរដ្ឋអាមេរិក ។ លោក ឱម យិនទៀង ទីប្រឹក្សាលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងជាសមាជិកក្រុមការងារសាលាក្តីបាននិយាយថា អង្គការសហប្រជាជាតិនឹងចំណាយ ២០លានដុល្លារ ហើយ២០លានដុល្លារទៀតគឺជាបន្ទុករបស់ភាគីកម្ពុជា ។ *(The Cambodia Daily, ១២ វិច្ឆិកា ២០០៣)*

## ១៩ វិច្ឆិកា ២០០៣

សភាសហរដ្ឋអាមេរិកអនុម័តលើសេចក្តីសម្រេចមួយលេខ (H. CON. RES. 83) ដោយសំដែងក្តីគោរពដល់ជនរងគ្រោះនៃសម័យខ្មែរក្រហម ។ សេចក្តីសម្រេចនេះបញ្ជាក់ថាសហរដ្ឋអាមេរិកប្តេជ្ញាបន្តស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ។ សមាជិកសភាសហរដ្ឋអាមេរិក លោក ដាណា រ៉ូរ៉ាបាឆឺ (Dana Rohrabacher) ថ្លែងថា សេចក្តីសម្រេចនេះជាសញ្ញានៃការទទួលស្គាល់នូវតួនាទីរបស់សហរដ្ឋអាមេរិក នៅក្នុងជម្លោះនៅឥណ្ឌូចិន ជាពេលដែលរបបខ្មែរក្រហមចាប់ផ្តើមកើតឡើង ។ *(The Cambodia Daily, ២៦ វិច្ឆិកា ២០០៣)*

**៧ ធ្នូ ២០០៣**

លោក ខាស្តេន ហ៊ែរែល (Karsten Harrel) ប្រធានក្រុមរៀបចំសាលាក្តីដែលមានសមាជិក៥នាក់ និយាយថា ទាំងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាកំពុងចាប់ផ្តើមធ្វើការសន្មត់ថា អង្គជំនុំជម្រះវិសាមញ្ញនឹងចាប់ប្រតិបត្តិការនៅឆ្នាំ២០០៤ ។ *(Reuters, ៧ ធ្នូ ២០០៣)*

**១០ ធ្នូ ២០០៣**

លោក កូហ្វី អាណាន់ ថ្លែងថា ដំណើរការនៃការបង្កើតសាលាក្តីនឹងចាប់ផ្តើមបាន លុះត្រាតែការមានសន្យាសម្រាប់រយៈពេល៣ឆ្នាំដំបូងនៃប្រតិបត្តិការរបស់តុលាការត្រូវបានទទួលស្គាល់ ហើយថវិកាសម្រាប់ប្រតិបត្តិការក្នុងឆ្នាំដំបូងត្រូវបានតម្កល់គ្រប់គ្រាន់នៅក្នុងមូលនិធិស្ម័គ្រចិត្ត ។ *(The Associated Press, ១៨ ធ្នូ ២០០៣)*

**១៧ ធ្នូ ២០០៣**

នាយកគម្រោងអ្នកការពារក្តីកម្ពុជាមានប្រសាសន៍ថា លោក ខៀវ សំផន ប្រមុខរដ្ឋរបស់ខ្មែរក្រហម បានធ្វើទស្សនកិច្ចការិយាល័យរបស់លោកកាលពីដើមឆ្នាំនេះ ដើម្បីស្វែងរកជំនួយផ្នែកច្បាប់ មុនពេលការបង្កើតសាលាក្តីដែលបានគ្រោងទុកនេះ ។

**១៩ ធ្នូ ២០០៣**

ប្រទេសអូស្ត្រាលីចេញសេចក្តីថ្លែងការណ៍ថា ខ្លួនបានផ្តល់ប្រាក់២លាន១សែនដុល្លារសហរដ្ឋអាមេរិកសម្រាប់តុលាការចម្រុះកម្ពុជា-អន្តរជាតិ ។

**២២ ធ្នូ ២០០៣**

បន្ទាប់ពីការអំពាវនាវសុំជំនួយផ្នែកច្បាប់របស់លោក ខៀវ សំផន លោក នួន ជា ដែលរស់នៅផ្ទះក្បែរគ្នា និងជាអ្នកបដិវត្តន៍ដូចគ្នានោះ បាននិយាយថា គាត់នឹងធ្វើតំណាងដោយខ្លួនឯង ប្រសិនបើគាត់ត្រូវបានកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ *(The Cambodia Daily, ២២ ធ្នូ ២០០៣)*

**២៩ ធ្នូ ២០០៣**

នៅក្នុងលិខិតចំហមួយច្បាប់ លោក ខៀវ សំផន បដិសេធចំពោះការរួមចំណែកក្នុងការសម្លាប់ប្រជាជនខ្មែរជាង១លាននាក់ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែគាត់ទទួលស្គាល់ថារបបនេះ បាន អនុវត្តនូវការ«សម្លាប់ជាប្រព័ន្ធ»ពិតមែន ។ *(The Cambodia Daily, ៣១ ធ្នូ ២០០៣)*

## ១០ មីនា ២០០៤

ក្រុមអ្នកច្បាប់របស់អង្គការសហប្រជាជាតិមកដល់ប្រទេសកម្ពុជា ដើម្បីរៀបចំគម្រោងសម្រាប់សាលាក្តី មុនពេលប្រគល់សំណើសុំថវិកាទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ *(The Cambodia Daily, ១១ មិនា ២០០៤)*

## ១២ មីនា ២០០៤

សម្តេចព្រះ នរោត្តម សីហនុ ទ្រង់ខ្វល់ចំពោះការបោះពុម្ពផ្សាយចម្លើយកសិណសាក្សីរបស់អតីតមេដឹកនាំខ្មែរក្រហមដែលបានអះអាងថា ខ្លួនគ្មានទោសពីបទឧក្រិដ្ឋដ៏ឃោរឃៅ ដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ឡើយ ។ សម្តេចព្រះ នរោត្តម សីហនុ ដែលបានចាត់ទុកឧក្រិដ្ឋកម្មរបស់មេដឹកនាំខ្មែរក្រហមនោះថា «អាក្រក់ហួសហេតុ»បានអះអាងថា តាមរយៈការប្រកាសជាសាធារណនូវភាពគ្មានទោសពៃរបស់ខ្លួន មេដឹកនាំទាំងនេះមិនចាំបាច់ស្នើសុំឲ្យមានការលើកលែងទោសចំពោះបទឧក្រិដ្ឋរបស់ខ្លួនឡើយ ។ *(The Cambodia Daily, ១៣-១៤ មិនា ២០០៤)*

## ១៨ មីនា ២០០៤

ក្នុងអំឡុងបេសកកម្មលើកទីពីរមកទីក្រុងភ្នំពេញ ដើម្បីរៀបចំអង្គជំនុំជម្រះមេដឹកនាំខ្មែរក្រហម លោក ខាស្តែន ហ៊ែរែល (Karsten Harrel) ប្រធាននៃគណៈប្រតិភូអង្គការសហប្រជាជាតិថ្លែងថាសាលាក្តីនឹង «ចំណាយអស់ថវិកាច្រើនដល់ទៅ»៥០លានដុល្លារ ។ លោក ហ៊ែរែល បានបដិសេធមិនផ្តល់នូវតួរលេខនៃចំនួនថវិកាជាក់លាក់ទេ ដោយនិយាយថា «ខ្ញុំចំណាយមួយចំនួនមិនត្រូវបានដឹងទាំងស្រុងនោះទេ» ។ *(The Cambodia Daily, ១៩ មីនា ២០០៤)*

## ២៥ មីនា ២០០៤

កិច្ចប្រជុំសភាសហរដ្ឋអាមេរិកលើកទី១០៨ *(2nd Session-H.CON.RES.399)*

សម្រេចដោយតំណាងរាស្ត្រ(ព្រឹទ្ធសភាបានយល់ស្រប) នៅក្នុងកិច្ចប្រជុំនេះថា ទីមួយ ៖ ជំរុញឲ្យលោកប្រធានាធិបតីជំរុញរដ្ឋសភាជាតិកម្ពុជា ឲ្យផ្តល់សច្ចាប័នទៅលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតសាលាក្តីមួយ គឺអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់កាត់សេចក្តីបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់ ដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗទៀត ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ និងទីពីរ ៖ បន្ទាប់ពីកិច្ចព្រមព្រៀងនោះ ត្រូវបានផ្តល់សច្ចាប័នហើយ ជំរុញឲ្យលោកប្រធានាធិបតីផ្តល់ការគាំទ្រក្នុងការបង្កើត និងផ្តល់ថវិកាសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ដែលស្របតាមច្បាប់យុត្តិធម៌ស្តីពីអំពើប្រល័យពូជសាសន៍កម្ពុជា ។ (http://thomas.loc.gov/home/gpoxmlc108/hc399_ih.xml)

## ៣ មេសា ២០០៤

នៅទីក្រុងឡុងប៊ិច សមាជិកសភាប្រចាំរដ្ឋកាលីហ្វ័រនីញ៉ាទទូចសុំឲ្យលោកប្រធាធិបតី ប៊ូស ផ្តល់មូលនិធិសម្រាប់សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់ ។ សមាជិកសភាលោកស្រី ជូនីតា មីលែនដឺម៉ាកដូណាល់ (Juanita Millender-McDonald) និងលោក ដាណា រ៉ូរ៉ាបាឆឺ (Dana Rohrabacher) ដែលអ្នកទាំងពីរជាតំណាងឲ្យសហគមន៍មួយក្នុងចំណោមសហគមន៍ខ្មែរធំជាងគេនៅសហរដ្ឋអាមេរិក បាននិយាយថា យុត្តិធម៌សម្រាប់អ្នកនៅរស់រានមានជីវិតពីសម័យខ្មែរក្រហមគឺមានការពន្យាយូរណាស់ហើយ ។ *(សារទូរលេខសារព័ត៌មាន ឡុងប៊ិច, ៣ មេសា ២០០៤)*

## ៧ មេសា ២០០៤

អ្នកដឹកនាំសង្គមស៊ីវិល១៧រូបនិងសមាជិកសភាមួយរូប បានចុះហត្ថលេខាលើញត្តិមួយ ស្នើសុំឲ្យព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចេញដីកាចាប់ខ្លួនមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដែលនៅរស់ចំនួន៣នាក់ ។ *(សារព័ត៌មាន Kyodo, ៧ មេសា ២០០៤)*

## ៨ មេសា ២០០៤

រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក លោក ខូលីន ផូវែល (Colin Powell) និយាយថា ចៅក្រមអន្តរជាតិអាចនឹងផ្តល់ការជឿទុកចិត្តចំពោះសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ លោក ផូវែល

បានឆ្លើយ បំភ្លឺនៅក្នុងសវនាការនៃកិច្ចប្រជុំសភា ដែលក្នុងនោះសមាជិកសភាមួយរូបបានចោទសួរថា ហេតុអ្វីបានជាសហរដ្ឋអាមេរិកគាំទ្រសាលាក្តីខ្មែរក្រហមដែលមានលក្ខណៈខ្វះខាត ដោយអនុលោមតាមប្រព័ន្ធច្បាប់កម្ពុជាដ៏ទន់ខ្សោយទៅវិញ ។ «ខ្ញុំមានការព្រួយបារម្ភដូចអ្នកទាំងអស់គ្នាដែរទាក់ទិនពីអត្ថិភាពនៃយុត្តិធម៌ ក្នុងនាមជាប្រជាជនកម្ពុជាដែលមិនអាចផ្តល់នូវយុត្តិធម៌ ដូចអ្វីដែលយើងចង់បាននោះទេ ។ ប៉ុន្តែយើងមានចៅក្រមអន្តរជាតិក្នុងតុលាការនេះ ដែលយ៉ាងហោចណាស់ជនត្រូវចោទ ហើយដែលមានវ័យចំណាស់ទាំងនោះនឹងត្រូវបាននាំយកមកកាត់ទោសនៅចំពោះ មុខតុលាការ ។ *(AFP, ៨ មេសា ២០០៤)*

## ៩ មេសា ២០០៤

អគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍សុំឲ្យព្រះរាជអាជ្ញាខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាបដាក់ពាក្យបណ្តឹងប្រឆាំងលោក ខៀវ សំផន និង នួន ជា ហើយសុំឲ្យចៅក្រមចេញដីកាឃាត់ខ្លួនដោយស្របតាមនីតិវិធីរបស់តុលាការ ។ «ចំពោះលោក អៀង សារី គឺចាំបាច់ត្រូវត្រួតពិនិត្យលើព្រះរាជក្រឹត្យលើកលែងទោសជាមុនសិន ។» *(The Cambodia Daily, ៣១ ខសភា ២០០៤)*

## ១៧ មេសា ២០០៤

សម្តេចព្រះ នរោត្តម សីហនុ បានធ្វើការកត់សម្គាល់ក្នុងខួបលើកទី២៩ ដែលក្រុងភ្នំពេញត្រូវបានធ្លាក់ចូលក្នុងការកាន់កាប់របស់ ខ្មែរក្រហម ដោយអំពាវនាវឲ្យមានការបូជាអដ្ឋិធាតុជនរងគ្រោះនៃរបបវាលពិឃាដ និងបោះបង់ចោលសាលាក្តីដែលគាំទ្រដោយអង្គការសហប្រជាជាតិដែលត្រូវបានស្នើឡើងនេះ ។ ព្រះអង្គ ទ្រង់ឡាយលិខិតជាភាសាខ្មែរថា «យើងជាពុទ្ធសាសនិក ដែលតាំងពីបុរាណមកមានជំនឿនិងប្រពៃណីបូជាសព ហើយបន្ទាប់មកនាំយកអដ្ឋិធាតុទៅដាក់ក្នុងចេតិយនៅវត្ត» ។ ព្រះអង្គ ក៏បានទិទៀនសាលាក្តីខ្មែរក្រហមថា សាលាក្តីគឺជាការប្រមាថមើលងាយដល់ជនរងគ្រោះ ដែលបានស្លាប់ទៅតែប៉ុណ្ណោះ ។ ព្រះអង្គទ្រង់បន្តទៀតថា «សហគមន៍អន្តរជាតិនិងអង្គការសហប្រជាជាតិ ផ្តល់មូលនិធិជាច្រើនសម្រាប់ដំណើរការសាលាក្តីនេះ ។ ខ្ញុំរំពឹងទុកជាមុនថា នេះគ្រាន់តែជារឿងកំប្លែង និងជាការមើលងាយដល់ព្រលឹងជនរងគ្រោះតែប៉ុណ្ណោះ» ។ *(The Cambodia Daily, ១៩ មេសា ២០០៤)*

## ២០ មេសា ២០០៤

ក្នុងរាជសារមួយដែលបានបោះពុម្ពក្នុងគេហទំព័ររបស់ព្រះអង្គ សម្តេចព្រះ នរោត្តម សីហនុ មានព្រះបន្ទូលថា សាលាក្តីខ្មែរក្រហមមិនអាចយកជាការបានទេ ប្រសិនបើសាលាក្តីនេះមិនធ្វើនៅទីក្រុងឡាអេ ដោយសារប្រព័ន្ធច្បាប់កម្ពុជាមិនដំណើរការបានល្អ ។ «ពិភពលោកទាំងមូលរួមទាំងសារព័ត៌មានដែលខ្ញុំតែងតែអាន

បានវាយតម្លៃថៅក្រុមរបស់យើងថាពុករលួយនិងគ្មានសមត្ថភាព» ។ (The Cambodia Daily, ២២ មេសា ២០០៤)

## ២៧ មេសា ២០០៤

លោក ខៀវ សំផន ចេញលិខិតចំហមួយសំដែងពីមតិសាធារណៈមកលើរូបលោក ដោយថ្លែងថា ខ្លួនលោកទទួលបានការចាប់អារម្មណ៍ពីប្រជាជនខ្មែរជាច្រើន ។ «ជនរួមជាតិកាន់តែច្រើន រួមទាំងព្រះសង្ឃផងបានសំដែងការអាណិតចំពោះខ្ញុំ ហើយខ្ញុំមិនចាំបាច់និយាយអ្វីគ្រប់យ៉ាង ដែលអ្នកដទៃបានប្រាប់ខ្ញុំ ជារៀងរាល់ថ្ងៃនៅតាមផ្លូវ ដោយបញ្ចេញស្នាមញញឹមដាក់ខ្ញុំ ហើយប្រាប់ខ្ញុំថាពួកគាត់បានអានសៀវភៅរបស់ខ្ញុំ» ។ (The Cambodia Daily, ២៨ មេសា ២០០៤)

## ២៨ មេសា ២០០៤

សម្ដេចព្រះ នរោត្តម សីហនុ ចេញព្រះរាជសារមួយច្បាប់ក្នុងគេហទំព័ររបស់ព្រះអង្គថា ព្រះអង្គ ចង់ធ្វើសក្ខីកម្មនៅចំពោះមុខសាលាក្ដីខ្មែរក្រហម ។ «ខ្ញុំធ្វើសក្ខីកម្មនៅមុខតុលាការមិនត្រឹមតែម្ដងនោះទេ តែគ្រប់ពេលទាំងអស់ដែលតុលាការបើកសវនាការសួរចម្លើយអ្នកនេះអ្នកនោះរាល់ថ្ងៃ រាល់សប្ដាហ៍ រាល់ខែ រាល់ឆ្នាំ ឲ្យតែខ្ញុំនៅមានជីវិត» ។ (The Cambodia Daily, ២៨ មេសា ២០០៤)

## ១៤ ឧសភា ២០០៤

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់កម្ពុជា លោក គាត ឈន់ មានប្រសាសន៍ថា លោកស្ម័គ្រចិត្តបង្ហាញខ្លួនធ្វើជាសាក្សីនៅឯសាលាក្ដីដែលគាំទ្រដោយអង្គការសហប្រជាជាតិ ។ លោកថ្លែងថា លោកនឹងធ្វើសក្ខីកម្មដើម្បីការពារឈ្មោះរបស់លោក ប្រសិនបើសាលាក្ដីសម្រេចចោទប្រកាន់លោកពីបទចូលរួមជាមួយខ្មែរក្រហម ។ រដ្ឋមន្ត្រីដែលទទួលការអប់រំនៅប្រទេសបារាំង ហើយដែលធ្លាប់បម្រើការឲ្យខ្មែរក្រហម ដែលរួមមានការធ្វើជាអ្នកបកប្រែឲ្យ ប៉ុល ពត បានដកខ្លួនចេញពីចលនានេះនៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៨០ ។ (Dow Jones Newswires, ១៦ ឧសភា ២០០៤)

## ២៤ ឧសភា ២០០៤

លោកឧបនាយករដ្ឋមន្ត្រី ស ខេង យល់ស្របចំពោះការបង្កើតគណៈកម្មការពិសេសមួយដើម្បីធានាសុវត្ថិភាពអ្នកចូលរួមក្នុងសាលាក្ដី ។ គណៈកម្មការនេះនឹងត្រូវដឹកនាំដោយរដ្ឋលេខាធិការក្រសួងមហាផ្ទៃលោកឯម សំអាន ។ អនុប្រធានជាច្រើនរូបទៀតរួមមាន លោក មៅ ចាន់ដារ៉ា អគ្គនាយករងនគរបាលជាតិ លោក

ប៉ុល សារឿន មេបញ្ជាការរងកងយោធពលខេមរភូមិន្ទ លោក នេត សាវឿន អគ្គនាយករងនគរបាលជាតិ និងលោក នៅ សំ នាយសេនាធិការរងនៃកងយោធពលខេមរភូមិន្ទ។ យោងតាមសម្តីរបស់លោក ម៉ៅ ចាន់ដារ៉ា បានឲ្យដឹងថា គណៈកម្មការពិសេសនេះក៏មានរួមបញ្ចូលអ្នកតំណាងម្នាក់មកពីក្រសួងហិរញ្ញវត្ថុ និង អភិបាលខេត្ត-ក្រុងទាំងឡាយ ដែលមានសាក្សីនិងជនសង្ស័យរស់នៅ។

## ៣០ ឧសភា ២០០៤

ព្រះរាជអាជ្ញាខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប ព្រងើយកន្តើយចំពោះដីការបញ្ជារបស់ អគ្គព្រះរាជអជ្ញាសាលាឧទ្ធរណ៍ក្នុងការឃាត់ខ្លួនអតីតមេដឹកនាំខ្មែរក្រហម ខៀវ សំផន និង នួន ជា។ លោក យ៉ម យ៉េត ព្រះរាជអាជ្ញាខេត្តបាត់ដំបងបាននិយាយថា លោកបានទទួលដីកានៅថ្ងៃទី៩ ខែមេសា រួចហើយ ប៉ុន្តែ លោកមិនទាន់ធ្វើសកម្មភាពទេ។ មានតែចៅក្រមពិសេសអន្តរជាតិរបស់សាលាក្តីខ្មែរក្រហមតែប៉ុណ្ណោះ ដែលអាចចេញដីកាចាប់ខ្លួនបាន។ លោក សូ វ៉ា ព្រះរាជអាជ្ញាខេត្ត សៀមរាបក៏បានអះអាងដែរថា លោក បានទទួលដីកាពីអគ្គព្រះរាជអាជ្ញាហើយ ប៉ុន្តែលោកខ្វះភ័ស្តុតាងឯកសារប្រឆាំងនឹងអតីតមេដឹកនាំទាំងនោះ និង ថវិកាដើម្បីធ្វើការស៊ើបអង្កេតអ្នកទាំងនោះឲ្យបានត្រឹមត្រូវ។ លោក ឱម យិនទៀង ទីប្រឹក្សាលោកនាយក រដ្ឋមន្ត្រី ហ៊ុន សែន និងជាអនុប្រធានក្រុមការងាររៀបចំសាលាក្តីបាននិយាយថា លោកមានការភ្ញាក់ផ្អើល ចំពោះការសម្រេចចិត្តចេញដីកាចាប់ខ្លួនរបស់សាលាឧទ្ធរណ៍ ខណៈពេលដែលអ្នកច្បាប់របស់គណបក្សប្រឆាំង លោក សុន ឆៃ បានតវ៉ាថាមន្ត្រីរដ្ឋាភិបាលបានគាបសង្កត់អាជ្ញាធរខេត្តមិនឲ្យធ្វើការចាប់ខ្លួនអតីតមេដឹកនាំ ខ្មែរក្រហម។ "ព្រះរាជអាជ្ញាទាំងនោះគួរតែត្រូវដាក់ពិន័យ ដោយសារតែពួកគេមិនគោរពតាមការបញ្ជារបស់ អគ្គព្រះរាជអាជ្ញា"។ (The Cambodia Daily, ៣១ ឧសភា ២០០៤)

## ៥ មិថុនា ២០០៤

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា តុលាការកម្ពុជាមិនមានយុត្តាធិការចេញបញ្ជាឲ្យ ចាប់ខ្លួនអតីតមេដឹកនាំខ្មែរក្រហមនោះទេ ដោយនិយាយថាមានតែសាលាក្តីគាំទ្រដោយអង្គការសហប្រជាជាតិ ប៉ុណ្ណោះទើបមានអំណាចនាំអ្នកទាំងនោះមកកាត់ទោសបាន។ "គ្មានការចាប់ខ្លួនណានឹងត្រូវធ្វើឡើងនោះទេ រហូតទាល់តែសាលាក្តីត្រូវបានបង្កើតឡើង។ ការផ្តល់សច្ចាប័នទៅលើសាលាក្តីនឹងក្លាយជារបៀបវារៈដំបូង របស់រដ្ឋសភាជាតិដែលទើបបង្កើតថ្មី។ លោកបានបញ្ជាក់ថា លោកគ្មានការព្រួយបារម្ភថា ខៀវ សំផន ឬ នួន ជា នឹងព្យាយាមរត់គេចទៅប្រទេសក្រៅ ដើម្បីចៀសវាងការកាត់ទោសរបស់សាលាក្តីនោះទេ ព្រោះ"អ្នក ទាំងពីរមិនដឹងថាត្រូវគេចទៅកន្លែងណានោះឡើយ។ អ្នកទាំងនេះនឹងត្រូវប្រឈមមុខចំពោះសាលាក្តី។ (The Cambodia Daily, ៧ មិថុនា ២០០៤)

ការចំណាយដែលប៉ាន់ស្មានទុកសម្រាប់ការកាត់ទោសខ្មែរក្រហមដែលបានស្នើឡើង ឥឡូវនេះឡើងដល់ ៦០លានដុល្លារសហរដ្ឋអាមេរិក ដែលចំនួននេះគឺច្រើនជាងការប៉ាន់ស្មានដំបូង១០លានដុល្លារ ។ សមាជិកការិយាល័យកិច្ចការសាធារណៈរបស់សាលាក្តីលោកស្រី ហេលែន ចាវីស (Helen Jarvis) បានអះអាងថា ការចំណាយប៉ាន់ស្មានឥឡូវនេះគឺលើស៦០លានដុល្លារ ដែលនឹងត្រូវយកទៅពិភាក្សានិងត្រួតពិនិត្យឡើងវិញដោយអ្នកផ្តល់ជំនួយសំខាន់ៗ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ។ *(Phnom Penh Post, ៤-១៧ មិថុនា ២០០៤)*

## ២០ កក្កដា ២០០៤

ប្រទេសអូស្ត្រាលីសន្យាផ្តល់ទឹកប្រាក់៥លានដុល្លារអូស្ត្រាលីបន្ថែមទៀត សម្រាប់អង្គជំនុំជម្រះវិសាមញ្ញបន្ថែមពីលើទឹកប្រាក់១លាន៥សែនដុល្លារអូស្ត្រាលីដែលបានប្រកាសកាលពីពេលមុន ។ ទឹកប្រាក់សរុប ៣លានដុល្លារអូស្ត្រាលី (២លាន២សែនដុល្លារអាមេរិក) ត្រូវបានបន្ថែមលើប្រាក់ ២៦៦.០០០ដុល្លារអូស្ត្រាលីដែលបានផ្តល់ជាទម្រង់ផ្សេងៗនៃជំនួយបច្ចេកទេស ដែលទាក់ទងនឹងការកាត់ទោសខ្មែរក្រហម ។ *(www.cambodia.gov.kh/krt/english/chrono.htm)*

## ៥ សីហា ២០០៤

លោក ស៊ាន វិសុទ្ធ ប្រធានការិយាល័យការងារសាលាក្តីខ្មែរក្រហមរបស់រាជរដ្ឋាភិបាលកម្ពុជានិយាយថា ក្រុមការងាររបស់អង្គការសហប្រជាជាតិដែលដឹកនាំដោយលោក ខាស្តែន ហ៊ែរែល (Karsten Harrel) នឹង មកដល់កម្ពុជានៅថ្ងៃទី២៣ ខែសីហា ដើម្បីប៉ាន់ប្រមាណបញ្ចប់ពីថវិការបស់សាលាក្តី ។ លោកបានបន្ថែមទៀតថា ការកាត់ក្តីរយៈពេល៣ឆ្នាំនេះ ត្រូវបានរំពឹងថានឹងចំណាយអស់ទឹកប្រាក់៥៧លានដុល្លារ ហើយការចំណាយចុងក្រោយនឹងត្រូវដោះស្រាយជាមួយប្រទេសម្ចាស់ជំនួយ ឬក្រុមប្រទេសដែលមានការចាប់អារម្មណ៍ ។ *(សារព័ត៌មាន Kyodo, ៥ សីហា ២០០៤)*

## ៦ សីហា ២០០៤

គណៈរដ្ឋមន្ត្រីបានអនុម័តលើសេចក្តីព្រាងច្បាប់ចំនួនពីរ ទីមួយ : វិសោធនកម្មច្បាប់ឆ្នាំ២០០១ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ ទីពីរ : ការឲ្យផ្តល់សច្ចាប័នទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដែលបានចុះហត្ថលេខានៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ។ វិសោធនកម្មដែលត្រូវបានអនុម័តនេះ គឺធ្វើឡើយក្នុងគោលបំណងធ្វើឲ្យមានភាពចុះសម្រុងរវាងច្បាប់ស្តីពីការបង្កើតអង្គ

ជំនុំជម្រះវិសាមញ្ញនិងកិច្ចព្រមព្រៀង ហើយវាឆ្លុះបញ្ចាំងពីវិសោធកម្មដែលស្នើដោយលោក ហាន់ កូរ៉ែល នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៣ ។ បន្ថែមពីលើនេះ ការពង្រីកដែនអជ្ញាយុកាលក្រោមមាត្រា៣ ត្រូវបាន ស្នើឲ្យធ្វើការផ្លាស់ប្តូរពី២០ឆ្នាំទៅ៣០ឆ្នាំ ។ (www.cambodia.gov.kh/krt/english/chrono.htm)

## ២៣ សីហា ២០០៤

ចៅក្រមនិងព្រះរាជអាជ្ញាចំនួន៣០រូប ដែលជ្រើសរើសដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចាប់ផ្តើមចូលរួមក្នុងវគ្គបណ្តុះបណ្តាលរយៈពេលពីរសប្តាហ៍ ស្តីពីច្បាប់មនុស្សធម៌អន្តរជាតិនៅសាលាភូមិន្ទចៅក្រម ។ យោងតាមសេចក្តីថ្លែងការណ៍ពីកម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ ដែលផ្តល់ជំនួយដល់វគ្គបណ្តុះបណ្តាលនេះ ចៅក្រមនិងព្រះរាជអាជ្ញានឹងត្រូវបានណែនាំពីប្រធានបទដែលរួមមាន ឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការកាត់ទោសដោយយុត្តិធម៌ និងដំណើរនីតិវិធីច្បាប់ ។ (The Cambodia Daily, ២៥ សីហា ២០០៤)

## ២៥ សីហា ២០០៤

គណៈកម្មការនីតិកម្មនៃរដ្ឋសភាជាតិ បានប្រគល់ឲ្យក្រុមការងារសាលាក្តីនូវសេចក្តីព្រាងច្បាប់សម្រាប់បង្កើតសាលាក្តីជាមួយនឹងការរិះគន់មួយចំនួនទៅលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ។ ប្រធានគណៈកម្មការនីតិកម្ម ឯកឧត្តម ឯក សំអុល មានប្រសាសន៍ថា សេចក្តីព្រាងច្បាប់មានកំហុសជាច្រើន ហើយតម្រូវឲ្យមានការផ្លាស់ប្តូរយ៉ាងច្រើនដែរ ។ គណៈកម្មការនេះបានបញ្ជូនសេចក្តីព្រាងច្បាប់នេះទៅឲ្យរដ្ឋាភិបាលវិញដើម្បីធ្វើការកែសម្រួល ។ ប៉ុន្តែប្រធានក្រុមការងារសាលាក្តីលោក ស៊ាន វិសុទ្ធ បាននិយាយថា កំហុសទាំងនោះជាកំហុសអក្ខរាវិរុទ្ធដែលអាចដោះស្រាយបានដោយងាយ ។ «គណៈកម្មការនីតិកម្ម គ្រាន់តែសុំឲ្យកែកំហុសអក្ខរាវិរុទ្ធខ្លះៗតែប៉ុណ្ណោះ» ។ (The Cambodia Daily, ២៧ សីហា ២០០៤)

## ១៣ កញ្ញា ២០០៤

បន្ទាប់ពីការប្រកាសពីការត្រឡប់មកវិញរបស់គណៈប្រតិភូអង្គការសហប្រជាជាតិ ដើម្បីរៀបចំថវិកានិងភ័ស្តុភារសម្រាប់សាលាក្តី មន្ត្រីរដ្ឋាភិបាលបានលុបចោលទស្សនកិច្ចរបស់ក្រុមការងារអង្គការសហប្រជាជាតិ ។ ទស្សនកិច្ចនេះ ត្រូវបានពន្យារពេលរហូតដល់រដ្ឋសភាជាតិផ្តល់សច្ចាប័នលើច្បាប់ស្តីពីការបង្កើតសាលាក្តីកាត់ទោសខ្មែរក្រហម ។ ទីប្រឹក្សារបស់នាយករដ្ឋមន្ត្រីលោក ឪម យិនទៀង បាននិយាយថា ក្រុមការងារនេះនឹងត្រូវអញ្ជើញឲ្យត្រឡប់មកវិញ នៅពេលសេចក្តីព្រាងច្បាប់ត្រូវបានអនុម័ត ។ លោកបានបន្ថែមថា «ខ្ញុំ

គិតថា ការពន្យារពេលមិនមែនជាការខ្ជះខ្ជាយពេលវេលានោះទេ» ។ (The Cambodia Daily, ២៧ សីហា ២០០៤)

## ១៦ កញ្ញា ២០០៤

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា កម្ពុជានឹងមិនរួមចំណែកថវិការរបស់ខ្លួនសម្រាប់អង្គជំនុំជម្រះសេចក្តីអតីតមេដឹកនាំខ្មែរក្រហមដែលពន្យារពេលដ៏យូរនោះទេ ។ «ឆាប់ៗនេះនឹងមានការជជែកពីថវិកា ។ ខ្ញុំចង់និយាយថា កម្ពុជាអាចផ្តល់ឲ្យតែសាលប្រជុំ បង់ថ្លៃទឹកភ្លើង និងកងសន្តិសុខតែប៉ុណ្ណោះ ។ វាគ្មានផ្លូវនោះទេ ដែលពួកគេអាចស្នើសុំឲ្យកម្ពុជាចំណាយសម្រាប់សាលាក្តី ។ បើអ្នកចង់ឲ្យមានសាលាក្តី អ្នកត្រូវតែចំណាយ» ។ លោកបានមានប្រសាសន៍បន្ថែមថា «យើងត្រូវតែមានភាពច្បាស់លាស់លើរឿងនេះ ។ កម្ពុជាអាចដំណើរការកាត់ក្តីបាន ប៉ុន្តែពួកគេនិយាយថា ពួកគេមិនជឿជាក់ថាកម្ពុជាអាចផ្តល់នូវយុត្តិធម៌បានទេ ។» (AFP, ១៦ កញ្ញា ២០០៤)

## ២ តុលា ២០០៤

រដ្ឋមន្ត្រីក្រសួងការបរទេសលោក ហោ ណាំហុង មានប្រសាសន៍ថា «លោក កូហ្វី អាណាន់ បានសុំឲ្យរាជរដ្ឋាភិបាលកម្ពុជាផ្ញើលិខិតមួយទៅអង្គការសហប្រជាជាតិ បន្ទាប់ពីផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ដើម្បីឲ្យលោកអគ្គលេខាធិការអាចស្នើប្ករៀបចំអង្គប្រជុំជាមួយម្ចាស់ជំនួយ ដើម្បីស្វែងរកថវិកាគាំទ្រសាលាក្តី ។ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានប្រាប់អ្នកយកព័ត៌មានថា មានតែធ្វើដូច្នេះទេ ទើបអង្គការសហប្រជាជាតិអាចស្វែងរកអ្នកផ្តល់ជំនួយ សម្រាប់ទឹកប្រាក់ប្រមាណជា ៥០ លានដុល្លារ ដែលត្រូវការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ (Reuters, ២ តុលា ២០០៤)

## ៤ តុលា ២០០៤

សមាជិករដ្ឋសភាជាតិចំនួន១០៧រូបក្នុងចំណោមសមាជិក១២៣រូប បានបោះឆ្នោតផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកាត់ទោសនៅក្រោមច្បាប់កម្ពុជាចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់ពីការបោះឆ្នោតផ្តល់សច្ចាប័ន លោក នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា «អ្វីដែលយើងបានរង់ចាំដ៏យូរនោះបានកើតឡើងហើយនៅថ្ងៃនេះ» ។ (ទស្សនាវដ្តីស្វែងរកការពិត ភាសាអង់គ្លេស លេខ៥៨ ខែតុលា ឆ្នាំ២០០៤ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងសន្និសីទកាសែតមួយដែលប្រារព្ធឡើងនៅមុខរដ្ឋសភាជាតិ បន្ទាប់ពីការប្រជុំផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា លោកនាយក រដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា លោកនឹងអនុញ្ញាតឲ្យមន្ត្រីរដ្ឋាភិបាលនិងប្រជាជនកម្ពុជាឈប់សម្រាកមួយថ្ងៃ នៅថ្ងៃដែលសាលាក្តីខ្មែរក្រហមបើកសវនាការដំបូង ។ ការប្រកាសនេះត្រូវបានធ្វើឡើង ដើម្បីជាការឆ្លើយតបទៅនឹងសំណូមពររបស់លោក ឆាំង យុ កាលពីខែកក្កដា ដើម្បីបង្កើតជា«ថ្ងៃនៃការចងចាំនិងយុត្តិធម៌» ។ *(ទស្សនាវដ្តីស្វែងរកការពិត ភាសាអង់គ្លេស លេខ៥៨ ខែតុលា ឆ្នាំ២០០៤ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

លិខិតមួយច្បាប់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្ញើទៅលោក កូហ្វី អាណាន់ ស្តីពីការយល់ព្រមរបស់រដ្ឋសភាជាតិលើសេចក្តីកម្ពុជាព្រាងច្បាប់ ដែលឯកភាពលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា អំពីការកាត់ទោសក្រោមច្បាប់កម្ពុជាចំពោះបទឧក្រិដ្ឋ ដែលប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ *(www.cambodia.gov.kh/krt/english/chrono.htm)*

## ៥ តុលា ២០០៤

សមាជិករដ្ឋសភាជាតិ៩៦រូបក្នុងចំណោមសមាជិក៩៨រូប បោះឆ្នោតយល់ព្រមចំពោះការធ្វើវិសោធនកម្មទៅលើមាត្រាចំនួន២៩ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់កាត់សេចក្តីពីបទឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មាត្រាទាំង២៩នោះរួមមានមាត្រា ២, ៣, ៩, ១០, ១១, ១៤, ១៧, ១៨, ២០, ២១, ២២, ២៣, ២៤, ២៧, ២៩, ៣១, ៣៣, ៣៤, ៣៥, ៣៦, ៣៧, ៣៩, ៤០, ៤២, ៤៣, ៤៤, ៤៥, ៤៦ និង៤៧ ។ វិសោធនកម្មពិនិត្យមើលជារួមទៅលើផ្នែកបច្ចេកទេសរបស់តុលាការពិសេសនេះ ដូចជារចនាសម្ព័ន្ធយុត្តាធិការនិងនីតិវិធី ។ *(ទស្សនាវដ្តីស្វែងរកការពិត ភាសាអង់គ្លេស លេខ៥៨ ខែតុលា ឆ្នាំ២០០៤ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

## ១៨ តុលា ២០០៤

រយៈពេលពីរសប្តាហ៍បន្ទាប់ពីធ្វើជាអធិបតីក្នុងការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង និងវិសោធនកម្មរបស់មាត្រាស្តីពីបទបញ្ញត្តិ ដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ប្រធានរដ្ឋសភា សម្តេចក្រុមព្រះនរោត្តម រណប្ញទ្ធិ បានប្រមានចោលតម្លៃរបស់សាលាក្តី ដោយមានព្រះរាជបន្ទូលថា គម្រោងថវិកានោះគួរតែចំណាយទៅលើការអភិវឌ្ឍវិស័យកសិកម្មរបស់ប្រទេសប្រសើរជាង ។ ព្រះអង្គមានព្រះបន្ទូលប្រាប់អ្នកយកព័ត៌មាននៅក្រៅរដ្ឋសភាជាតិថា «បើសិនខ្ញុំមានប្រាក់៥៥លានដុល្លារ ខ្ញុំនឹងយកប្រាក់នោះទៅអភិវឌ្ឍប្រទេសវិញ ។ វាមានប្រយោជន៍ជាងការកាត់ទោសមេដឹកនាំចាស់ជរានៃរបបខ្មែរក្រហមនេះ» ។ យុត្តិធម៌មានពីរប្រភេទ គឺយុត្តិធម៌សម្រាប់ជនរងគ្រោះ និងយុត្តិធម៌សម្រាប់ជនក្រីក្រ ។ ប្រាក់៥០លានដុល្លារ គឺច្រើនខ្លាំង

ណាស់» ។ ព្រះអង្គបានបន្ថែមថា «ជាមួយនឹងប្រាក់ទាំងនោះ តើប្រឡាយប៉ុន្មានដែលយើងអាចជីកបាន» ។ (The Cambodia Daily, ១៩ តុលា ២០០៤)

## ១៩ តុលា ២០០៤

កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ដែលអនុម័តយល់ព្រមដោយរដ្ឋសភាជាតិ នៅថ្ងៃទី៤ ខែតុលា ត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយប្រមុខរដ្ឋស្តីទី សម្តេច ជា ស៊ីម ។ (ព្រះរាជក្រមលេខ ១០០៤/០០៦)

## ២២ តុលា ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញបានអនុម័តយល់ស្រប ចំពោះច្បាប់ដែលបានធ្វើវិសោធនកម្មហើយថា មានលក្ខណៈស្របតាមរដ្ឋធម្មនុញ្ញ ។ (www.cambodia.gov.kh/krt/english/chrono.htm)

## ២៧ តុលា ២០០៤

ច្បាប់ស្តីពីការបង្កើតសាលាក្តីខ្មែរក្រហម ដែលត្រូវបានធ្វើវិសោធនកម្ម និងអនុម័តដោយរដ្ឋសភាជាតិ នៅថ្ងៃទី៥ ខែតុលា ត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយប្រមុខរដ្ឋស្តីទី សម្តេច ជា ស៊ីម ។ (ព្រះរាជក្រមលេខ ១០០៤/០០៦)

## ៨ វិច្ឆិកា ២០០៤

រាជរដ្ឋាភិបាលកម្ពុជាចេញសេចក្តីថ្លែងការណ៍មួយ ប្រកាសបញ្ចប់ការងារផ្នែកច្បាប់សម្រាប់សាលាក្តី ។ (The Cambodia Daily, ៨ វិច្ឆិកា ២០០៤)

## ១៦ វិច្ឆិកា ២០០៤

លោកឧបនាយករដ្ឋមន្ត្រី សុខ អាន ផ្ញើលិខិតមួយច្បាប់ទៅអគ្គលេខាធិការរង និងជាទីប្រឹក្សាផ្នែកច្បាប់នៃអង្គការសហប្រជាជាតិ លោក នីកូឡា មីសែល (Nicolas Michel) ដោយបានណែនាំថា ដោយអនុឡោមទៅតាមមាត្រា៣២នៃកិច្ចព្រមព្រៀង តម្រូវការផ្នែកច្បាប់នៅកម្ពុជាដើម្បីចូលជាធរមានត្រូវបានគោរពតាម ។ (www.cambodia.gov.kh/krt/english/chrono.htm)

## ៧ ធ្នូ ២០០៤

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន សម្តែងក្តីព្រួយបារម្ភពីការស្ទាក់ស្ទើរបស់អង្គការសហប្រជាជាតិក្នុងការចំណាយសម្រាប់សាលាក្តី ដែលអាចពន្យារដំណើរការនេះកាន់តែឲ្យយូរថែមទៀត ដែលអាចធ្វើឲ្យអតីតមេដឹកនាំខ្មែរក្រហមស្លាប់មុនទទួលការកាត់សេចក្តី ។ លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ក្នុងកំឡុងពិធីរំឭកខួបរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាកាលពីថ្ងៃទី២ធ្នូ ថា "ឥឡូវនេះយើងមានច្បាប់សម្រាប់កាត់ទោសខ្មែរក្រហម ប៉ុន្តែអង្គការសហប្រជាជាតិថ្លែងថាពួកគេមិនមានថវិកា ។" លោកបានបន្ថែមថា "ប្រជាជននិងខ្ញុំព្រួយបារម្ភថា អតីតមេដឹកនាំខ្មែរក្រហមនឹងស្លាប់មុនពេលកាត់ក្តី ។ នេះជាក្តីបារម្ភរបស់យើង ។ ថវិកាជាបន្ទុករបស់អង្គការសហប្រជាជាតិ ។" *(The Cambodia Daily, ៣ ធ្នូ ២០០៤)*

## ១០ ធ្នូ ២០០៤

អ្នកតំណាងឲ្យអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាបាននិយាយថា ថវិកាចុងក្រោយសម្រាប់ធ្វើការងារក្នុងសាលាក្តីរយៈពេល៣ឆ្នាំនេះ គឺត្រូវបានកំណត់ត្រឹម៥៦.២៧២លានដុល្លារសហរដ្ឋអាមេរិក បន្ទាប់មក អ្នកតំណាងបានបញ្ជាក់ថា ទីតាំងសម្រាប់សាលាក្តីប្រហែលជាត្រូវផ្លាស់ទៅទីបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ដែលទើបនឹងបានសាងសង់រួចនៅជាយក្រុង ។ អ្នកសម្របសម្រួលកិច្ចការរបស់អង្គការសហប្រជាជាតិលោក មូហាមីត សេត (Mohammed Said) បានប្រាប់អ្នកយកព័ត៌មាននៅទីស្តីការគណៈរដ្ឋមន្ត្រីថា ក្រុមការងាររបស់អង្គការសហប្រជាជាតិនឹងត្រឡប់ទៅទីក្រុងញ៉ូយ៉កវិញ ដើម្បីរាយការណ៍ពីចំនួនថវិកាថ្មីទៅកាន់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ មុនពេលដែលអង្គការអន្តរជាតិចាប់ផ្តើមធ្វើការរៃអង្គាសថវិកា ។ លោក ស៊ាន វិសុទ្ធ អគ្គលេខាធិការនៃក្រុមការងារសាលាក្តីរបស់រដ្ឋាភិបាលបាននិយាយថា កម្ពុជានឹងទទួលរ៉ាប់រងលើចំនួនទឹកប្រាក់ប្រហែល១៣លានដុល្លារសហរដ្ឋអាមេរិក ដែលជាចំនួនដ៏ច្រើនគួរឲ្យកត់សម្គាល់ជាងថវិកាចំនួន៧លានដុល្លារសហរដ្ឋអាមេរិកដែលកម្ពុជាបានស្នើ ។ ថវិកានេះគឺធ្លាក់ចុះពី៥៧លានមកត្រឹមច្រើនជាង៥៦លានដុល្លារសហរដ្ឋអាមេរិក ដែលលោក មូហាមីត សេត ហៅថា "ចំនួនដ៏តិចតួច" បើប្រៀបធៀបទៅនឹងការចំណាយរបស់សាលាក្តីអន្តរជាតិផ្សេងៗ ។ ចំពោះការសន្សំសំចៃខ្លះគឺប្រហែលជាបណ្តាលមកពីការស្នើសុំរបស់រដ្ឋាភិបាលក្នុងការផ្លាស់ប្តូរទីកន្លែងសម្រាប់សាលាក្តី ដែលពីមុនកំណត់យកមហោស្រពចតុមុខនៅទីក្រុងភ្នំពេញ និងមជ្ឈមណ្ឌលវប្បធម៌ជាតិ ។ លោក ស៊ាន វិសុទ្ធ បាននិយាយថា ទីបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទគឺមានបរិក្ខារគ្រប់គ្រាន់ ក្នុងការរ៉ាប់រងរាល់ដំណើរការនីតិវិធី ។ *(The Cambodia Daily, ១១-១២ ធ្នូ ២០០៤)*

### ១៥ ធ្នូ ២០០៤

សម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ មានព្រះរាជបន្ទូលថា ទីតាំងផ្សេងក្រៅពីទីបញ្ជាការដ្ឋានយោធា មានសារសំខាន់ក្នុងការធានាបាននូវ«បទដ្ឋានយុត្តិធម៌អន្តរជាតិមួយ...ចំពោះខ្ញុំវិញ ទីតាំងណាដែលក្រៅពីទីបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទគឺមានលក្ខណៈប្រសើរជាង» ។ *(The Cambodia Daily, ១៦ ធ្នូ ២០០៤)*

### ១៦ ធ្នូ ២០០៤

សម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ មានព្រះបន្ទូលថា កម្ពុជានិងអង្គការសហប្រជាជាតិនឹងមិនអាចចាប់ផ្ដើមដំណើរការរបស់តុលាការខ្មែរក្រហមអន្តរជាតិបានទេ ប្រសិនបើប្រទេសជប៉ុនមិនផ្ដល់ថវិកាយ៉ាងតិចពាក់កណ្ដាលនៃចំនួនទឹកប្រាក់ដែលត្រូវការ (៥៦លានដុល្លារសហរដ្ឋអាមេរិក) ។ ព្រះអង្គមានព្រះរាជបន្ទូលថា «ប្រសិនបើជប៉ុនមិនចំណាយលើថវិកាពាក់កណ្ដាល ពួកយើងនឹងមិនមានលទ្ធភាពក្នុងការចាប់ផ្ដើមសាលាក្ដីនោះទេ ។» *(Japan Today, ១៦ ធ្នូ ២០០៤)*

### ១៧ ធ្នូ ២០០៤

ប្រទេសបារាំងសន្យាថានឹងផ្ដល់ជំនួយចំនួន ៣លានយូរ៉ូ (៤លានដុល្លាសហរដ្ឋអាមេរិក) ទៅឲ្យសាលាក្ដីដែលគ្រោងទុកនេះ ។ លោក ហ្សាវីយេ ដាកូស (Xavier Darcos) រដ្ឋមន្ត្រីប្រតិភូសម្រាប់កិច្ចសហការនិងការអភិវឌ្ឍបានមានប្រសាសន៍ថា ប្រទេសបារាំងនឹងធ្វើការឧបត្ថមថវិកាចំនួន ១លានយូរ៉ូ ជារៀងរាល់ឆ្នាំសម្រាប់រយៈពេល៣ឆ្នាំនៃដំណើរការនីតិវិធី ដែលត្រូវបានប៉ាន់ស្មានទុកនោះ ។ *(AFP, ១៧ ធ្នូ ២០០៤)*

### ៨ មករា ២០០៥

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្ដីបន្ទោសចំពោះសហគមន៍អន្តរជាតិ ដែលបានផ្ដល់ជំនួយយ៉ាងលឿនដល់ប្រទេសដែលត្រូវបានបំផ្លិចបំផ្លាញដោយរលកស៊ូណាមិនៅថ្ងៃទី២៦ ខែធ្នូ ខណៈពេលដែលប្រទេសទាំងនោះព្រងើយកន្តើយចំពោះប្រទេសកម្ពុជាក្រោយរបបខ្មែរក្រហម ។ លោកនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា «ចំនួនប្រជាជនដែលស្លាប់ដោយស៊ូណាមិមានចំនួនតិចជាង១០ភាគរយ បើប្រៀបធៀបនឹងការខូចខាតនិងចំនួនមនុស្សស្លាប់នៅក្នុងរបបខ្មែរក្រហម» ។ លោកបានបន្ថែមទៀតថា «គ្មាននរណាម្នាក់ចង់យកខ្មែរក្រហមទៅកាត់ទោសជាង ហ៊ុន សែន ទេ» ។ *(សារព័ត៌មាន Kyodo, ៨ មករា ២០០៥)*

## ២៣ មករា ២០០៥

សម្តេចព្រះ នរោត្តម សីហនុ មានព្រះរាជបន្ទូលថា ការកាត់ទោសអតីតមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យមួយក្តាប់តូចគ្រាន់តែ«ជារឿងកំប្លែងនិងជាការលោកពុត»ប៉ុណ្ណោះ ។ ជាជាងការចំណាយទឹកប្រាក់ប្រមាណ ៥៦លានដុល្លារអាមេរិកដើម្បីបង្កើតតុលាការនិងការ«ជួយខបត្តម្ភក្នុងរយៈពេលបីឆ្នាំ ដែលអាចធ្វើឲ្យចៅក្រមរស់នៅក្នុងជីវភាពសម្បូរសប្បាយ» ព្រះអង្គស្នើថា វាប្រហែលជាមានភាពត្រឹមត្រូវជាង ប្រសិនយើងអាចផ្តល់ដីដែលមានដីជាតិនិងប្រព័ន្ធផ្គត់ទឹកទៅឲ្យគ្រួសាររបស់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ ព្រះអង្គបានសរសេរនៅលើគេហទំព័ររបស់ព្រះអង្គថា «សំណួររបស់ខ្ញុំគឺចង់ដឹងថា តើការផ្តន្ទាទោសមេដឹកនាំខ្មែរក្រហមដោយប្រើប្រាស់អង្គជំនុំជម្រះរបស់កម្ពុជានិងអង្គការសហប្រជាជាតិដ៏ល្បីល្បាញនេះ អាចធ្វើឲ្យខ្ញុំមានអារម្មណ៍ធូរស្រាលដែរឬទេ? ។» *(The Cambodia Daily, ២៥ មករា ២០០៥)*

## ២៧ មករា ២០០៥

សម្តេចព្រះ នរោត្តម សីហនុ ក្រើនរំឭកចំពោះលទ្ធភាពនៃការបះបោរដោយអតីតអ្នកគាំទ្រខ្មែរក្រហម ប្រសិនបើមេដឹកនាំរបស់ពួកគេត្រូវបានកាត់ទោស ដោយតុលាការដែលគាំទ្រដោយអង្គការសហប្រជាជាតិ ។ *(The Cambodia Daily, ២៨ មករា ២០០៥)*

## ២៨ មករា ២០០៥

ប្រទេសអង់គ្លេសប្រកាសផ្តល់ជំនួយ ៩៨ម៉ឺនដុល្លារសហរដ្ឋអាមេរិក ទៅឲ្យអង្គជំនុំជម្រះ ។ *(វិទ្យុអូស្ត្រាលី ABC, ២៨ មករា ២០០៥)*

## ២៩ មករា ២០០៥

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជំរុញឲ្យប្រទេសម្ចាស់ជំនួយ ប្រញាប់ប្រញាល់ផ្តល់មូលនិធិទៅឲ្យអង្គជំនុំជម្រះ មុនពេលឱកាសកាត់ទោសមេដឹកនាំខ្មែរក្រហមដែលមានវ័យចំណាស់ទាំងអស់នេះអាចបាត់បង់ទៅ ។ *(The Cambodia Daily, ៣១ មករា ២០០៥)*

## ៩ កុម្ភៈ ២០០៥

ជប៉ុនប្តេជ្ញាចិត្តថានឹងផ្តល់ថវិកា២១,៥លានដុល្លារសហរដ្ឋអាមេរិកទៅឲ្យអង្គជំនុំជម្រះ ហើយថាខ្លួននឹងប្រគល់ថវិកានេះទៅឲ្យអង្គការសហប្រជាជាតិនៅចុងខែមីនា ។ (The Cambodia Daily, ១០ កុម្ភៈ ២០០៥)

## ៧ មីនា ២០០៥

ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ដែលជាលេខាផ្ទាល់ខ្លួនរបស់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ បង្ហាញពីបំណងរបស់ព្រះអង្គក្នុងការប្តឹងរដ្ឋមន្ត្រីក្រសួងការបរទេស លោក ហោ ណាំហុង ដើម្បីស្វែងរកមូលហេតុនៃការស្លាប់របស់ព្រះមាតានិងព្រះបិតារបស់ព្រះអង្គ ប្រសិនបើពេលដែលតុលាការខ្មែរក្រហមត្រូវបានបង្កើតឡើង ។ ដោយបង្ហាញពីមន្ទិលសង្ស័យចំពោះឆន្ទៈរបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតតុលាការដែលត្រូវបានរង់ចាំយូរមកហើយនេះ ព្រះអង្គម្ចាស់ ធម្មិកោ មានព្រះរាជបន្ទូលថា ព្រះអង្គចង់ស្វែងរកយុត្តិធម៌អំពីការស្លាប់របស់ព្រះមាតានិងព្រះបិតារបស់ព្រះអង្គ គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មេថាវី និងអ្នកម្នាង ណាណែត មេថាវី ដែលជាបងស្រីរបស់ព្រះមហាក្សត្រី នរោត្តម មុនីនាថ ។ (The Cambodia Daily, ៩ មីនា ២០០៥)

## ១១ មីនា ២០០៥

ចៅក្រមស៊ើបអង្កេតរបស់តុលាការយោធាកម្ពុជានិយាយថា តាម៉ុក និង កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានចោទប្រកាន់នៅខែកុម្ភៈ ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងការធ្វើទុកបុកម្នេញលើជនជាតិបរទេសនៅក្នុងរយៈកាលនៃការគ្រប់គ្រងរបស់របបនេះពីឆ្នាំ១៩៧៥ដល់១៩៧៩ ។ (ABC Radio Australia, ១១ មីនា ២០០៥)

## ១៥ មីនា ២០០៥

រដ្ឋមន្ត្រីក្រសួងការបរទេស លោក ហោ ណាំហុង ឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍របស់ព្រះអង្គម្ចាស់ធម្មិកោ ដោយព្រមានថា លោកនឹងទាមទារសំណងជាប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ចំពោះពាក្យបណ្តឹងទាំងឡាយណាដែលប្តឹងប្រឆាំងនឹងរូបលោក នៅក្នុងតុលាការដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខ ។ ចំពោះសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ព្រះអង្គម្ចាស់ ធម្មិកោ ក្នុងការតាំងចិត្តដាក់ពាក្យប្តឹងប្រឆាំងនឹងលោករដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង លោកបានប្រាប់អ្នកសារព័ត៌មានថា អ្នកដែលមានបំណងប្តឹងលោកពីករណីនេះ ត្រូវត្រៀមប្រាក់ដើម្បីបង់ជាសំណងឲ្យហើយទៅ ។ (The Cambodia Daily, ១៧ មិនា ២០០៥)

## ២១ មីនា ២០០៥

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាលោក ឆាំង យុ បាននិយាយថា "មកទល់សព្វថ្ងៃនេះ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិមានថវិការគ្រប់ចំនួន ដើម្បីចំណាយសម្រាប់អង្គជំនុំជម្រះនៅឆ្នាំដំបូង (តុលាការមានថវិការចំនួន ៣៩លានដុល្លារហើយ ក្នុងចំនួនថវិការប៉ាន់ស្មាន ៥៦លានដុល្លារអាមេរិក) ដែលជាការចូលរួមវិភាគទានពី ប្រទេសជប៉ុន អូស្ត្រាលី ចក្រភពអង់គ្លេស និងបារាំង" ។ លោកបានអំពាវនាវសុំឲ្យមានជំនួយបន្ថែមទៀត និងការចូលរួមពីសំណាក់សហគមន៍អន្តរជាតិ ដើម្បីធ្វើឲ្យអង្គជំនុំជម្រះដែលប្រជាជនរង់ចាំជាយូរមកហើយក្លាយទៅជាការពិត ។ លោកបានថ្លែងថា "ខ្ញុំសង្ឃឹមថាសហគមន៍អន្តរជាតិនឹងចាប់ផ្តើមជួយដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្សនៅអាស៊ីខ្លាំងក្លាជាងមុន ដូចដែលខ្លួនបានធ្វើនៅទ្វីបអឺរ៉ុប និងទ្វីបអាហ្វ្រិកផងដែរ" ។ លោកបានបន្តថា "ការជួយប្រជាជនកម្ពុជាដើម្បីស្វែងរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តនៅក្នុងទឹកដីរបស់ខ្លួន គឺជាកិត្តិយសជាប្រវត្តិសាស្ត្រមួយរបស់ប្រទេសជាម្ចាស់ជំនួយ" ។ *(ទស្សនាវដ្តីស្វែងរកការពិត ភាសាអង់គ្លេស ត្រីមាសទី១ ឆ្នាំ២០០៥)*

## ២២ មីនា ២០០៥

យោងតាមលោក រូម រិត អ្នកសរសេរលិខិតឆ្លើយឆ្លងជាមួយអតីតព្រះមហាក្សត្រ នរោត្តម សីហនុ បានឲ្យដឹងថា សម្តេចព្រះ នរោត្តម សីហនុ មានព្រះរាជបន្ទូលថា ព្រះអង្គនឹងផ្តល់ប្រាក់ចំនួន ១ម៉ឺនដុល្លារជូនសព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ប្រសិនបើរដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង ប្តឹងព្រះអង្គម្ចាស់ពីបទបរិហារកេរ្តិ៍ ។ *(The Cambodia Daily, ២២ មីនា ២០០៥)*

## ២៥ មីនា ២០០៥

ប្រទេសកាណាដាប្រកាសថា ខ្លួននឹងផ្តល់ថវិការ២លានដុល្លារកាណាដា (១,៦៤លានដុល្លារសហរដ្ឋអាមេរិក) ទៅឲ្យអង្គការសហប្រជាជាតិដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយផ្តល់ ១លានដុល្លារ កាណាដាទៅលើប្រតិបត្តិការនៅឆ្នាំដំបូង និង៥សែនដុល្លារកាណាដា ក្នុងមួយឆ្នាំសម្រាប់ឆ្នាំទីពីរ និងទីបី ។ *(សេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតកាណាដាប្រចាំនៅទីក្រុងភ្នំពេញ, ២៥ មីនា ២០០៥)*

រាជរដ្ឋាភិបាលកម្ពុជាប្រកាសថា ខ្លួនអាចរួមវិភាគទានបានត្រឹមតែ១.៥លានដុល្លារសហរដ្ឋអាមេរិក ក្នុងចំនួនថវិកា១៣,៣ដុល្លារដែលបានរំពឹងទុកតែប៉ុណ្ណោះ ហើយបានអំពាវនាវសុំជំនួយពីប្រទេសដែលមានការចាប់អារម្មណ៍ ដើម្បីបំពេញលើការខ្វះខាតចំនួន១១,៨លានដុល្លារទៀត ។ ទីប្រឹក្សាជាន់ខ្ពស់របស់នាយករដ្ឋ-មន្ត្រី ហ៊ុន សែន លោក ឱម យិនទៀង មានប្រសាសន៍ថា តាមពិតប្រទេសកម្ពុជាត្រូវចូលរួមចំណែកជា

ថវិការចំនួន ៦,៧លានដុល្លារ ប្រសិនបើគិតទាំងការចំណាយទៅបញ្ហាសន្តិសុខនិងបរិវេណតុលាការ ។ (The Associated Press, ២៧ មីនា ២០០៥)

## ២៨ មីនា ២០០៥

ប្រទេសជាសមាជិករបស់អង្គការសហប្រជាជាតិសន្យាថា នឹងផ្តល់ថវិសរុបចំនួន ៣៨.៤៨លានដុល្លារ ដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដូច្នេះ អង្គជំនុំជម្រះនៅខ្វះថវិកាចំនួន ៤.៥២លានដុល្លារទៀតទើបគ្រប់គោលដៅ៤៣លានដុល្លារ ។ ប្រទេសដែលសន្យាផ្តល់ជំនួយរួមមាន ៖

| | |
|---|---|
| ជប៉ុន | ២១លាន ៦សែនដុល្លារ |
| បារាំង | ៤លាន ៨សែនដុល្លារ |
| ចក្រភពអង់គ្លេស | ២លាន ៨សែន ៧ម៉ឺនដុល្លារ |
| អូស្ត្រាលី | ២លាន ៣សែន ៥ម៉ឺនដុល្លារ |
| ហូល្លង់ | ២លានដុល្លារ |
| កាណាដា | ១លាន ៦សែន ១ម៉ឺនដុល្លារ |
| ន័រវេស | ១លានដុល្លារ |
| អាល្លឺម៉ង់ | ១លានដុល្លារ |
| ដេនម៉ាក | ៥សែន ២ម៉ឺន ៥ពាន់ដុល្លារ |
| អូទ្រីស | ៣សែន៦ ម៉ឺនដុល្លារ |
| ស៊ុីតដេន | ១សែន ៥ម៉ឺនដុល្លារ |
| សាធារណរដ្ឋកូរ៉េ | ១សែន ៥ម៉ឺនដុល្លារ |
| លុចសំបួរ | ៦ម៉ឺន ៦ពាន់ដុល្លារ ។ |

សមាជិកសភាសហរដ្ឋអាមេរិកមានប្រសាសន៍ថា អស់រយៈពេលជប់ឆ្នាំកន្លងមកនេះ សហរដ្ឋអាមេរិក "បានចំណាយថវិការអស់៧លានដុល្លារ ទៅលើថ្លៃស្រាវជ្រាវនិងប្រមូលឯកសារ ដើម្បីស៊ើបអង្កេតទៅលើឧក្រិដ្ឋកម្មនៅក្នុងប្រទេសកម្ពុជា" ហើយថា"ការជាប់គាំងផ្នែកច្បាប់ធ្វើឲ្យសហរដ្ឋអាមេរិកមិនអាចផ្តល់ថវិការបន្ថែមទៀតទៅឲ្យសាលាក្តីបានទេ" ។ (សេចក្តីប្រកាសព័ត៌មានរបស់អង្គការសហប្រជាជាតិលេខ L/3082)

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រសាសន៍ថា លោកជឿជាក់ថា ការខ្វះខាតថវិកានឹងអាចត្រូវបានបំពេញបន្ថែម ហើយថារាជរដ្ឋាភិបាលកម្ពុជាគួរតែពិចារណាសុំឲ្យស្ថាប័នឯកជន នៅក្នុងប្រទេសជួយបំពេញបន្ថែមការខ្វះខាតនេះ ។ (AFP, ២៩ មីនា ២០០៥)

## ១១ មេសា ២០០៥

រដ្ឋាភិបាលប៊ែលហ្ស៊ិកសន្យាថា នឹងផ្តល់ថវិការចំនួន១៩៣.៥០០ដុល្លារ ទៅឲ្យតុលាការខ្មែរក្រហម ដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខ។ លោក ដើរើន ខរមេន (Jeroen Cooreman) អនុប្រធានបេសកកម្មនៃស្ថានទូតប៊ែលហ្ស៊ិកប្រចាំនៅទីក្រុងបាងកក បានសរសេរនៅក្នុងអ៊ីមែលថា ប្រទេសប៊ែលហ្ស៊ិក មិនអាចប្រកាសនៅក្នុងសន្និសីទសន្យាផ្តល់ថវិការ នៅទីស្នាក់ការអង្គការសហប្រជាជាតិ កាលពីថ្ងៃ២៨ ខែមីនា បានទេ ពីព្រោះ«ការសម្រេចចិត្តជាផ្លូវការមិនទាន់ត្រូវបានសម្រេចនៅឡើយ នៅពេលមានសន្និសីទនោះ» ។

## ១៧ មេសា ២០០៥

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវទៅរដ្ឋាភិបាលដែលមានស្ថានទូតប្រចាំនៅប្រទេសកម្ពុជា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងស្ថានទូតមួយចំនួនទៀតប្រចាំនៅទីក្រុងបាំងកក ដែលបានតាមដានពីព្រឹត្តិការណ៍ខ្មែរក្រហម ក៏ដូចជាអង្គភាព និងបុគ្គលឯកជនទាំងឡាយ ឲ្យផ្តល់ឯកសារដែលខ្លួនកាន់កាប់មកឲ្យអង្គជំនុំជម្រះវិសាមញ្ញ ។ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានថ្លែងអំណរគុណដល់បណ្ឌិត ស៊្ទីវ ហេដ័រ (Steve Heder) នៃសាកលវិទ្យាល័យឡុងដុង និងលោក ដេវីដ ហក (David Hawk) អតីតមន្ត្រីនៅការិយាល័យប្រចាំការនៅកម្ពុជានៃមជ្ឈមណ្ឌលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលបានផ្តល់ឯកសារពាក់ព័ន្ធនឹងរបបខ្មែរក្រហមដោយការគិតទុកជាមុនពីការបង្កើតសាលាក្តី ។ ហើយលោកបានបង្ហាញសេចក្តីសង្ឃឹមថា អ្នកឯទៀតនឹងយកគំរូតាមនេះ ។ *(ទស្សនាវដ្ដីស្វែងរកការពិត ភាសាអង់គ្លេស លេខ៦៤ ខែមេសា ឆ្នាំ២០០៥)*

## ២១ មេសា ២០០៥

ក្រសួងការបរទេសសហរដ្ឋអាមេរិកបានធ្វើសេចក្តីថ្លែងការណ៍ថា «ដើម្បីឲ្យសហរដ្ឋអាមេរិកចូលរួមវិភាគទានដល់ដំណើរការនេះ បើតាមវិធានច្បាប់របស់សហរដ្ឋអាមេរិកចែងថា អង្គជំនុំជម្រះវិសាមញ្ញត្រូវតែអនុលោមទៅតាមបទដ្ឋានយុត្តិធម៌ ដែលទទួលស្គាល់ជាអន្តរជាតិ ។ នៅពេលដែលអង្គជំនុំជម្រះមានដំណើរការទៅមុខ យើងនឹងធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ និងក្រុមប្រទេសដែលមានការចាប់អារម្មណ៍ ដើម្បីសម្រេចឲ្យបាននូវគោលដៅនេះ» ។ *(សេចក្តីប្រកាសព័ត៌មានលេខ 2005/438, ២១ មេសា ២០០៥)*

## ២២ មេសា ២០០៥

រដ្ឋាភិបាលវៀតណាមឆ្លើយតបនឹងការស្នើសុំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី១៧ ខែមេសា ចំពោះឯកសារដែលពាក់ព័ន្ធនឹងខ្មែរក្រហមដោយថ្លែងថា «លិខិតរបស់លោកនឹងត្រូវបានផ្ញើទៅអង្គរក្សាពាក់ព័ន្ធរបស់វៀតណាម ហើយខ្ញុំជឿជាក់ថា អ្នកទាំងនោះនឹងចាប់អារម្មណ៍ចំពោះរឿងនេះ» ។

## ២៥ មេសា ២០០៥

ឆ្លើយតបនឹងការស្នើសុំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីថ្ងៃទី១៧ ខែមេសា ចំពោះឯកសារដែលពាក់ព័ន្ធនឹងរបបខ្មែរក្រហម ប្រទេសអាល្លឺម៉ង់បានផ្ញើឯកសារមកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ។

## ២៩ មេសា ២០០៥

កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចូលជាធរមាន ។ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥ អគ្គលេខាធិការអង្គការសហប្រជាជាតិបានសរសេរលិខិតមួយច្បាប់ផ្ញើជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីជម្រាបថា តម្រូវការផ្នែកច្បាប់ខាងអង្គការសហប្រជាជាតិមានគ្រប់គ្រាន់អស់ហើយ ។ យោងតាមមាត្រា៣២នៃកិច្ចព្រមព្រៀងច្បាប់នេះបានចូលជាធរមាននៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ដោយសារកាលពី ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ លោក សុខ អាន បានជូនដំណឹងដល់លោក នីកូឡា មីសេល ថាតម្រូវការផ្នែកច្បាប់របស់កម្ពុជាមានគ្រប់គ្រាន់អស់ហើយ ។ *(សេចក្តីប្រកាសព័ត៌មានរបស់ទីស្តីការគណៈរដ្ឋមន្ត្រី, ៣ ឧសភា ២០០៥)*

យោងទៅតាមរបាយការណ៍ព័ត៌មានរបស់អង្គការសហប្រជាជាតិ ការសន្យានិងវិភាគទានទាំងឡាយមានគ្រប់គ្រាន់អស់ហើយនាពេលបច្ចុប្បន្ននេះ ក្នុងការផ្តល់ប្រាក់ខែដល់បុគ្គលិកសម្រាប់អង្គជំនុំជម្រះទាំងពីរថ្នាក់នេះ ។ *(មជ្ឈមណ្ឌលសារព័ត៌មានអង្គការសហប្រជាជាតិ, ២៩ មេសា ២០០៥)*

គណកម្មាការសហគមន៍អឺរ៉ុបសន្យាផ្តល់ថវិការចំនួន១លាន៣សែនដុល្លារសហរដ្ឋអាមេរិក ដល់សាលាក្តីកាត់ទោសខ្មែរក្រហម ។ *(AFP, ២៩ មេសា ២០០៥)*

## ៣០ មេសា ២០០៥

កម្ពុជាស្វាគមន៍ចំពោះការប្រកាសរបស់អង្គការសហប្រជាជាតិ ដែលថាមានថវិកាគ្រប់គ្រាន់អស់ហើយ ដើម្បីបង្កើតសាលាក្តី ។ *(ABC News Online, ៣០ មេសា ២០០៥)*

## ៦ ឧសភា ២០០៥

ប្រទេសបារាំងប្រកាសថានឹងផ្តល់ថវិកាចំនួន ១លានពាន់សែនដុល្លារបន្ថែមនៅឆ្នាំ២០០៥ សម្រាប់ដំណើរការកាត់ទោសក្នុងឆ្នាំ២០០៦ ។ យោងតាមសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេសបារាំងបានឲ្យដឹងថា "ប្រទេសបារាំងធ្វើបែបនេះ ដើម្បីលើកទឹកចិត្តដល់ប្រទេសជាដៃគូរបស់ខ្លួន ឲ្យបន្ថែមកិច្ចខិតខំប្រឹងប្រែង ដើម្បីឲ្យមានថវិកាគ្រប់គ្រាន់ សម្រាប់ចាប់ផ្តើមនីតិវិធីរបស់តុលាការដែលមានរយៈពេល៣ឆ្នាំ" ។ *(The Cambodia Daily, ៧-៨ ឧសភា ២០០៥)*

## ៩ ឧសភា ២០០៥

ជាការឆ្លើយតបទៅនឹងការអំពាវនាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី១៧ ខែមេសា ទាក់ទងនឹងឯកសារដែលពាក់ព័ន្ធជាមួយរបបខ្មែរក្រហម ប្រទេសអង់គ្លេសផ្ញើរឯកសារជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ។

## ១៩ ឧសភា ២០០៥

សហរដ្ឋអាមេរិកនិយាយថា ខ្លួននឹងមិនចូលរួមក្នុងសាលាក្តីខ្មែរក្រហមទេ បើសិនជាសាលាក្តីមិនអាចបង្ហាញពីភាពយុត្តិធម៌ និងចាកផុតពីឥទ្ធិពល និងការគ្រប់គ្រងពីផ្នែកនយោបាយ ។ លោក ព្យែរ រីឆាតប្រូស្ពើ (Pierre Richard Prosper) ឯកអគ្គរដ្ឋទូតអាមេរិកទទួលបន្ទុកផ្នែកឧក្រិដ្ឋកម្មសង្គ្រាម បានប្រាប់អ្នកយកព័ត៌មាននៅអំឡុងទស្សនកិច្ចរយៈពេលពីរថ្ងៃរបស់លោកមកកាន់ទីក្រុងភ្នំពេញថា "សហរដ្ឋអាមេរិកចង់ស្ថិតនៅក្នុងជំហរមួយ ដែលយើងអាចគាំទ្រទាំងផ្នែកនយោបាយនិងហិរញ្ញវត្ថុ" ។ លោកនិយាយថា "អ្វីដែលយើងចង់ចៀសវាងនោះ គឺបញ្ហាមួយចំនួនដែលកើតឡើងជាធម្មតាក្នុងប្រព័ន្ធតុលាការកម្ពុជា ហើយដែលនឹងត្រូវបញ្ជូនមកសាលាក្តីខ្មែរក្រហម" ។ លោកបានបន្ថែមទៀតថា "សាលាក្តីត្រូវតែចាកផុតពីអំពើពុករលួយ/ពីការគ្រប់គ្រង ឬឥទ្ធិពលផ្នែកនយោបាយ និងត្រូវតែមានតម្លាភាព" ។ *(Reuters ១៩ ឧសភា ២០០៥)*

## ២០ ឧសភា ២០០៥

ប្រជាជនខ្មែរប្រមាណ១ពាន់នាក់ បានមកជួបជុំគ្នានៅវាលពិឃាតជើងឯក ដើម្បីរំឭកដល់ជនរងគ្រោះដែលបានបាត់បង់ជីវិតពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ខណៈពេលដែលមានការអំពាវនាវឲ្យមានការបង្កើតសាលាក្តី ដើម្បីនាំយកអតីតមេដឹកនាំខ្មែរក្រហមមកប្រឈមមុខនឹងតុលាការឲ្យបានឆាប់ ។ ញាតិសណ្តាន ជនរងគ្រោះ សិស្ស និស្សិត មន្ត្រីរាជការ និងព្រះសង្ឃបានមកចូលរួមក្នុងពិធីនេះ ដែលត្រូវបានប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីរំឭកដល់របបកសិកម្មសមូហភាវូបនីយកម្មម៉ៅនិយមរបស់ ប៉ុល ពត នៅវាលពិឃាតជើងឯកប៉ែកនិរតីនៃទីក្រុងភ្នំពេញ ។ *(AFP, ២០ ឧសភា ២០០៥)*

## ៣០ ឧសភា ២០០៥

លោកឧបនាយករដ្ឋមន្ត្រី សុខ អាន បានអំពាវនាវដល់អ្នកការទូតបរទេសនៅទីក្រុងភ្នំពេញឲ្យជួយកម្ពុជាបំពេញចំណែកថវិការបស់ខ្លួនចំនួន (១៣,៣លានដុល្លារ) នៃចំនួនថវិការសរុបរបស់សាលាក្តី ដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ លោក ស៊ាន វិសុទ្ធ លេខាធិការនៃក្រុមការងារសាលាក្តីរបស់រាជរដ្ឋាភិបាលកម្ពុជាបានថ្លែងថា "ប្រទេសឥណ្ឌា សិង្ហបូរី និងថៃ បានបង្ហាញពីចំណាប់អារម្មណ៍ក្នុងការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ។ លោកបានបន្ថែមទៀតថា សហព័ន្ធអឺរ៉ុបកំពុងរារែកចិត្តថា តើត្រូវផ្តល់ប្រាក់១,៣លានដុល្លារដែលបានសន្យា ទៅឲ្យអង្គការសហប្រជាជាតិឬរដ្ឋាភិបាលកម្ពុជា" ។ *(វិទ្យុសម្លេងសហរដ្ឋអាមេរិក, ភ្នំពេញ, ៣១ ឧសភា ២០០៥)*

## ២ មិថុនា ២០០៥

អង្គទូតនិងអ្នកតំណាងមកពីស្ថានទូតចំនួន១៣នៅទីក្រុងភ្នំពេញ បានធ្វើទស្សនកិច្ចទៅកាន់ទីតាំងអង្គជំនុំជម្រះវិសាមញ្ញដែលមានស្នាក់ការនៅភូមិកំបូល ។ *(www.cambodia.gov.kh/krt/english/chrono.htm)*

## ៥ មិថុនា ២០០៥

អ្នកជំនួញកម្ពុជាសំខាន់ៗជាច្រើននាក់និយាយថា ពួកគេនឹងផ្តល់ប្រាក់ដើម្បីបំពេញលើថវិកាដែលរដ្ឋាភិបាលនៅខ្វះចំនួន១១.៨លានដុល្លារសម្រាប់សាលាក្តីខ្មែរក្រហម ប្រសិនបើរដ្ឋាភិបាលធ្វើការស្នើសុំជាផ្លូវការ ។ លោក សុខ គង់ អគ្គនាយកក្រុមហ៊ុនសូគីម៉ិចបានមានប្រសាសន៍ថា "ខ្ញុំនឹងបរិច្ចាគថវិកាសម្រាប់សាលាក្តី ដើម្បីជួយរដ្ឋាភិបាល ។" លោកបានបន្ថែមទៀតថា លោកជឿថា លោកមិនមែនជាអ្នកជំនួញតែម្នាក់ដែលត្រៀមខ្លួនក្នុងការជួយបំពេញការខ្វះខាតនេះទេ ។ លោក គិត ម៉េង ប្រធានក្រុមហ៊ុនរូយ៉ាល់គ្រុបបាននិយាយដូចគ្នាដែរថា "បើសម្តេច ហ៊ុន សែន មានគោលនយោបាយ ឬធ្វើការស្នើសុំជាផ្លូវការយើងនឹងមិនបដិសេធឡើយ" ។ *(The Cambodia Daily, ៦ មិថុនា ២០០៥)*

## ៦ មិថុនា ២០០៥

អ្នកនាំពាក្យគណបក្ស សម រង្ស៊ី លោក អ៊ឹង ប៊ុនអាង បានស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជារៀបចំពិធីរៃអង្គាសប្រាក់ថ្នាក់ជាតិមួយ ដើម្បីបំពេញថវិកាខ្វះខាតរបស់រដ្ឋាភិបាល ដែលរដ្ឋាភិបាលបាននិយាយថាជាឧប

សក្តុចុងក្រោយនៃការបង្កើតសាលាក្តី ដែលប្រជាជនបានរង់ចាំអស់ពេលជាយូរមកហើយ ។ លោក អ៊ីង ប៊ុនអាង បានបន្ថែមថា «វាហាក់ដូចជាអ្នកគ្រប់គ្នាបានចូលរួមផ្តល់ថវិការសម្រាប់សាលាក្តីខ្មែរក្រហម លើកលែងតែប្រជាជនខ្មែរនៅទីនេះនិងនៅក្រៅប្រទេស» ។ *(The Cambodia Daily, ៧ មិថុនា ២០០៥)*

## ៧ មិថុនា ២០០៥

នួន ជា បានទទួលស្គាល់ថា សុខភាពរបស់គាត់កំពុងចុះទ្រុឌទ្រោម ហើយសម្ពាធឈាមខ្ពស់កំពុងបង្កបញ្ហាដល់គាត់ ។ ប៉ុន្តែគាត់និយាយថា គាត់កំពុងព្យាយាមថែរក្សាសុខភាព ក្នុងករណីដែលគាត់ត្រូវតុលាការកោះហៅឲ្យទៅបង្ហាញខ្លួននៅចំពោះមុខសាលាក្តីខ្មែរក្រហម ដែលជាប់គាំងជាយូរមកហើយនោះ ។ គាត់បានថ្លែងថា «ខ្ញុំកំពុងថែរក្សាខ្លួននិងសុខភាពរបស់ខ្ញុំ ពីព្រោះខ្ញុំកំពុងត្រៀមខ្លួនទៅកាន់តុលាការ ប៉ុន្តែខ្ញុំមិនដឹងថាខ្ញុំអាចទ្រាំទ្រដល់ពេលណានោះទេ» ។ *(The Cambodia Daily, ៨ មិថុនា ២០០៥)*

## ៨ មិថុនា ២០០៥

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបដិសេធសំណើរៃអង្គាសប្រាក់ថ្នាក់ជាតិ ដើម្បីជួយបំពេញចន្លោះខ្វះខាតចំនួន១១.៨លានដុល្លាររបស់រដ្ឋាភិបាល សម្រាប់ការបង្កើតសាលាក្តីខ្មែរក្រហម ។ ប្រការនេះធ្វើឲ្យអ្នកអង្កេតការមួយចំនួនជឿថា អាចបង្កការសង្ស័យចំពោះការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការបង្កើតសាលាក្តីដែលខ្លួនរង់ចាំអស់រយៈពេលជាយូរនេះ ។ ឆ្លើយតបទៅនឹងការស្នើរសុំឲ្យមានការរៃអង្គាសប្រាក់សម្រាប់សាលាក្តីខ្មែរក្រហម ពីការបរិច្ចាគរបស់ប្រជាជនខ្មែរក្នុងប្រទេស លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា «ខ្ញុំគិតថាសំណើបែបនេះមិនអាចទទួលយកបានទេ ។ ប្រជាជនខ្មែររកប្រាក់គ្រាន់តែចិញ្ចឹមជីវិតប៉ុណ្ណោះ» ។ លោក ឱម យិនទៀង សមាជិកក្រុមការងារសាលាក្តីខ្មែរក្រហមរបស់រដ្ឋាភិបាលបាននិយាយបន្តថា នឹងមិនមានការអំពាវនាវទៅអ្នកជំនួញធំៗ ឬអ្នកដទៃទៀត ដើម្បីឲ្យគេជួយនោះទេ ។ *(The Cambodia Daily, ៩ មិថុនា ២០០៥)*

## ១០ មិថុនា ២០០៥

ក្រសួងការបរទេសជប៉ុននិយាយថា ប្រទេសជប៉ុនមិនអាចផ្តល់ហិរញ្ញវត្ថុដោយផ្ទាល់ ដើម្បីបំពេញការខ្វះខាតថវិការខ្វះខាតរបស់កម្ពុជាចំនួន១១,៨លានដុល្លារនោះបានទេ ប៉ុន្តែជប៉ុនកំពុងសិក្សាពីលទ្ធភាពនៃការបង្កើតមូលនិធិតាមរយៈជំនួយទ្វេភាគីរបស់ជប៉ុនមកកម្ពុជា ។ លោក ហាតស៊ុយហ៊ិ តាកា ស៊ីម៉ា (Hatsuhisa

Taka shima) បានប្រាប់អ្នកយកព័ត៌មាននៅក្នុងសន្និសីទកាសែតមួយថា «រដ្ឋាភិបាលជប៉ុនតាមរយៈរដ្ឋមន្ត្រីក្រសួងការបរទេស (Nobutaka Machimura) ចង់ឃើញសាលាក្តីខ្មែរក្រហមចាប់ផ្តើមដំណើរការឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។ «ដើម្បីអាចធ្វើដូច្នេះបានរដ្ឋាភិបាលជប៉ុនស្ម័គ្រចិត្តពិភាក្សាដោយលម្អិតអំពីវិធីដែលអាចឲ្យជប៉ុនមានមធ្យោបាយផ្តល់ហិរញ្ញវត្ថុ តាមរយៈជំនួយទ្វេភាគីរវាងកម្ពុជា និងជប៉ុន» ។ *(The Cambodia Daily, ១១-១២ មិថុនា ២០០៥)*

## ២១ មិថុនា ២០០៥

រដ្ឋមន្ត្រីក្រសួងការបរទេស លោក ហោ ណាំហុង ថ្លែងថា ឧបសគ្គមួយទៀតនៃការបង្កើតសាលាក្តីខ្មែរក្រហមត្រូវបានដោះស្រាយដោយនឹងសេចក្តីប្រកាស ដែលថាកម្ពុជានឹងប្រើប្រាស់មូលនិធិពិសេសមួយដែលបង្កើតឡើងដោយរដ្ឋាភិបាលជប៉ុន ដើម្បីចំណាយលើចំណែកដែលនៅសល់នៃថវិកាក្នុងការបង្កើតសាលាក្តីខ្មែរក្រហម ។ លោករដ្ឋមន្ត្រីបានបន្ថែមថា «រដ្ឋាភិបាលជប៉ុនបានផ្តល់ប្រាក់រួចហើយ ។ យើងនឹងប្រើប្រាស់ថវិកានេះ ដូច្នេះយើងសង្ឃឹមថាសាលាក្តីខ្មែរក្រហមអាចដំណើរការបានក្នុងពេលឆាប់ៗនេះ» ។ *(The Cambodia Daily, ២២ មិថុនា ២០០៥)*

## ២២ មិថុនា ២០០៥

សេចក្តីប្រកាសរបស់លោក ហោ ណាំហុង ដែលថាកម្ពុជានឹងប្រើប្រាស់មូលនិធិពិសេសមួយដែលបង្កើតឡើងដោយរដ្ឋាភិបាលជប៉ុន ដើម្បីចំណាយលើចំណែកដែលនៅសល់នៃថវិកាសាលាក្តីខ្មែរក្រហម បានធ្វើឲ្យស្ថានទូតជប៉ុននៅទីក្រុងភ្នំពេញមានភាពភ្ញាក់ផ្អើល ។ មន្ត្រីកិច្ចការនយោបាយរបស់ស្ថានទូតជប៉ុន លោក ហ្វូមីអូ ហ្គូតុ (Fumio Goto) មានប្រសាសន៍ថាកម្មវិធីជំនួយទ្វេភាគីរបស់ជប៉ុនមិនអាចបង្គ្រប់ថវិកាខ្វះខាតទាំងអស់របស់កម្ពុជាបានទេ ហើយលោកបានស្នើសុំឲ្យប្រទេសដទៃរួមចំណែកផងដែរ ។ លោកបានបន្ថែមថា «ដោយសារមិនមែនមានតែជប៉ុនទេដែលជួយសាលាក្តីខ្មែរក្រហម ដូច្នេះយើងអាចយល់បានថា ឥឡូវរាជរដ្ឋាភិបាលកម្ពុជាបានត្រៀមខ្លួនរួចហើយ ដូច្នេះសូមអំពាវនាវដល់ប្រទេសផ្តល់ជំនួយទាំងអស់ដើម្បីជួយរួមចំណែកដល់កម្ពុជាដែលត្រូវចំណាយផង» ។ *(វិទ្យុសម្លេងសហរដ្ឋអាមេរិក ២២ មិថុនា ២០០៥)*

## ២៧ មិថុនា ២០០៥

ប្រទេសអាល្លឺម៉ង់ជំរុញឲ្យសាលាក្តីខ្មែរក្រហមខិតទៅរកការចាប់ផ្តើម ដោយប្រកាសបរិច្ចាគថវិកាចំនួន ១,៩លានដុល្លារបន្ថែមទៀត សម្រាប់ថវិកាចំណាយសរុប ៥៦,៣លានដុល្លាររបស់សាលាក្តី ។ *(The Cambodia Daily, ២៨ មិថុនា ២០០៥)*

## ៣០ មិថុនា ២០០៥

អ្នកការទូតមួយរូបដែលនិយាយក្នុងលក្ខខណ្ឌសុំមិនបញ្ចេញឈ្មោះបានថ្លែងថា អង្គការសហប្រជាជាតិអនុម័តយល់ព្រមយកអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទនៅជាយក្រុងភ្នំពេញ ធ្វើជាទីតាំងសាលាក្តីខ្មែរក្រហម ។ការសម្រេចចិត្តនេះត្រូវបានធ្វើឡើងនៅក្នុងការប្រជុំជាឯកជនមួយ នៅទីក្រុងញូវយ៉កកាលពីថ្ងៃទី៣០ ខែមិថុនា រវាងអង្គការសហប្រជាជាតិ និងអ្នកតំណាងមកពីប្រទេសដែលជាប់ពាក់ព័ន្ធជាមួយនឹងសាលាក្តីនេះ ។ *(The Cambodia Daily, ២០ កក្កដា ២០០៥)*

## ៣០ មិថុនា ២០០៥

អង្គការសហប្រជាជាតិអំពាវនាវឲ្យប្រទេសជាសមាជិក ប្រគល់បញ្ជីឈ្មោះចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិ ដែលប្រទេសទាំងនោះចង់ឲ្យតែងតាំងសម្រាប់សាលាក្តីខ្មែរក្រហម ។ លេខាធិការដ្ឋានអង្គការសហប្រជាជាតិបានផ្ញើលិខិតទៅប្រទេសជាសមាជិកនៅថ្ងៃទី៣០ ខែមិថុនា ជាមួយការតែងតាំងសម្រាប់តំណែងសរុប៩ ពីសហគមន៍អន្តរជាតិ ដែលត្រូវប្រគល់ត្រឹមថ្ងៃទី២៩ ខែសីហា ។ លោក នីកូឡា មីសែល Nicolas Michel) អគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់បានសរសេរថា “តាងនាមឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ខ្ញុំមានកិត្តិយសស្នើសុំឲ្យរដ្ឋាភិបាលស្នើឈ្មោះបុគ្គលដែលលោកអគ្គលេខាធិការនឹងជ្រើសរើសដើម្បីធ្វើការតែងតាំង ។ លិខិតនោះបានថែងថា មន្ត្រីតុលាការអន្តរជាតិនឹងទទួលបានប្រាក់បៀវត្សរ៍ចំនួន ១២៩,៤០០ដុល្លារក្នុងមួយឆ្នាំ ដោយគណនាទៅតាមរយៈពេលដែលមន្ត្រីទាំងនោះធ្វើការងារជាក់ស្តែង ។ មន្ត្រីទាំងនោះនឹងចាប់ ផ្តើមបំពេញការងារនៅពេលផ្សេងគ្នា និងបម្រើការងារក្នុងរយៈពេលផ្សេងគ្នា អាស្រ័យលើដំណាក់កាលនីមួយៗ ដូចជាដំណាក់កាលស៊ើបអង្កេតការកាត់ទោស និងការប្តឹងឧទ្ធរណ៍ ។ *(The Cambodia Daily, ២០ កក្កដា ២០០៥)*

## ៣០ មិថុនា ២០០៥

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានស្នើឲ្យរដ្ឋាភិបាលនៃប្រទេសក្នុងសមាគមន៍អាស៊ានចូលរួមបន្ថែមទៀតនៅក្នុងដំណើរការសាលាក្តីខ្មែរក្រហម (ដោយផ្តល់ជំនួយដែលត្រូវការចាំបាច់ដូចជាជំនួយបច្ចេកទេសផ្តល់ឯកសារដែលពាក់ព័ន្ធនឹងខ្មែរក្រហមទៅសាលាក្តី) ការផ្តល់ប្រឹក្សា (ជួយដល់ប្រជាជនដែលរងការឈឺចាប់ដោយសារជំងឺបាក់ស្បាត) កុំព្យូទ័រ មធ្យោបាយដឹកជញ្ជូន (រថយន្តដឹកអ្នកដំណើរធំៗ ឬរថយន្តក្រុងតូចៗសម្រាប់ដឹកប្រជាជនពីជនបទមកចូលរួមការកាត់ក្តីនៅទីក្រុង) និងវិទ្យុ ។ *(ស្វែងរកការពិត, ភាសាអង់គ្លេស, ត្រីមាសទី២, ឆ្នាំ២០០៥)*

## ១៤ កក្កដា ២០០៥

មន្ត្រីរដ្ឋាភិបាលមួយរូបបាននិយាយនៅក្នុងសន្និសីទស្តីពីសាលាក្តីថា រដ្ឋាភិបាលនៅកំពុងរង់ចាំជំនួយអន្តរជាតិ ដើម្បីបង្គ្រប់ថវិកាជាចំណែករបស់កម្ពុជាសម្រាប់សាលាក្តីខ្មែរក្រហម ដែលនៅខ្វះ ១១.៨លានដុល្លារទៀត និងកំពុងរង់ចាំឲ្យអង្គការសហប្រជាជាតិផ្ញើការតែងតាំងអនុប្រធានសម្របសម្រួល មុនពេលបោះជំហានទៅមុខទៀត ។ លោក ស៊ាន វិសុទ្ធ លេខាធិការនៃក្រុមការងារសាលាក្តីខ្មែរក្រហមរបស់រដ្ឋាភិបាលបាននិយាយថា "ពេលណាយើងទទួលបានព័ត៌មានពីអង្គការសហប្រជាជាតិអំពីអ្នកដែលនឹងមកកាន់តំណែងជាអនុប្រធានផ្នែកសម្របសម្រួលពេលនោះកម្ពុជានឹងស្វែងរកប្រធានផ្នែកសម្របសម្រួលរបស់ខ្លួន ។ យើងកំពុងរង់ចាំអង្គការសហប្រជាជាតិ" ។ អង្គការសហប្រជាជាតិបានប្រកាសជ្រើសរើសអនុប្រធានផ្នែកសម្របសម្រួលនៅខែមេសា ។ ការដាក់ពាក្យផុតកំណត់នៅថ្ងៃទី៨ ខែឧសភា ។ យោងតាមមន្ត្រីទាំងនោះ អង្គការសហប្រជាជាតិបានទទួលពាក្យសុំជាង១០០ច្បាប់ ។ អគ្គរាជទូត ជប៉ុន ហ្វូមីអាគី តាកាហាស៊ី (Fumiaki Takahashi) បានមានប្រសាសន៍នៅឯសន្និសីទដែលរៀបចំឡើងដោយសាកលវិទ្យាល័យកម្ពុជាថា វាជាដំណាក់កាលចុងក្រោយក្នុងការសម្រេចថា អ្នកណានឹងកាន់មុខដំណែងនេះ ។ *(The Cambodia Daily, ១៥ កក្កដា ២០០៥)*

## ២៥ កក្កដា ២០០៥

*លោក អ៊ាន ភាសិន* (Ian Pearson) រដ្ឋមន្ត្រីការបរទេសសម្រាប់កិច្ចការពាណិជ្ជកម្មរបស់អង់គ្លេសបាននិយាយបន្ទាប់ពីជំនួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានពិភាក្សាពីសាលាក្តីថា "អង់គ្លេសនឹងផ្តល់ថវិកាប្រមាណ២,៦លានដុល្លារដល់សាលាក្តីខ្មែរក្រហមដែលបានរង់ចាំអស់រយៈពេលយ៉ាងយូរនោះ ។ យើងបាននិយាយហើយថា យើងប្តេជ្ញាផ្តល់ថវិការ២,៦លានដុល្លារសម្រាប់រយៈពេល៣ឆ្នាំខាងមុខទៅឲ្យភាគីអន្តរជាតិរបស់សាលាក្តី" ។ *(The Cambodia Daily, ២៦ កក្កដា ២០០៥)*

## ១ សីហា ២០០៥

*ហារុហិស្សា ហាន់ដា* (Haruhisa Handa) អ្នកបរិច្ចាគ មេដឹកនាំសាសនា អ្នកជំនាញពាណិជ្ជកម្ម និងជាអ្នកនិពន្ធដែលមានឈ្មោះថា តូស្សុ ហ្វុកាមី (Toshu Fukami) បានប្រកាសផ្តល់ថវិការចំនួន ១,៣លានដុល្លារ សម្រាប់សំណង់និងការសាងសង់វិមានរំឭកវិញ្ញាណក្ខ័ន្ធដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ។ លោកបាននិយាយថា ហារុហិស្សា ហាន់ដា ដែលជាស្ថាបនិកសមាគមកីឡាកូនហ្គោលជនពិការជប៉ុននឹងផ្តល់មូលនិធិ ៣

សែនដុល្លារ ចំណែកឯអង្គការសុខុមាលភាពរបស់លោកឈ្មោះ វើល មេត (World Mate) នឹងចេញចំណាយថវិកាដែលនៅសល់ ។ អ្នកដែលនៅរស់ពីរបបនេះនឹងត្រូវបានហៅឲ្យទៅដាក់ពាក្យសុំថវិកាពីមូលនិធិនេះ ដែលមានគោលបំណងផ្តល់ប្រាក់ ១០០ដុល្លារក្នុងមួយគ្រួសារសម្រាប់គ្រួសារចំនួន១ម៉ឺន ។ ហារុហិសា្ន ហាន់ដាបាននិយាយថា "បើខ្ញុំទទួលប្រាក់បរិច្ចាគច្រើនដាងនេះ ខ្ញុំអាចផ្តល់ប្រាក់ដល់ប្រជាជនច្រើនដាងនេះដែរ" ។ *(The Cambodia Daily, ៧ សីហា ២០០៥)*

## ៨ សីហា ២០០៥

"មុនរយៈពេលមួយខែ ក្នុងការបញ្ចប់ដំណើរការជ្រើសរើសតាំងចៅក្រមនិងព្រះរាជអាជ្ញា សម្រាប់អង្គជំនុំជម្រះវិសាមញ្ញថ្មី អង្គការលើកលែងទោសអន្តរជាតិ បានស្នើឲ្យគ្រប់ប្រទេសទាំងអស់ ធ្វើការតែងតាំងបេក្ខជន ដែលមានសមត្ថភាពខ្ពស់បំផុតទៅអង្គជំនុំជម្រះវិសាមញ្ញ ។ ដោយសារតែភាពទន់ខ្សោយខ្លាំងនៅក្នុងប្រព័ន្ធតុលាការកម្ពុជា អង្គការលើកលែងទោសអន្តរជាតិ មានការខកចិត្តចំពោះការសម្រេចតែងតាំងចៅក្រមកម្ពុជាភាគច្រើន ដើម្បីបម្រើការងារក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ ចៅក្រម១១រូប ក្នុងចំណោម១៩រូប និងសហព្រះរាជអាជ្ញាមួយរូបក្នុងចំណោម២រូបជាជនជាតិខ្មែរ ។ អង្គការលើកលែងទោសអន្តរជាតិយល់ឃើញថាប្រព័ន្ធតុលាការកម្ពុជានៅតែមានភាពទន់ខ្សោយ ហើយប្រឈមនឹងសម្ពាធនយោបាយ ជាពិសេសក្នុងករណីសំខាន់ៗ ។ នាពេលបច្ចុប្បន្ននេះ វាមិនអាចធានាថាសាលាក្តីនឹងប្រព្រឹត្តទៅតាមច្បាប់អន្តរជាតិ និងស្តង់ដារយុត្តិធម៌បានទេ" ។ *(អង្គការលើកលែងទោសអន្តរជាតិ, ៨ សីហា ២០០៥, News Service No. 211, AI Index: ASA 23/004/2005 Public)*

## ១៥ សីហា ២០០៥

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា បញ្ហាក្នុងការបង្កើតសាលាក្តីខ្មែរក្រហមកំពុងតែធ្វើឲ្យលោកឈឺក្បាល ហើយព្រមានថា សាលាក្តីនេះនឹងមិនកើតមានទេ ប្រសិនបើសហគមន៍អន្តរជាតិមិនអាចបង្គ្រប់ចំណែកថវិការបស់រដ្ឋាភិបាលសម្រាប់សាលាក្តី ។ *(The Cambodia Daily, ១៦ សីហា ២០០៥)*

## ២៥ សីហា ២០០៥

អង្គការសហប្រជាជាតិប្រកាសថា លោកស្រី មីសែល លី (Michelle Lee) មកពីប្រទេសចិន គឺជាអ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិ នៅក្នុងសាលាក្តីខ្មែរក្រហម ។ ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០០៥ លោកស្រីនឹងបម្រើការជាអនុប្រធានការិយាល័យរដ្ឋបាលតំណាងឲ្យភាគីអន្តរជាតិ ។ លោកស្រីបានចូលបម្រើការងារនៅអង្គការសហប្រជាជាតិនៅឆ្នាំ១៩៧៨ ហើយថ្មីៗនេះ លោកស្រីទទួលខុសត្រូវសេវាគាំទ្រកិច្ចការរដ្ឋបាលនៅឯតុលាការប្រល័យពូជសាសន៍សម្រាប់ប្រទេសរ៉ាវ៉ាន់ដា ក្នុងទីក្រុងអារូសា (Arusha)

ប្រទេសតង់ហ្សានី តាំងពីខែកក្កដា ឆ្នាំ២០០៣ ។ ពីមុនលោកស្រីជាប្រធានផ្នែករដ្ឋបាលនៅក្នុងគណៈកម្មការសង្គម និងសេដ្ឋកិច្ចតំបន់អាស៊ីនិងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិនៅទីក្រុងបាងកក ពីខែកុម្ភៈ ឆ្នាំ ២០០១ ដល់ខែកក្កដា ឆ្នាំ២០០៣ ។ (AP, ២៦ សីហា ២០០៥)

## ២៩ សីហា ២០០៥

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្វាគមន៍ចំពោះការតែងតាំង លោកស្រី មីសែល លី ជាអ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិ សម្រាប់ការខិតខំប្រឹងប្រែងរបស់អង្គការសហប្រជាជាតិ និងកម្ពុជា ក្នុងការបង្កើតសាលាក្តីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រាប់អ្នកយកព័ត៌មានថា «យើងស្វាគមន៍ចំពោះជំហានទាំងអស់របស់អង្គការសហប្រជាជាតិ ។ យើងក៏ស្វាគមន៍ចំពោះការតែងតាំងបុគ្គលិកណាមួយរបស់អង្គការសហប្រជាជាតិដែរ ។ លោកបានបន្ថែមថា អង្គការសហប្រជាជាតិមានបទបញ្ញត្តិរបស់ខ្លួន គឺថានរណាម្នាក់ដែលបម្រើការងារក្នុងអង្គការនេះត្រូវតែបម្រើផលប្រយោជន៍របស់អង្គការសហប្រជាជាតិ ។ (Kyodo, ២៩ សីហា ២០០៥)

## ២០ កញ្ញា ២០០៥

ប្រធានាធិបតីបារាំង ហ្សាក់ ស៊ីរ៉ាក់ (Jacques Chirac) ជួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីពិភាក្សាគ្នាពីសហប្រតិបត្តិការនិងកិច្ចខិតខំប្រឹងប្រែងទ្វេភាគី ក្នុងការយកមេដឹកនាំនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហមដែលនៅរស់មកកាត់ទោស ។ (ABC Radio Australia, ២០ កញ្ញា ២០០៥)

## ២៣ កញ្ញា ២០០៥

ឯកអគ្គរដ្ឋទូតថ្មីរបស់សហរដ្ឋអាមេរិកប្រចាំនៅកម្ពុជានិយាយថា វាជាពេលវេលាដែលត្រូវនាំអតីតមេដឹកនាំខ្មែរក្រហមទាំងនោះមកកាត់ទោស ។ លោកមានប្រសាសន៍ទៀតថា «សាលាក្តីនេះគឺជាសាលាក្តីមួយយ៉ាងល្អពិតប្រាកដ ។ ប្រសិនបើសាលាក្តីធានាបាននូវបទដ្ឋានអន្តរជាតិរដ្ឋាភិបាលអាមេរិកនឹងគាំទ្រសាលាក្តីនេះ ។ អ្វីដែលយើងត្រូវការនោះគឺការកាត់ក្តីពិតប្រាកដ មិនមែនជាការកាត់ទោសក្លែងបន្លំនោះទេ» ។ (Kyodo, ២៣ កញ្ញា ២០០៥)

## ៧ តុលា ២០០៥

ប្រទេសឥណ្ឌាផ្តល់ថវិការចំនួន១លានដុល្លារ មកឲ្យភាគីកម្ពុជាសម្រាប់ការបង្កើតតុលាការខ្មែរក្រហម ។ (www.hindu.com/2005/10/08/stories/2005100803181300.htm)

## ២៥ តុលា ២០០៥

អតីតមេបញ្ជាការខ្មែរក្រហម ឈូក រិន ដែលរត់គេចខ្លួន ត្រូវបានចាប់ខ្លួននៅជិតព្រំដែនថៃក្នុងខេត្តឧត្តរមានជ័យ ។ ការចាប់ខ្លួននេះធ្វើឡើងតាមសំណូមពររបស់ប្រធានាធិបតីបារាំង លោក ហ្សាក់ ស៊ីរ៉ាក់ ក្នុងអំឡុងជំនួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី២១ ខែកញ្ញា នៅទីក្រុងប៉ារីស ។ ឈូក រិន បានគេចខ្លួនតាំងពីខែកុម្ភៈ នៅពេលតុលាការកំពូលបានបដិសេធបណ្តឹងតវ៉ាចុងក្រោយរបស់គាត់ប្រឆាំងនឹងសាលក្រមកាត់ទោសជាប់គុកអស់មួយជីវិត ដែលសម្រេចក្នុងឆ្នាំ២០០២ ដោយជាប់ចោទពីបទសម្លាប់អ្នកទេសចរបីនាក់មកពីប្រទេសអូស្ត្រាលី អង់គ្លេស និងបារាំង កាលពីឆ្នាំ១៩៩៤ ។ អ្នកទេសចរណ៍ទាំងបីត្រូវបានចាប់ជាចំណាប់ខ្មាំងបន្ទាប់ពីការវាយឆ្មក់មកលើរទេះភ្លើងមួយខ្សែ ហើយក្រោយមកត្រូវបានសម្លាប់នៅលើភ្នំវល្លិ៍ ក្នុងខេត្តកំពត ។ *(The Cambodia Daily, ២៦ តុលា ២០០៥)*

## ១២ វិច្ឆិកា ២០០៥

ព្រះមហាក្សត្រ សម្តេចព្រះ នរោត្តម សីហមុនី បានឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំងលោក ស៊ាន វិសុទ្ធ ជាប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ និងតែងតាំងលោកស្រី មីសែលលី ជាអនុប្រធាន ដែលតំណែងនេះត្រូវបានតែងតាំងនៅថ្ងៃទី១៤ ខែតុលា ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ *(ព្រះរាជក្រឹត, នស/រកត/១១០៥/៤៦២ និង នស/រកត/១១០៥/៤៦៦)*

## ២០ វិច្ឆិកា ២០០៥

អតីតព្រះមហាក្សត្រ សម្តេចព្រះ នរោត្តម សីហនុ បានចោទប្រកាន់លោក រីឆាដ និចសុន (Richard Nixon) អតីតប្រធានាធិបតីសហរដ្ឋអាមេរិក និងលោក ហិនរី ឃីស៊ីងជឺ (Henry Kissinger) ដែលពេលនោះជារដ្ឋមន្ត្រីក្រសួងការបរទេសថា បានបម្រើផលប្រយោជន៍ឲ្យខ្មែរក្រហមក្នុងពេលដែលសហរដ្ឋអាមេរិកកំពុងធ្វើសកម្មភាពយោធានៅកម្ពុជា ។ ឯកសារដែលចេញផ្សាយកាលពីសប្តាហ៍មុននៅសហរដ្ឋអាមេរិក បានរៀបរាប់យ៉ាងលម្អិតពីការបោកប្រាស់របស់ និចសុន ក្នុងអំឡុង«សង្គ្រាមសម្ងាត់»របស់សហរដ្ឋអាមេរិកនៅកម្ពុជានៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ដែលនៅពេលនោះ សហរដ្ឋអាមេរិកបានធ្វើការទម្លាក់គ្រាប់បែកដ៏ច្រើនសន្ធឹកសន្ធាប់មកលើប្រទេសកម្ពុជា ។ សម្តេចព្រះ នរោត្តម សីហនុ ទ្រង់បានចារនៅលើក្បាលទំព័រសារព័ត៌មានមួយ ដែលបានដាក់បង្ហាញនៅលើគេហទំព័ររបស់ព្រះអង្គថា «ដោយប្រើប្រាស់អ្នកនិយម លន់ នល់ និង

សិរិមតៈ ដើម្បីលុបបំបាត់សង្គមរាស្ត្រនិយម និង នរោត្តម សីហនុ នៅទីបំផុត និចសុន-ឃីស៊ីងជឺ បានបម្រើផលប្រយោជន៍ឲ្យខ្មែរក្រហម ប៉ុល ពត និងរបបកុម្មុយនីស្ត ប៉ុល ពត។ (The Cambodia Daily, ២២ វិច្ឆិកា ២០០៥)

## ២៣ វិច្ឆិកា ឆ្នាំ២០០៥

អង្គការសហប្រជាជាតិបានបោះជំហានទៅមុខ ជាមួយនឹងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

«ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៥ ការប្រឹងប្រែងរបស់អង្គការសហប្រជាជាតិ ដើម្បីជួយប្រទេសកម្ពុជាក្នុងការបង្កើតតុលាការចម្រុះពិសេសមួយ ដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមដែលមានវ័យចាស់ជរា ពីបទសម្លាប់ជនស៊ីវិលរាប់ពាន់នាក់ នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ កំពុងតែមានដំណើរការទៅមុខ ខណៈពេលដែលលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ កំពុងតែងតាំងបុគ្គលិកអន្តរជាតិសម្រាប់សាលាក្តីនេះ» ។

អ្នកនាំពាក្យរបស់អង្គការសហប្រជាជាតិ លោក ស្ទីវហ្វានី ឌូហ្សារីក (Stephane Dujaric) បានថ្លែងប្រាប់អ្នកយកព័ត៌មានថា «បេក្ខជនដែលមានឈ្មោះក្នុងបញ្ជី http://www.un.org/law/khmerrougetrials នឹងត្រូវសម្ភាសន៍នៅដើមខែធ្នូសម្រាប់មុខតំណែងជាចៅក្រមអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ» ។

«អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីបង្កើតអង្គសាលាដំបូង និងតុលាការកំពូលក្នុងប្រព័ន្ធច្បាប់កម្ពុជា ដើម្បីកាត់ទោសអ្នកដែលមានការទទួលខុសត្រូវខ្ពស់បំផុត ចំពោះបទឧក្រិដ្ឋកម្មនិងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់កម្ពុជានិងអន្តរជាតិ រវាងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩» ។

«តុលាការនឹងរៀបចំឲ្យមានចៅក្រមជាតិនិងអន្តរជាតិចំរុះមួយ ។ យោងតាមកិច្ចព្រមព្រៀង ដែលសង្កត់ធ្ងន់លើអព្យាក្រឹតភាព និងឯករាជ្យរបស់គណៈវិនិច្ឆ័យ ។ ការសម្រេចចិត្តក្នុងអង្គជំនុំជម្រះទាំងពីរ ត្រូវតែធ្វើឡើងតាមមតិភាគច្រើន ដោយចៅក្រម៤រូបនៅសាលាដំបូង និងចៅក្រម៥រូបនៅតុលាការកំពូល» ។

«មាត្រា៣នៃកិច្ចព្រមព្រៀងចែងថា អង្គជំនុំជម្រះសាលាដំបូងរួមមានចៅក្រមកម្ពុជា៣រូបនិងចៅក្រមអន្តរជាតិពីររូប ហើយអង្គជំនុំជម្រះតុលាការកំពូលមានចៅក្រមកម្ពុជា៤រូប និងចៅក្រមអន្តរជាតិ ៣រូប» ។

«យោងតាមមាត្រា៣ កថាខណ្ឌ៥ នៃកិច្ចព្រមព្រៀង ចៅក្រមអន្តរជាតិទាំង៥រូបនេះនឹងត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ចេញពីបញ្ជីនៃបេក្ខជនមិនតិចជាង ៧រូប ដែលបញ្ជូនមកពីអគ្គលេខាធិការអង្គការសហប្រជាជាតិ» ។

“យោងតាមមាត្រា៣ កថាខណ្ឌទី៨ នៃកិច្ចព្រមព្រៀង អ្នកដែលត្រូវបានជ្រើសតាំងជាចៅក្រមអន្តរជាតិផ្សេងទៀត អាចត្រូវបានតែងតាំងប្រសិនបើមានកន្លែងទំនេរ ។ អ្នកទាំងនេះអាចនឹងត្រូវបានតែងតាំងឲ្យបម្រើការជាចៅក្រមក្នុងករណីជាក់លាក់មួយចំនួន” ។

“តាងនាមឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទីប្រឹក្សាផ្នែកច្បាប់បានរៀបចំបញ្ជីសម្រាំងបុគ្គលដែលលោកអគ្គលេខាធិការអាចនឹងតែងតាំងជាចៅក្រមអន្តរជាតិ ឬជាចៅក្រមនៃអង្គបុរេជំនុំជម្រះ ៖

- ស៊ីវាល ខាតរ៉ាយ (Silvia Cartwright) អគ្គអភិបាល ប្រទេសនូវែលសេឡង់
- រ៉ូវ៉ាន ដូនីង (Rowan Downing) សមាជិកនៃអ្នកប្រឹក្សាផ្នែកច្បាប់របស់ប្រទេសអូស្ត្រាលី
- ខ្លូឌី ហ៊្វិន (Claudia Fenz) អតីតចៅក្រមអន្តរជាតិ ជនជាតិអូស្ទ្រីន (Austrian) ទទួលបន្ទុកបេសកកម្មរបស់អង្គការសហប្រជាជាតិក្នុងតំបន់កូសូវ៉ូ ។
- ចាន់ដ្រា ចាយ៉ាស៊ីងហ្គីល (Chandra Javasinghe)
- ម៉ាទីន ខារ៉ូបគីន (Martin Karopkin) ចៅក្រមតុលាការព្រហ្មទណ្ឌក្រុងញូវយ៉ក និងជាចៅក្រមស្តីទីនៃតុលាការកំពូលក្រុងញូវយ៉ក ។
- អាកនីសខា ខ្លូណូវីខា មីឡាត (Agnieszka Klonowiecka-Milart) អតីតចៅក្រមអន្តរជាតិ ជនជាតិប៉ូឡូញ ទទួលបន្ទុកបេសកកម្មអង្គការសហប្រជាជាតិក្នុងតំបន់កូសូវ៉ូ ។
- ជីន ម៉ាក ឡាវឺចនី (Jean-Marc Lavergne)
- ហ្វ្រិដ ម៉ាកអិលរៀ (Fred McElrea) ចៅក្រមតុលាការស្រុកអកលែន (Auckland District) ប្រទេសនូវែលសេឡង់ ។
- អាឌែល អ៊ីប្រាហ៊ីម ម៉ាគិដ (Adel Ibrahim Maged) ចៅក្រមជនជាតិអេហ្ស៊ីប របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនិងអធិបតេយ្យភាពជាតិ ។
- ម៉ូតូ ណូហ្គូឈី (Motoo Noguchi)
- រ៉ូបឺត ស្ពៀរ (Robert Spear)

“អ្នកដែលមានឈ្មោះ ត្រូវបានអញ្ជើញទៅសម្ភាសន៍នៅទីក្រុងញូវយ៉ក នៅខែធ្នូ ឆ្នាំ២០០៥” ។

### សហព្រះរាជអាជ្ញាបរទេស

“មាត្រា៦នៃកិច្ចព្រមព្រៀងចែងថា ព្រះរាជអាជ្ញាជាតិមួយរូប និងព្រះរាជអាជ្ញាអន្តរជាតិមួយរូបនឹងបម្រើការងារជាសហព្រះរាជអាជ្ញា” ។

“យោងតាមមាត្រា៦ កថាខណ្ឌទី៥ សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចេញពីបញ្ជីឈ្មោះបេក្ខជនពីររូប ដែលប្រគល់ឲ្យដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ” ។

“បេក្ខជនមួយរូបទៀតនឹងត្រូវតែងតាំងជាសហព្រះរាជអាជ្ញាអន្តរជាតិបម្រុង ដើម្បីបំពេញមុខតំណែង ជាសហព្រះរាជអាជ្ញានៅពេលមានតម្រូវការ” ។

“តាងនាមឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទីប្រឹក្សាផ្នែកច្បាប់បានបង្កើតបញ្ជីឈ្មោះ បេក្ខជនដែលលោកអគ្គលេខាធិការ អង្គការសហប្រជាជាតិអាចនឹងតែងតាំងជាសហព្រះរាជអាជ្ញាអន្តរជាតិ ៖

- Maria BENEDETTI
- Charles CARUSO
- Paul COFFEY
- Dermot GROOME
- Robert PETIT
- Jude ROMANO

“អ្នកដែលមានឈ្មោះត្រូវបានអញ្ជើញឲ្យទៅធ្វើសម្ភាសន៍នៅទីក្រុងញូវយ៉កនៅខែធ្នូ ឆ្នាំ២០០៥” ។

## សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

“មាត្រា៥ នៃកិច្ចព្រមព្រៀងចែងពីចៅក្រមស៊ើបអង្កេតជាតិមួយរូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិ មួយរូប ដែលបម្រើការងារជាសហចៅក្រមស៊ើបអង្កេត” ។

“យោងតាមមាត្រា៥ កថាខណ្ឌទី៥ សហចៅក្រមស៊ើបអង្កេតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមកម្ពុជា ចេញពីបញ្ជីបេក្ខជនពីររូប ដែលផ្តល់ឲ្យដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ” ។

“បេក្ខជនមួយរូបទៀតនឹងត្រូវតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ដើម្បីបំពេញមុខ តំណែងជាសហចៅក្រមស៊ើបអង្កេតនៅពេលមានតម្រូវការ” ។

“ក្នុងនាមលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទីប្រឹក្សាផ្នែកច្បាប់បានបង្កើតបញ្ជីឈ្មោះបេក្ខជន ដែលនឹងអាចត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ៖

- Abdulkadir KAYA
- Agnieszka KLONOWIECKA-MILART
- Marcel LEMONDE

“អ្នកមានឈ្មោះត្រូវបានអញ្ជើញឲ្យទៅធ្វើសម្ភាសន៍នៅទីក្រុងញូវយ៉ក នៅខែធ្នូ ឆ្នាំ២០០៥” ។

## ចៅក្រមអន្តរជាតិនៅអង្គបុរេជំនុំជម្រះ

“មាត្រា៧នៃកិច្ចព្រមព្រៀងចែងថា អង្គបុរេជំនុំជម្រះមានចៅក្រមបីរូប ដែលនឹងត្រូវតែងតាំងដោយ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងចៅក្រម២រូបទៀតតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាម ការស្នើរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ” ។

“អង្គបុរេជំនុំជម្រះត្រូវកោះប្រជុំចៅក្រមរបស់ខ្លួន នៅពេលមានការសម្រេចផ្ទុយគ្នា រវាងសហព្រះរាជអាជ្ញា ឬរវាងសហចៅក្រមស៊ើបអង្កេត” ។

“តាងនាមឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទីប្រឹក្សាផ្នែកច្បាប់បានបង្កើតបញ្ជីឈ្មោះ បេក្ខជន ដែលនឹងអាចតែងតាំងជាចៅក្រមអន្តរជាតិ ឬជាចៅក្រមនៃអង្គបុរេជំនុំជម្រះ ៖

- Silvia CARTWRIGHT
- Rowan DOWNING
- Claudia FENZ
- Candra JAYASINGHE
- Martin KAROPKIN
- Agnieszka KLONOWIECKA-MILART
- Jean-Marc LAVERGNE
- Fred McELREA
- Adel Ibrahim MAGED
- Motoo NOGUCHI
- Michael PROULX អតីតចៅក្រមសាលាឧទ្ធរណ៍ក្រុងខ្យូប៊ិច (Quebec) ប្រទេសកាណាដា ។
- Phillip RAPOZA ចៅក្រមសាលាឧទ្ធរណ៍នៅរដ្ឋម៉ាសូឈូសេត (Massachusetts) សហរដ្ឋអាមេរិក និងជាអតីតចៅក្រមអន្តរជាតិនៅទីម័រខាងកើត ។
- Robert SPEAR

  "អ្នកមានឈ្មោះត្រូវបានអញ្ជើញឲ្យទៅធ្វើសម្ភាសន៍នៅទីក្រុងញូវយ៉ក នៅខែធ្នូ ឆ្នាំ២០០៥" ។

## ២៥ វិច្ឆិកា ២០០៥

លេខាធិការដ្ឋាននៃក្រុមការងារសាលាក្តីខ្មែរក្រហម បានចេញផ្សាយសេចក្តីប្រកាសព័ត៌មានមួយដែលថា ព្រះមហាក្សត្រព្រះបាទសម្តេចព្រះ នរោត្តម សីហមុនី បានឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តែងតាំងលោក ស៊ាន វិសុទ្ធ ជាប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ និងតែងតាំងលោកស្រី មីសែល លី (Michelle Lee) ជាអនុប្រធាន ដែលតំណែងនេះត្រូវបានជ្រើសតាំង នៅថ្ងៃទី១៤ ខែតុលា ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ទាក់ទងនឹងថវិកា រាជរដ្ឋាភិបាលកម្ពុជានៅខ្វះទឹកប្រាក់ចំនួន១០.៨លានដុល្លារទៀត ហើយកំពុងអំពាវនាវទៅរដ្ឋាភិបាលដទៃទៀត ដើម្បីជួយបំពេញបន្ថែមការខ្វះខាតនេះ ។ (សេចក្តីប្រកាសព័ត៌មានរបស់លេខាធិការដ្ឋាននៃក្រុមការងារសាលាក្តីខ្មែរក្រហម, ២៥ វិច្ឆិកា ២០០៥)

## ១ ធ្នូ ២០០៥

ប្រាក់វិភាគទានសរុបសម្រាប់ភាគីអង្គការសហប្រជាជាតិ នៃចំនួនថវិកាសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ មានការកើនឡើង ដោយមានការសន្យាថ្មីៗពីប្រទេសអាមីនៀរ (១ពាន់ដុល្លារ) ណាមីប៊ី (៥រយ ដុល្លារ) និងប្រទេសអៀរឡង់ (៣សែនដុល្លារ) ។ (www.cambodia.gov.kh/krt/english/chrono.htm)

## ៦ ធ្នូ ២០០៥

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាលោក ឆាំង យុ ស្នើទៅរាជរដ្ឋាភិបាលកម្ពុជាឲ្យចរចាជាមួយរដ្ឋាភិបាលបារាំង ដើម្បីសុំខ្សែភាពយន្តខ្នាត៣៥មីលីម៉ែត្រមកឲ្យប្រទេសកម្ពុជាវិញ ដោយសារខ្សែភាពយន្តទាំងនេះអាចនឹងប្រើជាភ័ស្តុតាងនៅក្នុងតុលាការខ្មែរក្រហមបាន ។ ខ្សែភាពយន្តនេះត្រូវបានដឹងថា បានបញ្ជូនទៅប្រទេសបារាំងដើម្បីជួសជុលឡើងឆ្នាំ១៩៩៨ ។ លោកមានប្រសាសន៍ថា លោកធ្លាប់បានចរចារជាមួយមន្ត្រីបារាំងជាច្រើនរូបដើម្បីសុំខ្សែភាពយន្តមកវិញ ប៉ុន្តែខាងភាគីបារាំងឆ្លើយតបថា វាជាបញ្ហាបុគ្គល ។ *(រស្មីកម្ពុជា, ៨ ធ្នូ ២០០៥)*

លោកស្រី មីសែល លី តំណាងអង្គការសហប្រជាជាតិសម្រាប់សាលាក្តីខ្មែរក្រហម បានមកបំពេញបេសកកម្មនៅក្រុងភ្នំពេញរយៈពេលពីរសប្តាហ៍ពី (ថ្ងៃទី៦-១៦ ខែធ្នូ) ដែលនេះបង្ហាញឲ្យឃើញពីដំណាក់កាលឆ្ពោះទៅរកសាលាក្តីមួយដ៏ពិតប្រាកដ ។ *(The Cambodia Daily, ៨ ធ្នូ ២០០៥)*

## ៩ ធ្នូ ២០០៥

នៅក្នុងសេចក្តីថ្លែងការណ៍រួមមួយ ជាមួយប្រធានការិយាល័យរដ្ឋបាលសម្រាប់សាលាក្តីខ្មែរក្រហម លោកស្រី មីសែល លី មានប្រសាសន៍ថា ឧបសគ្គចម្បងដែលនៅសេសសល់គឺទាក់ទងនឹងបញ្ហាថវិកា ។ លោកស្រីបានសរសេរនៅក្នុងសេចក្តីថ្លែងការណ៍ថា «នៅពេលបច្ចុប្បន្នទឹកប្រាក់ ៤៣លានដុល្លារនៃថវិការបស់ភាគីអង្គការសហប្រជាជាតិជិតគ្រប់ហើយ ប៉ុន្តែភាគីកម្ពុជានៅខ្វះ១០,៨លានដុល្លារ» ។ លោកស្រីបានបន្ថែមទៀតថា រាជរដ្ឋាភិបាលកម្ពុជាកំពុងអំពាវនាវសុំជំនួយជាបន្ទាន់ ដើម្បីបំពេញការខ្វះខាតនេះ ។

## ១០ ធ្នូ ២០០៥

រដ្ឋាភិបាលប្រទេសអូស្ត្រាលីប្រកាសផ្តល់ប្រាក់ចំនួន៤៨.៣០៦ដុល្លារអូស្ត្រាលី ដល់លេខាធិការដ្ឋានក្រុមការងារសាលាក្តី ដើម្បីរៀបចំវេទិកាផ្សព្វផ្សាយតាមមូលដ្ឋានក្នុងទីរួមខេត្ត នៅទូទាំងប្រទេស ។ ថវិការនេះគឺជាចំណែកនៃគម្រោងជំនួយកិច្ចការសិទ្ធិមនុស្សឆ្នាំ២០០៥-២០០៦ និងជាប្រាក់ជំនួយបន្ថែមលើទឹកប្រាក់ ចំនួន១៩.៩៦០ដុល្លារសហរដ្ឋអាមេរិក ដែលផ្តល់ឲ្យនៅខែតុលា តាមរយៈការិយាល័យសិទ្ធិមនុស្សរបស់ស្ថានទូតអូស្ត្រាលី និងមូលនិធិគ្រប់គ្រងសម្រាប់ការបោះពុម្ពនិងចែកចាយ ទៅតាមថ្នាក់រៀននៅក្នុងប្រទេសកម្ពុជាអំពីសៀវភៅព័ត៌មាន «ការណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម» ដែលបោះពុម្ពនៅឆ្នាំ២០០៤ ក្រោមជំនួយឧបត្ថម្ភពីទីភ្នាក់ងារអូស្ត្រាលី ដើម្បីការអភិវឌ្ឍអន្តរជាតិ (AusAID) ។ *(www.cambodia.gov.kh/krt/english/chrono.htm)*

## ១២ ធ្នូ ២០០៥

លោកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាលសម្រាប់សាលាក្តីខ្មែរក្រហម និងក្រុមការងាររបស់លោកស្រីបានមកទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងគោលបំណងវាយតម្លៃប្រភពឯកសារ និងសម្ភារៈបរិក្ខារសម្រាប់ដំណើរការសាលាក្តី ដែលរំពឹងថានឹងចាប់ផ្តើមនាពេលឆាប់ៗនេះ ។ លោកស្រី មីសែល លី ដឹកនាំក្រុមបេសកកម្មវាយតម្លៃរបស់អង្គការសហប្រជាជាតិពីថ្ងៃទី៦ ដល់ ១៦ ខែធ្នូ ឆ្នាំ ២០០៥ ដែលមានសមាជិក៧រូប រួមមានប្រធានផ្នែកសន្តិសុខ បច្ចេកវិជ្ជាព័ត៌មាននិងទំនាក់ទំនងថវិកានិងហិរញ្ញវត្ថុ និងផ្នែកសេវាកម្មទូទៅចំនួន៤រូប ព្រមទាំងមន្ត្រីមកពីអង្គការសហប្រជាជាតិដែលមានទីស្នាក់ការនៅទីក្រុងញូវយ៉ក (Anne-Marie Ibanez) មកពីនាយកដ្ឋានកិច្ចការនយោបាយដែលធ្វើជាអ្នកនាំពាក្យឲ្យក្រុមបេសកម្ម និង David Hutchinson មកពីការិយាល័យកិច្ចការច្បាប់ ។

## ១៤ ធ្នូ ២០០៥

អង្គការសហប្រជាជាតិកំពុងរិះរកវិធីដើម្បីប្រើប្រាស់កញ្ចប់ថវិការ ទៅលើគម្រោងចំណាយរបស់សាលាក្តីខ្មែរក្រហម ។ បញ្ហាគឺនៅត្រង់ថា តើស្ថាប័នពិភពលោកមួយនេះ អាចប្រើប្រាស់កញ្ចប់ថវិការនេះដែរឬយ៉ាងណា ។ លោកស្រី មីសែល លី ប្រធានការិយាល័យរដ្ឋបាលរបស់អង្គការសហប្រជាជាតិបាននិយាយថា ទឹកប្រាក់សរុបប្រមាណ៦,៩លានដុល្លារ (៥,៧លានអឺរ៉ូ) គឺជាការប្រាក់ដែលបានកើនឡើង ពីការរួមវិភាគទានរបស់ប្រទេសផ្សេងៗ សម្រាប់បេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅកម្ពុជាក្នុងដើមទសវត្សរ៍ឆ្នាំ១៩៩០ ។ *(The Associated Press, ១៦ ធ្នូ ២០០៥)*

## ១៦ ធ្នូ ២០០៥

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាលោក ឆាំង យុ បានសរសេរលិខិតមួយច្បាប់ទៅកាសែតបាងកកប៉ុស្តិ៍ ដោយប្រាប់ពីចំណុចមួយចំនួនដែលរដ្ឋាភិបាលកម្ពុជាអាចធ្វើ ដើម្បីឲ្យឧបសគ្គក្នុងការរកថវិកាសម្រាប់សាលាក្តីខ្មែរក្រហមអាចដោះស្រាយបាន ។ ចំណុចទាំងនោះរួមមាន ទី១) យល់ព្រមឲ្យប្រទេសជប៉ុនបំពេញលើថវិការដែលខ្វះខាត ទី២) អំពាវនាវតាមរយៈសារព័ត៌មាន ដោយធ្វើសំណូមពរ និងស្នើជាផ្លូវការឲ្យបានទូលំទូលាយទាំងក្នុងស្រុកនិងអន្តរជាតិ ប្រសិនបើរដ្ឋាភិបាលចង់ឲ្យប្រជាជនខ្មែរផ្តល់មូលនិធិឧបត្ថម្ភ និងទី៣) ស្វែងរកប្រភពថវិកាដោយខ្លួនឯងសម្រាប់សាលាក្តីនេះ ។ លោកបានបន្ថែមថា ប្រទេសផ្តល់ជំនួយអាចពិចារណាធ្វើការបរិច្ចាគមួយឆ្នាំម្តងៗក៏បានប្រសិនបើប្រទេសទាំងនោះខ្លាចចំណាយថវិកាឥតប្រយោជន៍នៅទីក្រុងភ្នំពេញ ។ *(បាងកកប៉ុស្តិ៍, ១៦ ធ្នូ ២០០៥)*

## ២៨ ធ្នូ ២០០៥

គណៈកម្មាការសហគមន៍អឺរ៉ុបសន្យាផ្តល់ប្រាក់១,២លានដុល្លារ ដើម្បីជួយបង្គ្រប់លើចំណែកថវិការរបស់រដ្ឋាភិបាលសម្រាប់សាលាក្តីខ្មែរក្រហម ។ *(The Cambodia Daily, ២៩ ធ្នូ ២០០៥)*

### ១០ មករា ២០០៦

មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានការស្នើសុំជាផ្លូវការលើកដំបូងពីលោកបណ្ឌិត ស្ទីវ ហេដឌឺ (Steve Heder) តាងនាមឲ្យជំនួយការរបស់អង្គការសហប្រជាជាតិសម្រាប់សាលាក្តីខ្មែរក្រហម ស្តីពីវិធីដែលលោកអាចទទួលបានឯកសារសង្ខេប និងឯកសារបកប្រែដែលមានស្រាប់ ។ *(សារអ៊ីម៉ែលរបស់លោក បណ្ឌិត ស្ទីវ ហេដឌឺ ចុះថ្ងៃទី១០ មករា ២០០៦)*

### ១៨ មករា ២០០៦

ប្រទេសថៃផ្តល់ថវិការចំនួន២ម៉ឺន៥ពាន់ដុល្លារសហរដ្ឋអាមេរិក ទៅឲ្យសាលាក្តីកាត់ទោសខ្មែរក្រហម ។

### ១៨ មករា ២០០៦

មួយផ្នែកនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទនៅកំបូល ត្រូវបានប្រគល់ឲ្យក្រុមការងាររាជរដ្ឋាភិបាលសម្រាប់ការកាត់ក្តីខ្មែរក្រហម ។ អគារចំនួនពីរនិងបរិវេណជុំវិញអគារនឹងត្រូវប្រើជាកន្លែងធ្វើការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ *(សេចក្តីថ្លែងការពីការប្រគលអគារទៅឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ថ្លែងដោយឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាល និងរដ្ឋលេខាធិការដ្ឋាន របស់ក្រុមការងាររាជរដ្ឋាភិបាលសម្រាប់សាលាក្តីខ្មែរក្រហម)*

### ៥ កុម្ភៈ ២០០៦

លោកស្រី មីសែល លី តំណាងអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការសាលាក្តីខ្មែរក្រហម បានមកដល់ប្រទេសកម្ពុជា ដើម្បីរៀបចំបុគ្គលិកសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានរង់ចាំអស់រយៈពេលយ៉ាងយូរ ។ *(The Cambodia Daily, ៦ កុម្ភៈ ២០០៦)*

### ៧ កុម្ភៈ ២០០៦

លោក រាជ សម្បត្តិ ដែលជាគ្រូបង្រៀនផ្នែកសារព័ត៌មាន ត្រូវបានតែងតាំងជាមន្ត្រីសារព័ត៌មានសម្រាប់សាលាក្តីខ្មែរក្រហមដែលនឹងត្រូវបង្កើតឡើង ។ លោកធ្លាប់ធ្វើជាអ្នករាយការណ៍ព័ត៌មានឲ្យកាសែត

បារាំង (Agence France Press) អស់រយៈពេល១២ឆ្នាំ ហើយបច្ចុប្បន្នធ្វើការក្រៅម៉ោងឲ្យកាសែតញូយ៉កថែម (The New York Times) និងជាគ្រូបង្រៀនផ្នែកប្រព័ន្ធផ្សព្វផ្សាយនិងទូរគមនាគមន៍នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ លោកទទួលសញ្ញាប័ត្រផ្នែកសារព័ត៌មានពីសាកលវិទ្យាល័យរដ្ឋកាលីហ្វញ៉ា និងបរិញ្ញាប័ត្រផ្នែកសាកវិប្បកម្ម (ដាំដុះ) នៅហ្វូលតុន (Fullerton) ប្រទេសឥណ្ឌា និងសញ្ញាប័ត្រអនុបណ្ឌិតផ្នែកសារព័ត៌មានពីសាកលវិទ្យាល័យកូឡុំបៀ (Columbia University) នៅទីក្រុងញូវយ៉ក ។ *(The Cambodia Daily,* ៨ កុម្ភៈ ២០០៦)

## ៨ កុម្ភៈ ២០០៦

លោក នួន ជា បងធំទីពីរបន្ទាប់ពី ប៉ុល ពត នៃរបបខ្មែរក្រហម បានបំភ្លឺចំពោះពាក្យចចាមអារ៉ាមស្តីពីការស្លាប់របស់លោក ដែលផ្សព្វផ្សាយនៅទូទាំងប្រទេសកាលពីយប់ថ្ងៃអង្គារ ។ លោកបាននិយាយថា "ខ្ញុំមិនទាន់ស្លាប់ទេ" ។ *(The Cambodia Daily,* ៩ កុម្ភៈ ២០០៦)

## ៩ កុម្ភៈ ២០០៦

ប្រធានកិច្ចការរដ្ឋបាលនៃសាលាក្តីខ្មែរក្រហមថ្លែងថា ចៅក្រមនិងព្រះរាជអាជ្ញាត្រូវបានរំពឹងថានឹងចូលកាន់តំណែងនៅពាក់កណ្តាលឆ្នាំនេះ ហើយសាលាក្តីដែលបានរង់ចាំអស់រយៈពេលយ៉ាងយូរនេះ គួរតែចាប់ផ្តើមដំណើរការនៅឆ្នាំ២០០៧ ។

លោកស្រី មីសែល លី អនុប្រធានកិច្ចការរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ មានយោបល់លើបញ្ហាថវិកាថា ត្រឹមថ្ងៃទី១៥ ខែកុម្ភៈ បុគ្គលិកសាលាក្តីនឹងដឹងថា តើប្រទេសផ្តល់ជំនួយដល់កម្ពុជាទាំង២៩បានយល់ព្រមផ្ទេរមូលនិធិរួមនៅសល់ពីសម័យអ៊ុនតាក់ ដែលមានទឹកប្រាក់សរុប៦.៩លានដុល្លារ ដើម្បីដោះស្រាយ ការខ្វះខាតថវិការបស់កម្ពុជាដែរឬយ៉ាងណា ។

លោក ស៊ាន វិសុទ្ធ បានប្រកាសថា អគ្គនាយករងនគរបាលជាតិលោក ម៉ៅ ចាន់ដារ៉ា ត្រូវបានតែងតាំងជាប្រធានសន្តិសុខសម្រាប់សាលាក្តី ។ *(The Cambodia Daily,* ១០ កុម្ភៈ ២០០៦)

## ២០ កុម្ភៈ ២០០៦

យោងតាមអ្នកនាំពាក្យរបស់សាលាក្តី លោក រាជ សម្បត្តិ ប្រធានរដ្ឋបាលរបស់កម្ពុជា និងអង្គការសហប្រជាជាតិនៃសាលាក្តីខ្មែរក្រហម កំពុងរង់ចាំការយល់ព្រមពីប្រទេសចំនួន២៧ ដើម្បីផ្ទេរប្រាក់ ៦,៩ លានដុល្លារពីមូលនិធិរួមដែលនៅសល់ពីសម័យអ៊ុនតាក់ ដើម្បីយកទៅចំណាយសម្រាប់ការកាត់ក្តី ។ លោកបានបន្ថែមថា "យើងទទួលបានការបញ្ជាក់ថា ប្រទេសអង់គ្លេសនិងជប៉ុនបានយល់ព្រមលើការផ្ទេរថវិការនេះ

ហើយ ។ យើងមានសុទិដ្ឋិនិយមថា វានឹងមិនមានបញ្ហាអ្វីទេ ហើយការកាត់ក្តីនឹងដំណើរការទៅមុខតាមកាលកំណត់» ។ (The Cambodia Daily, ២១ កុម្ភៈ ២០០៦)

## ២៥-២៦ កុម្ភៈ ២០០៦

ប្រជាជន៤៨០នាក់មកពីទូទាំងប្រទេស ដែលរួមមាន ដូនជី ចាមមូស្លីម សិស្ស និស្សិត និងអ្នកស្រាវជ្រាវដែលមួយចំនួនអាចត្រូវបានស្នើសុំឲ្យធ្វើជាសាក្សីនៅសាលាក្តី បានចំណាយពេល២ថ្ងៃមកទស្សនាទីទិដ្ឋភាពនៃអំពើឃោរឃៅរបស់ខ្មែរក្រហម (គុកទួលស្លែងនិងជើងឯក) និងទីតាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីសួរសំណួរអំពីតុលាការ ដែលត្រូវបានបង្កើតដើម្បីស្វែងរកយុត្តិធម៌ឲ្យជនរងគ្រោះ ។ ដំណើរទស្សនកិច្ច នេះត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ (The Cambodia Daily, ២៧ កុម្ភៈ ២០០៦)

## ៨ មីនា ២០០៦

*ជំនួយការអង្គការសហប្រជាជាតិសម្រាប់សាលាក្តីខ្មែរក្រហម*

អគ្គលេខាធិការអង្គការសហប្រជាជាតិបានសរសេរលិខិតមួយច្បាប់ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៦ ផ្ញើជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយប្រគល់នូវឈ្មោះបេក្ខជនដែលត្រូវបានជ្រើសរើសសម្រាប់មុខតំណែងចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអជ្ញាអន្តរជាតិ និងចៅក្រមអន្តរជាតិសម្រាប់អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីពីបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាកាលពីឆ្នាំ២០០៣ ចែងថា តុលាការដំបូងរួមមានចៅក្រមជាតិ៣រូប និងចៅក្រមអន្តរជាតិ២រូប ហើយតុលាការកំពូលមានចៅក្រមជាតិ៤រូប និងចៅក្រមអន្តរជាតិ៣រូប ។ កិច្ចព្រមព្រៀងនេះបង្ហាញថា ចៅក្រមអន្តរជាតិ៥រូបត្រូវបានតែងតាំងឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ចេញពីបញ្ជីឈ្មោះបេក្ខជនមិនតិចជាង ៧រូប ដែលផ្ញើដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

នៅថ្ងៃទី៨ ខែមិនា ឆ្នាំ២០០៦ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានផ្ញើរបញ្ជីឈ្មោះបេក្ខជនជ្រើសតាំងទាំង៧រូប សម្រាប់តំណែងជាចៅក្រមអន្តរជាតិ ដូចមានរាយនាមខាងក្រោម ៖

- លោកស្រី Silvia Cartwright (នូវែលសេឡង់)
- លោកស្រី Claudia Fenz (អូស្ត្រាលី)
- លោក Chandra Nihal Jayasinghe (ស្រីលង្កា)

- លោក Martin Karopkin (សហរដ្ឋអាមេរិក)
- លោកស្រី Agnieszka Klonowiecka-Milart (ប៉ូឡូញ)
- លោក Jean-Marc Laverge (បារាំង)
- លោក Motoo Noguchi (ជប៉ុន)

កិច្ចព្រមព្រៀងនោះក៏មានចែងអំពី ចៅក្រមស៊ើបអង្កេតកម្ពុជាមួយរូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ដែលនឹងធ្វើជាសហចៅក្រមស៊ើបអង្កេត ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិនឹងត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ចេញពីបញ្ជីបេក្ខជនចំនួនពីររូប ដែលប្រគល់ដោយអគ្គ-លេខាធិការ ។ បេក្ខជនមួយរូបទៀតត្រូវតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ។

នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៦ អគ្គលេខាធិការអង្គការសហប្រជាជាតិ បានប្រគល់លិខិតតែងតាំងសម្រាប់តំណែងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដូចខាងក្រោម ៖

- លោក Marcel Lemonde (បារាំង)

អគ្គលេខាធិការអង្គការសហប្រជាជាតិសន្យាថា នឹងប្រគល់បញ្ជីឈ្មោះបេក្ខជនបន្ថែមទៀត សម្រាប់តំណែងសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនៅពេលក្រោយ ។

កិច្ចព្រមព្រៀងបានចែងថា ព្រះរាជអាជ្ញាជាតិមួយរូបនិងព្រះរាជអាជ្ញាអន្តរជាតិមួយរូប ធ្វើជាសហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាអន្តរជាតិត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ចេញពីបញ្ជីឈ្មោះបេក្ខជន២រូបដែលប្រគល់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ បេក្ខជនមួយរូបទៀតត្រូវតែងតាំងជាសហព្រះរាជអាជ្ញាអន្តរជាតិបម្រុង ។

អគ្គលេខាធិការអង្គការសហប្រជាជាតិ បានផ្ញើបញ្ជីឈ្មោះបេក្ខជនសម្រាប់តំណែងសហព្រះរាជអាជ្ញាអន្តរជាតិដូចខាងក្រោម ៖

- លោក Paul Coffey (សហរដ្ឋអាមេរិក)
- លោក Robert Petit (កាណាដា)

ចុងក្រោយ កិច្ចព្រមព្រៀងចែងអំពីចៅក្រម៥រូបនៃអង្គបុរេជំនុំជម្រះ ដែល៣រូបតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង២រូបទៀតតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមការជ្រើសតាំងរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៦ អគ្គលេខាធិការអង្គការសហប្រជាជាតិបានប្រគល់បញ្ជីឈ្មោះបេក្ខជនសម្រាប់តំណែងចៅក្រមនៃអង្គបុរេជំនុំជម្រះ ដែលមានរាយនាមដូចខាងក្រោម ៖

- លោក Rowan Downing (អូស្ត្រាលី)
- លោកស្រី Katinka Lahuis (ហូឡង់)

*អគ្គលេខាធិការអង្គការសហប្រជាជាតិ បានស្នើឲ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ជូនបញ្ជីឈ្មោះបេក្ខជនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ។*

*នៅមិនទាន់មានការបញ្ជាក់នៅឡើយទេ ថាតើនៅពេលណាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នឹងប្រកាសថាអ្នកណានឹងត្រូវតែងតាំងក្នុងចំណោមបេក្ខជនទាំងនោះទេ ។ (សេចក្តីប្រកាសព័ត៌មានរបស់អង្គការសហប្រជាជាតិ, ៨ មីនា ២០០៦)*

## ១៤ មីនា ២០០៦

*អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា បានចុះកិច្ចព្រមព្រៀងបង្កើតមូលដ្ឋានច្បាប់ សម្រាប់ការរៀបចំផ្នែករដ្ឋបាលនិងប្រតិបត្តិការរបស់អង្គជំនុំជម្រះ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដ៏ឃោរឃៅ ដូចជាការសម្លាប់រង្គាលក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ។ តាមរបាយការណ៍របស់លោក* Stephane Dujarric *កិច្ចព្រមព្រៀងមួយដែលចុះហត្ថលេខានៅថ្ងៃនេះ គឺទាក់ទិននឹងការចាត់ចែងបន្ថែមលើសម្ភារៈ ទឹកភ្លើង និងសេវាកម្មដែលរដ្ឋាភិបាលកម្ពុជានឹងផ្តល់សម្រាប់ការបំពេញការងាររបស់តុលាការទាំងពីរនោះ ។ កិច្ចព្រមព្រៀងមួយផ្សេងទៀត គឺទាក់ទងនឹងការរៀបចំសុវត្ថិភាពនិងសន្តិសុខ ។ (UN News, ១៤ មីនា ២០០៦)*

## ៦ មេសា ២០០៦

*យោងតាមសម្តីរបស់អជ្ញាធរក្រុងប៉ៃលិន ខៀវ សំផន និង នួន ជា មេដឹកនាំខ្មែរក្រហមដែលនៅរស់រានមានជីវិត មានបំណងចង់បួសជាសង្ឃ ដើម្បីរៀនសូត្រអប់រំកាយ និងចិត្តតាមផ្លូវព្រះពុទ្ធសាសនា ។ (កម្ពុជាថ្មី, ៧ មេសា ២០០៦)*

## ៨ មេសា ២០០៦

*ព័ត៌មានថ្មីៗទាក់ទងនឹងថវិការសម្រាប់សាលាក្តីខ្មែរក្រហម*

*បញ្ជីឈ្មោះប្រទេសផ្តល់ជំនួយ ដែលសន្យាផ្តល់ថវិការដល់ភាគីកម្ពុជាបញ្ជីឈ្មោះប្រទេសផ្តល់ជំនួយដែលសន្យាផ្តល់ថវិការដល់ភាគីអង្គការសហប្រជាជាតិ ។ (Helen Javis/ECCC, ៨ មេសា ២០០៦)*

## ១៧ មេសា ២០០៦

*ប្រទេសកម្ពុជាកាន់ទុក្ខខួបលើកទី៣១ ថ្ងៃដែលខ្មែរក្រហមឡើងកាន់អំណាច ។*

## ២១ មេសា ២០០៦

គណៈប្រតិភូសហគមន៍អឺរ៉ុបមួយក្រុម ដឹកនាំដោយ Mark Tarabela និយាយនៅអំឡុងទស្សនកិច្ចនៅកម្ពុជាថា សហគមន៍អឺរ៉ុបនឹងគាំទ្រសាលាក្តីខ្មែរក្រហម នៅពេលភាគីកម្ពុជានិងអន្តរជាតិដាក់សំណើថ្មីបន្ថែមទៀត ។ *(វិទ្យុសម្លេងសហរដ្ឋអាមេរិក, ២១ មេសា ២០០៦)*

## ២៤ មេសា ២០០៦

អតីតព្រះមហាក្សត្រ សម្តេចព្រះ នរោត្តម សីហនុ បានចំអកថា អ្វីដែលព្រះអង្គមានព្រះបន្ទូល គឺជាការរំពុកឡើងវិញនូវអ្វីដែលបានផ្សព្វផ្សាយថាអតីតមេដឹកនាំខ្មែរក្រហមលោក ប៉ុល ពត ជាវីរបុរសរបស់ជាតិ ។ ព្រះអង្គមានព្រះបន្ទូលឆ្លើយតបទៅនឹងសារព័ត៌មានស្តីពីពិធីបុណ្យតាមបែបព្រះពុទ្ធសាសនា ដែលប្រារព្ធធ្វើឡើងដើម្បីរំពុកខួបលើកទី៨នៃមរណភាពរបស់ ប៉ុល ពត ថ្ងៃទី១៥ ខែមេសា ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ អ្នកក្រោមបង្គាប់របស់លោក ប៉ុល ពត បានយកចំណីអាហារ និងទៀនធូបទៅកាន់កន្លែងផ្នូររបស់ ប៉ុល ពត នៅថ្ងៃទី១៥ ខែមេសា ដោយសារតែប្រជាជនដែលមានជំនឿសង្ឃឹមថា ប៉ុល ពត អាចផ្តល់សំណាងដល់ពួកគាត់ ។ «ប្រជាជនទាំងនោះបានធ្វើដំណើរធម្មាយាត្រាទៅកាន់ផ្នូររបស់ទេវតាថ្មី ប៉ុល ពត ដើម្បីអុជធូបទៀន បួងសួងឲ្យ ប៉ុល ពត ទៅដល់សុគតិភព ជំនួសឲ្យឋាននរក និងឆាប់ចាប់ជាតិថ្មី» ។ ព្រះមហាក្សត្រ មានព្រះបន្ទូលបន្ថែមទៀតថា ព្រះអង្គសង្ឃឹមថា បើទោះបីជា ប៉ុល ពត ចាប់ជាតិសារជាថ្មីក៏ដោយ ក៏រដ្ឋាភិបាលបច្ចុប្បន្ននេះអាចនៅកាន់អំណាចបានដដែល ។ *(The Cambodia Daily, ២៥ មេសា ២០០៦)*

## ២៦ មេសា ២០០៦

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លោក អង់ វង្សវឌ្ឍនា និយាយថា «ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នឹងជ្រើសរើសចៅក្រមនិងព្រះរាជអាជ្ញាជាតិនិងអន្តរជាតិ សម្រាប់សាលាក្តីខ្មែរក្រហម នៅថ្ងៃទី៤ ខែឧសភា» ។ *(The Cambodia Daily, ២៧ មេសា ២០០៦)*

## ៧ ឧសភា ២០០៦

ចៅក្រម ព្រះរាជអាជ្ញាជាតិនិងអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា នៅថ្ងៃទី៤ ខែឧសភា ដោយព្រះរាជក្រឹត្យ នស/

រកត ០៥០៦/២១៨ របស់ព្រះបាទសម្តេចព្រះ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ ខាងក្រោមគឺជាបញ្ជីឈ្មោះដូវការ ៖

**១) ចៅក្រមសាលាដំបូង**

- លោក និល ណុន (កម្ពុជា)
- លោក ធូ មណី (កម្ពុជា)
- លោក យ៉ា សុខន (កម្ពុជា)
- លោកស្រី Silvia Cartwright (នូវែលសេឡង់)
- លោក Jean-Marc Lavergne (បារាំង)

**ចៅក្រមបម្រុង**

- លោក យូរ ឧត្តរា (កម្ពុជា)
- លោកស្រី Claudia Fenz (អូទ្រីស)

**២) ចៅក្រមតុលាការកំពូល**

- ឯកឧត្តម គង់ ស្រីម (កម្ពុជា)
- លោក សោម សេរីវុឌ្ឍ (កម្ពុជា)
- លោក ស៊ិន រិទ្ធ (កម្ពុជា)
- លោក យ៉ា ណារិន (កម្ពុជា)
- លោក Motoo Noguchi (ជប៉ុន)
- លោកស្រី Agnieszka Klonowiecka-Milart (ប៉ូឡូញ)
- លោក Chandra Nihal Javasinghe (ស្រីលង្កា)

**ចៅក្រមបម្រុង**

- លោក ម៉ុង មុន្នីចរិយា (កម្ពុជា)
- លោក Martin Karopkin (សហរដ្ឋអាមេរិក)

**៣) សហចៅក្រមស៊ើបអង្កេត**

- លោក យូ ប៊ុនឡេង (កម្ពុជា)
- លោក Marcel Lemonde (បារាំង)

**ចៅក្រមបម្រុង**

- លោក ថោង អុល (កម្ពុជា)

**៤) សហព្រះរាជអាជ្ញា**

- *លោកស្រី ជា លាង (កម្ពុជា)*
- *លោក* Robert Pertit *(កាណាដា)*

**សហព្រះរាជអាជ្ញាបម្រុង**

- *ឯកឧត្តម ជួន ស៊ុនឡេង (កម្ពុជា)*
- *លោក* Paul Coffey *(សហរដ្ឋអាមេរិក)*

**៥) អង្គបុរេជំនុំជម្រះ**

- *ឯកឧត្តម ប្រាក់ គឹមសាន (កម្ពុជា)*
- *ឯកឧត្តម ន័យ ថុល (កម្ពុជា)*
- *លោក ហួត វុទ្ធី (កម្ពុជា)*
- *លោក* Rowan Downing *(អូស្ត្រាលី)*
- *លោកស្រី* Katinka Lahuis *(ហូឡង់)*

**ចៅក្រមបម្រុង**

- *លោក ប៉ែន ពេជ្រសាលី (កម្ពុជា)*
- *អន្តរជាតិ (គ្មាន)*

*(បញ្ជីរាយឈ្មោះផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី៨ ខែឧសភា)*

## ១០ ឧសភា ២០០៦

*លោកស្រី មីសែល លី និងសមភាគីខាងកម្ពុជាលោក ស៊ាន វិសុទ្ធ មន្ត្រីការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រាប់សន្និសីទកាសែតថា នឹងមានការពន្យារសម្រាប់អង្គជំនុំជម្រះរហូតដល់ខែមិថុនា ដោយសារខ្វះបុគ្គលិកកម្ពុជាដែលមានគុណសម្បត្តិគ្រប់គ្រាន់ និងបានបន្ថែមថា ពួកគេសង្ឃឹមថា ស្ថានភាពនេះនឹងត្រូវកែតម្រូវនៅត្រឹមខែកក្កដា ទោះបីជាអាចត្រូវបានដោះស្រាយនៅពេលក្រោយទៀតក៏ដោយ ។ (Bangkok Post, ១១ ឧសភា ២០០៦)*

## ១១ ឧសភា ២០០៦

*ថ្ងៃនៅឯពិធីប្រគល់សញ្ញាប័ត្រនៅសាលាភូមិន្ទរដ្ឋបាល លោកនាយរដ្ឋមន្ត្រី ហ៊ុន សែន រិះគន់អ្នកដែលមានការសង្ស័យពីលក្ខណៈសម្បត្តិរបស់ចៅក្រមនិងសហព្រះរាជអាជ្ញា ដែលត្រូវបានតែងតាំងសម្រាប់សាលាក្តីខ្មែរក្រហម ។ (The Cambodia Daily, ១១ ឧសភា ២០០៦)*

### ១២ ឧសភា ២០០៦

រូបបដិមាលោកតាដំបងដែក ត្រូវបានសម្ពោធនៅខេត្តកណ្តាលកាលពីព្រឹកថ្ងៃសុក្រ ។ យោងតាមបទបញ្ញត្តិច្បាប់របស់កម្ពុជា សាក្សីត្រូវស្បថថានឹងប្រាប់ការពិតនៅចំពោះមុខបដិមាករនេះ មុនពេលផ្តល់ចម្លើយកសិណសាក្សី ។ *(The Cambodia Daily, ១៣-១៤ ឧសភា ២០០៦)*

### ១៧ ឧសភា ២០០៦

ឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ លោក លូីស អាបឺរ (Louis Arbour) បានរៀបចំការជជែកពិភាក្សារយៈពេល២ម៉ោងស្តីពីកំណែទម្រង់ប្រព័ន្ធតុលាការ និងបានធ្វើដំណើរទស្សនកិច្ចទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ *(The Cambodia Daily, ២៥ ឧសភា ២០០៦)*

### ២៤ ឧសភា ២០០៦

ចៅក្រមនិងសហព្រះរាជអាជ្ញាកម្ពុជាថ្មីចំនួន១៧រូប របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានណែនាំខ្លួនជាផ្លូវការដល់មន្ត្រីការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ចៅក្រម និងសហព្រះរាជអាជ្ញា៥រូប ត្រូវអញ្ជើញឲ្យចូលរួមវេទិកាពិភាក្សា “សន្និសីទស្តីពីការយល់ដឹងអំពីតុលាការនៅទីម័រខាងកើត” ដែលធ្វើឡើងនៅទីក្រុងបាងកក នៅថ្ងៃទី២៨-២៩ ខែឧសភា រៀបចំដោយមជ្ឈមណ្ឌលអ៊ីសវែស (East-West Center) និងមជ្ឈមណ្ឌលសិក្សាឧក្រិដ្ឋកម្មសង្គ្រាម បឺខែលី (Berkeley War Crimes Studies Center) ។ *(The Cambodia Daily, ២៥ ឧសភា ២០០៦)*

### ១៥ មិថុនា ២០០៦

រាជរដ្ឋាភិបាលកម្ពុជានិងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្នុងការផ្តល់ប្រាក់ប្រមាណ៦,៣លានដុល្លារអាមេរិកដល់អង្គជំនុំជម្រះវិសាមញ្ញ ។ ថវិការចំនួន ៥លានដុល្លារអាមេរិកបានមកពីប្រទេសន័រវែស ស៊ុយអែត ដាណឺម៉ាក អូស្ត្រាលី ជប៉ុន នូវែលសេឡង់ អៀរឡង់ កាណាដា អង់គ្លេស ហូឡង់ បារាំង និងអាល្លឺមង់ ដែលត្រូវបានផ្តល់សម្រាប់ប្រតិបត្តិការអ៊ិនតាក់នៅកម្ពុជា និងទឹកប្រាក់១លានអឺរ៉ូទៀតបានមកពីរដ្ឋជាសមាជិករបស់បេសកកម្មសហគមន៍អឺរ៉ុប ។ ចំណែករបស់កម្ពុជាមានចំនួន១៣,៣លានដុល្លារអាមេរិក ។ ថវិការបន្ថែមចុងក្រោយនេះបានកាត់បន្ថយកង្វះថវិការរបស់ភាគីកម្ពុជាមកត្រឹម ៤,៩៦លានដុល្លារអាមេរិក ។ *(សេចក្តីថ្លែងការណ៍របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជា*

ប្រធានក្រុមការងាររាជរដ្ឋាភិបាល និងលោក Douglas Gardner តំណាងឲ្យកម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ (UNDP) និងជាអ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិនៅឯពិធីចុះហត្ថលេខា)

## ១៦ មិថុនា ២០០៦

លោក ជួន ជឿន រដ្ឋមន្ត្រីក្រសួងសុខាភិបាលក្នុងសម័យខ្មែរក្រហម ដែលទទួលបានសញ្ញាប័ត្រពេទ្យពីប្រទេសបារាំង ស្លាប់ដោយជំងឺចាស់ជរាក្នុងអាយុ៨៦ឆ្នាំ នៅទីក្រុងភ្នំពេញ ។ ប្អូនប្រុសរបស់គាត់ ជួន ប្រាសិទ្ធិ ជាឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំអង្គការសហប្រជាជាតិពីឆ្នាំ១៩៧៨-១៩៩២ ពេលដែលខ្មែរក្រហមតំណាងឲ្យប្រទេសកម្ពុជានៅក្នុងវេទិកាពិភពលោក ។ ប្អូនប្រុសម្នាក់ទៀត ជួន ម៉ុម ក៏បានបម្រើក្នុងតំណែងជាន់ខ្ពស់នៅក្នុងជួរខ្មែរក្រហមដែរ ។ ប្អូនប្រុសទាំងពីរនាក់ដែលមានវ័យក្មេងជាង ជួន ជឿន ត្រូវបានជឿថានៅរស់នៅឡើយ (តាមរបាយការណ៍ចុងក្រោយបានឲ្យដឹងថា ជួន ប្រាសិទ្ធិ កំពុងរស់នៅទីក្រុងញូវយ៉កបន្ទាប់ពីអាណត្តិការទូតរបស់គាត់ត្រូវបញ្ចប់ ។ គាត់ត្រូវបានអនុញ្ញាតឲ្យបន្តរស់នៅទីនោះ ដោយសារប្រពន្ធរបស់គាត់ធ្វើការនៅអង្គការសហប្រជាជាតិ) ។ *(Sopheng Cheang, AP Writer, ២១ មិថុនា ២០០៦)*

## ២៦-២៧ មិថុនា ២០០៦

មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញមេឃុំចំនួន៥៣០រូប មកពីខេត្តចំនួន១២ ធ្វើទស្សនកិច្ចនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ជើងឯក និងទីតាំងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ៣ កក្កដា ២០០៦

ចៅក្រមនិងសហព្រះរាជអាជ្ញាកម្ពុជា១៧រូប និងអន្តរជាតិ៨រូប ដែលត្រូវបានជ្រើសរើសឲ្យធ្វើជាអធិបតីនៃសាលាក្តីខ្មែរក្រហម បានធ្វើពិធីសច្ចាប្រណិធានចូលកាន់តំណែង ដែលប្រារព្ធឡើងនៅព្រះបរមរាជវាំង ។ *(The Cambodia Daily, ៣ កក្កដា ២០០៦)*

## ៦ កក្កដា ២០០៦

មេធាវីរបស់ ឌុច លោក កា សាវុធ និយាយថា លោកនឹងធ្វើពហិការមិនចូលរួមការកាត់ក្តីនេះទេ ដោយសារចៅក្រមកម្ពុជាស្ទើរតែទាំងអស់នៅសាលាក្តីខ្មែរក្រហម បានបាត់បង់សាច់ញាតិនៅក្នុងរបបខ្មែរក្រហមដែរ ។ *(Reuters, ៦ កក្កដា ២០០៦)*

## ៧ កក្កដា ២០០៦

អន្តជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រកាសនៅឯសន្និសីទកាសែតថា ដើម្បីធានាថាអតីតមេដឹកនាំខ្មែរក្រហមទទួលបានការការពារគ្រប់គ្រាន់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងបង្កើតការិយាល័យការពារក្តី ដែលមានមេធាវីបរទេសជាបុគ្គលិក ។ លោក រូផឺត ស្គីលបេក (Rupert Skilbeck) ប្រធានក្រុមមេធាវីការពារក្តី ដែលដឹកនាំការិយាល័យនេះបាននិយាយថា ច្បាប់ស្តីពីការចាត់តាំងគណៈមេធាវីត្រូវតែធ្វើវិសោធនកម្ម ដើម្បីឲ្យមេធាវីបរទេសអាចធ្វើជាសហមេធាវីការពារក្តីនៅកម្ពុជា ហើយថាមេធាវី១៥រូបនឹងធ្វើជាបុគ្គលិកការិយាល័យការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីធានាបាន“ភាពស្មើគ្នា”រវាងភាគីព្រះរាជអាជ្ញា និងមេធាវីការពារក្តីនៅសាលាក្តី ។ *(The Cambodia Daily, ៨-៩ កក្កដា ២០០៦)*

## ៨ កក្កដា ២០០៦

អតីតព្រះមហាវីរក្សត្រ សម្តេចព្រះ នរោត្តម សីហនុ ចេញព្រះរាជប្រកាសថា ព្រះអង្គជំទាស់ទៅនឹងសាលាក្តីខ្មែរក្រហមដែលទើបត្រូវបានបង្កើតឡើងនេះ ដោយមានព្រះរាជបន្ទូលថា សាលាក្តីនេះនឹងកាត់ទោសតែអ្នកដែលមានការទទួលខុសត្រូវខ្ពស់មួយចំនួនតូចប៉ុណ្ណោះ ហើយថាថវិកានេះគួរតែចំណាយទៅលើការកាត់បន្ថយភាពក្រីក្រវិញប្រសើរជាង ។ *(The Cambodia Daily, ១០ កក្កដា ២០០៦)*

## ១១ កក្កដា ២០០៦

រដ្ឋមន្ត្រីក្រសួងព័ត៌មានលោក ខៀវ កាញារីទ្ធ ចោទប្រកាន់អ្នកកាសែតពីបទរំខានដល់វិចិត្ត និងបំភិតបំភ័យអតីតមេដឹកនាំខ្មែរក្រហម ដោយបន្ថែមថាការខិតខំប្រឹងប្រែងរាយការណ៍ស្តីពីចលនាខ្មែរក្រហមរបស់ពួកគេគឺជាផ្នែកមួយនៃ“ការឃ្លាំមើលខ្មែរក្រហម” ដែលអាចបង្កគ្រោះថ្នាក់ដល់សាលាក្តី ។ *(The Cambodia Daily, ១២ កក្កដា ២០០៦)*

ក្មួយស្រីរបស់ តាម៉ុក ឈ្មោះ វិន រ៉ា បាននិយាយថា តាម៉ុកបានប្រាប់អ្នកស្រីថា តុលាការយោធាបានបដិសេធមិនព្រមផ្តល់ការព្យាបាលឲ្យបានត្រឹមត្រូវដល់គាត់ អស់រយៈពេលជាច្រើនខែមកហើយ នៅពេលដែលលោកស្រីបានទៅមើលគាត់នៅចុងសប្តាហ៍នេះ ។ “គាត់ប្រាប់ខ្ញុំថា គាត់បានសុំឲ្យអ្នកដែលមើលថែគាត់បញ្ជូនគាត់ទៅមន្ទីរពេទ្យបីខែ មុនពេលគាត់ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ” ។ *(The Cambodia Daily, ១៣ កក្កដា ២០០៦)*

## ១២ កក្កដា ២០០៦

លោក នួន ជា អតីតបងធំទីពីរនៅក្នុងសម័យខ្មែរក្រហម បដិសេធពាក្យចចាមអារ៉ាមដែលថាលោក និងលោក ខៀវ សំផន ដែលជាប្រមុខរដ្ឋ ព្យាយាមរត់គេចខ្លួន ។ “ខ្ញុំសូមបញ្ជាក់ថា អតីតមេដឹកនាំរបប

កម្ពុជាប្រជាធិបតេយ្យ នឹងមិនរត់ចោលប្រទេសជាតិនិងប្រជាជនទេ ហើយយើងនឹងរស់នៅក្នុងប្រទេស» ។ *(The Cambodia Daily, ១៣ កក្កដា ២០០៦)*

## ១៥ កក្កដា ២០០៦

ទោះបីជាអតីតព្រះមហាក្សត្រ នរោត្តម សីហនុ ជិតាស់ទៅនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏ដោយ ក៏ព្រះអង្គបានចេញព្រះរាជសារថា ព្រះអង្គស្ម័គ្រព្រះទ័យនឹងឡើងធ្វើសេចក្តីអធិប្បាយនៅក្នុងតុលាការ ។ «ខ្ញុំមិនមែនខ្វះសេចក្តីក្លាហានក្នុងការផ្តល់ចម្លើយនៅមុខអង្គជំនុំជម្រះទេ ។ គ្រួសាររបស់ខ្ញុំ ក្រុមគ្រួសាររបស់សម្តេចព្រះអគ្គមហេសី ព្រមទាំងមនុស្សជាច្រើនដែលគាំទ្រ នរោត្តម សីហនុ សុទ្ធតែទទួលរងទារុណកម្មនិងត្រូវបានសម្លាប់ដោយក្រុមខ្មែរក្រហម ប៉ុល ពត» ។ ទោះបីជាយ៉ាងនេះក្តី រដ្ឋមន្ត្រីក្រសួងព័ត៌មានលោក ខៀវ កាញារីទ្ធិ បាននិយាយថា រដ្ឋាភិបាលមិនចង់ឲ្យអតីតព្រះមហាក្សត្រ ដែលចូលនិវត្តន៍បង្ហាញព្រះកាយនៅចំពោះមុខអង្គជំនុំជម្រះទេ ពីព្រោះព្រះអង្គគឺជានិមិត្តរូបរបស់ជាតិទាំងមូល ។ *(The Cambodia Daily, ១៩ កក្កដា ២០០៦)*

## ២១ កក្កដា ២០០៦

អស់រយៈពេល៧ឆ្នាំ៤ខែ និង២សប្តាហ៍ បន្ទាប់ពីត្រូវបានចាប់ខ្លួននិងឃុំឃាំង ដោយគ្មានការកាត់ទោស តា ម៉ុក ស្លាប់នៅមន្ទីរពេទ្យយោធាព្រះកេតុមាលាវេលាម៉ោង៨:៤៥នាទីព្រឹក ក្នុងអាយុ៨១ឆ្នាំ ។ វេជ្ជបណ្ឌិតម្នាក់ដែលបដិសេធមិនបញ្ចេញឈ្មោះបាននិយាយថា តា ម៉ុក ស្លាប់ដោយជំងឺចាស់ជរានិងរបេង ។ *(The Cambodia Daily, ២២-២៣ កក្កដា ២០០៦)*

## ២៤ កក្កដា ២០០៦

សាកសពរបស់ តា ម៉ុក ត្រូវបានយកទៅបញ្ចុះនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ *(រស្មីកម្ពុជា, ២៥ កក្កដា ២០០៦)*

មជ្ឈមណ្ឌលឯកសារកម្ពុជាចាប់ផ្តើមបណ្តុះបណ្តាលមន្ត្រីប៉ូលិស១២រូប អំពីវិធីសាស្ត្រស៊ើបអង្កេតឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តដោយខ្មែរក្រហម និងវិធីសាស្ត្រសម្ភាសន៍ជនរងគ្រោះនិងជនសង្ស័យ ។ *(The Cambodia Daily, ២៦ កក្កដា ២០០៦)*

## ២៤-២៥ កក្កដា ២០០៦

មេឃុំចំនួន៥១២នាក់មកពីទូទាំងប្រទេសធ្វើដំណើរទស្សនកិច្ច ទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាដជើងឯក និងទីតាំងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ពួកគាត់ក៏បានជជែកជាមួយសមាជិករដ្ឋសភាដែលចូលរួមក្នុងការរៀបចំសេចក្តីព្រាងច្បាប់ មន្ត្រីមកពីសាលាក្តី និងអគ្គរដ្ឋទូតអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ ។ *(ទស្សនាវដ្តីស្វែងរកការពិត ភាសាអង់គ្លេស លេខ៧៩ ខែកក្កដា ឆ្នាំ២០០៦)*

## ១៧-២៨ សីហា ២០០៦

នៅក្រោមគម្រោងចុះផ្សព្វផ្សាយដល់មូលដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តចំនួន១៨២នាក់ មកពីសាកលវិទ្យាល័យនានានៅក្រុងភ្នំពេញ បានធ្វើដំណើរទៅកាន់ខេត្តចំនួន១៦ ដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពីសាលាក្តីខ្មែរក្រហម ។ ពួកគេក៏បានសម្ភាសន៍អ្នកនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យផងដែរ ។ ព័ត៌មានដែលបានផ្តល់ទៅប្រជាជនរួមមាន សៀវភៅណែនាំស្តីពីការកាត់ទោសខ្មែរក្រហម កូនសៀវភៅពីរក្បាលដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ស្តីពីច្បាប់កាត់ទោសខ្មែរក្រហម កិច្ចព្រមព្រៀងស្តីពីការបង្កើតសាលាក្តី និងសុន្ទរកថានិងអត្ថបទផ្សេងៗដែលទាក់ទងទៅនឹងសាលាក្តីខ្មែរក្រហម ។

## ២៩ សីហា ២០០៦

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រកាសដល់ក្រុមហ៊ុនឯកជនឲ្យមកដេញថ្លៃទទួលសិទ្ធិសាងសង់មណ្ឌលឃុំខ្លួនចុងចោទរបស់សាលាក្តី ។ អ្នកនាំពាក្យសាលាក្តីខ្មែរក្រហមលោក រាជ សម្បត្តិ បាននិយាយថា មណ្ឌលឃុំខ្លួននេះនឹងត្រូវសាងសង់ក្នុងបរិវេណសាលាក្តីក្នុងខេត្តកណ្តាល ។ លោកមានប្រសាសន៍ថា មណ្ឌលនេះមានសារសំខាន់ ដោយសារអង្គជំនុំជម្រះវិសាមញ្ញមានទីតាំងនៅក្រៅទីក្រុង ហើយសាលាក្តីមិនចង់ដឹកជញ្ជូនជនសង្ស័យទៅមកតុលាការនោះទេ ។ *(The Cambodia Daily, ២៩ កក្កដា ២០០៦)*

## ៣០ តុលា ២០០៦

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្កើតគេហទំព័រថ្មីមួយសម្រាប់សាធារណជន ។ គេហទំព័រនេះ (www.eccc.gov.kh) នឹងផ្តល់ជាខ្សែអាត់សំឡេង និងវីដេអូនៃដំណើរការរបស់សវនាការ និងដីកាតុលាការ ។ គេហទំព័រនេះនឹងមានជាភាសាបារាំង បន្ថែមពីលើភាសាខ្មែរ និងអង់គ្លេស ។ *(The Cambodia Daily, ៣០ តុលា ២០០៦)*

## ៣ វិច្ឆិកា ២០០៦

សាលាក្តីខ្មែរក្រហមបានចេញសេចក្តីព្រាងវិធានផ្ទៃក្នុង ដើម្បីឲ្យសាធារណជនផ្តល់យោបល់ ។ សេចក្តីព្រាងវិធានផ្ទៃក្នុងនេះកំណត់ពីតួនាទីរបស់ចៅក្រម ព្រះរាជអាជ្ញា មេធាវីការពារក្តី ជនសង្ស័យ សាក្សី និងជនរងគ្រោះ ដែលត្រូវបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ។ មានវិធានការដូចជា ការបំប្លែងសំឡេង និងការបិទបាំងមុខមាត់ដើម្បីការពារសាក្សី ។ ប្រាក់ពិន័យ១ម៉ឺនដុល្លារសហរដ្ឋអាមេរិក នឹងត្រូវពិន័យ ប្រសិនបើអត្តសញ្ញាណរបស់សាក្សីត្រូវបានបញ្ចេញ ។ សេចក្តីព្រាងវិធានផ្ទៃក្នុងនេះ ក៏អនុញ្ញាតឲ្យជនរងគ្រោះធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទារការខូចខាតផងដែរ ។ (The Cambodia Daily, ៤-៥ វិច្ឆិកា ២០០៦)

## ១២ វិច្ឆិកា ២០០៦

អង្គជំនុំជម្រះវិសាមញ្ញបញ្ចប់ការងារសាងសង់មណ្ឌលឃុំខ្លួន ដែលមាន៤បន្ទប់ ។ បន្ទប់នីមួយៗមានបំពាក់ដោយម៉ាស៊ីនត្រជាក់និងប្រព័ន្ធទឹកក្តៅ ។ ការចំណាយលើការសាងសង់អស់ទឹកប្រាក់ចំនួន ៤ម៉ឺន ៥ពាន់ដុល្លារសហរដ្ឋអាមេរិក ត្រូវបានឲ្យដោយប្រទេសជប៉ុន ។ (The Cambodia Daily, ១៣ វិច្ឆិកា ២០០៦)

## ១៦ វិច្ឆិកា ២០០៦

គណៈមេធាវីកម្ពុជាប្រកាសថា សេចក្តីព្រាងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបំពានលើច្បាប់កម្ពុជា ហើយទាមទារតួនាទីច្រើនជាងមុន ក្នុងការការពារជនសង្ស័យខ្មែរក្រហម ។ លោក គី តិច ប្រធានគណៈមេធាវី បានគំរាមប្តឹងមេធាវីបរទេសដែលធ្វើការនៅសាលាក្តី ប្រសិនបើការទាមទាររបស់គណៈមេធាវីមិនត្រូវបានដោះស្រាយ ។ (The Cambodia Daily, ១៧ វិច្ឆិកា ២០០៦)

## ២០ វិច្ឆិកា ២០០៦

មន្ត្រីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធ្វើការជជែកពិភាក្សាគ្នាស្តីពីវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះ ។ ការផ្តល់យោបល់ពីខាងក្រៅជាង២០ទៅលើសេចក្តីព្រាងវិធានផ្ទៃក្នុងនេះ ត្រូវបានប្រគល់ឲ្យសាលាក្តី ។ (The Cambodia Daily, ២១ វិច្ឆិកា ២០០៦)

លោក អៀង សារី អាយុ៧៧ឆ្នាំ បងធំទីបីរបស់ខ្មែរក្រហម មានជំងឺបេះដូង ហើយត្រូវបានបញ្ជូនទៅទីក្រុងបាងកកដើម្បីព្យាបាល អស់រយៈពេលជាង១សប្តាហ៍ ។ (Phnom Penh Post, លេខ១៥/ ២៤, ១-១៤ ធ្នូ ២០០៦)

## ២២ វិច្ឆិកា ២០០៦

លោក គី តិច ប្រធានគណៈមេធាវីកម្ពុជា គំរាមប្តឹងអ្នកដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាលរយៈពេល ៥ថ្ងៃ ស្តីពីច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិដែលរៀបចំឡើងដោយការិយាល័យការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ និងគណៈមេធាវីអន្តរជាតិ ។ លោកបាននិយាយថា វគ្គបណ្តុះបណ្តាលនេះបំពានទៅលើច្បាប់កម្ពុជា ហើយចាត់ទុកអ្នកដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះថា ជាអ្នកជ្រុលនិយម ។ (The Cambodia Daily, ២៣ វិច្ឆិកា ២០០៦)

## ២៣ វិច្ឆិកា ២០០៦

គណៈមេធាវីកម្ពុជាបានបញ្ជាមិនឲ្យសមាជិករបស់ខ្លួនចូលរួមវគ្គបណ្តុះបណ្តាល ដែលរៀបចំឡើងដោយការិយាល័យការពារក្តីនិងគណៈមេធាវីអន្តរជាតិ ។ គណៈមេធាវីកម្ពុជាបានហៅវគ្គបណ្តុះបណ្តាលនេះថា "ខុសច្បាប់" ។ (The Cambodia Daily, ២៤ វិច្ឆិកា ២០០៦)

## ២៤ វិច្ឆិកា ២០០៦

គណៈមេធាវីអន្តរជាតិប្រកាសពីការលុបចោលកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន សម្រាប់មេធាវីកម្ពុជា ដោយសារការរារាំងពីគណៈមេធាវីកម្ពុជា ។ (International Herald Tribune, ២៤ វិច្ឆិកា ២០០៦)

## ២៥ វិច្ឆិកា ២០០៦

មន្ត្រីតុលាការជាតិនិងអន្តរជាតិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រកាសពីបរាជ័យនៃការអនុម័តវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះ ដោយសារការមិនឯកភាពគ្នាលើបញ្ហាសំខាន់ៗមួយចំនួន ៖

១) របៀបនៃការបង្រួមបញ្ចូលគ្នារវាងច្បាប់កម្ពុជានិងស្តង់ដារអន្តរជាតិ

២) តួនាទីរបស់អង្គភាពគាំពារការការពារក្តី ដែលរួមមានបញ្ហាលក្ខណៈសម្បត្តិរបស់មេធាវីការពារក្តី

៣) តួនាទីរបស់សហព្រះរាជអាជ្ញា និងផលប៉ះពាល់ទៅលើនីតិវិធីបោះឆ្នោត

៤) ប្រតិបត្តិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា ។

(សេចក្តីថ្លែងការណ៍រួមរវាងមន្ត្រីតុលាការជាតិ និងអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ភ្នំពេញ, ២៥ វិច្ឆិកា ២០០៦)

(http://www.eccc.gov.kh/english/cabinet/press/15/PRESSRELEASE_PLENARY_in_ENG_FRENCH_.pdf)

## ៥ ធ្នូ ២០០៦

លោក ប្រាដ អាដាម (Brad Adams) ប្រធានអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីរិះគន់ពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលក្នុងការអនុម័តវិធានផ្ទៃក្នុង របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ដោយនិយាយថា ការជ្រៀតជ្រែកនេះនឹងកាន់តែពន្យារដំណើរការនេះថែមទៀត ។ *(អង្គការឃ្លាំមើលសិទ្ធិមនុស្ស ៥ ធ្នូ ២០០៦)*

លោករដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សុខ អាន សរសេរលិខិតមួយច្បាប់ទៅអង្គការសហប្រជាជាតិស្នើសុំការពិភាក្សាដើម្បីដោះស្រាយជម្លោះ ស្តីពីតួនាទីរបស់អង្គភាពគាំពារការការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នៅលិខិតមួយច្បាប់ផ្ញើទៅកាន់លោក នីកូឡាស មីសែល (Nicolas Michel) អគ្គលេខាធិការរងទទួលបន្ទុកផ្នែកច្បាប់របស់អង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក លោក សុខ អាន និយាយថា “រដ្ឋបាល តួនាទីនិងមុខងាររបស់ផ្នែកគាំពារការការពារក្តីនៃអង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាទំនាក់ទំនងរបស់អង្គភាពនេះជាមួយគណៈមេធាវីកម្ពុជា មិនត្រូវបានបង្ហាញនៅក្នុងកិច្ចព្រមព្រៀងរវាងកម្ពុជានិងអង្គការសហប្រជាជាតិទេ ។ *(The Cambodia daily, ១៨ ធ្នូ ២០០៦)*

## ៦ ធ្នូ ២០០៦

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាមទារភ័ស្តុតាងនៃការចោទប្រកាន់របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ។ លោក ហួត វុទ្ធី ចៅក្រមនៃអង្គបុរេជំនុំជម្រះក្នុងតុលាការកម្ពុជា បានរិះគន់អង្គការឃ្លាំមើលសិទ្ធិមនុស្ស និងទាមទារភ័ស្តុតាងនៃការជ្រៀតជ្រែករបស់រដ្ឋាភិបាលកម្ពុជា ដែលត្រូវបានចោទប្រកាន់ដោយអង្គការសិទ្ធិមនុស្សអន្តរជាតិមួយនេះ ។

លោក ប្រាដ អាដាម (Brad Adams) ប្រធានអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំតំបន់អាស៊ី សរសេរអ៊ីមែលមួយអះអាងថា ការចោទប្រកាន់នេះត្រឹមត្រូវ ។ *(The Cambodia Daily, ៧ ធ្នូ ២០០៦)*

## ៧ ធ្នូ ២០០៦

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្វាគមន៍ចំពោះបណ្តឹងរបស់ជនរងគ្រោះ ។ សហព្រះរាជអាជ្ញា រ៉ូប៊ែ ពេទីត (Robert Petit) បាននិយាយថា ជនរងគ្រោះនៃរបបខ្មែរក្រហមអាចប្តឹងទាមទាសំណងចំពោះការខូចខាតបាន ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រសាសន៍ថា អង្គការរបស់លោកនឹងជួយដល់ជនរងគ្រោះ ដែលចាប់អារម្មណ៍ក្នុងការដាក់ពាក្យបណ្តឹងទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ *(The Cambodia Daily, ៨ ធ្នូ ២០០៦)*

## ១៣ ធ្នូ ២០០៦

លោក គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសារភាពពីការពាក់ព័ន្ធរបស់លោកក្នុងរបបខ្មែរក្រហម(១៩៧៥-១៩៧៩) ។ លោកបានឆ្លើយតបបែបនេះ បន្ទាប់ពីមេដឹកនាំគណបក្សប្រឆាំងលោក

សម រង្ស៊ី បានចោទប្រកាន់លោកថា បានដើរតួនាទីយ៉ាងសំខាន់ក្នុងរបបខ្មែរក្រហម ក្នុងនាមជាទីប្រឹក្សារបស់ ប៉ុល ពត ដែលជាមេខ្លោងនៃរបបវាលពិឃាដ ។ លោក គាត ឈន់ បាននិយាយថា លោកស្ម័គ្រចិត្តធ្វើជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ ។ *(វិទ្យុសម្លេងសហរដ្ឋអាមេរិក, ១៣ ធ្នូ ២០០៦)*

លោក គាត ឈន់ បានថ្លែងប្រាប់រដ្ឋសភាជាតិថា “ប្រសិនបើខ្ញុំត្រូវបានគេកោះហៅឲ្យទៅឆ្លើយនៅចំពោះមុខប្រជាជន និងប្រទេសជាតិអំពីអតីតកាលរបស់ខ្ញុំ ខ្ញុំនឹងឆ្លើយ” ។ *(The Cambodia Daily, ១៨ ធ្នូ ២០០៦)*

## ១៨ ធ្នូ ២០០៦

សមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជាលោក ជាម យៀប មានប្រសាសន៍ថា មេដឹកនាំគណបក្សប្រជាជនកម្ពុជាមិនខ្លាចនឹងធ្វើកសិណសាក្សីនៅសាលាក្តីខ្មែរក្រហមទេពីព្រោះមិនមានមេដឹកនាំណាមួយស្ថិតនៅក្នុងនិយមន័យ“មេដឹកនាំជាន់ខ្ពស់”ក្នុងរបបខ្មែរក្រហម ឬ“អ្នកដែលមានការទទួលខុសត្រូវខ្ពស់បំផុត” លើបទឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅរវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ *(The Cambodia Daily, ១៥ ធ្នូ ២០០៦)*

## ១៩ ធ្នូ ២០០៦

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រៀបចំការពិភាក្សាតុមូលស្តីពីតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយនិងសាលាក្តី ។ ការពិភាក្សានេះធ្វើឡើងក្នុងគោលបំណងធានាឲ្យបានថា ការផ្សព្វផ្សាយព័ត៌មានអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានលក្ខណៈត្រឹមត្រូវនិងយុត្តិធម៌ ។ លោក ក្រាញ់ តូនី ប្រធានផ្នែកគ្រប់គ្រងការងារសាលាក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រាប់ដល់អ្នកចូលរួមថា “តាងនាមឲ្យប្រទេសរបស់យើង និងក្នុងនាមជាម្ចាស់ផ្ទះនៃអង្គជំនុំជម្រះវិសាមញ្ញ យើងត្រូវសរសេរដោយគោរពតាមក្រមសីលធម៌ និងសីលធម៌ជាបុគ្គល នៅពេលសរសេរអត្ថបទអំពីសាលាក្តីនេះ” ។ លោកបានបន្ថែមថាអ្នកសារព័ត៌មានត្រូវតែគោរពបីចំណុច សន្តិភាព ការផ្សះផ្សាជាតិ និងយុត្តិធម៌ សម្រាប់ជនរងគ្រោះ ។ *(The Cambodia Daily, ២០ ធ្នូ ២០០៦)*

អង្គការសហប្រជាជាតិឆ្លើយតបនឹងសំណូមពររបស់រាជរដ្ឋាភិបាលក្នុងការបើកកិច្ចពិភាក្សា ដើម្បីដោះស្រាយជម្លោះស្តីពីតួនាទីរបស់អង្គភាពគាំពារការការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ និងប្រធានអង្គភាពការពារក្តី លោក រូភឺត ស្គីលប៊ិត (Rupert Skillbeck) ។

នៅក្នុងអត្ថបទដកស្រង់ចេញពីការឆ្លើយតបជាផ្លូវការរបស់អង្គការសហប្រជាជាតិ ដែលផ្តល់ឲ្យដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីថ្ងៃអង្គារ លោក នីកូឡាស មីសែល (Nicolas Michel) អគ្គលេខាធិការរងទទួលបន្ទុកផ្នែកច្បាប់របស់អង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក ថ្លែងថា អង្គការសហ

ប្រជាជាតិចូលរួមរំលែកការព្រួយបារម្ភរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយមានទំនុកចិត្តថា បញ្ហាទាំងនេះនឹងអាចដោះស្រាយបាន ។ លោក មីសែល បាននិយាយសំដៅដល់របាយការណ៍មួយរបស់បេសកកម្មអង្គការសហប្រជាជាតិមកកម្ពុជា កាលពីខែធ្នូ ឆ្នាំ២០០៣ ដែលបានពិភាក្សាពីរចនាសម្ព័ន្ធ និងកិច្ចការរបស់“អង្គភាពកម្រិតតូចស្វ័យយ័តមួយ ដែលនឹងផ្សារភ្ជាប់ដោយឯករាជ្យទៅនឹងការិយាល័យរដ្ឋបាល ដែលអង្គភាពនេះនឹងផ្តល់ជំនួយនិងការគាំទ្រជាមូលដ្ឋានផ្នែកច្បាប់ ។ *(The Cambodia Daily, ២១ ធ្នូ ២០០៦)*

## ១១ មករា ២០០៧

ក្រុមហ៊ុនមៃក្រូសហ្វ (Microsoft) របស់សិង្ហបុរី បានបោះជំហានដំបូងគេក្នុងនាមជាផ្នែកឯកជនដើម្បីជួយបំពេញកង្វះថវិការបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយបានបរិច្ចាគថវិការចំនួន ១ សែនដុល្លារអាមេរិកដល់ភាគីអង្គការសហប្រជាជាតិដោយគ្មានលក្ខខណ្ឌ ។

*(http://www.playfuls.com/news_10_8423-Microsoft-Becomes-First-Private-Donor-For-Khmer-Rouge-Trials.html)*

## ១៨ មករា ២០០៧

សេវាកម្មអភិវឌ្ឍអាល្លឺម៉ង់ផ្តល់ជំនួយជាទឹកប្រាក់ចំនួន ៣សែនដុល្លារអាមេរិក ដល់កម្មវិធីសហគមន៍សម្រាប់ការគាំទ្រសាលាក្តីខ្មែរក្រហម ។ ប្រាក់ជំនួយនេះមិនមែនផ្តល់ទៅសាលាក្តីដោយផ្ទាល់នោះទេ ប៉ុន្តែផ្តល់តាមរយៈ ដៃគូក្នុងស្រុករបស់ខ្លួនគឺមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ។

*(http://news.monstersandcritics.com/europe/news/article_1248130.php/DED_donates_300000_dollars_toward_Khmer_Rouge_trials)*

## ១២ កុម្ភៈ ២០០៧

មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលបានឯកសារទាក់ទងនឹងសម័យខ្មែរក្រហម ចំនួនជាង៤រយគីឡូក្រាម ដែលត្រូវបានរក្សាទុកជិតពាទសវត្សរ៍នៅប្រទេសស៊ុយអែដ ។ ឯកសារទាំងនោះមានជាភាសាខ្មែរ អង់គ្លេស បារាំង និងស៊ុយអែត ។ *(The Nation, ១៣ កុម្ភៈ ២០០៧)*

## ១៤ កុម្ភៈ ២០០៧

អង្គការដែលមានទីតាំងនៅទីក្រុងញូវយ៉ក ឈ្មោះថា Open Society Justice Initiative (OSJI) បានចេញសេចក្តីថ្លែងការណ៍មួយចោទប្រកាន់ថា ចៅក្រមនិងមន្ត្រីតុលាការកម្ពុជានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រព្រឹត្តអំពើពុករលួយ ។ អង្គការនេះបានអះអាងថា ភាគីកម្ពុជាត្រូវកាត់ប្រាក់បៀវត្សរ៍មួយចំណែកទៅឲ្យមន្ត្រីរដ្ឋាភិបាលដើម្បីបានកាន់តំណែង ។ អង្គការ (OSJI) ក៏បានអំពាវនាវដល់ម្ចាស់ជំនួយ

និងសហគមន៍អន្តរជាតិឲ្យស៊ើបអង្កេតការចោទប្រកាន់ពីអំពើពុករលួយដោយហ្មត់ចត់ ។ *(សេចក្តីប្រកាសព័ត៌មានរបស់ OSJI ១៤ កុម្ភៈ ២០០៧)*

## ៨ មីនា ២០០៧

ចៅក្រមកម្ពុជារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានស្នើឲ្យឲ្យអង្គការ (OSJI) កែតម្រូវសេចក្តីថ្លែងការណ៍របស់ខ្លួនដែលចេញផ្សាយកាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៧ ដោយចោទប្រកាន់ថា ភាគីកម្ពុជាពុករលួយ ។ ចៅក្រមកម្ពុជាដែលត្រូវបានតែងតាំងឲ្យទៅធ្វើការនៅអង្គជំនុំជម្រះបានអះអាងថា ការចោទប្រកាន់ដែលគ្មានភស្តុតាង ហើយដែលបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ នៅតាមសារព័ត៌មានក្នុងស្រុកនិងអន្តរជាតិ បានបង្កឲ្យមានការយល់ច្រឡំដល់សាធារណៈជននិងបង្ខូច កិត្តិយសនិងភាពស្មោះត្រង់របស់ពួកគេ ។ *(សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជា, ៨ មីនា ២០០៧)*

## ១៦ មីនា ២០០៧

បន្ទាប់ពីការប្រជុំរយៈពេល១០ថ្ងៃស្តីពីវិធានផ្ទៃក្នុង គណៈកម្មាធិការត្រួតពិនិត្យបានធ្វើការសន្និដ្ឋានថា ចំណុចមិនឯកភាពដែលនៅសេសសល់ទាំងអស់ ត្រូវបានដោះស្រាយរួចរាល់ហើយ បើទោះបីជាការកែតម្រូវតិចតួចមិនទាន់ត្រូវបានធ្វើនៅឡើយក៏ដោយ ។

បញ្ហាចម្បងមួយទៀតដែលមិនទាន់បានចែងក្នុងវិធានផ្ទៃក្នុង គឺមេធាវីបរទេសត្រូវបង់ថ្លៃចុះឈ្មោះដល់ទៅ៥ពាន់ដុល្លារសហរដ្ឋអាមេរិកឲ្យទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ចៅក្រមអន្តរជាតិបានបដិសេធសំណើនេះ និងបានអះអាងថា ការទាមទារនេះគឺមិនអាចទទួលយកបានទេ ហើយវាប៉ះពាល់ដល់សិទ្ធិជនជាប់ចោទនិងជនរងគ្រោះក្នុងការជ្រើសរើសមេធាវីដោយខ្លួនឯង ។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានស្នើសុំឲ្យពិចារណាចំពោះការសម្រេចចិត្តនេះឡើងវិញឲ្យបានឆាប់ ដើម្បីឲ្យអង្គជំនុំជម្រះវិសាមញ្ញធ្វើការប្រជុំពេញអង្គ ស្តីពីការអនុម័តវិធានផ្ទៃក្នុងនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៧ ។ *(សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ១៦ មីនា ២០០៧)*

## ៥ មេសា ២០០៧

ចៅក្រមជាតិចំនួន១៥រូបរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សរសេរលិខិតមួយច្បាប់ឆ្លើយតបទៅភាគីអន្តរជាតិនៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៧ ។ លិខិតនេះមានគោលបំណងជំរុញឲ្យចៅក្រមអន្តរជាតិពិចារណាឡើងវិញពីការធ្វើពហិការមិនចូលរួមការប្រជុំពេញអង្គ ដែលគ្រោងធ្វើនៅថ្ងៃទី៣០ ខែមេសា

ដើម្បីអនុម័តសេចក្តីព្រាងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងក្នុងគោលបំណងឆ្លើយតបទៅនឹងសំណើដែលសុំដកគណៈមេធាវីកម្ពុជាចេញពីការងារអង្គជំនុំជម្រះវិសាមញ្ញ ។ ចៅក្រមជាតិយល់ឃើញថា ទង្វើនេះមិនស្របទៅតាមខ្លឹមសារនិងការអនុវត្ត ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនិងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញទេ ។ ចៅក្រមជាតិក៏បានចង្អុលបង្ហាញផងដែរថា ថ្លៃចុះឈ្មោះដែលកំណត់ដោយគណៈមេធាវីកម្ពុជា មិនមានចែងនៅក្នុងវិធានផ្ទៃក្នុងទេ ដូច្នេះរឿងនេះមិនមែនជាហេតុផលដើម្បីពន្យារការអនុម័តវិធានផ្ទៃក្នុងនោះឡើយ ។ *(សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ៥ មេសា ២០០៧)*

## ៣០ មេសា ២០០៧

គណៈមេធាវីកម្ពុជាបានបញ្ចុះថ្លៃចុះឈ្មោះ ពី៥ពាន់ដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ មកត្រឹម៥រយដុល្លារសម្រាប់រយៈពេលពេញនៃដំណើរការរបស់សាលាក្តីខ្មែរក្រហម ។ *(The Cambodia Daily, ២៨-២៩ មេសា-១ ឧសភា ២០០៧)*

## ២៥ ឧសភា ២០០៧

លោកស្រី ជា លាង សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានប្រសាសន៍ថា សាលាក្តីខ្មែរក្រហមអាចនឹងពិនិត្យមើលញត្តិជនរងគ្រោះជាង១លានញត្តិ ដែលបានដាក់ប្តឹងនៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ។ លោកស្រីបានបន្ថែម ពុំមានច្បាប់ណាហាមឃាត់សាលាក្តីមិនឲ្យទទួលយកញត្តិទាំងនោះទេ ។ *(រស្មីកម្ពុជា, ២៧-២៨ ឧសភា ២០០៧)*

## ១២ មិថុនា ២០០៧

វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានអនុម័តជាឯកច្ឆន្ទ បន្ទាប់ពីការចរចាអស់រយៈពេលជិតមួយឆ្នាំ ។ បញ្ហាដែលមិនអាចដោះស្រាយក្នុងអង្គប្រជុំលើកមុនត្រូវបានដោះស្រាយ ដោយរួមមានការធានាសិទ្ធិនិងការចូលរួមរបស់ជនរងគ្រោះ ដែលឥឡូវនេះជនរងគ្រោះនឹងមានសិទ្ធិធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែ អាចទទួលបានតែសំណងជាសមូហភាព និងសំណងមិនមែនជាសាច់ប្រាក់តែប៉ុណ្ណោះ ។ *(UN News Service, ១៣ មិថុនា ២០០៧)*

## ២២ មិថុនា ២០០៧

កិច្ចប្រជុំមួយរវាងមន្ត្រីមកពីអង្គការកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ UNDP និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានធ្វើឡើងដើម្បីពិភាក្សាពីអនុសាសន៍របស់ UNDP បន្ទាប់ពីធ្វើសវនកម្មមកលើផ្នែកធនធានមនុស្សរបស់កម្ពុជា ។ អនុសាសន៍មួយចែងថា "ប្រាក់បៀវត្សរ៍របស់បុគ្គលិកកម្ពុជាត្រូវកាត់បន្ថយជិតពាក់កណ្តាលដោយសារកង្វះថវិកា" ។ *(The Cambodia Daily, ២៣-២៤ មិថុនា ២០០៧)*

## ២៦ មិថុនា ២០០៧

ភាគីកម្ពុជានៃអង្គជំនុំជម្រះវិសាមញ្ញបានទទួលយកអនុសាសន៍ទាំងអស់នោះ ហើយបានអនុវត្តរួចរាល់ហើយ ។ *(សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ២៦ មិថុនា ២០០៧)*

## ១៨ កក្កដា ២០០៧

សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រគល់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូងរបស់ខ្លួនទៅសហចៅក្រមស៊ើបអង្កេត ។ ដីកានេះ"មានផ្ទុកនូវហេតុការណ៍ដែលបង្ហាញពីអំពើឧក្រិដ្ឋអ្នកដែលត្រូវសង្ស័យថា ជាអ្នកទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋទាំងនោះ និងសំណូមពរឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតឧក្រិដ្ឋកម្មនិងជនសង្ស័យទាំងនោះ ។ ដីកាសន្និដ្ឋាននេះថ្លែងថា "អនុលោមទៅតាមការស៊ើបអង្កេតជាបឋម សហព្រះរាជអាជ្ញាបានគូសបញ្ជាក់ និងប្រគល់ឯកសារស៊ើបអង្កេតអង្គហេតុចំនួន២៥ផ្សេងគ្នា ស្តីពីការសម្លាប់ ការធ្វើទារុណកម្ម ការបង្ខំឲ្យផ្លាស់ទីលំនៅ ការឃុំ ឃាំងមិនស្របច្បាប់ ការបង្ខំឲ្យធ្វើពលកម្ម និងការធ្វើទុក្ខបុកម្នេញលើផ្នែកសាសនា នយោបាយ និងជនជាតិ ដើម្បីធ្វើជាភស្តុតាងនៃឧក្រិដ្ឋកម្ម ដែលធ្វើឡើងក្នុងការអនុវត្តផែនការឧក្រិដ្ឋកម្មនេះ" ។ "ការចោទប្រកាន់ជាក់ស្តែងរួមមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ការបំពានយ៉ាងធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ អំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនា ។ សហព្រះរាជអាជ្ញាបានកំណត់អត្តសញ្ញាណជនសង្ស័យ៥រូប ដែលបានប្រព្រឹត្ត ជួយទំនុកបម្រុង សមគំនិត ឬដែលមានការទទួលខុសត្រូវខ្ពស់ក្នុងអំពើឧក្រិដ្ឋកម្មទាំងនេះ ។ ដើម្បីគាំទ្រការចោទប្រកាន់នេះ សហព្រះរាជអាជ្ញាបានប្រគល់ឯកសារជាង១ពាន់ច្បាប់ (ស្មើ១ម៉ឺន៨ពាន់ទំព័រ) ទៅឲ្យសហចៅក្រមស៊ើបអង្កេត ដោយរួមមានសេចក្តីថ្លែងរបស់ភាគីទីបី និងកំណត់ត្រាជាលាយល័ក្ខអក្សររបស់សាក្សីជាង៣៥០រូប បញ្ជីនៃសាក្សីសំខាន់ៗចំនួន៤០រូប ឯកសារក្នុងសម័យកម្ពុជាប្រជាធិបតេយ្យរាប់ពាន់ទំព័រ និងទីតាំងរណ្តៅសាកសពជាង៤០កន្លែង ។
*(http://dccam.org/Tribunal/Documents/Statement_of_Co-Prosecutor_on_18-July-2007.pdf)*

## ២០ កក្កដា ២០០៧

នួន ជា ដោយធ្វើការទស្សន៍ទាយថា គាត់ប្រាកដជាមនុស្សម្នាក់ក្នុងចំណោមបេក្ខជន៥នាក់ដែលកំណត់ដោយសហព្រះរាជអាជ្ញាទៅកាន់សាលាក្តីខ្មែរក្រហម បានប្រាប់កាសែតឌឺខេមបូឌាដែលីថា សាលាក្តីនឹងក្លាយជាសមរភូមិរបស់គាត់ ។ គាត់បានអះអាងថា ពុំមានគោលនយោបាយសម្លាប់ប្រជាជននោះទេ និងបានបន្ថែមថា "កុំព្រួយបារម្ភ ខ្ញុំនឹងទៅកាន់តុលាការនៅពេលគេត្រូវការខ្ញុំ ហើយខ្ញុំនឹងបញ្ជាក់ប្រាប់អ្វីៗឲ្យបានច្បាស់នៅតុលាការ និងបញ្ឈប់ការចោទប្រកាន់ និងឈប់ឲ្យប្រជាជននិយាយថាខ្មែរក្រហមជាបិសាច" ។ *(The Cambodia Daily, ២០ កក្កដា ២០០៧)*

## ២៤ កក្កដា ២០០៧

លោក អៀង វុធ អភិបាលរងក្រុងប៉ៃលិន និងជាកូនប្រុសរបស់លោក អៀង សារី និងអ្នកស្រី អៀង ធីរិទ្ធ រិះគន់កាសែតរស្មីកម្ពុជាដែលបានផ្សាយថា ឪពុកម្តាយរបស់លោកជាមនុស្សពីរនាក់ក្នុងចំណោមមនុស្សប្រាំនាក់នៅក្នុងបញ្ជីសម្ងាត់របស់សហព្រះរាជអាជ្ញា ដែលត្រូវបានចោទប្រកាន់នៅមុខសាលាក្តីខ្មែរក្រហម ។ លោករំពឹងថាសាលាក្តីនេះ នឹងមិនមែនជាយុត្តិធម៌សម្រាប់អ្នកឈ្នះនោះទេ ។ លោកបានថ្លែងថា "យុត្តិធម៌គឺនៅជាមួយអ្នកដែលខ្លាំងតែប៉ុណ្ណោះ" ។ *(The Cambodia Daily, ២៤ កក្កដា ២០០៧)*

## ៣១ កក្កដា ២០០៧

ឌុច ត្រូវបានបញ្ជូនខ្លួនជាផ្លូវការទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជាជនសង្ស័យដំបូងដែលត្រូវបានឃុំខ្លួនដោយសាលាក្តី ។ *(AFP, ៣១ កក្កដា ២០០៧)*

## ៣១ កក្កដា ២០០៧

ឌុច ត្រូវបានចោទប្រកាន់ជាផ្លូវការពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយសហចៅក្រមស៊ើបអង្កេតនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។ *(សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត, ៣១ កក្កដា ២០០៧)*

ឈ្មោះ : កាំង ហ្កេកអ៊ាវ

ថ្ងៃខែឆ្នាំកំណើត : ១៥ កុម្ភៈ ១៩៤៥

មុខរបរ : គ្រូបង្រៀនគណិតវិទ្យា ខេត្តកំពង់ធំ

## ៨ សីហា ២០០៧

មេធាវីរបស់ ឌុច លោក ហ្រ្វង់ស័រ រូ (Francois Roux) មេធាវីជនជាតិបារាំង ដែលធ្លាប់ការពារក្តីឲ្យភេរវករដែលធ្វើការវាយប្រហារថ្ងៃទី១១ ខែកញ្ញា ត្រូវបានតែងតាំងឲ្យធ្វើជាមេធាវីបរទេសធ្វើការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ *(International Herald Tribune, ៨ សីហា ២០០៧)*

## ៩ សីហា ២០០៧

ព្រះរាជក្រឹត្យមួយច្បាប់ ចុះថ្ងៃទី៩ សីហា ២០០៧ បានលើកឡើងថា លោក យូ ប៊ុនឡេង ដែលជាសហចៅក្រមស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងត្រូវតែងតាំងជាប្រធានសាលាឧទ្ធរណ៍ជំនួសឲ្យលោកស្រី លី វួចឡេង ។ លោកស្រី លី វួចឡេង ត្រូវបានដកចេញពីដំណែង ដោយសារតែលោកស្រីមានជាប់ពាក់ព័ន្ធជាមួយនឹងរឿងអាស្រូវពុករលួយ ទាក់ទងនឹងករណីជួយដូរមនុស្សខុសច្បាប់ ។ លោក យូ ប៊ុនឡេង មានការព្រួយបារម្ភថា លោកប្រហែលជានឹងមិនអាចបន្តធ្វើ ជាសហចៅក្រមស៊ើបអង្កេតនៅសាលាក្តីខ្មែរក្រហមបន្តទៀតទេ ដោយសារលោកមិនអាចធ្វើកិច្ចការធំៗពីរក្នុងពេលតែមួយបានទេ ។ *(The Cambodia Daily, ១៣ សីហា ២០០៧, ព្រះរាជក្រឹត្យ ចុះថ្ងៃទី៩ សីហា ២០០៧)*

## ១៥ សីហា ២០០៧

ទាក់ទិននឹងការតែងតាំងលោកជាប្រធានសាលាឧទ្ធរណ៍ លោក យូ ប៊ុនឡេង បានថ្លែងថា លោកនឹងបន្តធ្វើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រសិនបើមុខតំណែងរបស់លោកមានសារសំខាន់សម្រាប់ដំណើរការនេះ ។ "ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគិតថា វត្តមានរបស់ខ្ញុំមានសារសំខាន់ នោះវាជាកាតព្វកិច្ចរបស់ខ្ញុំក្នុងការបន្តធ្វើការងារតទៅមុខទៀត ដើម្បីធានាឲ្យបានថានឹងមិនមានការអាក់ខានឬពន្យារពេលនៅក្នុងដំណើរការនេះ ។ ខ្ញុំនឹងបន្តបេសកកម្មរបស់ខ្ញុំក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រហូតដល់ពេលវេលាមួយសមរម្យនិងដំណើរការរលូនអាចកើតមានឡើង ។ *(សេចក្តីថ្លែងការណ៍របស់លោក យូ ប៊ុនឡេង, ១៥ សីហា ២០០៧)*

## ១៦ សីហា ២០០៧

អង្គការសហប្រជាជាតិបានសម្តែងនូវការព្រួយបារម្ភ ចំពោះការតែងតាំងលោក យូ ប៊ុនឡេង ជាប្រធានសាលាឧទ្ធរណ៍កម្ពុជា ដោយនិយាយថា ការតែងតាំងនេះអាច"ប៉ះពាល់ទាំងប្រសិទ្ធិភាពការងារ និងឯករាជ្យភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ *(UN News Centre, ១៦ សីហា ២០០៧)*

## ២០ សីហា ២០០៧

គណៈកម្មការកម្ពុជាដើម្បីយុត្តិធម៌និងភាពស្មើគ្នា (CACJE) បានសរសេរលិខិតមួយច្បាប់ជូន សម្តេច ហេង សំរិន ប្រធានរដ្ឋសភាជាតិ ដោយស្នើសុំឲ្យសម្តេចរៀបចំសម័យប្រជុំពិសេសមួយ ដើម្បីដកអភ័យឯកសិទ្ធិពិសេសរបស់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ និងទុកជាមោឃៈនូវមាត្រា៧ កថាខណ្ឌទី៣ដែលចែងថា "ច្បាប់មិនអាចចោទប្រកាន់ព្រះមហាក្សត្របានឡើយ" ក្នុងរយៈកាលនៃដំណើរការសាលាក្តីខ្មែរក្រហម ។ លិខិតបានបញ្ជាក់ថា គោលបំណងនៃការធ្វើដូច្នេះគឺដើម្បីឲ្យចៅក្រមមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការចេញដីកា និងកោះអញ្ជើញសាក្សីនិងជនរងគ្រោះ ដើម្បីឡើងមកធ្វើសក្ខីកម្មនៅចំពោះមុខសាលាក្តី ។ លិខិតនេះ បានដកស្រង់មាត្រា៣១នៃរដ្ឋធម្មនុញ្ញ ដែលចែងថា "ប្រជាជនខ្មែរគ្រប់រូបមានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ ដោយទទួលបាននូវសិទ្ធិ សេរីភាពស្មើគ្នា និងបំពេញកតព្វកិច្ចដូចៗគ្នា ដោយមិនប្រកាន់ពូជសាសន៍ ពណ៌ សំបុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ប្រភពកំណើត វណ្ណៈសង្គម ទ្រព្យសម្បត្តិ ឬឋានៈអ្វីផ្សេងទៀតឡើង ។ *(សារលិខិតរបស់គណៈកម្មការកម្ពុជា ដើម្បីយុត្តិធម៌និងភាពស្មើគ្នា ចុះថ្ងៃទី២០ សីហា ២០០៧)*

## ២៣ សីហា ២០០៧

តំណាងពិសេសនិងរាយការណ៍ពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ បានចេញសេចក្តីថ្លែងការរួមគ្នាមួយ បង្ហាញពីការព្រួយបារម្ភរបស់ខ្លួនថា ការតែងតាំងសហចៅក្រមស៊ើបអង្កេតរបស់សាលាក្តី លោក យូ ប៊ុនឡេង ជាប្រធានសាលាឧទ្ធរណ៍ ទំនងជាមិនមានលក្ខណៈត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ។ សេចក្តីថ្លែងការនេះសរសេរថា "យោងតាមច្បាប់កម្ពុជារាល់ការតែងតាំងមន្ត្រីតុលាការ ការផ្ទេរមុខងារ ការតំឡើងឋានៈ ការព្យួរការងារ ឬការដាក់ពិន័យ ត្រូវសម្រេចដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងអនុវត្តដោយព្រះរាជក្រឹត្យ ។ ប៉ុន្តែ ព្រះរាជក្រឹត្យចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៧ ស្តីពីការតែងតាំងថ្មីនូវតំណែងប្រធានសាលាឧទ្ធរណ៍ (នស-រកត-០៨០៧-៣៣៩) ទំនងជាមិនត្រូវបានធ្វើឡើងក្រោមការសម្រេចចិត្តរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទេ ៖ មុនការចេញ ព្រះរាជក្រឹត្យនេះ មិនមានការប្រជុំណាមួយរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានធ្វើឡើងទេ" ។ *(សេចក្តីថ្លែងការណ៍រួមរបស់តំណាងពិសេសនិងអ្នករាយការពិសេស, ការិយាល័យអគ្គស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស, ២៣ សីហា ២០០៧)*

## ២៤ សីហា ២០០៧

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសពីជំហរដាច់ខាតរបស់រដ្ឋាភិបាល ក្នុងការការពារបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ ហើយបានហៅលិខិតរបស់គណៈកម្មការ

កម្ពុជាដើម្បីយុត្តិធម៌និងភាពស្មើគ្នា ដែលបានអំពាវនាវឲ្យរដ្ឋសភាជាតិដកព្រះរាជបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់អតីតព្រះមហាក្សត្រថា ជាការស្នើដែលគ្មានមនសិការ ។ ទាក់ទិនទៅនឹងការតែងតាំងសហចៅក្រមស៊ើបអង្កេត លោក យូ ប៊ុនឡេង លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអះអាងថា តួនាទីនិងកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតនៅសាលាក្តីខ្មែរក្រហមគឺនៅដដែល ហើយថា ការតែងតាំងនេះនឹងមិនប៉ះពាល់ដល់ដំណើរការរបស់តុលាការនោះទេ ។ *(សេចក្តីថ្លែងការស្តីពីការផ្ញើសេចក្តីសម្រេចចិត្តរបស់កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី, ២៤ សីហា ២០០៧)*

## ៥ កញ្ញា ២០០៧

ឌុច ដាក់ពាក្យបណ្តឹងជាមួយនឹងអង្គបុរេជំនុំជម្រះ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រឆាំងនឹងបញ្ជារបស់សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះ ដែលបានចេញដីកាឃុំខ្លួនលោក នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ។ *(ការប្តឹងឧទ្ធរណ៍របស់ ឌុច, ៥ កញ្ញា ២០០៧)*

## ១៩ កញ្ញា ២០០៧

នួន ជា ដែលត្រូវបានស្គាល់ថាជាបងធំទី២នៃរបបខ្មែរក្រហម និងដែលមានអាយុ៨២ឆ្នាំ ត្រូវបានចាប់ខ្លួននៅឯផ្ទះរបស់លោកនៅទីក្រុងប៉ៃលិន ហើយត្រូវបានបញ្ជូនមកឃុំឃាំងនៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅទីក្រុងភ្នំពេញ ។ ដោយត្រូវបានចោទប្រកាន់ជាផ្លូវការពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម នួន ជា បានជ្រើសរើសលោក សួន អារុណ មេធាវីកម្ពុជាដើម្បីការពាររូបលោក ។ តុលាការនឹងផ្តល់មេធាវីបរទេសមួយរូបទៀត ប្រសិនបើលោកស្នើសុំ ។ *(The Associated Press, Radio Free Asia, ២០ កញ្ញា ២០០៧)*

## ២ តុលា ២០០៧

នៅទីបញ្ចប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញរបាយការណ៍សវនកម្មរបស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ដែលបដិសេធមិនព្រមបញ្ចេញកាលពីដំបូង ដោយអះអាងថា របាយការណ៍នេះគឺជាឯកសារផ្ទៃក្នុងនិងសម្ងាត់ ។ របាយការណ៍សវនកម្មបានបង្ហាញគុណវិបត្តិនៃអនុវត្តផ្នែកធនធានមនុស្សរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចជាការជួលបុគ្គលិកដែលខ្វះសមត្ថភាព ការផ្តល់ប្រាក់កម្រៃច្រើនហួសហេតុ និងការជ្រើសរើសបុគ្គលិកជាដើម ។ កំហុសទាំងនេះមានលក្ខណៈធ្ងន់ធ្ងរ ដែលធ្វើឲ្យសវនករផ្តល់អនុសាសន៍ថា រាល់កិច្ចសន្យាបុគ្គលិកទាំងអស់របស់ភាគីកម្ពុជានៅក្នុងតុលាការត្រូវតែទុកជាមោឃៈ ហើយប្រាក់ខែត្រូវកាត់បន្ថយ និងផ្តល់តួនាទីដោយផ្ទាល់ទៅឲ្យកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ក្នុងការត្រួត

ពិនិត្យលើរឿងនេះដោយផ្ទាល់ ។ មន្ត្រីកម្ពុជាបានជំទាស់យ៉ាងខ្លាំងក្លាទៅនឹងអនុសាសន៍នេះ ដោយនិយាយថា "ការធ្វើបែបនេះនឹងធ្វើឲ្យអង្គជំនុំជម្រះទាំងមូលក្លាយទៅជាតុលាការអន្តរជាតិ" ។ *(Newsweek, ៧ តុលា ២០០៧)*

## ៧ តុលា ២០០៧

សហព្រះរាជអជ្ញារបស់សាលាក្តីខ្មែរក្រហម លោក រ៉ូប៊ឺត ពេទីត (Robert Petit) បានអំពាវនាវឲ្យមានការផ្តល់ថវិកាបន្ថែមដល់សាលាក្តី ដែលកំពុងតែជួបការខ្វះខាតថវិការ និងដែលកំពុងតែបន្តការងារដ៏មានសារសំខាន់ ។ *(DPA, ៧ តុលា ២០០៧)*

## ១៧ តុលា ២០០៧

នួន ជា ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ *(សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ១៧ តុលា ២០០៧)*

## ១៨ តុលា ២០០៧

នួន ជា បានជ្រើសរើសមេធាវីរបស់ ឌុច លោក ម៉ៃឃើល ភេសមែន (Michiel Pestman) ដើម្បីតំណាងឲ្យរូបលោក ។ *(ប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ១៨ តុលា ២០០៧)*

## ២៥ តុលា ២០០៧

រដ្ឋមន្ត្រីក្រសួងការបរទេសលោក ហោ ណាំហុង បានអំពាវនាវទៅដល់ប្រទេសជាម្ចាស់ជំនួយឲ្យជួយផ្តល់ជំនួយបន្ថែមទៅដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលកំពុងតែជិតអស់ថវិការ ។ *(AFP, ២៥ តុលា ២០០៧)*

## ១២ វិច្ឆិកា ២០០៧

អៀង សារី អតីតរដ្ឋមន្ត្រីក្រសួងការបរទេស និងប្រពន្ធរបស់លោក អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចត្រូវបានចាប់ខ្លួននិងបញ្ជូនទៅឃុំឃាំងនៅឯសាលាក្តីខ្មែរក្រហម ។ អៀង សារី ត្រូវបានចោទប្រកាន់ជាផ្លូវការ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាម ហើយប្រពន្ធរបស់លោកត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ *(The Cambodia Daily, ១៣ វិច្ឆិកា ២០០៧)*

## ១៩ វិច្ឆិកា ២០០៧

ខៀវ សំផន អតីតប្រធានប្រមុខរដ្ឋសម័យខ្មែរក្រហមត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ សាលាក្តីខ្មែរក្រហមបានសម្រេចចិត្តឃុំខ្លួនលោក ខៀវ សំផន រយៈពេល១ឆ្នាំមុនការកាត់សេចក្តី។ ក្នុងថ្ងៃដំណាលគ្នានេះដែរ ខៀវ សំផន បានជ្រើសរើសលោក បណ្ឌិត សាយ បូរី និងលោក ហ្សាក់ វែហ្សេស (Jacques Verges) ជាសហមេធាវីរបស់លោក។ *(Reuters, ២១ វិច្ឆិកា ២០០៧, The Cambodia Daily, ២២ វិច្ឆិកា ២០០៧, សេចក្តីថ្លែងការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ, ១៩ វិច្ឆិកា ២០០៧)*

## ៣ ធ្នូ ២០០៧

សាលាក្តីខ្មែរក្រហមបានច្រានចោលការប្តឹងប្រឆាំងនឹងការឃុំខ្លួនរបស់ ឌុច ជាឯកច្ឆ័ន្ទ។ យោងតាមសេចក្តីសម្រេចសាលាក្តីបានថ្លែងថា សេចក្តីសម្រេចនេះមិនមានជាប់ទាក់ទងគ្នាជាមួយនឹងអង្គភាពតុលាការនៅក្នុងប្រព័ន្ធតុលាការកម្ពុជាទេ ហើយយុត្តាធិការរបស់សាលាក្តី ត្រូវបានកំហិតតាមកម្មវត្ថុនៃបណ្តឹងដែលមានចែងនៅក្នុងច្បាប់ស្តីពីសាលាក្តី។ ដូច្នេះ សាលាក្តីមិនមានយុត្តាធិការ ក្នុងការពិនិត្យមើលកិច្ចការរបស់តុលាការយោធា ដែលបានឃុំខ្លួន ឌុច អស់រយៈពេលជាច្រើនឆ្នាំ មុនពេលបញ្ជូនគាត់មកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ។ ជាងនេះទៅទៀត សន្តិសុខផ្ទាល់ខ្លួនរបស់ ឌុច អាចជួបគ្រោះថ្នាក់ ប្រសិនបើគាត់ត្រូវបានដោះលែងមុនការកាត់សេចក្តី។ ដើម្បីធានាឲ្យបាននូវវត្តមានរបស់គាត់នៅសាលាក្តី និងដើម្បីជៀសវាងលទ្ធភាពនៃការគំរាមកំហែងសាក្សីនិងភស្តុតាងប្រឆាំងនឹងរូបលោក សាលាក្តីសម្រេចចិត្តបន្តឃុំខ្លួនរូបលោកបន្តទៀត។ *(The Cambodia Daily, ៤ ធ្នូ ២០០៧)*

## ៧-៨ កុម្ភៈ ២០០៨

អង្គបុរេជំនុំជម្រះបើកសវនាការលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអា-សន្ន។ មេធាវីរបស់ នួន ជា បានតវ៉ាថា (១) នួន ជា មិនទាន់បានទាមទាសិទ្ធិឲ្យបានត្រឹមត្រូវ ក្នុងការទទួលបានការផ្តល់ប្រឹក្សា នៅពេលគាត់បង្ហាញខ្លួនជាលើកដំបូងនៅឡើយទេ។ (២) ដើមបណ្តឹងរដ្ឋប្បវេណីបួនរូបដែលចូលរួមក្នុងសវនាការបណ្តឹងឧទ្ធរណ៍ មិនមានចំណាប់អារម្មណ៍ទៅលើបញ្ហាផ្លូវច្បាប់ជាក់លាក់ណាមួយទេ។ (៣) មិនមានអង្គហេតុគ្រប់គ្រាន់ក្នុងការបង្ហាញថា ការឃុំខ្លួនបណ្តោះអាសន្នមានសារសំខាន់ក្នុងការការពារសណ្តាប់ធ្នាប់សាធារណៈ ការពារគ្រោះថ្នាក់ចំពោះ នួន ជា ការពារការជ្រៀតជ្រែកទៅលើសាក្សី ឬការធានាវត្តមានរបស់ នួន ជា នៅចំពោះមុខតុលាការទេ។

### ២៧ កុម្ភៈ ២០០៨

អតីតប្រធានមន្ទីរស-២១ កាំង ហ្កេចអ៊ាវ ហៅ ឌុច បានវិលត្រឡប់ទៅគុកទួលស្លែងនិងវាលពិឃាតជើងឯកជាលើកទីមួយបន្ទាប់រយៈពេលជិត៣០ឆ្នាំ ដើម្បីចូលរួមក្នុង«ការអនុម័តឡើងវិញ»របស់សហចៅក្រមស៊ើបអង្កេត ក្នុងគោលបំណងជម្រុញឲ្យ ឌុច ពន្យល់អំពីព្រឹត្តិការក្នុងអតីតកាល ។ ភាពចម្រូងចម្រាស់បានកើតឡើងបន្ទាប់ពីមានការបង្ហាញឲ្យដឹងថា ទោះបីជា«សារព័ត៌មាន»ត្រូវបានដកចេញមិនឲ្យចូលរួមក្នុងព្រឹត្តិការនេះក៏ដោយ ក៏អ្នកផលិតកុនជាតិបារាំងឯកជនពីរនាក់ត្រូវបានអនុញ្ញាតឲ្យថតយកឯកសារនៃដំណើរការនីតិវិធីនេះដែរ ។

### ៧ មីនា ២០០៨

មជ្ឈមណ្ឌលឯកសារកម្ពុជាឧបត្ថម្ភដល់ការពិភាក្សាជាសាធារណៈ រវាងក្លឹបអ្នកកាសែតកម្ពុជា និងតំណាងមកពីការិយាល័យសហចៅក្រមស៊ើបអង្កេត ស្តីអំពីសេរីភាពនិងការសម្ងាត់របស់សារព័ត៌មាននៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការជួបប្រជុំនេះត្រូវបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងការខ្វល់ខ្វាយរបស់អ្នកកាសែត ទៅលើការហាមឃាត់ក្នុងការចូលទៅយកព័ត៌មានអំពីដំណើរការនីតិវិធីរបស់តុលាការ ដែលរួមទាំង«ការអនុម័តឡើងវិញ»នៅគុកទួលស្លែងផង ។

### ២០ មីនា ២០០៨

អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចចិត្ត ចំពោះការប្តឹងប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ នួន ជា ដោយរកឃើញថា សិទ្ធិទទួលបានមេធាវីមិនត្រូវបានរំលោភបំពាន ហើយមូលហេតុចំពោះការឃុំខ្លួនបណ្តោះអាសន្នគឺមានគ្រប់គ្រាន់ ។ សេចក្តីសម្រេចក៏បានបញ្ជាក់ផងដែរថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមនៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន ។

### ២១ មេសា ២០០៨

មជ្ឈមណ្ឌលព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថ្មីមួយ នៅក្នុងទីក្រុងត្រូវបានបើកទ្វារធ្វើការ ។ ការិយាល័យនេះគឺធ្វើឡើងដើម្បីជួយសម្រួលដល់សាធារណៈជន ដែលមានបំណងចូលមើលតុលាការ ហើយនឹងត្រូវបានប្រើប្រាស់ដោយអង្គភាពជនរងគ្រោះ និងផ្នែកកិច្ចការសាធារណៈ ។

### ២៣ មេសា ២០០៨

នៅឯសវនាការបណ្ដឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្ដោះអាសន្នរបស់ ខៀវ សំផន សហមេធាវីអន្តរជាតិលោក ហ្សាក់ វែហ្សេស (Jacques Verges) បានបដិសេធមិនចូលរួម ដោយឈរលើមូលដ្ឋានដែលថា ឯកសារនៅក្នុងសំណុំរឿងមិនទាន់ត្រូវបានបកប្រែទៅជាភាសាបារាំង ដែលជាភាសាមួយក្នុងចំណោមភាសាផ្លូវការទាំងបីរបស់សាលាក្ដី ។ លោក ខៀវ សំផន អះអាងថា ប្រការនេះនឹងដកសិទ្ធិតំណាងស្របច្បាប់របស់លោកចេញពីសវនាការ ។ អង្គបុរេជំនុំជម្រះបានពន្យារពេលដំណើរការនីតិវិធីទៅថ្ងៃក្រោយទៀត ហើយបានចេញលិខិតព្រមានទៅលោក ហ្សាក់ វែហ្សេស បន្ទាប់ពីរកឃើញថា លោកមិនបានផ្ដល់កំណត់សម្គាល់ចំពោះការបដិសេធរបស់ខ្លួន ហើយថា អាកប្បកិរិយារបស់លោកបានរំលោភបំពានទៅលើដំណើរការរបស់តុលាការនិងសិទ្ធិរបស់ចុងចោទ ។

## ២៥ មេសា ២០០៨

ការពិនិត្យមើលទៅលើការគ្រប់គ្រងធនធានមនុស្ស ដែលធ្វើឡើងដោយ Deloitte Touche Tohmatsu ត្រូវបានប្រកាស ។ ក្រុមគ្រូតពិនិត្យបានវាយតម្លៃថា តើវិធានការក្នុងការដោះស្រាយដែលលើកឡើងដោយសវនកម្មធនធានមនុស្សកាលពីដំបូងត្រូវបានអនុវត្តដែរឬទេ? និងថា តើគោលនយោបាយនិងការអនុវត្តផ្នែកធនធានមនុស្សរបស់ភាគីកម្ពុជា នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុលោមទៅតាមស្តង់ដារអន្តរជាតិដែរឬទេ? ក្រុមគ្រូតពិនិត្យបានរកឃើញថា «ប្រព័ន្ធរឹងមាំមួយ ត្រូវបានបង្កើតឡើង និងអនុវត្តដើម្បីដោះស្រាយបញ្ហាដែលមានពីមុន ផ្ដល់ការគាំទ្រដ៏មានប្រសិទ្ធិភាពដល់ដំណើរការសាលាក្ដី និងកាត់បន្ថយហានិភ័យចំពោះការអនុវត្តការគ្រប់គ្រងធនធានមនុស្ស ដែលអាចកើតមានឡើងនាពេលអនាគត» ។ ក្រុមនេះក៏បាននិយាយផងដែរថា វិធានការពង្រឹងសមត្ថភាពនឹងតម្រូវឲ្យមានការធ្វើបន្តទៀត ។

## ៣០ មេសា ២០០៨

អង្គបុរេជំនុំជម្រះរកឃើញថា សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងដែលដាក់កំហិតលើការទាក់ទងគ្នារវាងប្ដីប្រពន្ធ លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ មិនមានហេតុផលគ្រប់គ្រាន់ទេ ។ ដោយសារតែមិនមានអ្វីដែលបញ្ជាក់ថា ប្ដីប្រពន្ធទាំងពីរនេះបានពិភាក្សាអស់រយៈពេល៣០ឆ្នាំ អំពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នោះ អង្គបុរេជំនុំជម្រះបានរកឃើញថា សហចៅក្រមស៊ើបអង្កេត«មិនបានពន្យល់ថា តើការដាក់កំហិតទៅលើការទាក់ទងនេះ មានសារសំខាន់អ្វីខ្លះទៅលើវិធានការ ក្នុងការការពារផលប្រយោជន៍នៃការស៊ើបអង្កេតនោះទេ» ។ ជាលទ្ធផល អង្គបុរេជំនុំជម្រះបានសម្រេចថា យោងទៅតាមសិទ្ធិក្នុងការទទួលបាន«ការប្រព្រឹត្តប្រកបដោយលក្ខណៈមនុស្សធម៌» ប្ដីប្រពន្ធត្រកូល អៀង «គួរតែត្រូវបានអនុ-

ញ្ញាតឲ្យជួបគ្នា ដោយអនុលោមទៅតាមច្បាប់ក្នុងការឃុំខ្លួន ដែលអនុម័តនៅមន្ទីរឃុំខ្លួនបណ្ដោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។

## ១៥ ឧសភា ២០០៨

សហចៅក្រមស៊ើបអង្កេតបានផ្ដល់ដំណឹងដល់ភាគីពាក់ព័ន្ធទាំងអស់ថា ខ្លួនបានធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់លើសំណុំរឿងទីមួយ ដែលទាក់ទងនឹង ឌុច ។

## ២១ ឧសភា ២០០៨

អង្គបុរេជំនុំជម្រះបើកសវនាការលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការឃុំខ្លួនលោកស្រីជាបណ្ដោះអាសន្ន ។ បណ្ដឹងឧទ្ធរណ៍នេះទាមទាឲ្យមានការដោះខ្លួនលោកស្រី ដែលប្រឈមទៅនឹងលក្ខខណ្ឌដែលអង្គបុរេជំនុំជម្រះចាត់ទុកថាមានសារសំខាន់ ក្នុងការធានាឲ្យបាននូវការបង្ហាញខ្លួនរបស់លោកស្រី នៅក្នុងសវនាការលើកក្រោយៗទៀត ។ មេធាវីការពារក្ដីបានលើកឡើងការតវ៉ាចំនួនពីរ ៖ (១)ការរកឃើញរបស់សហចៅក្រមស៊ើបអង្កេត «ដែលជឿថា អៀង ធីរិទ្ធ បានប្រព្រឹត្ត»នូវអំពើឧក្រិដ្ឋកម្ម មិនមានភស្តុតាងគាំទ្រគ្រប់គ្រាន់ និងរំលោភទៅលើគោលការណ៍នៃការសន្និដ្ឋានគ្មានទោសពៃមុនការកាត់ក្ដី និង២)សហចៅក្រមស៊ើបអង្កេត«មិនមានមូលដ្ឋានភស្តុតាងសមស្រប» ក្នុងការរកឃើញថា ការឃុំខ្លួននេះមានសារសំខាន់ ។

## មិថុនា ២០០៨

លោកស្រី មីសែល លី (Michelle Lee) អ្នកសម្របសម្រួលសាលាក្ដីខ្មែរក្រហមរបស់អង្គការសហប្រជាជាតិ និងជាអនុប្រធានការិយាល័យរដ្ឋបាល របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចូលនិវត្តន៍ពីការងាររបស់លោកស្រីនៅអង្គការសហប្រជាជាតិ ហើយបានលាលែងចេញពីតំណែងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លោកស្រីត្រូវបានជំនួសដោយ Knut Rosandhang មកពីប្រទេសន័រវេ ។

## ៣០ មិថុនា-៣ កក្កដា ២០០៨

អង្គបុរេជំនុំជម្រះបើកសវនាការលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ន ។ មេធាវីការពារក្ដីបានអះអាងថា ការលើកលែងទោសដល់លោក អៀង សារី នៅឆ្នាំ១៩៩៦ ជួយឲ្យលោករួចផុតពីការកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

### ១ កក្កដា ២០០៨

លោកបណ្ឌិត សាយ បូរី លាលែងពីតួនាទីរបស់លោកពីសហមេធាវីការពារក្តីរបស់លោក ខៀវ សំផន ដោយសារបញ្ហាសុខភាព ។ (សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ១ កក្កដា ២០០៨)

### ៩ កក្កដា ២០០៨

អង្គបុរេជំនុំជម្រះប្រកាសសេចក្តីសម្រេចរបស់ខ្លួន ដោយច្រានចោលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ អៀង ធីរិទ្ធ ដោយរកឃើញថា “ការឃុំខ្លួននៅតែជាវិធានការចាំបាច់” ។ (The Associated Press, ៩ កក្កដា ២០០៨)

### ១៨ កក្កដា ២០០៨

សហព្រះរាជអាជ្ញាបញ្ជូនសេចក្តីសន្និដ្ឋានស្ថាពរ ទាក់ទងនឹងករណី ឌុច ដោយបង្ហាញពី“ការពិនិត្យមើលយ៉ាងល្អិតល្អន់ នូវអ្វីដែលសហព្រះរាជអាជ្ញាចាត់ទុកថា ជាភស្តុតាងពាក់ព័ន្ធដែលមាននៅក្នុងសំណុំរឿង” ក៏ដូចជាការអះអាងផ្លូវច្បាប់សម្រាប់គាំទ្រដល់ការចោទប្រកាន់ ដែលសហព្រះរាជអាជ្ញាចង់ឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការចោទប្រកាន់ទៅលើ ឌុច ។

### ៨ សីហា ២០០៨

សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ដោយចោទប្រកាន់ និងបញ្ជូល ឌុច ទៅជំនុំជម្រះក្តីពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ
និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ។

### ២១ សីហា ២០០៨

សហព្រះរាជអាជ្ញាបានប្រកាសពីការប្តឹងឧទ្ធរណ៍ ទៅលើដីកាដំណោះស្រាយលើករណី ឌុច ដោយបានអះអាងថា “ដីកានេះកំណត់ព្រំដែននៃបទឧក្រិដ្ឋ និងទម្រង់នៃបទឧក្រិដ្ឋរបស់ ឌុច” និងថា ការធ្វើបែបនេះ “នឹងធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូង មិនអាចធ្វើការកាត់សេចក្តីឲ្យបានពេញលេញទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ ឌុច នៅមន្ទីរស-២១បានទេ” ។ ជាពិសេស សហព្រះរាជអាជ្ញាយល់ឃើញថា ដីកាដំណោះស្រាយមាននៅមានចន្លោះខ្វះខាត ដោយសារដីកាធ្វើការលុបចោលបទចោទប្រកាន់ ឌុច ពីបទឧក្រិដ្ឋនៅ

ក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងការទទួលខុសត្រូវរបស់ ឌុច ក្នុងនាមជាសហជនដៃដល់នៃការប្រព្រឹត្តខុក្រិដ្ឋកម្មរួម ។

## ២៩ សីហា ២០០៨

អង្គបុរេជំនុំជម្រះសម្រេចថា (១) «ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានតំណាងតាមផ្លូវច្បាប់នឹងទទួលបានការឆ្លើយបំភ្លឺនៅចំពោះមុខអង្គបុរេជំនុំជម្រះដោយផ្ទាល់ ប្រសិនបើផលប្រយោជន៍របស់ពួកគេខុសពីផលប្រយោជន៍ក្នុងការកាត់សេចក្តី» ។ (២) «ដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយណាដែលមិនមានតំណាង ហើយដែលទាមទារសិទ្ធិក្នុងការក្នុងការឡើងថ្លែងនៅចំពោះមុខអង្គបុរេជំនុំជម្រះដោយផ្ទាល់ នៅក្នុងសវនាការដែលគ្រោងធ្វើឡើងណាមួយ ត្រូវដាក់សំណើរជាលាយល័ក្ខអក្សរ ពន្យល់អំពីខ្លឹមសារនិងភាពជាប់ទាក់ទងនៃសារណារបស់ខ្លួនយ៉ាងហោចណាស់ឲ្យបាន១០ថ្ងៃ មុនថ្ងៃបើកសវនាការ» ។

## ១-៥ កញ្ញា ២០០៨

ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចូលរួមក្នុងកិច្ចប្រជុំពេញអង្គ ហើយអនុម័តការធ្វើវិសោធនកម្មទៅលើវិធានផ្ទៃក្នុងរបស់តុលាការទៅលើប្រធានបទដូចជា ការតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ និងតុល្យភាពរវាងការរក្សាការសម្ងាត់ និងតម្រូវការនៃការបើកសវនាការជាសាធារណៈ ។ ក្រុមចៅក្រមក៏បានអនុម័តទៅលើក្រមសីលធម៌របស់តុលាការផងដែរ ។

## ៣ កញ្ញា ២០០៨

ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីលើកទីមួយ ដែលប្តឹងពីការរំលោភលើផ្លូវភេទ ត្រូវបានដាក់ដោយបុរសម្នាក់ ដែលទទួលរងការរំលោភបំពានលើផ្លូវភេទ នៅពេលស្ថិតនៅក្នុងការឃុំខ្លួន ហើយត្រូវបានបង្ខំឲ្យរៀបការជាមួយនឹងនារីម្នាក់ ។

## ១៦ កញ្ញា ២០០៨

សហចៅក្រមស៊ើបអង្កេតបានពន្យាការឃុំខ្លួន នួន ជា ថែមមួយឆ្នាំទៀត ។ នួន ជា បានប្តឹងឧទ្ធរណ៍ចំពោះដីកាបញ្ជានេះ ។ វិធានផ្ទៃក្នុងទី៦៣របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អនុញ្ញាតឲ្យជនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម ទទួលការឃុំខ្លួនរយៈពេលមួយឆ្នាំដំបូង ដែលការឃុំខ្លួននេះអាចត្រូវបានពន្យារពេលបន្តចំនួនពីរដងយ៉ាងច្រើនបំផុត ប្រសិនបើលក្ខខណ្ឌចាំបាច់មានគ្រប់គ្រាន់ ។

## ២៦ កញ្ញា ២០០៨

អង្គបុរេជំនុំជម្រះបានដកចេញនូវដីកាបញ្ជារបស់សហចៅក្រមស៊ើបអង្កេត ដែលហាមប្រាមមិនឲ្យជនជាប់ចោទទាក់ទងគ្នា ។ ដោយលើកយកច្បាប់ពីតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការសិទ្ធិមនុស្ស អឺរ៉ុប ក៏ដូចជាការអនុវត្តរបស់តុលាការកម្ពុជា អង្គបុរេជំនុំជម្រះរកឃើញថា ការកំណត់ទំនាក់ទំនងរវាងជនជាប់ឃុំឃាំងអាចត្រូវបានបញ្ជា តែក្នុងករណីដែលមានភស្តុតាងបង្ហាញថា ការទាក់ទងគ្នានេះ អាចបង្កគ្រោះថ្នាក់ចំពោះការដាក់សម្ពាធទៅលើសាក្សីនិងជនរងគ្រោះ ។

## មករា ២០០៩

សហមេធាវីអន្តរជាតិរបស់ នួន ជា បានដាក់ពាក្យបណ្តឹងទៅតុលាការក្រុងភ្នំពេញ ស្នើសុំឲ្យតុលាការនេះស៊ើបអង្កេតការចោទប្រកាន់ពីអំពើពុករលួយ របស់ភាគីកម្ពុជានៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ពាក្យបណ្តឹងនេះត្រូវបានច្រានចោលក្នុងខែកុម្ភៈ ។

## ៣១ មករា ២០០៩

ព្រះបាទសម្តេចព្រះ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានតែងតាំងលោក ផ្លោរ៉ង់ មុមបា (Florence Mumba) ជនជាតិហ្សាំប៊ី (Zambia) ឲ្យធ្វើជាចៅក្រមបម្រុងរបស់អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ២ កុម្ភៈ ២០០៩

អង្គភាពជនរងគ្រោះបានប្រកាសថា ខ្លួនបានទទួលទម្រង់បែបបទរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩៤ ទាក់ទងនឹងសំណុំរឿង០០១ ដែលផុតកំណត់នៅថ្ងៃនេះសម្រាប់ជនរងគ្រោះនៅគុកទួលស្លែង ។ បន្ទាប់ពីការផុតកំណត់ ពាក្យបណ្តឹងបន្ថែមមួយទៀតត្រូវបានទទួលពីកុមាររងគ្រោះនៅគុកទួលស្លែង គឺលោក នង ចាន់ផល ។ ទោះជាយ៉ាងនេះក្តី ពាក្យស្នើសុំរបស់លោកមិនទាន់ត្រូវបានទទួលយកនៅឡើយទេ ។

## ១៧ កុម្ភៈ ២០០៩

អង្គជំនុំជម្រះសេចក្តីជាផ្លូវការប្រឆាំង ឌុច បានចាប់ផ្តើមជាមួយនឹងសវនាការបឋមមួយ ដែលលើកឡើងអំពីបញ្ហាច្បាប់និងនីតិវិធីបឋម ដែលមានផលប៉ះពាល់ដល់ការប្រព្រឹត្តទៅរបស់សវនាការនៃអង្គសេចក្តី និងការកំណត់ពេលវេលាសម្រាប់សាក្សីនិងអ្នកជំនាញ ។

### ២៣ កុម្ភៈ ២០០៩

តំណាងអង្គការសហប្រជាជាតិបានជួបជាមួយលោក សុខ អាន ប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាលសម្រាប់សាលាក្ដីខ្មែរក្រហម ហើយបានយល់ព្រមទៅលើការអនុម័តលើយន្តការប្រហាក់ប្រហែលគ្នាមួយរវាងយន្តការជាតិនិងអន្តរជាតិ ដើម្បីទទួលយកពាក្យបណ្ដឹងនិងការណែនាំទាំងឡាយ ទាក់ទងនឹងបញ្ហាក្រមសីលធម៌ ។ ការចរចារនឹងបន្តនៅខែមេសា ។

### ២៤ កុម្ភៈ ២០០៩

អង្គបុរេជំនុំជម្រះបើកសវនាការលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងការពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្នលើរូបលោកស្រី ។ អៀង ធីរិទ្ធ បានប្រាប់អង្គចៅក្រមថា លោកស្រីគ្មានទោសពៃ ហើយបានស្ដីបន្ទោស នួន ជា និង ឌុច ចំពោះការសម្លាប់កូនសិស្សរបស់លោកស្រី និងជនរងគ្រោះដទៃទៀត ។

### ២៦ កុម្ភៈ ២០០៩

អង្គបុរេជំនុំជម្រះបើកសវនាការលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្នលើរូបលោក ។ ដោយសារអវត្តមានរបស់ អៀង សារី ដោយបញ្ហាសុខភាពសវនាការត្រូវបានលើកទៅថ្ងៃទី៧ ខែមេសា ។

### ២៧ កុម្ភៈ ២០០៩

អង្គបុរេជំនុំជម្រះបើកសវនាការលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងការពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្នលើរូបលោក ។ ដោយសារចៅក្រមអន្តរជាតិរបស់លោក ខៀវ សំផន គឺលោក ហ្សាក់ វែហ្សេស (Jacques Verges) មិនអាចចូលរួមក្នុងសវនាការបាន អង្គបុរេជំនុំជម្រះបានលើកការជំនុំជម្រះទៅថ្ងៃទី៤ ខែមេសា ។

### ៣ មីនា ២០០៩

សហចៅក្រមស៊ើបអង្កេតបានចេញដីកាបញ្ជាមួយ ទៅលើការរំលោភបំពានលើការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ បន្ទាប់ពីមានការបោះពុម្ពផ្សាយដោយក្រុមមេធាវីការពារក្ដីរបស់លោក អៀង សារី ដែលមិនទាន់ត្រូវបានចេញផ្សាយជាសាធារណ នៅលើគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សហចៅក្រមស៊ើបអង្កេតបានបញ្ជាឲ្យមេធាវីការពារក្ដី ដកព័ត៌មាន«សម្ងាត់» ចេញពីគេហទំព័ររបស់ពួកគេក្នុងរយៈពេល៤៨ម៉ោង ហើយផ្ញើសេចក្ដីរាយការណ៍ទៅគណៈមេធាវីនៃប្រទេសរបស់ខ្លួន ។ ក្រុម

មេធាវីការពារក្ដីបានប្ដឹងខទូរណ៍ ដោយអះអាងថាខ្លួនមិនបានបង្ហាញព័ត៌មានណាមួយទាក់ទងនឹងការស៊ើបអង្កេតឡើយ ។ សហព្រះរាជអាជ្ញាបានដាក់លិខិតគាំទ្រមួយ ។

## ២-៦ មីនា ២០០៩

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បើកកិច្ចប្រជុំពេញអង្គលើកទី៥ ដោយបានធ្វើការអនុម័តទៅលើវិសោធនកម្មវិធានផ្ទៃក្នុងរបស់តុលាការចំនួន២៧ ដែលរួមបញ្ចូលទាំងការផ្លាស់ប្ដូរក្នុងការទទួលស្គាល់សិទ្ធិក្នុងការប្ដឹងខទូរណ៍មានដែនកំណត់ និងការសម្រួលឲ្យមានការចូលរួមពីជនរងគ្រោះ ។

## ៣០ មីនា ២០០៩

សវនាការអង្គសេចក្ដីទៅលើរឿងក្ដីនៅមន្ទីរស-២១បានចាប់ផ្ដើម ។ នៅក្នុងឱកាសដំបូងបំផុត ឌុច បានធ្វើការសុំទោសចំពោះជនរងគ្រោះ ហើយបានទទួលយកការទទួលខុសត្រូវទាំងស្រុង ចំពោះការសម្លាប់ និងទារុណកម្មនៅក្នុងគុក ។ ក្នុងពេលជំណាលគ្នានេះដែរ ឌុច បានថ្លែងថា ខ្លួនគាត់ក៏ជាជនរងគ្រោះដែរ ដោយសារគាត់បានធ្វើតាមបញ្ជាពីថ្នាក់លើ ហើយមានការព្រួយបារម្ភចំពោះសុវត្ថិភាពក្រុមគ្រួសាររបស់គាត់ ប្រសិនបើគាត់មិនគោរពតាមបញ្ជា ។

## ២ មេសា ២០០៩

សវនាការស្ដីពីការពន្យាពេលការឃុំខ្លួនបណ្ដោះអាសន្នរបស់ អៀង សារី ដែលត្រូវបានពន្យាពេលកាលពីខែកុម្ភៈ ដោយសារបញ្ហាសុខភាពនោះត្រូវបានធ្វើឡើង ។

## ៣ មេសា ២០០៩

សហចៅក្រមស៊ើបអង្កេតបានឆ្លើយតបទៅនឹងសំណើររបស់ក្រុមមេធាវីការពារក្ដីមួយចំនួន ដែលបានស្នើរឲ្យមានការស៊ើបអង្កេតទៅលើអំពើពុករលួយ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយបានប្រកាសថា ខ្លួនមិនមានយុត្តាធិការក្នុងការស៊ើបអង្កេតលើរឿងនេះទេ ។

## ៣ មេសា ២០០៩

សវនាការស្ដីពីការពន្យាពេលការឃុំខ្លួនបណ្ដោះអាសន្នរបស់ ខៀវ សំផន ដែលត្រូវបានពន្យាពេលកាលពីខែកុម្ភៈ ដោយសារមេធាវីអន្តរជាតិរបស់លោកមិនអាចចូលរួមត្រូវបានធ្វើឡើង ។

### ៨ ខុសភា ២០០៩

អង្គបុរេជំនុំជម្រះបានសម្រេចថា វាមានសារសំខាន់ណាស់ ក្នុងការបន្តឃុំខ្លួន អៀង សារី ជាបណ្តោះអាសន្នក្នុងរយៈពេលមួយឆ្នាំទៀត ។

### ១១ ខុសភា ២០០៩

អង្គបុរេជំនុំជម្រះបានសម្រេចថា វាមានសារសំខាន់ណាស់ ក្នុងការបន្តឃុំខ្លួន អៀង ធីរិទ្ធ ជាបណ្តោះអាសន្នក្នុងរយៈពេលមួយឆ្នាំទៀត ។

### ១៨ ខុសភា ២០០៩

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាសថា លោក រាជ សម្បត្តិ ដែលពីមុនជាមន្ត្រីកិច្ចការព័ត៌មានរបស់តុលាការ ត្រូវមកជំនួសតំណែងរបស់លោកស្រី ហេលែន ចារីស (Helen Jarvis) ។ លោកស្រី ហេលែន ចារីស មកជំនួសតំណែងរបស់លោកស្រី គាត បូផល ដែលបានលាលែងចេញពីតំណែងជាប្រធានអង្គភាពជនរងគ្រោះ បន្ទាប់ពីការបម្រើការងារអស់រយៈពេល១៥ខែ ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានសរសេរលិខិតផ្ញើរទៅប្រធាននិងអនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយបង្ហាញកង្វល់ដែលថា តុលាការមិនបានអនុលោមទៅតាមបទបញ្ញត្តិ ស្តីពីការជ្រើសរើសធនធានមនុស្សរបស់ខ្លួនក្នុងការដាក់លោកស្រី ហេលែន ចារីស ឲ្យទៅបម្រើការងារនៅអង្គភាពជនរងគ្រោះ ដោយមិនបានធ្វើការផ្សព្វផ្សាយពីតួនាទីនេះជាមុន ។ លោក ឆាំង យុ ក៏បានបង្ហាញទស្សនមួយដែលថា ការតែងតាំងនេះមិនបានធ្វើតាមស្មារតីនៃកិច្ចព្រមព្រៀងក្នុងការបង្កើតតុលាការ និងការលើកកំពស់ភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់កម្ពុជាឲ្យកាន់តែខ្លាំងឡើង ។

### ១៩ ខុសភា ២០០៩

អង្គបុរេជំនុំជម្រះបានចេញលិខិតព្រមានមួយដល់ លោក ហ្សាក់ វែហ្សេស (Jacques Verges) មេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ដោយសារកំហុសឆ្គងផ្នែកអាកប្បកិរិយាពីលើកមុន និងសេចក្តីថ្លែងការមួយចំនួន ដែលត្រូវបានធ្វើឡើងក្នុងកំឡុងពេលនៃការកាត់ក្តី ។ លិខិតព្រមានបានថែងថា "ប្រសិនបើលោកនៅតែបន្តប្រព្រឹត្តល្មើស ឬរំលោភបំពាន ឬបង្កការរាំងស្ទះដល់ដំណើរការកាត់ក្តី ឬធ្វើអំពើណាមួយដែលរំលោភបំពានទៅលើដំណើរការអង្គបុរេជំនុំជម្រះនឹងដាក់ទណ្ឌកម្ម" ។ ការព្រមាននេះត្រូវបានចម្លងជូនគណៈមេធាវីកម្ពុជា និងគណៈមេធាវីនៃប្រទេសបារាំង ។

## ២៣ មិថុនា ២០០៩

សហព្រះរាជអជ្ញាអន្តរជាតិ លោក រ៉ូប៊ែ ពើទីត (Robert Petit) បានប្រកាសពីការសុំលាលែងចេញពីតំណែងរបស់លោក ដោយសារហេតុផលផ្ទាល់ខ្លួននិងគ្រួសារ ដែលនឹងចូលជាធរមានចាប់ពីថ្ងៃទី១ ខែកញ្ញា ។

## ២៦ មិថុនា ២០០៩

អង្គបុរេជំនុំជម្រះសម្រេចថា វាមានសារសំខាន់ណាស់ក្នុងការពន្យាការឃុំខ្លួនបណ្តោះអាសន្នលើរូបលោកក្នុងរយៈពេលមួយឆ្នាំបន្ថែមទៀត ។

## ២៩ មិថុនា ២០០៩

មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំយុវជននិងកីឡា បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ សម្រាប់ការបង្រៀនសៀវភៅ«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ។ នៅក្នុងកំឡុងពេលនៃវគ្គបណ្តុះបណ្តាលរយៈពេល១០ថ្ងៃ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជារួមជាមួយនឹងសាស្ត្រាចារ្យនិងប្រវត្តិវិទូអន្តរជាតិ បានផ្តល់ការបណ្តុះបណ្តាលជូនដល់គ្រូបង្គោល ថ្នាក់ខេត្តចំនួន២៤រូប ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រក្នុងការបង្រៀន។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងធ្វើការបណ្តុះបណ្តាលគ្រូប្រហែលជាពពាន់នាក់ នៅទូទាំងប្រទេសកម្ពុជាក្នុងចន្លោះឆ្នាំ២០០៩ និងឆ្នាំ២០១០ ដើម្បីឲ្យប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យត្រូវបានយកទៅបង្រៀននៅតាមសាលាមធ្យមសិក្សានៅទូទាំងប្រទេស ។

## ៣ កក្កដា ២០០៩

អង្គបុរេជំនុំជម្រះបានបញ្ជាក់ ទៅលើសេចក្តីសម្រេចចិត្តរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការពន្យាពេលការឃុំខ្លួនលោក ខៀវ សំផន រយៈពេលមួយឆ្នាំបន្ថែមទៀត ដោយយល់ឃើញថា ការពន្យាពេលនេះមានសារសំខាន់ ក្នុងការធានាសុវត្ថិភាពជនជាប់ចោទ និងរក្សាសណ្តាប់ធ្នាប់សាធារណៈ ។

## ១៣ សីហា ២០០៩

អង្គការសហប្រជាជាតិនិងកម្ពុជា បានប្រកាសកិច្ចព្រមព្រៀង ក្នុងការបង្កើតតួនាទីសម្រាប់«ទីប្រឹក្សាឯករាជ្យ» ដើម្បីពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងទទួលយករាល់ពាក្យបណ្តឹងទាក់ទងនឹងអំពើពុករលួយ ។

លោក អ៊ុត ឈន អគ្គសវនករនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានតែងតាំងសម្រាប់តួនាទីនេះ ។ យន្តការថ្មីនេះត្រូវបានស្វាគមន៍ភ្លាមៗពីប្រទេសម្ចាស់ជំនួយ ទោះបីជាវិសាលភាពនៃដែនអំណាចរបស់លោក អ៊ុត ឈន ក្នុងការដោះស្រាយការចោទប្រកាន់ផ្នែកសីលធម៌ និងទប់ស្កាត់ការសងសឹកនៅមិនមានភាពទាន់ច្បាស់លាស់នៅឡើយក៏ដោយ ។

### ២៦ សីហា ២០០៩

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាសថា រហូតមកទល់នឹងថ្ងៃនេះ ចំនួនប្រជាជនដែលបានចូលរួមក្នុងសវនាការ ឌុច ឡើងលើស២ម៉ឺននាក់ ដែលក្នុងមួយថ្ងៃមានអ្នកទស្សនាជាមធ្យមចំនួន ៣១១ នាក់ ។

### ២៩ សីហា ២០០៩

សហព្រះរាជអជ្ញារង លោក វីលៀម ស្មីត (William Smith) ត្រូវបានតែងតាំងជាសហព្រះរាជអជ្ញាអន្តរជាតិស្តីទី ។ បេក្ខជនជ្រើសតាំងពីររូប ដែលនឹងត្រូវមកជំនួសលោក រ៉ូប៊ឺត ពេទីត (Robert Petit) ជាអចិន្ត្រៃយ៍ ត្រូវបានអគ្គលេខាធិការអង្គការសហប្រជាជាតិបញ្ជូនមករាជរដ្ឋាភិបាលកម្ពុជា ។ សេចក្តីសម្រេចចុងក្រោយ នឹងត្រូវធ្វើឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

### ២ កញ្ញា ២០០៩

អង្គបុរេជំនុំជម្រះបានប្រកាសពីភាពបរាជ័យរបស់ខ្លួន ក្នុងការសម្រេចឲ្យបាននូវការព្រមព្រៀងគ្នាទៅលើជម្លោះរវាងសហព្រះរាជអជ្ញា ទាក់ទងនឹងបញ្ហាថាតើត្រូវធ្វើការស៊ើបអង្កេតលើជនសង្ស័យចំនួន ៥នាក់បន្ថែមទៀតឬយ៉ាងណា ។ ចៅក្រមអន្តរជាតិពីររូបបានកំណត់ថា សំណើរបស់សហព្រះរាជអជ្ញាអន្តរជាតិ គួរតែត្រូវបានចាត់ការបន្ត ។ ទោះជាយ៉ាងនេះក្តី ចៅក្រមកម្ពុជាបីរូបបានយល់ស្របជាមួយសហព្រះរាជអជ្ញាជាតិ ដែលថាសំណើរនេះមិនគួរត្រូវធ្វើបន្តទេ ។ ដោយសារតែសម្លេងគាំទ្រពីចៅក្រម ចំនួន៤រូបមិនអាចសម្រេចបាន ដូច្នេះយោងតាមវិធានផ្ទៃក្នុងសំណើរនេះត្រូវតែចាត់ការបន្ត ។

### ៧ កញ្ញា ២០០៩

សហព្រះរាជអជ្ញាអន្តរជាតិស្តីទី លោក ប៊ីល ស្មីត (Bill Smith) បានបញ្ជូនដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ និងទីបី ទៅសហចៅក្រមស៊ើបអង្កេត ។ នៅក្នុងការប្រកាសដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ លោកបានបញ្ជាក់បន្ថែមថា «លោកមិនមានផែនការរៀបចំធ្វើការស៊ើបអង្កេតបឋមទៅលើជនសង្ស័យបន្ថែម នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះទេ» ។

## ១១ កញ្ញា ២០០៩

កិច្ចប្រជុំពេញអង្គលើកទី៦របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបញ្ចប់ ។ អង្គចៅ-ក្រមបានអនុម័តសំណើររបស់គណៈកម្មាធិការច្បាប់និងនីតិវិធី ផ្តើឡើងក្នុងគោលបំណងបង្កើនប្រសិទ្ធិភាពក្នុងការគ្រប់គ្រងសាលាក្តី តាមរយៈការដាក់ដើមបណ្តឹងរដ្ឋប្បវេណីជាក្រុម ការផ្តល់តំណាងជាសហមេធាវី ការកាត់បន្ថយថ្ងៃផុតកំណត់ក្នុងការទទួលយកពាក្យបណ្តឹង និងការពារសេចក្តីជំទាស់ក្នុងការទទួលយកដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមនៅក្នុងដំណាក់កាលកាត់សេចក្តី ។

## ១៦ កញ្ញា ២០០៩

សហចៅក្រមស៊ើបអង្កេត បានពន្យាការឃុំខ្លួន នួន ជា សម្រាប់ឆ្នាំទីបី ។ នេះគឺជាការពន្យាពេលការឃុំខ្លួនបណ្តោះអាសន្នចុងក្រោយ ដែលត្រូវបានអនុញ្ញាតដោយវិធានផ្ទៃក្នុងរបស់តុលាការ ។

## ១៧ កញ្ញា ២០០៩

នីតិវិធីពិនិត្យភស្តុតាងនៅក្នុងសំណុំរឿងរបស់ ឌុច ត្រូវបានបញ្ចប់ ។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនឹងត្រូវបានធ្វើឡើងនៅថ្ងៃទី២៣ ខែវិច្ឆិកា ។

## ៨ តុលា ២០០៩

សេចក្តីប្រកាសមួយបានថ្លែងថា នៅក្នុងខែកញ្ញា សហចៅក្រមស៊ើបអង្កេតអន្តរជាតិលោក ម៉ាកសែលឡឺម៉ុង (Marcel Lemonde) ដោយមិនបានសហការជាមួយដៃគូកម្ពុជារបស់លោក បានផ្ញើរដីកាកោះហៅមន្ត្រីជាន់ខ្ពស់កម្ពុជាចំនួន៦រូប ឲ្យមកធ្វើសក្ខីកម្មបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មន្ត្រីជាន់ខ្ពស់កម្ពុជាទាំង៦រូបនេះរួមមាន ប្រធានគណបក្សប្រជាជនកម្ពុជា លោក ជា ស៊ីម ប្រធានរដ្ឋសភា លោក ហេង សំរិន រដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គាត ឈន និងសមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជា លោក អ៊ុក ប៊ុនឈឿន និង សីម កា ។ មន្ត្រីទាំងអស់នេះមិនទាន់បានយល់ព្រមទៅនឹងសំណើរនេះទេ ។

## ៥ វិច្ឆិកា ២០០៩

សហចៅក្រមស៊ើបអង្កេតបានចេញផ្សាយព័ត៌មាន បង្ហាញអំពីអង្គហេតុដែលស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេតទៅលើ អៀង សារី, នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ។ ជនរងគ្រោះដែលមានបំណងចូលរួមធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០២ ត្រូវតែជាអ្នកដែលទទួលរងការឈឺចាប់ដែលជាប់ពាក់ព័ន្ធទៅនឹងស្ថានភាពមួយក្នុងចំណោមស្ថានភាពទាំងនេះ ។

## ១០ វិច្ឆិកា ២០០៩

សហចៅក្រមស៊ើបអង្កេតបានបន្តពន្យារការឃុំខ្លួនបណ្តោះអាសន្នលើ អៀង សារី និង អៀង ធីរិទ្ធ សម្រាប់រយៈពេលយូរបំផុតមួយឆ្នាំទៀត ។

## ២៣ វិច្ឆិកា ២០០៩

មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានកិច្ចសហការជាមួយក្រសួងអប់រំយុវជននិងកីឡា បានបើកវគ្គបណ្តុះបណ្តាលលើកទីពីរ ស្តីពីការបង្រៀនប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ។ ក្នុងរយៈពេល១២ថ្ងៃនៃវគ្គបណ្តុះបណ្តាល បុគ្គលិកជាន់ខ្ពស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រូបង្គោលថ្នាក់ជាតិអ្នកជំនាញ និងប្រវត្តិវិទូអន្តរជាតិ បានធ្វើការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្តចំនួន១៨៦រូប នៅមជ្ឈ-មណ្ឌលគរុកោសល្យចំនួន៦ នៅក្នុងប្រទេសកម្ពុជា ។ ដូចវគ្គបណ្តុះបណ្តាលលើកទីមួយដែរ វគ្គបណ្តុះបណ្តាលលើកទីពីរផ្តោតទៅលើ ការពិតនៃប្រវត្តិសាស្រ្ត វិធីសាស្រ្តបង្រៀន និងរបៀបនៃការប្រើប្រាស់សម្ភារៈបង្រៀនដែលរួមមាន សៀវភៅប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩), សៀវភៅណែនាំសម្រាប់គ្រូបង្រៀន និងសៀវភៅលំហាត់សម្រាប់សិស្ស ។ ឯកសារទាំងអស់នេះបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

## ២៣-២៧ វិច្ឆិកា ២០០៩

សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ត្រូវបានធ្វើឡើងសម្រាប់សំណុំរឿងមន្ទីរស-២១ (គុកទួលស្លែង) ដែលរួមមានសំណើរដែលមិនបានគ្រោងទុករបស់មេធាវីការពារក្តីជាតិ ដែលបានសុំឲ្យមានការលើកលែងបទចោទប្រកាន់ និងការដោះលែងប្រធានគុក ឌុច ដោយឈរលើហេតុផលដែនយុត្តាធិការ ។ ការរៀបរាប់លម្អិតអំពីការជជែកដេញដោលអាចរកមើលបានតាមរយៈគេហទំព័រ www.cambodiatribunal.org ។

## ២ ធ្នូ ២០០៩

អគ្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រកាសថា លោក អែនឌ្រូ ខេលី (Andrew T. Cayley) មកពីអង់គ្លេស ត្រូវបានតែងតាំងជាសហព្រះរាជអជ្ញាអន្តរជាតិថ្មីជំនួសឲ្យលោក រ៉ូប៊ឺត ពើទីត (Robert Petit) មកពីកាណាដា ដែលបានសុំលាលែងកាលពីខែសីហា ។ លោក ខេលី មានបទ ពិសោធន៍ជាព្រះរាជអជ្ញាជាន់ខ្ពស់ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី (ICTY) និងជាមេធាវីការពារក្តីនៅ ICTY និងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូន ។

សហគមន៍អឺរ៉ុបបានផ្តល់ថវិការពាលានដុល្លារសហរដ្ឋអាមេរិក ដល់សាលាក្តីខ្មែរក្រហម ជាវិភាគទានដល់ភាគីជាតិកម្ពុជាសម្រាប់សាលាក្តីនេះ ។

## ៨ ធ្នូ ២០០៩

សហចៅក្រមស៊ើបអង្កេតនៃអគ្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញលិខិតបញ្ជាមួយអនុញ្ញាតឲ្យទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជាការប្រព្រឹត្តឧក្រិដ្ឋកម្មរួម អាចត្រូវបានយកមកប្រើប្រាស់សម្រាប់បទឧក្រិដ្ឋអន្តរជាតិ ប៉ុន្តែមិនមែនសម្រាប់បទឧក្រិដ្ឋក្នុងស្រុកនោះទេ សម្រាប់កាត់សេចក្តីនៅក្នុងអគ្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការបញ្ជានេះអនុញ្ញាតឲ្យប្រើប្រាស់ទម្រង់ទាំងបីនៃការប្រព្រឹត្តឧក្រិដ្ឋកម្មរួម ។

## ២៥ ធ្នូ ២០០៩

ជប៉ុនសន្យាផ្តល់ជំនួយ២លានដុល្លារសហរដ្ឋអាមេរិក ទៅឲ្យរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការសាងសង់កន្លែងសម្រាប់រក្សាឯកសាររបស់សាលាក្តីខ្មែរក្រហម និងមជ្ឈមណ្ឌលច្បាប់សម្រាប់«ក្រុមដែលងាយរងគ្រោះក្នុងសង្គម» ។

# កាលប្បវត្តិព្រឹត្តិការកម្ពុជាចាប់តាំងពីឆ្នាំ១៩៥០ ដោយសាកលវិទ្យាល័យយ៉េល

**១៩៥០** ចលនាកុម្មុយនីស្តកម្ពុជារួមកម្លាំងគ្នាជាមួយនឹងវៀតណាម ដើម្បីប្រឆាំងនឹងអាណានិគមនិយមបារាំង ។

**១៩៥៤** សន្និសីទទីក្រុងហ្សឺណែវ ៖ បារាំងបានដកខ្លួនចេញពីកម្ពុជា វៀតណាម និងឡាវ ។

**១៩៥៤-៧០** ព្រះរាជាណាចក្រកម្ពុជា នៅក្រោមការដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ ៖ របបរាជាធិបតេយ្យ គោលនយោបាយការបរទេសមិនចូលបក្សសម្ព័ន្ធ និងអព្យាក្រឹត្យនៅក្នុងសង្គ្រាមវៀតណាម ។

១៩៦២ មេដឹកនាំចលនាកុម្មុយនីស្តនៅកម្ពុជាបានបាត់ខ្លួន ។ ប៉ុល ពត បានឡើងជំនួសកន្លែងរបស់គាត់ ហើយបានរៀបចំផែនការសម្រាប់ការបះបោរ ។ ប៉ុល ពត បានធ្វើដំណើរទស្សនកិច្ចទៅប្រទេសចិននិងវៀតណាម នៅឆ្នាំ១៩៦៤-១៩៦៥ ។

១៩៦៥ សហរដ្ឋអាមេរិកបង្កើនការធ្វើសង្គ្រាមនៅវៀតណាម ។ កងកម្លាំងកុម្មុយនីស្តវៀតណាមបានចូលមកជ្រកកោណលើទឹកដីកម្ពុជាកាន់តែច្រើនឡើងៗ ។ សម្តេចព្រះ នរោត្តម សីហនុ បានផ្តាច់ចំណងការទូតជាមួយសហរដ្ឋអាមេរិក ខណៈពេលដែលព្រះអង្គបន្តវាយកម្ទេចក្រុមកុម្មុយនីស្តនិងក្រុមប្រឆាំងនៅក្នុងស្រុក ។

១៩៦៧ ក្រុមកុម្មុយនីស្តកម្ពុជារបស់ ប៉ុល ពត (ខ្មែរក្រហម) បានធ្វើកុបកម្មប្រឆាំងនឹងសម្តេចព្រះ នរោត្តម សីហនុ នៅភូមិភាគពាយព្យនៃប្រទេស ។ រដ្ឋាភិបាលបានធ្វើការបង្ក្រាបយ៉ាងសាហាវ ។

១៩៦៩ សហរដ្ឋអាមេរិកចាប់ផ្តើមទម្លាក់គ្រាប់បែក បេ-៥២ មកលើជម្រករបស់វៀតណាមនៅលើទឹកដីកម្ពុជា ។

១៩៧០-៧៥ របបសាធារណរដ្ឋខ្មែរ ៖ ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ឧត្តមសេនីយ៍ លន់ នល់ បានក្លាយទៅជាប្រធានាធិបតីនៃរបបសាធារណរដ្ឋខ្មែរ ដែលគាំទ្រដោយសហរដ្ឋអាមេរិក ។ សម្តេចព្រះ នរោត្តម សីហនុ បាននិរទេសព្រះកាយទៅប្រទេសចិន ហើយបានរួមកម្លាំងជាមួយវៀតណាម និងក្រុមកុម្មុយនីស្តកម្ពុជា (ខ្មែរក្រហម) ។ នៅក្នុងដំណាក់កាលដំបូង ការដឹកនាំរបស់ លន់ នល់ ទទួលបានការគាំទ្រពីប្រជាជនរស់នៅតាមទីក្រុង ប៉ុន្តែក្រោយមក ការដឹកនាំកាន់តែមានលក្ខណៈផ្តាច់ការទៅ ។

១៩៧៣ ការទម្លាក់គ្រាប់បែកបេ-៥២ មកលើទីជនបទនៅក្នុងប្រទេសកម្ពុជា ដើម្បីគាំទ្រកងកម្លាំងរបស់ លន់ នល់ បានឡើងដល់ចំណុចកំពូល ។ គ្រាប់បែកប្រមាណ ២ម៉ឺន៥សែនតោនត្រូវបានទម្លាក់អស់រយៈពេល៧ខែ មុនពេលសភាសហរដ្ឋអាមេរិកបញ្ជាឲ្យមានការបញ្ឈប់ការទម្លាក់គ្រាប់បែក នៅថ្ងៃទី១៥ ខែសីហា ។ ចំនួនជនស៊ីវិលស្លាប់ ដោយសារការទម្លាក់គ្រាប់បែកពីឆ្នាំ១៩៦៩ ទៅឆ្នាំ១៩៧៣ មានប្រហែលពី៥ម៉ឺននាក់ទៅ១សែន៥ម៉ឺននាក់ ។ កងកម្លាំងរបស់ ប៉ុល ពត បានប្រើប្រាស់ការស្លាប់និង ការបំផ្លិចបំផ្លាញដោយសារការទម្លាក់គ្រាប់បែកជាការឃោសនាក្នុងការជ្រើសរើសកម្លាំងបន្ថែម និងជាលេសក្នុងការបោះបង់ចោលគោលនយោបាយសង្គមនិយមកំរិតកណ្តាល នៅក្នុងតំបន់បដិវត្តន៍របស់ខ្លួន ។ វិសុទ្ធកម្មទៅលើជនកុម្មុយនីស្តនិយម កណ្តាល ដែលត្រូវបានសង្ស័យថាមិនស្មោះត្រង់នឹង ប៉ុល ពត បានចាប់ផ្តើម ។

**១៩៧៥ - ៧៩** របបកម្ពុជាប្រជាធិបតេយ្យ ៖ កងកម្លាំងរបស់ខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត បាន ផ្តួលរំលំកងយោធារបស់ លន់ នល់ ហើយកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ប្រជាជននៅតាមក្រុងត្រូវបានជម្លៀស ហើយប្រទេសទាំងមូលត្រូវបាន កាត់ផ្តាច់ពីពិភពលោកខាងក្រៅ ។ មន្ត្រីជាន់ខ្ពស់ ទាហាន និងអ្នករដ្ឋការរបស់របប លន់ នល់ ដែលចុះចាញ់ត្រូវបានសម្លាប់ ។ ប្រជាជននៅទូទាំងប្រទេសត្រូវបានបង្ខំឲ្យធ្វើការងារ កសិកម្ម ដោយមិនទទួលបានប្រាក់កម្រៃអ្វីទាំងអស់ ហើយមានការធ្វើទុក្ខបុកម្នេញមកលើ សាសនា និងក្រុមជនជាតិភាគតិចដូចជា ចិន វៀតណាម ចាម និង ថៃ ។

**១៩៧៦** គ្រោះអត់ឃ្លានបានកើតឡើងនៅផ្នែកខ្លះនៃភាគពាយព្យនៃប្រទេស បន្ទាប់ពីមានការបញ្ជូន អ្នករស់នៅក្នុងទីក្រុងរាប់រយពាន់នាក់ ។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យត្រូវបានប្រកាស ឡើងដោយមាន ខៀវ សំផន ជាប្រមុខរដ្ឋ ប៉ុល ពត ជានាយករដ្ឋមន្ត្រី និង អៀង សារី និង សុន សេន ជាឧបនាយករដ្ឋមន្ត្រី ។ មេបញ្ជាការភូមិភាគ ឈិត ជឿន (ហៅតាម៉ុក) និង កែ ពក ទទួលមើលការខុសត្រូវកងយោធារបស់កម្ពុជាប្រជាធិបតេយ្យ ។ ប៉ុល ពត នៅតែធ្វើជាលេខាបក្សកុម្មុយនីស្តកម្ពុជាដ៏សម្ងាត់ និង នួន ជា ជាអនុលេខាបក្ស ។

**១៩៧៧** វិសុទ្ធកម្មប្រកបដោយការបង្ហូរឈាមលើកទីពីរ បានផ្ទុះឡើងនៅក្នុងប្រទេសកម្ពុជា ដែល ដឹកនាំដោយក្រុមរបស់ ប៉ុល ពត ក្នុងគោលបំណងកម្ទេចចោលនូវក្រុមកុម្មុយនីស្តប្រឆាំង អ្នកនិយមកណ្តាល និងអ្នកដែលមិនស្តាប់បង្គាប់ ។ វិសុទ្ធកម្មនេះបានរាលដាលទៅដល់ ប្រជាកសិករ ក៏ដូចជាអ្នកជម្លៀសមកពីតាមទីប្រជុំជន ដែលទទួលរងការធ្វើទុកបុកម្នេញ ។ កម្ពុជាប្រជាធិបតេយ្យ ក៏បានធ្វើការវាយប្រហារដោយយោធានៅតាមបណ្តោយព្រំដែន ទាំងបី ដោយបានសម្លាប់រង្គាលជនស៊ីវិលថៃ វៀតណាម និង ឡាវ ។

**១៩៧៨** កម្ពុជាប្រជាធិបតេយ្យបដិសេធមិនព្រមធ្វើការចរចារជាមួយវៀតណាម ជុំវិញបញ្ហា សង្គ្រាមនៅតាមព្រំដែន ។ នៅឯក្នុងស្រុកឯណោះវិញ វិសុទ្ធកម្មដ៏ធំធេងបានបង្កឲ្យមានការ បះបោរនៅភូមិភាគបូព៌ា ប្រឆាំងទៅនឹងរបបរបស់ ប៉ុល ពត ។ ក្រុមបះបោរទទួលបរា ជ័យ ហើយបានមកប្រមូលផ្តុំគ្នានៅតាមបណ្តោយព្រំដែនវៀតណាម ហើយបានអំពាវនាវ សុំជំនួយពីរដ្ឋាភិបាលក្រុងហាណូយ ។

**១៩៧៩** របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ៖ កងទ័ពវៀតណាមបានឈ្លានពាននិងផ្តួលរំលំរបប ប៉ុល ពត ។ អតីតមេដឹកនាំបះបោរនៅភូមិភាគបូព៌ា ហេង សំរិន ត្រូវបានប្រកាសជា ប្រធានាធិបតី ហើយ ហ៊ុន សែន ជារដ្ឋមន្ត្រីការបរទេស(ក្រោយមកជានាយករដ្ឋមន្ត្រី) ។

១៩៨៩ សន្និសីទទីក្រុងប៉ារីសលើកទីមួយស្តីពីបញ្ហាកម្ពុជា ទទួលបរាជ័យ ។ កងទ័ពវៀតណាម បានដកចេញពីកម្ពុជា ។ កងកម្លាំងខ្មែរក្រហមរបស់ ប៉ុល ពត និងសម្ព័ន្ធមិត្តរបស់ខ្លួន (ដែលរួមទាំងសម្តេចព្រះ នរោត្តម សីហនុ ផង) បានប៉ុនប៉ងដើម្បីយកអំណាចពីរបបរដ្ឋកម្ពុជាទើបបង្កើតថ្មីរបស់ ហ៊ុន សែន ។

១៩៩០ ឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់កម្ពុជាត្រូវបានបង្កើតឡើង ដែលមានសមាជិក៦រូបមកពីភាគីរដ្ឋកម្ពុជា និង២រូបមកពីភាគីនីមួយៗក្នុងចំណោមភាគីប្រឆាំងទាំងបី ដែលរួមទាំងប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ លោក ខៀវ សំផន និងឧបនាយករដ្ឋមន្ត្រី សុន សេន ។

១៩៩១ កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីបញ្ហាកម្ពុជា ត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៣ ខែតុលា ដោយភាគីកម្ពុជាទាំងបួន និងរដ្ឋមន្ត្រីការបរទេសចំនួន១៨ នៃប្រទេស ដែលមានការចាប់អារម្មណ៍ ។ កងកម្លាំងខ្មែរក្រហមបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ប៉ុន្តែបានបដិសេធមិនព្រមគោរពតាមបទបញ្ញត្តិ ចំពោះបទឈប់បាញ់គ្នា ការគ្រប់គ្រង ដោយអង្គការសហប្រជាជាតិ ការរំសាយកងទ័ព និងការដកអាវុធ ។

១៩៩៣ ការបោះឆ្នោតជាតិទូទៅមួយត្រូវបានរៀបចំឡើង ដោយមានការធ្វើពហិការពីក្រុមខ្មែរក្រហម ។ រដ្ឋាភិបាលចំរុះមួយត្រូវបានបង្កើតឡើង ដោយគណបក្សហ្វ៊ុនស៊ិនប៉ិច របស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងគណបក្សប្រជាជនកម្ពុជារបស់លោក ហ៊ុន សែន ។ ខ្មែរក្រហមបន្តវាយប្រហារមកលើកងកម្លាំងរបស់រដ្ឋាភិបាល ។

១៩៩៤ រដ្ឋសភាកម្ពុជាបានបង្កើតច្បាប់ ដាក់ក្រុមខ្មែរក្រហមឲ្យនៅក្រៅច្បាប់ ។

១៩៩៦ កងកម្លាំងរបស់ខ្មែរក្រហមបានបែកបាក់គ្នា ដោយក្រុមរបស់ អៀង សារី បានចុះចូលជាមួយរដ្ឋាភិបាល ជាថ្នូរទៅនឹងការទទួលបានការលើកលែងទោស ។

១៩៩៧ ភាពចលាចលនៅក្នុងក្រុមខ្មែរក្រហមបានកើតឡើង ។ ប៉ុល ពត បានប្រហារជីវិត សុន សេន ហើយក្រោយមកត្រូវបានចាប់ដាក់ឃុំឃាំងនៅក្នុងផ្ទះមួយដោយ តាម៉ុក នួន ជា និង ខៀវ សំផន ។

១៩៩៨ កែ ពក បានបះបោរប្រឆាំងនឹង តាម៉ុក ហើយបានចូលរួមជាមួយនឹងកងកម្លាំងរបស់រាជរដ្ឋាភិបាល ។ ប៉ុល ពត ស្លាប់ ។ ការបោះឆ្នោតជាតិបានប្រគល់អំណាច មកឲ្យរដ្ឋាភិបាលចំរុះរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលគ្រប់គ្រងដោយ ហ៊ុន សែន ។ នួន ជា និង ខៀវ សំផន បានចុះចូលជាមួយ ហ៊ុន សែន ។ តាម៉ុក បន្តស្ថិតនៅជាមេដឹកនាំខ្មែរក្រហមចុងក្រោយគេបង្អស់ ។

១៩៩៩ ក្រុមអ្នកជំនាញនៃបេសកកម្មរបស់អង្គការសហប្រជាជាតិមួយ បានផ្តល់យោបល់ឲ្យមានការបង្កើតតុលាការអន្តរជាតិមួយ និងគណកម្មាការស្វែងរកការពិត ដើម្បីកាត់សេចក្តីពីបទឧក្រិដ្ឋ ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបខ្មែរក្រហម ។ តាម៉ុក ត្រូវបានចាប់ខ្លួនដោយកងកម្លាំងរបស់រដ្ឋាភិបាល ហើយត្រូវបានកាត់ទោសដោយតុលាការយោធា ។ អតីតប្រធានគុកទួលស្លែង កាំង ហ្គេកអ៊ាវ ហៅ ឌុច ក៏ត្រូវ បានចាប់ខ្លួនផងដែរ ៕

**សូមមើលកាលប្បវត្តិតុលាការខ្មែរក្រហមជាភាសាអង់គ្លេសតាមអាសយដ្ឋានដូចខាងក្រោមនេះ**

**www.dccam.org/Archives/Chronology/Chronology.htm**